**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Universite Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# របបនៃការប្រកាសទោស

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ស៊ីម សុនី**

**ឈាង ភីនុត**

សាស្ត្រាចារ្យណែនាំ

**លោក ម៉ម ចាន់ណែត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ស៊ឹម សូនី** និង **លាង តីនុត** ជានិស្សិតសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រឆ្នាំទី៤ ថ្នាក់L4A8 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២២ ក្នុងឆ្នាំសិក្សា ២០១៨-២០២២ សូមថ្លែងនូវកតញ្ញូ និង ដឹងគុណដ៏ជ្រាលជ្រៅមិនអាចកាត់ថ្លៃបានដល់លោកអ្នកមានគុណរបស់យើងខ្ញុំទាំងពីរ ដែលបានផ្តល់កំណើត លះបង់កម្លាំងកាយចិត្ត ពុះពារគ្រប់ឧបសគ្គ ដល់រូបយើងខ្ញុំទាំងពីរ និងចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មាន ប្រៀនប្រដៅ និងការឧបត្ថម្ភទំនុកបម្រុងគ្រប់បែបយ៉ាង ដល់ការរស់រានមានជីវិត ដោយលោកទាំងពីរ បានខិតខំពុះពារគ្រប់បែបឧបសគ្គមិនខ្លាចនឿយហត់ និងព្រមទាំងជួយទំនុកបំរុងដល់ការសិក្សារៀនសូត្រឱ្យយើងខ្ញុំបានសិក្សាក្រេបយកចំណេះដឹង រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនៃថ្នាក់ឧត្តមសិក្សា និងទទួលបានជោគជ័យដោយមោទនភាពជាទីបំផុត។ ចំពោះសេចក្តីដឹងគុណទាំងអស់នេះពុំអាចកាត់ថ្លៃបាន មិនអាចរៀបរាប់នៅក្នុងសេចក្តីថ្លែងអំណរគុណនេះអស់បានឡើយ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ឯកឧត្តមសាកលវិទ្យាធិការ **លុយ ចន្ណា** ព្រមទាំងសាកលវិទ្យាធិការរង គណៈកម្មការ សាស្ត្រាចារ្យ និងលោកគ្រូ អ្នកគ្រូ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំដឹកនាំគ្រប់គ្រងក្នុងគោលបំណងបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីក្លាយជាសសរទ្រូងនៃប្រទេសជាតិ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រងនៃ **បណ្ណាល័យនីតិសាស្ត្រ** ដែលបានរៀបចំ និងគ្រប់គ្រងឯកសារ ព្រមទាំងសៀវភៅដែលបង្កលក្ខណៈងាយស្រួលដល់ការស្រាវជ្រាវ និងចូលរួមចំណែកក្នុងការរៀបចំ និងតាក់តែងជាសារណានេះឡើង។

ជាងនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ **ម៉ម ចាន់ណែត** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការធ្វើឱ្យមាននូវកិច្ចដំណើរការ នៃការតាក់តែងឯកសារសារណានេះប្រកបដោយលទ្ធផលផ្លែផ្កា ដោយលោកគ្រូបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការប្រឹក្សាយោបល់ និងបានជួយលើកទឹកចិត្តត្រួសត្រាយផ្លូវ ព្រមទាំងផ្តល់នូវដំបូន្មានល្អៗដល់យើងខ្ញុំ រហូតធ្វើឱ្យសារណានេះធ្វើឡើងដោយឈរលើអត្ថន័យល្អគ្រប់គ្រាន់ ព្រមទាំងបានផ្តល់នូវបទពិសោធន៍ការងារល្អៗ ដែលធ្វើឱ្យកិច្ចប្រតិបត្តិការនេះប្រកបដោយរលូន។

ជាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីសួស្តី វិបុលសុខ បវរមហាប្រសើដល់លោកអ្នកមានគុណទាំងអស់ទទួលបានជោគជ័យគ្រប់ភារកិច្ច និងសុខភាពរឹងមាំទទួលទានគ្រប់ៗគ្នាព្រមទាំងពុទ្ធពរ ទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាមុខវិជ្ជានានានៃថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅ **សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** រយៈពេលបួនឆ្នាំកន្លងទៅនេះ និងជាពិសេសក្រោយពីបានសិក្សាមុខវិជ្ជានីតិព្រហ្មទណ្ឌរួចមក បានធ្វើឱ្យយើងខ្ញុំទាំងពីរនាក់គិតថាក្រមព្រហ្មទណ្ឌគឺជារឿងដែលគួរតែសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់ក្នុងនាមយើងជាប្រជាពលរដ្ឋម្នាក់ ព្រោះក្រមព្រហ្មទណ្ឌមិនត្រឹមតែជាបទដ្ឋានសម្រាប់ធ្វើការសម្រេចសេចក្ដីប៉ុណ្ណោះទេ ប៉ុន្តែគឺជាបទដ្ឋានមួយដែលបង្ហាញពីរូបមន្តរបស់តុលាការក្នុងការថ្លឹងថ្លែងបទល្មើស មុននឹងឈានដល់ការកំណត់ទោស ដើម្បីចេញសាលក្រមជាស្ថាពរ និងការប្រកាសទោសព្រមទាំងសិទ្ធិដែលទទួលបានពីការប្រកាសទោសនោះ គំនិតមួយនេះបានធ្វើឱ្យយើងខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំងលើក្រមព្រហ្មទណ្ឌ។ ស្របពេលដែលយើងខ្ញុំបានទទួលសិទ្ធិក្នុងការសរសេរសារណា ដើម្បីបញ្ចប់ការសិក្សា យើងខ្ញុំក៏បានពិភាក្សាគ្នា ហើយក៏បានសម្រេចចិត្តជ្រើសរើសយកប្រធានបទស្ដីពី **"របបនៃការប្រកាសទោស"** មកសរសេរជាសារណាបញ្ចប់ការសិក្សា។ ដោយឆ្លងកាត់ការបង្ហាត់បង្រៀន និងការបង្ហាញយ៉ាងយកចិត្តទុកដាក់ពីសំណាក់ លោកគ្រូ អ្នកគ្រូ ដែលជាសាស្ត្រាចារ្យ និងដោយមានការជួយណែនាំបន្ថែមពីសំណាក់រៀមច្បងជំនាន់មុនៗផង ក៏បានធ្វើឱ្យយើងខ្ញុំមានការយល់ដឹងយ៉ាងច្រើនលើប្រធានបទមួយនេះ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមគោរពដល់ សម្ដេច ឯកឧត្ដម លោកជំទាវ សាស្ត្រាចារ្យ លោក លោកស្រី និងសូមសួស្ដីមិត្តអ្នកអានទាំងឡាយដែលកំពុងតែអានសារណាមួយនេះ ហើយយើងខ្ញុំពិតជាមានសេចក្ដីសោមនស្សយ៉ាងក្រៃលែងដែល សម្ដេច ឯកឧត្ដម លោកជំទាវ សាស្ត្រាចារ្យ លោក លោកស្រី និងមិត្តអ្នកអានបានចាប់អារម្មណ៍ និងបានជ្រើសរើសយកសារណារបស់យើងខ្ញុំមកអាន ឬ ស្រាវជ្រាវបន្ត។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសង្ឃឹម និង ជឿជាក់យ៉ាងម៉ឺងម៉ាត់ថា សារណាបញ្ចប់ការសិក្សាមួយនេះនឹងអាចផ្ដល់ជូននូវពុទ្ធិជាមូលដ្ឋាន និង វិភាគទានមួយចំនួនទាក់ទងនឹងរបបនៃការប្រកាសទោសនៅកម្ពុជាដើម្បីជាប្រយោជន៍ដល់ការសិក្សាស្វែងយល់ និង ការសិក្សាស្រាវជ្រាវណាមួយជាបន្តទៀត។ ឆ្លៀតក្នុងឱកាសនេះផងដែរ យើងខ្ញុំទាំងពីរ សូមថ្លែងអំណរគុណ និងសូមជូនពរដល់ សម្ដេច ឯកឧត្ដម លោកជំទាវ សាស្ត្រាចារ្យ លោក លោកស្រី និងមិត្តអ្នកអានដែលបានអានសារណាបញ្ចប់ការសិក្សាមួយនេះឱ្យជួបតែពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។ **សូមអរគុណ!**

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ........................................ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ ១

៣. គោលបំណងនៃការស្រាវជ្រាវ ........................................ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........................................ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........................................ ៣

៦. វិធីសាស្រ្តនៃការស្រាវជ្រាវ ........................................ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ ៣

**ជំពូកទី១**

**របបទូទៅនៃការប្រកាសផ្តន្ទាទោសព្រហ្មទណ្ឌ**

**១. គោលការណ៍មូលដ្ឋានក្នុងការប្រកាសផ្តន្ទាទោសព្រហ្មទណ្ឌ** ........................................ ៤

១.១ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ........................................ ៤

១.២. គោលការណ៍ឯកត្តកម្មនៃទោស ........................................ ៥

**២. ការប្រកាសទោសព្រហ្មទណ្ឌចំពោះរូបវន្តបុគ្គល និងនីតិបុគ្គល** ........................................ ៦

២.១ ការប្រកាសមូលទោស ........................................ ៦

២.១.១ ការប្រកាសមូលទោសទៅលើរូបវន្តបុគ្គលជានីតិជន ........................................ ៧

២.១.២ ការប្រកាសមូលទោសទៅលើរូបវន្តបុគ្គលជាអនីតិជន ........................................ ៨

២.១.២.១ អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ........................................ ៨

២.១.២.២ អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ........................................ ៨

២.១.៣ ការប្រកាសមូលទោសទៅលើនីតិបុគ្គល ........................................ ១១

២.២ ការប្រកាសទោសបន្ថែម ........................................ ១២

២.២.១ ការប្រកាសទោសបន្ថែមទៅលើរូបវន្តបុគ្គលជានីតិជន ........................................ ១២

២.២.២ ការប្រកាសទោសបន្ថែមទៅលើរូបវន្តបុគ្គលជាអនីតិជន ..... ១៥
២.២.២.១ អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ..... ១៥
២.២.២.២ អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ..... ១៥
២.២.៣ ការប្រកាសទោសបន្ថែមទៅលើនីតិបុគ្គល ..... ១៦
២.៣ ការប្រកាសទោសជំនួស ..... ១៧
២.៣.១ ការប្រកាសទោសការងារសហគមន៍ ..... ១៧
២.៣.២ ការប្រកាសទោសស្ដីបន្ទោស ..... ១៩
២.៣.៣ ការមិនប្រកាសទោសជំនួសចំពោះនីតិបុគ្គល ..... ១៩

## ជំពូកទី២

## របបទូទៅនៃការប្រកាសព្យួរទោស

**១. ការប្រកាសព្យួរទោសធម្មតា** ..... ២១
១.១ ការប្រកាសព្យួរទោសចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ..... ២២
១.១.១ លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្ដន្ទាទោសពីមុន ..... ២២
១.១.២ លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលនាំឱ្យមានការព្យួរទោស ..... ២២
១.១.៣ ចំណុចផ្សេងទៀតពាក់ព័ន្ធនឹងការព្យួរទោសធម្មតា ..... ២២
១.១.៣.១ ការព្យួរទោសមួយផ្នែក ..... ២២
១.១.៣.២ ការដកហូតការព្យួរទោស ..... ២៣
១.១.៣.៣ ការមិនដកហូតការព្យួរទោស ..... ២៤
១.១.៣.៤ ការទុកជាអសារបង់នូវការផ្ដន្ទាទោស ..... ២៤
១.២ ការប្រកាសព្យួរទោសចំពោះបទលហុ ..... ២៤
១.២.១ លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្ដន្ទាទោសពីមុន ..... ២៥
១.២.២ លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលនាំឱ្យមានការព្យួរទោស ..... ២៥
១.២.៣ ការដកហូតការព្យួរទោស ..... ២៥
១.២.៤ ការមិនដកហូតការព្យួរទោស ..... ២៦
១.២.៥ ការចាត់ទុកជាអសារបង់នូវការផ្ដន្ទាទោស ..... ២៦

**២. ការប្រកាសព្យួរទោសសាកល្បង** ............ ២៦
២.១ លក្ខខណ្ឌនៃការព្យួរទោសសាកល្បង និងរយៈពេលនៃការសាកល្បង ............ ២៧
២.១.១ លក្ខខណ្ឌនៃការព្យួរទោសសាកល្បង ............ ២៧
២.១.២ រយៈពេលនៃការសាកល្បង ............ ២៧
២.២ តួនាទីរបស់បុគ្គលដែលដាក់ឱ្យទណ្ឌិត អនុវត្តនូវការព្យួរទោសសាកល្បង ............ ២៧
២.២.១ តួនាទីរបស់ចៅក្រមជំនុំជម្រះ ............ ២៨
២.២.២ តួនាទីរបស់ព្រះរាជអាជ្ញា ............ ២៨
២.៣ វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែកដែលអាចដាក់លើទណ្ឌិត ............ ២៨
២.៣.១ វិធានការត្រួតពិនិត្យដែលអាចដាក់លើទណ្ឌិត. ............ ២៩
២.៣.២ កាតព្វកិច្ចដោយឡែកដែលអាចដាក់លើទណ្ឌិត ............ ២៩
២.៤ ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ ............ ៣១
២.៤.១ ការដកហូតការព្យួរទោសសាកល្បង និងការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់ ............ ៣១
២.៤.១.១ ការដកហូតការព្យួរទោសាកល្បង ............ ៣១
២.៤.១.២ ការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់ ............ ៣២

## ជំពូកទី៣

## របបដោយឡែកនៃការប្រកាសទោសព្រហ្មទណ្ឌ

**១. របបពាក់កណ្តាលសេរីភាព** ............ ៣៣
១.១ លក្ខខណ្ឌ និងបែបបទនៃរបបពាក់កណ្តាលសេរីភាព ............ ៣៣
១.១.១ លក្ខខណ្ឌនៃរបបពាក់កណ្តាលសេរីភាព ............ ៣៣
១.១.២ បែបបទនៃរបបពាក់កណ្តាលសេរីភាព ............ ៣៤
១.២ ចំណុចផ្សេងៗទៀតនៃរបបពាក់កណ្តាលសេរីភាព ............ ៣៤
១.២.១ ការគិតបញ្ចូលរយៈពេលនៃរបបពាក់កណ្តាលសេរីនៅក្នុងទោស ............ ៣៤
១.២.២ ការរៀបចំ និងការលុបចោលនៃរបបពាក់កណ្តាលសេរីភាព ............ ៣៥
១.២.៣ ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត ............ ៣៥

**២. របបនៃការបែងចែកទោសជាប្រភាគ** ......................................... ៣៦
២.១ លក្ខខណ្ឌ និងបែបបទនៃការបែងចែកទោសជាប្រភាគ ......................................... ៣៦
២.១.១ លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ ......................................... ៣៦
២.១.២ បែបបទនៃការបែងចែកទោសជាប្រភាគ ......................................... ៣៧
២.២ ភាពដូចគ្នា រវាងការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្តាលសេរីភាព ......................................... ៣៧
២.២.១ លក្ខខណ្ឌដែលទទួលបាន ......................................... ៣៧
២.២.២ ការកែប្រែនៃការបែងចែកទោស ......................................... ៣៨
២.២.៣ ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត ......................................... ៣៨
២.៣ ភាពខុសគ្នារវាងការបែងចែកទោសជាប្រភាគ និង របបពាក់កណ្តាលសេរីភាព ......................................... ៣៩
**៣. របបនៃការផ្អាកការប្រកាសទោស** ......................................... ៣៩
៣.១ លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស ......................................... ៤០
៣.១.១ បទល្មើសដែលត្រូវចោទប្រកាន់ ......................................... ៤០
៣.១.១.១ ភាពច្របូកច្របល់នៃបទល្មើសត្រូវបានបញ្ឈប់ ......................................... ៤០
៣.១.១.២ ជនជាប់ចោទបង្ហាញការធានាក្នុងការចូលរួមរស់ក្នុងសង្គមវិញ ......................................... ៤០
៣.១.១.៣ ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត ......................................... ៤១
៣.១.២ ជនជាប់ចោទត្រូវតែមានវត្តមាននៅពេលសវនាការ ......................................... ៤០
៣.២ សវនាការពិនិត្យរឿងដែលបង្អង់ ......................................... ៤១
៣.៣ ភាពខុសគ្នារវាងការបែងចែកទោសជាប្រភាគ និង របបពាក់កណ្តាលសេរីភាព ......................................... ៤២
**សេចក្តីសន្និដ្ឋាន** ......................................... ៤៣
**អនុសាសន៍** ......................................... ៤៥
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

យើងបានដឹងហើយថា ប្រទេសកម្ពុជាជាប្រទេសដែលប្រកាន់នូវលទ្ធិប្រជាធិបតេយ្យគឺអំណាចនៃការដឹកនាំរដ្ឋត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា ដោយមិនមានការប្រមូលផ្តុំទៅលើអំណាចនៃបុគ្គលដែលជាថ្នាក់ដឹកនាំតែមួយនោះទេ គឺអំណាចនៃការដឹកនាំរដ្ឋត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា ដូចជាអង្គការនីតិបញ្ញត្តិ អង្គនីតិប្រតិបត្តិ និងអង្គការតុលាការ។ នៅក្នុងចំណោមអង្គការទាំងបីដែលបានជម្រាបជូននេះ សុទ្ធតែមាននូវភារកិច្ចខុសៗគ្នា ដោយយោងតាមមាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិយ៉ាងច្បាស់ថា អំណាចតុលាការគ្រប់គ្រងទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផងដែរ។ ចំណុចនេះបង្ហាញឱ្យឃើញថានៅក្នុងចំណោមអង្គការទាំង ៣(បី) ខាងលើនេះមានតែអង្គការតុលាការមួយគត់ ដែលមាននូវសិទ្ធិអំណាចនៅក្នុងការសម្រេចសេចក្តី និងជម្រះក្តីដោយយុត្តិធម៌ពាក់ព័ន្ធជាមួយនឹងវិវាទដែលកើតមានឡើង ហើយបើផ្អែកតាមមាត្រា ៦ នៃក្រមព្រហ្មទណ្ឌបានចែងថា "គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការទេ" ចំពោះការប្រកាសអំពីទោសរបស់តុលាការមានតែចៅក្រមទេដែលមាន សិទ្ធិនៅក្នុងការជម្រះក្តីដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់អស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។

ជាគោលការណ៍តុលាការព្រហ្មទណ្ឌ គឺទទួលបន្ទុកនៅក្នុងការដោះស្រាយបញ្ហាដែលមានការពាក់ព័ន្ធតែទៅលើរឿងក្តីព្រហ្មទណ្ឌតែប៉ុណ្ណោះ ដែលបញ្ហាពាក់ព័ន្ធនឹងព្រហ្មទណ្ឌនេះពិតជាមានលក្ខណៈពិសេសណាស់ ព្រោះវាមាននូវទំនាក់ទំនងដែលឈានទៅដល់ការសម្រេចនៃជោគវាសនារបស់មនុស្ស ក្នុងការទទួលនូវទោសព្រហ្មទណ្ឌណាមួយដែលពាក់ព័ន្ធជាមួយការជាប់ពន្ធនាគារ ឬការពិន័យជាប្រាក់ជាដើម។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសារតែការប្រកាសទោសព្រហ្មទណ្ឌមានសារៈសំខាន់ណាស់សម្រាប់បុគ្គលទាំងឡាយដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ហើយត្រូវបានចោទប្រកាន់នោះមុននឹងឈានទៅដល់ការសម្រេចសេចក្តីដោយតុលាការនូវទោសព្រហ្មទណ្ឌចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលមានចែងយ៉ាងជាក់លាក់ក្នុងក្រមព្រហ្មទណ្ឌ ហេតុដូច្នេះហើយទើបការសម្រេចសេចក្តីរបស់តុលាការទាំង ២៥ ខេត្តក្រុងគឺមានលក្ខណៈដាច់ខាតនៅក្នុងការប្រកាសឱ្យជនណាម្នាក់ទទួលនូវទោសព្រហ្មទណ្ឌ។ តើចៅក្រមត្រូវពិនិត្យលើមូលដ្ឋានណាខ្លះមុនឈានដល់ការប្រកាសទោស? ហើយមានរបបពិសេសអ្វីខ្លះដែលផ្តល់លទ្ធភាពដល់ទណ្ឌិតក្នុងការកែខ្លួន?

ដោយហេតុថា មានតែតុលាការព្រហ្មទណ្ឌតែប៉ុណ្ណោះជាអ្នកមានសិទ្ធិស្វ័យសម្រេចនូវទោសទណ្ឌចំពោះជនល្មើស ដែលបានប្រព្រឹត្តនូវអំពើណាមួយដែលបញ្ញត្តិយ៉ាងជាក់លាក់ក្នុងច្បាប់ព្រហ្មទណ្ឌ។ នៅក្នុងការសម្រេចសេចក្តី អំពីជនណាម្នាក់ដែលត្រូវទទួលទោសប្រភេទណាមួយនោះ គឺមានស្ថានភាពជាច្រើនដែលតុលាការត្រូវធ្វើការពិចារណា ពោលគឺដូចជា ស្ថានភាពគ្រួសារ ពេលវេលា ទីកន្លែង ស្ថានភាពហិរញ្ញវត្ថុ ចំណេះដឹង ការប្រព្រឹត្តបទល្មើស និងបុគ្គលិកលក្ខណៈរបស់ជនល្មើសនៅមុន និងក្រោយពេលប្រព្រឹត្តបទល្មើស ជាដើម។ ដោយសារតែស្ថានភាពទាំងឡាយនេះហើយ ដែលជាមូលដ្ឋានសម្រាប់ចៅក្រមក្នុងការពិចារណា មុននឹងឈានដល់ការសម្រេចសេចក្តី ក៏ដូចជាការប្រកាសផ្តន្ទាទោស ឬ ប្រកាសនូវការព្យួរទោស ក៏ដូចជាការប្រកានូវរបបដោយឡែក ដែលមានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌ។ តើអ្វីទៅដែលជារបបពិសេស ក៏ដូចជារបបដោយឡែកថ្មីក្នុងរបបនៃការប្រកាសផ្តន្ទាទោសព្រហ្មទណ្ឌ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដោយផ្អែកលើការយល់ឃើញច្បាស់ពីកម្មវត្ថុនៃការស្រាវជ្រាវ ក៏ដូចជាឆ្លើយតបទៅនឹងចំណោទបញ្ហានៃការស្រាវជ្រាវខាងលើនេះ យើងខ្ញុំបានធ្វើការស្រាវជ្រាវ និងរៀបចំតាក់តែងឯកសារក្នុងការសរសេរសារណានេះឡើងគឺក្នុង គោលបំណងពង្រីកបន្ថែមនូវចំណេះដឹងផ្ទាល់ខ្លួន និងចែករំលែកគំនិត ក៏ដូចជាផលទុនមួយគ្រាន់ទុកជាឯកសារដល់អ្នកអាន និងនិស្សិតជំនាន់ក្រោយៗទៀត។ បន្ថែមពីនេះក្រុមយើងខ្ញុំនឹងសិក្សាផ្តោតសំខាន់ទៅលើ៖

- អ្វីទៅដែលជារបបនៃការប្រកាសផ្តន្ទាទោសព្រហ្មទណ្ឌ?
- តើការប្រកាសផ្តន្ទាទោសព្រហ្មទណ្ឌនេះតុលាការត្រូវយោងលើលក្ខខណ្ឌអ្វីខ្លះ?
- អ្វីទៅជាការប្រកាសព្យួរទោស? តើមានលក្ខខណ្ឌអ្វីខ្លះដើម្បីអាចប្រកាសព្យួរទោសបាន?
- តើការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បងមានលក្ខណៈខុសគ្នាដូចម្តេច?
- តើរបបដោយឡែកនៃការប្រកាសទោសព្រហ្មទណ្ឌមានអ្វីខ្លះ?

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទដែលបានលើកឡើងក្នុងចំណោទបញ្ហាខាងលើយើងខ្ញុំខិតខំសិក្សាស្រាវជ្រាវទៅលើឯកសារគ្រឹះ និងជាមូលដ្ឋានដ៏សំខាន់គឺក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ និងឯកសារដែលពាក់ព័ន្ធទាំងឡាយដែលមានយោងក្នុងឯកសារពិគ្រោះយោបល់ដូចមានភ្ជាប់ជូនមកជាមួយ ដើម្បីសរសេរសារណានេះឡើងដោយមានចំនួន ៣ ជំពូក។ ការស្រាវជ្រាវទៅលើប្រធានបទស្តីពីរបបនៃការប្រកាសផ្តន្ទាទោស គឺជាការសិក្សាដែលផ្តោតសំខាន់ទាក់ទងទៅនឹង គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គោលការណ៍ឯកត្តកម្មនៃទោស លក្ខខណ្ឌនៃការប្រកាសផ្តន្ទាទោសទៅលើជនល្មើស ការព្យួរទោស ការផ្អាកការប្រកាស

ទោស របបពាក់កណ្ដាលសេរីភាព និងការចែងចែកទោសជាប្រភាគ ដោយអនុលោមតាមជំពូកទី៣ របបនៃការប្រកាសទោស ដែលមានចែងចាប់ពីមាត្រា ៩៦ ដល់មាត្រា ១៣៥ និងមាត្រាពាក់ព័ន្ធមួយចំនួនទៀត នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ និង ក្រមនីតិវិធីព្រហ្មទណ្ឌ ព្រមទាំងសេចក្ដីណែនាំរបស់ក្រសួងយុត្តិធម៌មួយចំនួនដែលពាក់ព័ន្ធផងដែរ ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

យើងដឹងហើយថាការស្រាវជ្រាវទៅលើប្រធានបទមួយ គឺជាការបកស្រាយក៏ដូចជាពន្យល់នូវអ្វីដែលពាក់ព័ន្ធនឹងប្រធានបទ។ ដូច្នេះសារណានេះអាចធ្វើឱ្យ បងប្អូនក៏ដូចជាមិត្តនិស្សិតជំនាន់ក្រោយទុកជាឯកសារជំនួយដល់ស្មារតីនៃការសិក្សាស្រាវជ្រាវរបស់ខ្លួន នឹងបានយល់ដឹងកាន់តែច្បាស់ថា៖

- អ្វីទៅជារបបប្រកាសទោសព្រហ្មទណ្ឌ?
- តើការប្រកាសទោសព្រហ្មទណ្ឌត្រូវមានលក្ខខណ្ឌអ្វីខ្លះ?
- តើការប្រកាសព្យួរទោសត្រូវមានលក្ខខណ្ឌ និងបែបបទអ្វីខ្លះ?
- តើការប្រកាសព្យួរទោសធម្មតា និងការប្រកាសព្យួរទោសសាកល្បងមានលក្ខណៈខុសគ្នាដូចម្ដេច?
- តើរបបដោយឡែកនៃការប្រកាសទោសព្រហ្មទណ្ឌមានអ្វីខ្លះ?

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការសរសេសារណានេះ យើងខ្ញុំធ្វើការសិក្សាបែបពិពណ៌នា និង វិភាគ ។ ការសិក្សាស្រាវជ្រាវបានធ្វើតាមរយៈការប្រមូលនូវព័ត៌មានទាំងឡាយ ក៏ដូចជាឯកសារពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណានេះ ដើម្បីឱ្យសារណាមានភាពត្រឹមត្រូវ និងមានប្រសិទ្ធិភាព។ ព័ត៌មានដែលជ្រើសរើសយកមក តាមការស្រាវជ្រាវ និងមតិយោបល់ពីអ្នកជំនាញការខាងច្បាប់ព្រហ្មទណ្ឌ ព្រមទាំងមានបទពិសោធន៍នៅក្នុងវិស័យច្បាប់នេះផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងរចនាសម្ព័ននៃការស្រាវជ្រាវ លើប្រធានបទស្ដីពី **របបនៃការប្រកាសទោស** នេះយើងខ្ញុំបានបែងចែក និងផ្ដោតសំខាន់ទៅលើ ៣ ជំពូកធំៗ ដូចជា៖

**ជំពូកទី១**៖របបទូទៅនៃការប្រកាសទោសព្រហ្មទណ្ឌ

**ជំពូកទី២**៖របបទូទៅនៃការប្រកាសព្យួរទោស

**ជំពូកទី៣**៖របបដោយឡែកនៃការប្រកាសទោសព្រហ្មទណ្ឌ។

# ជំពូកទី១
# របបទូទៅនៃការប្រកាសផ្តន្ទាទោសព្រហ្មទណ្ឌ

# ជំពូកទី១

# របបទូទៅនៃការប្រកាសផ្តន្ទាទោសព្រហ្មទណ្ឌ

## ១. គោលការណ៍មូលដ្ឋានក្នុងការប្រកាសផ្តន្ទាទោសព្រហ្មទណ្ឌ

យើងសូមបកស្រាយជូនអំពីគោលការណ៍មូលដ្ឋានក្នុងការប្រកាសផ្តន្ទាទោសព្រហ្មទណ្ឌទាក់ទងជាមួយរបបនៃការប្រកាសទោសនេះ ពីព្រោះក្រមព្រហ្មទណ្ឌបានចែងនូវគោលការណ៍ដ៏ធំមួយ គោលការណ៍នេះត្រូវបានចាត់ទុកថាជាគោលការណ៍គ្រឹះដែលមានចែងក្នុងមាត្រា ៩៦ នៃក្រមក្រមព្រហ្មទណ្ឌ គឺ **"គោលការណ៍ឯកត្តកម្មនៃទោស"** ហើយយើងសូមលើកយកនូវ **"គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ"** ដែលបានបញ្ញត្តិក្នុងមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ។ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌនឹងបកស្រាយក្នុងចំណុច (**១.១**) ហើយគោលការណ៍ឯកត្តកម្មនៃទោសនឹងបកស្រាយក្នុងចំណុច (**១.២**) ខាងក្រោម។ គោលការណ៍ ដែលបានរៀបរាប់ខាងលើនេះ គឺមានសារៈសំខាន់ណាស់សម្រាប់ចៅក្រមយកទៅប្រើប្រាស់ក្នុងការកំណត់អំពីទោសឱ្យត្រូវទៅតាមស្ថានភាពរបស់បុគ្គលម្នាក់ៗ ដែលបានប្រព្រឹត្តបទល្មើស[1]។

### ១.១ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ[2]គឺជាការទទួលខុសត្រូវចំពោះអំពើល្មើសផ្ទាល់ខ្លួនតែប៉ុណ្ណោះ។ ចំពោះពាក្យថាអំពើផ្ទាល់ខ្លួនត្រង់នេះមានន័យថា នៅពេលបុគ្គលណាម្នាក់បានប្រព្រឹត្តបទល្មើសណាមួយដែលជាបទល្មើសដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់នោះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្តប៉ុណ្ណោះ។ ក្រមព្រហ្មទណ្ឌមិនអនុញ្ញាតឱ្យអ្នកដទៃចូលមកទទួលទោសជំនួសបាននោះទេ មិនថាទោសនោះជាប្រភេទទោសដាក់ពន្ធនាគារ ឬ ទោសពិន័យជាប្រាក់នោះទេ គឺបុគ្គលដែលបានប្រព្រឹត្តបទល្មើសត្រូវតែទទួលទោសដោយខ្លួនឯង សូម្បីតែការបង់ប្រាក់ពិន័យក៏ច្បាប់មិនអនុញ្ញាតឱ្យអ្នកដទៃបង់ប្រាក់ជំនួសបានដែរ។ ផ្ទុយទៅវិញបើច្បាប់អនុញ្ញាតឱ្យអ្នកដទៃអាចទទួលទោសពន្ធនាគារ ឬ ការបង់ប្រាក់ពិន័យជំនួសបុគ្គលនោះបាន គឺពិតណាស់ច្បាស់ជាបុគ្គលនោះមិនមានភាពខ្លាចរអារនឹងច្បាប់ ឬ កែខ្លួនមកចូលរស់នៅក្នុងសង្គមវិញនោះទេ គឺនៅតែបន្តប្រព្រឹត្តបទល្មើសម្តងហើយម្តងទៀត ដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសង្គមយ៉ាងខ្លាំង នេះគឺផ្ទុយពីគោលបំណងនៃក្រមព្រហ្មទណ្ឌទាំងស្រុងតែម្តង ។

---

[1] យោងតាមអនុសាសន៍របស់ **ឯកឧត្តម កើត រិទ្ធ** អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារ សេចក្តីព្រាងក្រមព្រហ្មទណ្ឌ (បច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌) នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា។

[2] មាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ហេតុដូច្នេះហើយទើបក្រមព្រហ្មទណ្ឌបានចែងអំពីគោលការណ៍គ្រឹះមួយហៅថា គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ហើយគោលការណ៍នេះទៀតសោតគឺជាគោលគំនិតនៃក្រមព្រហ្មទណ្ឌ ព្រោះថាគោលបំណងនៃក្រមព្រហ្មទណ្ឌ គឺធ្វើយ៉ាងណាដើម្បីឱ្យទណ្ឌិតនោះខ្លាចរអារ និងដើម្បីឱ្យទណ្ឌិតនោះកែខ្លួនចូលរស់នៅក្នុងសង្គមវិញ ។ ហើយម្យ៉ាងវិញទៀតការដាក់ទោសនេះ គឺធ្វើឱ្យគាត់មានអារម្មណ៍មួយទទួលរងថាអ្វីដែលគាត់បានប្រព្រឹត្តគឺខុសហើយនៅពេលខុសតើគាត់បានទទួលរងនូវផលវិបាកអ្វីខ្លះចំពោះខ្លួនឯងជាដើម។

## ១.២ គោលការណ៍ឯកត្តកម្មនៃទោស

គោលការណ៍ឯកត្តកម្មនៃទោស[3]គឺមានន័យថា ជាគោលការណ៍មូលដ្ឋានដែលបញ្ញត្តិសម្រាប់ចៅក្រមយកមកពិចារណាអំពីស្ថានភាពរបស់ជនល្មើស ក្នុងពេលប្រព្រឹត្តបទល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស និងពិចារណាអំពីចរិតលក្ខណៈ សភាពផ្លូវចិត្តរបស់ជនល្មើស កិរិយាមាយាទរបស់ជនជាប់ចោទ ទំហំព្យសនកម្មដែលបង្កដល់ជនរងគ្រោះ និងសង្គមជាតិជាដើម មុននឹងធ្វើការប្រកាសផ្តន្ទាទោសទោសព្រហ្មទណ្ឌ។ ជាការពិតណាស់ មុននឹងធ្វើការសម្រេចអំពីការផ្តន្ទាទោសលើបទល្មើសនីមួយៗ តុលាការចាំបាច់សិក្សាពីមូលហេតុ និងកត្តាជំរុញដែលនាំឱ្យមានបទល្មើស ឬកិរិយាមាយាទក្រោយពេលប្រព្រឹត្តបទល្មើស ដោយគោរពនឹងភាពមិនរើសអើង និងស្មើភាពគ្នា ភាព សមាមាត្រនៃទោស និងគោលការណ៍ដោយឡែកដោយផ្អែកលើស្ថានភាពប្រែប្រួលរបស់ជនល្មើសនីមួយៗ។ ផ្ទុយទៅវិញ បើការប្រកាសផ្តន្ទាទោសពុំបានឆ្លងកាត់ការវិនិច្ឆ័យដោយគោរពតាមគោលការណ៍ឯកត្តកម្មនៃទោសទេ ការប្រកាសផ្តន្ទាទោសលើជនល្មើសនឹងនាំឱ្យមានភាពលម្អៀង និងអយុត្តិធម៌ ឬ ឈានដល់មោឃៈភាពនីតិវិធី។ លើសពីនេះទៅទៀត គោលការណ៍នេះក៏ជាមូលដ្ឋានសំខាន់ពាក់ព័ន្ធនឹងរបបទូទៅនៃការប្រកាសទោសរបស់តុលាការដែរ ពោលគឺត្រូវប្រកាសទោសដោយគោរពគោលការណ៍ឯកត្តកម្មនៃទោសដែលអាចឱ្យចៅក្រមធ្វើការពិចារណាក្នុងការសម្រេចលើការប្រកាសមូលទោស ការប្រកាសទោសជំនួស ការប្រកាសទោសបន្ថែមលើមូលទោស ការប្រកាសទោសជំនួស ការព្យួរទោសធម្មតា ការព្យួរទោសសាកល្បង របបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគ ជាអាទិ៍។ ជាសរុបមកវិញ គោលការណ៍ឯកត្តកម្មនៃទោសព្រហ្មទណ្ឌ គឺជាគោលការណ៍ពិសេសមួយដែលមានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបង្កើតឡើងដើម្បីកំណត់ជាមូលដ្ឋានគ្រឹះមួយសម្រាប់ចៅក្រម ធ្វើការថ្លឹងថ្លែង ពិចារណា និងប្រើប្រាស់អំណាចឆន្ទានុសិទ្ធិ ដោយគោរពតាមគោលការណ៍នេះក្នុងការប្រកាសផ្តន្ទាទោសព្រហ្មទណ្ឌទៅតាមកម្រិតនៃអំពើដែលជនជាប់ចោទបានប្រព្រឹត្ត និងទំហំព្យសនកម្មដែលបានបង្កដល់ជនរងគ្រោះ និងសង្គមជាតិដើម្បីផ្តល់ភាពត្រឹមត្រូវ និងយុត្តិធម៌។

[3] មាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

## ២. ការប្រកាសទោសព្រហ្មទណ្ឌចំពោះរូបវន្តបុគ្គល និងនីតិបុគ្គល

ជាទូទៅទោសមាន ៣ (បី) ប្រភេទសម្រាប់រូបវន្តបុគ្គលគឺមូលទោស ទោសបន្ថែម និងទោសជំនួស ហើយទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គលមាន ២ (ពីរ) គឺមូលទោស និងទោសបន្ថែម ដោយមិនមានទោសជំនួសនោះទេ។ ក្នុងការសម្រេចសេចក្ដីផ្ដន្ទាទោសទាំងឡាយ គឺត្រូវមានការពិចារណាទៅលើចំណុចជាច្រើន ព្រោះថាទោសដែលបានប្រកាស គឺមិនមានលក្ខណៈដូចគ្នាទាំងអស់នោះទេ ចំណែកឯលក្ខខណ្ឌក៏មិនដូចគ្នា។ ជាក់ស្តែងដូចជា មូលទោសគឺមានតែទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ទេ ហើយបើមើលទៅលើទោសបន្ថែមវិញឃើញថា គឺជាការបន្ថែមទោសមួយ ឬច្រើនទៅលើមូលទោស ចំណែកឯទោសជំនួសវិញគឺ ជាការយកនូវទោសការងារសហគមន៍ ឬទោសស្ដីបន្ទោសជំនួសឱ្យមូលទោស។

### ២.១ ការប្រកាសមូលទោស

មូលទោស គឺជាទោសចម្បងដែលតុលាការតែងតែយកមកប្រើប្រាស់ក្នុងការប្រកាសផ្ដន្ទាទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស។ អនុលោមតាមមាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌ មូលទោសមាន ២ ប្រភេទគឺ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ដែលការពិន័យត្រូវគិតជាប្រាក់រៀល[4]។

ការពិន័យជាប្រាក់នេះដែរ គឺមិនមែនជាសំណងទៅជនរងគ្រោះទេ គឺជាប្រាក់ពិន័យដែលត្រូវបង់ចូលថវិការដ្ឋ[5]។

ទោសដាក់ពន្ធនាគារ ជាទោសបង្ខំដាក់ទណ្ឌិតក្នុងពន្ធនាគារដោយរាទៅតាមបញ្ញត្តិច្បាប់ដែលកំណត់អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ។ តាមមាត្រា ៤៩ នៃក្រមព្រហ្មទណ្ឌ[6] ទោសដាក់ពន្ធនាគារត្រូវគណនាចិរវេលានៃទោសដាក់ពន្ធនាគារដូចតទៅ៖

-ទោសដាក់ពន្ធនាគារ ១ (មួយ) ថ្ងៃ ត្រូវគិត ២៤ (ម្ភៃបួន) ម៉ោង។

-ទោសដាក់ពន្ធនាគារ ១ (មួយ) ខែ ត្រូវគិត ៣០ (សាមសិប) ថ្ងៃ។

-ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែងដែលមាននៅក្នុងខែនោះ។

-ទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ ត្រូវគិត ១២ (ដប់ពីរ) ខែ។

ទោសដាក់ពន្ធនាគារត្រូវដកចេញនូវចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន។ មានន័យថា ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នត្រូវគិតបញ្ចូលទាំងស្រុងនៅក្នុងចិរវេលានៃទោសដាក់ពន្ធនាគារ ដែលទណ្ឌិតត្រូវទទួល។ ទោសដាក់ពន្ធនាគារត្រូវបានបញ្ចប់ទោសដោយផ្អែកតាមលក្ខខណ្ឌដោយឡែកនៃការបញ្ចប់ទោស

[4] មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[5] មាត្រា ៥២ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[6] មាត្រា ៤៩ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

មានន័យថា កាលណាទណ្ឌិតបានបញ្ចប់ទោសចំថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃបុណ្យ ដូច្នេះអាជ្ញាធរមានសមត្ថកិច្ចត្រូវបង្គាប់ដោះលែងទណ្ឌិតទាំងនោះឱ្យមានសេរីភាពឡើងវិញនៅមុនថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃបុណ្យនោះ[7]។

**២.១.១ ការប្រកាសមូលទោសទៅលើរូបវន្តបុគ្គលជានីតិជន**

ជាគោលការណ៍ដែលទាក់ទងជាមួយការប្រកាសអំពីមូលទោសនេះ គឺមានចែងបញ្ជាក់ក្នុងមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ដែលបានចែងបញ្ជាក់យ៉ាងច្បាស់ត្រង់ចំណុចនេះថា នៅក្នុងមូលទោសមានទោស ២ (ពីរ) ប្រភេទ គឺមានទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ដូច្នេះនៅក្នុងបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌនេះគឺបានចែងកំណត់ផ្គន្ទាទោសចំពោះបទល្មើសមួយដាក់ពន្ធនាគារពីប៉ុន្មានឆ្នាំទៅប៉ុន្មានឆ្នាំ និង ពិន័យជាប្រាក់ពីប៉ុន្មានទៅប៉ុន្មានរៀល។ មិនមែនត្រឹមតែក្រមព្រហ្មទណ្ឌទេ ករណីខ្លះក៏អាចមានបទប្បញ្ញត្តិនៃច្បាប់ពិសេសដទៃផ្សេងទៀតដែលមានចែងដូចគ្នា ហើយជាទូទៅភាគច្រើនក៏មានផងដែរ គឺមានចែងអំពីទោសដាក់ពន្ធនាគាររួច ក៏មានចែងអំពីទោសពិន័យជាប្រាក់ថែមទៀតផង។ ក៏ប៉ុន្តែចាប់តាំងពីក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជានេះបានចូលជាធរមាន និងត្រូវបានយកមកអនុវត្តជាពិសេសក្នុងគន្លីទី១ នេះយើងសម្គាល់ឃើញថាក្រមព្រហ្មទណ្ឌបានចែងអំពីគោលការណ៍ទូទៅមួយដែលគ្របដណ្តប់ទៅលើគ្រប់បទល្មើសព្រហ្មទណ្ឌ រាល់ទោសព្រហ្មទណ្ឌទាំងអស់ទាក់ទងជាមួយនឹងមូលទោសនេះ។

លើសពីនេះទៅទៀត ក្រមព្រហ្មទណ្ឌក៏ចែងអំពីបទប្បញ្ញត្តិស្តីពីរបបនៃការប្រកាសមូលទោស ពោលគឺបានចែងកំណត់ថា ប្រសិនបើបទល្មើសមួយមានចែងផ្គន្ទាទោសដាក់ពន្ធនាគារផង និង ទោសពិន័យជាប្រាក់ផងនោះចៅក្រមគាត់មានសិទ្ធិអំណាច និងសេរីភាពធ្វើការជ្រើសរើសក្នុងការសម្រេចកំណត់អំពីទោសដូចតទៅ៖[8]

១. ចៅក្រមអាចប្រកាសទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ជាមួយគ្នា។

២. ប៉ុន្តែជម្រើសមួយទៀត គឺអនុញ្ញាតឱ្យចៅក្រមមានសិទ្ធិប្រកាសតែទោសដាក់ពន្ធនាគារតែមួយ បានន័យថាមិនមានការប្រកាសទោសពិន័យជាប្រាក់នោះទេ។

៣. ចំណែកឯជម្រើសចុងក្រោយ គឺអនុញ្ញាតឱ្យចៅក្រមមានសិទ្ធិក្នុងការប្រកាសតែទោសពិន័យជាប្រាក់ ដែល ស្មើនឹងការមិនប្រកាសទោសដាក់ពន្ធនាគារក៏បានដែរ។យើងសូមបញ្ជាក់បន្ថែមថា ចំណុចទាំង៣ ដែលបានលើកឡើងខាងលើនេះអាចអនុវត្តទៅបានលុះត្រាតែមិនមានបដិប្បញ្ញត្តិពិសេសចែងផ្ទុយអំពីចំណុចនេះ បើមានបទប្បញ្ញត្តិចែងថាត្រូវតែប្រកាសទោសដាក់ពន្ធនាគារផង និងទោសពិន័យជាប្រាក់ផង នោះចៅក្រមត្រូវតែប្រកាសទោសទាំងពីរនោះព្រមគ្នាតែម្តង។

---

[7] មាត្រា ៥០ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[8] មាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

### ២.១.២ ការប្រកាសមូលទោសទៅលើរូបវន្តបុគ្គលជាអនីតិជន

អនីតិជនគឺជាជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬ ជនដែលអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។ ម្យ៉ាងទៀត អនីតិជនគឺជាជនដែលច្បាប់មិនទាន់ឱ្យទទួលខុសត្រូវលើអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ឬជាជនដែលច្បាប់កំណត់ឱ្យទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត តែការទទួលខុសត្រូវនោះគឺមានកម្រិត។

#### ២.១.២.១ អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ

អនីតិជនប្រភេទនេះ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ មានន័យថាតុលាការមិនអាចសម្រេចផ្តន្ទាទោសទៅលើអនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំបានឡើយ មិនថាក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ ក៏មិនអាចចោទប្រកាន់ទៅលើអនីតិជនដែលមានអាយុ ១៤ ឆ្នាំដែរ ហើយជាទូទៅចៅក្រមមិនចោទប្រកាន់ទេ។ ក៏ប៉ុន្តែអាចមានករណីពិសេសខ្លះក៏ចៅក្រមអាចសម្រេចចោទប្រកាន់ចំពោះអនីតិជនដែលមានអាយុ ១៤ឆ្នាំ នេះដែរដូចជាករណីដែលប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ឬកាចសាហាវជាដើម ។

#### ២.១.២.២ អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ

ប្រសិនជាអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោមអាយុ ១៨ ឆ្នាំ គឺក្នុងករណីនេះ ច្បាប់ទុកលទ្ធភាពឱ្យចៅក្រមធ្វើការពិនិត្យទៅលើជម្រើសនៃវិធានការចំនួន ០២ ដូចតទៅៈ

**ទីមួយៈ** ចៅក្រមមិនប្រកាសអំពីទោសព្រហ្មទណ្ឌទេ បានន័យថាអត់សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់ចំពោះអនីតិជននោះទេ តែចៅក្រមអាចប្រើប្រាស់នូវរបបផ្សេងដូចជាគោលការណ៍ដែលទាក់ទងនឹងវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ជាដើម ដូចមានចែងក្នុងមាត្រា ៤០[9] នៃក្រមព្រហ្មទណ្ឌ។ ហើយបទបញ្ញត្តិទាំងអស់នេះ គឺមាននៅក្នុងបទបញ្ញត្តិនៃមាត្រា ៣៩ មាត្រា ៤០ និងមាត្រា ៤១ នៃក្រមព្រហ្មទណ្ឌ ដែលចែងអំពីរបបគតិយុត្តិពិសេសទាក់ទងនឹងអនីតិជន។ ហេតុនេះ បើសិនជាចៅក្រមមិនជ្រើសរើសយកវិធានការព្រហ្មទណ្ឌក្នុងការផ្តន្ទាទោសទេ គឺចៅក្រមអាចដាក់អនីតិជននោះឱ្យស្ថិតនៅក្រោមវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ហើយលក្ខខណ្ឌនៃការប្រើប្រាស់វិធានការនីមួយៗនេះ គឺមានចែងបញ្ជាក់ជូនច្បាស់នៅក្នុងបទបញ្ញត្តិនៃមាត្រា ៤០ និងមាត្រា ៤១ នៃក្រមព្រហ្មទណ្ឌ។

**ទីពីរៈ** ប្រសិនបើចៅក្រមបានពិនិត្យមើលឃើញយ៉ាងជាក់ច្បាស់អំពីកាលៈទេសៈនៃបទល្មើសហើយនឹងបុគ្គលិកលក្ខណៈរបស់ជនល្មើសដែលជាអនីតិជននោះតម្រូវ ច្បាប់បើកសិទ្ធិឱ្យតុលាការអាចប្រកាសអំពីទណ្ឌកម្មព្រហ្មទណ្ឌ ទៅលើអនីតិជនបានផងដែរ គឺចំពោះអនីតិជនដែលមានអាយុចាប់ ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ។ ប៉ុន្តែបើសិនតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌចំពោះអនីតិជន ដោយយោងតាមកាលៈទេសៈ និងបុគ្គលិក

[9] មាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

លក្ខណៈរបស់ អនីតិជននោះ គឺតុលាការត្រូវអនុវត្តនូវមូលទោសដែលមានចែងនៅក្នុងបទបញ្ញត្តិនៃមាត្រា ១៦០[10] នៃក្រមព្រហ្មទណ្ឌ ព្រោះមាត្រានេះបានចែងអំពីមូលទោសសម្រាប់អនុវត្តចំពោះអនីតិជន។ ផ្ទុយទៅវិញក្នុងករណីនេះគឺមិនមែនប្រើគ្រប់ អនីតិជនទាំងអស់ត្រូវផ្តន្ទាទោសនោះទេ ដូចជាករណីអនីតិជនខ្លះគឺតុលាការគាត់មិនប្រកាសផ្តន្ទាទោសព្រហ្មទណ្ឌអ្វីទេ តែគាត់បែរជាដាក់ក្រោមវិធានការដែលយើងបានលើកឡើងពីខាងលើនោះ ឬក៏តុលាការប្រកាសទោសការងារសហគមន៍ដែលមានចែងក្នុងមាត្រា ១៦២[11] នៃក្រមព្រហ្មទណ្ឌ។ ក៏ប៉ុន្តែ ក្នុងករណីខ្លះជាជម្រើសចុងក្រោយបំផុតរបស់តុលាការ ពីព្រោះស្ថានភាពនៃការប្រព្រឹត្តបទល្មើសនោះវាសាហាវឃោរឃៅខ្លាំងពេក។ **ឧទាហរណ៍**អនីតិជនម្នាក់ឈ្មោះ "ក" មានអាយុ ១៦ ឆ្នាំ បានប្រព្រឹត្តបទឧក្រិដ្ឋមួយដ៏សាហាវឃោឃៅដោយគាត់បានពួនស្ទាក់សម្លាប់ជនរងគ្រោះ ហើយថែមទាំងបានយកកាំបិតកាត់ផ្តាច់អាវៈជីវៈជនរងគ្រោះថែមទៀត។ ក្នុងករណីនេះគឺជា អំពើដ៏សាហាវឃោរឃៅ ដែលចៅក្រមមិនអាចប្រើប្រាស់វិធានការតាមដាន អប់រំការពារ និងឧបត្ថម្ភ អ្វីទៅលើអនីតិជននោះបានទេ គឺចៅក្រមត្រូវតែសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជននោះតែម្តង។ ដូច្នេះបើចៅក្រមសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌគឺគាត់ត្រូវពិនិត្យអំពីមូលទោសដែលមានច្បាស់នៅក្នុងបទប្បញ្ញត្តិមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ បើយោងតាមមាត្រានេះ យើងឃើញថាស្ថានភាពនៃទោសដែលដាក់ចំពោះអនីតិជនដែលបានប្រព្រឹត្តិបទល្មើសគឺត្រូវបានគេសម្រាល។ ជាទូទៅចំពោះអតិបរមានៃទោសដាក់ពន្ធនាគារគឺត្រូវបានសម្រាលពាក់កណ្តាល។ ហើយប្រសិនជាអតិបរមានៃទោសដាក់ពន្ធនាគារ ជាអតិបរមានៃទោសដាក់ពន្ធនាគារអស់មួយជីវិត គឺត្រូវបានសម្រាលដោយត្រូវបន្ថយមកត្រឹមតែ ២០ ឆ្នាំតែប៉ុណ្ណោះ សម្រាប់អតិបរមា។ ចំណែកឯ អប្បរមារនៃទោសដាក់ពន្ធនាគារក៏ត្រូវសម្រាលពាក់កណ្តាលដែរ ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារនេះលើសពីមួយថ្ងៃឡើងទៅគឺបានសេចក្តីថា បើអប្បបរមាចាប់ពីមួយថ្ងៃទៅបើសម្រាលពាក់កណ្តាល គឺនៅសល់កន្លះថ្ងៃ វាអត់ត្រឹមត្រូវនោះទេ ប៉ុន្តែបើចាប់ពី ២ ថ្ងៃទៅច្បាប់ឱ្យសម្រាលមកនៅត្រឹម ១ ថ្ងៃបាន។ នេះគឺទាក់ទងជាមួយទោសដាក់ពន្ធនាគារ។ ចំណែកឯទោសពិន័យជាប្រាក់ក៏ដូចទោសពន្ធនាគារដែរ គឺអប្បបរមា និង អតិបរមានៃទោសពិន័យជាប្រាក់នោះក៏ត្រូវបន្ថយឱ្យអស់ពាក់កណ្តាលដែរ។ ដូចជានៅពេលប្រព្រឹត្តបទល្មើសនីតិជនត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០ (ដប់) លានរៀល ទៅ ២០ (ម្ភៃ) លានរៀល។ តែបើសម្រាប់អនីតិជនវិញ ត្រូវបន្ថយពាក់កណ្តាល គឺមកនៅសលត្រឹមប្រាក់ពី ៥ (ប្រាំ) លានរៀល ទៅ ១០ (ដប់) លានរៀលតែប៉ុណ្ណោះ។ ទាំងនេះគឺជារបបគតិយុត្តិពិសេសមួយសម្រាប់អនីតិជន។

[10] មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[11] មាត្រា ១៦២ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

សូមបញ្ជាក់ថា មូលទោសដែលអនុវត្តនេះគឺវាមានរបបគតិយុត្តិរបស់វាពិសេស ដោយសារវាជាទោសចម្បង ទើបបានជាក្រមព្រហ្មទណ្ឌចែងបញ្ជាក់អំពី "អាជ្ញាយុកាលនៃទោស"[12] ដែលបានចែងបញ្ជាក់ច្បាស់ក្នុងក្រមព្រហ្មទណ្ឌ ពិសេសក្នុងឋានៈជាមូលទោសតែម្តង។ ជាគោលការណ៍ក្រមនីតិវិធីព្រហ្មទណ្ឌ គឺបានចែងច្បាស់អំពីអាជ្ញាយុកាលនៃបទល្មើសព្រហ្មទណ្ឌ ឬ ក៏អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ដែលអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានចែងក្នុងមាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[13] ដែលបានកំណត់យ៉ាងច្បាស់ថា បើសិនជាបទល្មើសមួយជាបទឧក្រិដ្ឋ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា សម្រាប់ធ្វើការចោទប្រកាន់នោះមានរយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំ បទល្មើសមជ្ឈិមមានរយៈពេល ៥ (ប្រាំ) ឆ្នាំ និងបទល្មើសលហុមានរយៈពេល ១ (មួយ) ឆ្នាំ។ ប៉ុន្តែនៅពេលដែលតុលាការសម្រេចផ្តន្ទាទោសរួចហើយសាលក្រមបានចូលជាស្ថាពរ ទោសនោះត្រូវយកទៅអនុវត្តតែដើម្បីអាចយកទៅអនុវត្តបាន គឺទោសនោះត្រូវអនុវត្តនៅក្នុងអាជ្ញាយុកាលផងដែរ ដែលត្រង់ចំណុចនេះហៅថា "អាជ្ញាយុកាលនៃទោស" អាជ្ញាយុកាលនៃទោសគឺមានចែងក្នុងមាត្រា ១៤៤[14] នៃក្រមព្រហ្មទណ្ឌ។ មួយវិញទៀត បើសិនជាទោសនេះមិនត្រូវបានយកទៅអនុវត្តនៅពេលដែលតុលាការផ្តន្ទាទោសហើយ សាលក្រម ឬសាលដីកា ដែលបានចូលជាស្ថាពររួចនោះ បើមិនបានយកទៅអនុវត្តនៅក្នុងអាជ្ញាយុកាលនៃទោសនោះទេ នោះមានន័យថាផុតអាជ្ញាយុកាលនៃទោស ដូច្នេះទោសនោះមិនអាចយកទៅអនុវត្តបានទៀតឡើយ[15]។ ចំពោះអាជ្ញាយុកាលវាប្រែប្រួលទៅតាមចំណាត់ថ្នាក់នៃបទល្មើសរួមមាន៖ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។ ហើយទោសក៏ដូចគ្នាដែររួមមានទោសឧក្រិដ្ឋ ទោសមជ្ឈិម និងទោសលហុ។ យោងតាមមាត្រា ៤៦ មាត្រា ៤៧ និងមាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌបានចែងកំណត់ច្បាស់នូវបទល្មើសជាមួយបទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ។ ប្រសិនបើទោសដែលប្រកាសនោះ ប្រកាសសម្រាប់បទឧក្រិដ្ឋមួយ នោះមានន័យថា ជាបទឧក្រិដ្ឋ ដូច្នេះផ្អែកតាមមាត្រា ១៤៤ នៃក្រមព្រហ្មទណ្ឌ បានចែងថាទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ (ម្ភៃ) ឆ្នាំ ហើយទោសដែលប្រកាសពាក់ព័ន្ធនឹងបទមជ្ឈិមគឺមានអាជ្ញាយុកាលរយៈពេល ៥ (ប្រាំ) ឆ្នាំ ចំណែកឯទោសដែលប្រកាសទៅលើបទលហុគឺមានអាជ្ញាយុកាល ១ (មួយ) ឆ្នាំ។ ហើយចំពោះអាជ្ញាយុកាលនេះទៀតសោតគឺត្រូវគិតចាប់ពីថ្ងៃប្រកាសសាលក្រម ឬសាលដីកាផ្តន្ទាទោសបានចូលជាស្ថាពរ[16] ដែលមានន័យថា បើសាលក្រម ឬ សាលដីកាមួយបានផ្តន្ទាទោសពីបទឧក្រិដ្ឋចូលជាស្ថាពរ រួចពេលជននោះរត់គេចខ្លួនបាត់ទៅ គឺយើងមានរយៈពេល ២០ ឆ្នាំ

[12] មាត្រា ១៤២ ដល់មាត្រា ១៤៦ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[13] មាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[14] មាត្រា ១៤៤ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[15] មាត្រា ១៤២ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[16] មាត្រា ១៤៥ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

គិតចាប់ពីថ្ងៃសាលក្រម ឬសាលដីកាបានចូលជាស្ថាពរ ដើម្បីតាមចាប់ជននឹងឱ្យបាន យើងយកជននឹងទៅអនុវត្តទោសនៅក្នុងពន្ធនាគារ។ ក៏ប៉ុន្តែបើផុតរយៈពេល ២០ ឆ្នាំហើយចាប់ជននោះមិនបានទេ ហើយជននោះត្រឡប់មកវិញ គឺមិនអានអនុវត្តបាននោះទេ ព្រោះថាអាជ្ញាយុកាលនៃទោសត្រូវបានផុតរលត់បាត់ទៅហើយ។ ទាំងនេះគឺសម្រាប់តែបទល្មើសធម្មតានោះទេ ប៉ុន្តែបើសម្រាប់បទល្មើសខ្លះគឺច្បាប់កំណត់ថាគ្មានអាជ្ញាយុកាលទេ[17] ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាដើម។ បទល្មើសឧក្រិដ្ឋកម្មទាំង ៣ នេះ គឺជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរខ្លាំងណាស់ ហើយចំពោះករណីពិសេសផ្សេងទៀតច្បាប់ក៏អាចចែងសម្រាប់បទល្មើសពិសេសធ្ងន់ធ្ងរដូចជាក្នុងវិស័យប្រឆាំងភេរវកម្មនោះ ក៏គេអាចចែងអំពីភាពមិនអាចផុតរលត់អាជ្ញាយុកាលបានដែរ ចំណុចនេះគឺអាស្រ័យទៅតាមបទប្បញ្ញត្តិនីមួយៗ។

### ២.១.៣ ការប្រកាសមូលទោសទៅលើនីតិបុគ្គល

នីបុគ្គល គឺជាក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ឬដែលត្រូវបានទទួលស្គាល់ដោយច្បាប់ ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច[18]។ ពីមុនច្បាប់ចែងតែអំពីការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ឡើងសម្រាប់តែរូបវន្តបុគ្គលតែប៉ុណ្ណោះ។ ប៉ុន្តែក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងយ៉ាងច្បាស់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលផងដែរ តួយ៉ាងដូចជាមាត្រា ៤២ ស្តីពី "ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល" បានចែងកំណត់ថា៖ "នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើស ដែលប្រព្រឹត្តដោយអង្គការ ឬ អ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍ របស់នីតិបុគ្គលនោះ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ"[19]។ នៅក្នុងមូលទោសគឺមិនមានការប្រកាសទោសដាក់ពន្ធនាគារទៅលើនីតិបុគ្គលនោះទេ គឺមានតែទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោស[20]។ ទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោសនេះ មិនមែនមានន័យថា រាល់បទល្មើសដែលចោទប្រកាន់លើនីតិបុគ្គលជាបទលហុនោះទេ។ បទល្មើសប្រព្រឹត្តដើម្បីជាប្រយោជន៍របស់នីតិបុគ្គល ត្រូវចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬ បទលហុ វាអាស្រ័យទៅតាមទម្ងន់នៃបទល្មើសនីមួយៗដែលច្បាប់តម្រូវឱ្យនីតិបុគ្គលទទួលខុសត្រូវ បើទោះបីជាទោសដែលនីតិបុគ្គលត្រូវទទួលរងខុសគ្នាអំពីទោសដែលរូបវន្តត្រូវទទួលក៏ដោយ។

---

[17] មាត្រា ១៤៣ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[18] សន្ទានុក្រមពាក្យច្បាប់ ផ្នែកព្រហ្មទណ្ឌ ទីស្តីការគណៈទីស្តីការគណៈរដ្ឋមន្ត្រី បោះពុម្ពថ្ងៃទី...ខែ...ឆ្នាំ២០១១ លេខរៀងទី ៥៦

[19] មាត្រា ៤២ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[20] មាត្រា ១៦៧ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

សូមបញ្ជាក់ផងដែរថា បានជារដ្ឋមិនទទួលខុសត្រូវព្រហ្មទណ្ឌ ព្រោះមូលហេតុ សត្យានុម័តនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬយុត្តិកម្មនៃបទល្មើសត្រូវបានរំលេចឡើងសម្រាប់នីតិបុគ្គលសាធារណៈ។ អំពើល្មើសនេះត្រូវផ្តន្ទាទោសតាមច្បាប់ តែត្រូវបានចាត់ទុកថា ជាការអនុវត្តសិទ្ធិ ឬជាការបំពេញកាតព្វកិច្ច ដែលអំពើនេះកើតឡើងដោយសារតែអំណាចរដ្ឋ ហើយជាផលប្រយោជន៍ស្របច្បាប់ប៉ុណ្ណោះ។ គួរបញ្ជាក់ផងដែរថា តួនាទីរបស់រដ្ឋគឺបម្រើផលប្រយោជន៍សាធារណៈ ខុសពីនីតិបុគ្គលដែលបម្រើផលប្រយោជន៍ឯកជន ឬទាក់ទងនឹងសេដ្ឋកិច្ច ដូច្នេះកាលណារដ្ឋត្រូវចាត់ទុកថាទទួលខុសត្រូវព្រហ្មទណ្ឌដែលនោះ វានឹងនាំឱ្យមានភាពលំអៀង ឬអយុត្តិធម៌ណាមួយកើតឡើងមិនខានឡើយ ។

## ២.២ ការប្រកាសទោសបន្ថែម

ទោសបន្ថែម គឺជាទោសដែលតុលាការយកមកប្រើនៅក្នុងការប្រកាសបន្ថែមទៅលើមូលទោសតាមការកំណត់ របស់ច្បាប់ដែលចែងក្នុងមាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌ មាន ១៩ ចំណុច[21]។ ទោសបន្ថែមនឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុដែលត្រូវប្រកាស។ ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បាន។ ទោសបន្ថែម ត្រូវប្រកាសជាកាតព្វកិច្ចប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់[22]។

### ២.២.១ ការប្រកាសទោសបន្ថែមទៅលើរូបវន្តជានីតិជន

ជាគោលការណ៍ក្នុងការប្រកាសទោសបន្ថែមគឺមានចែងក្នុងបទបញ្ញត្តិនៃមាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌ។ ផ្អែកតាមមាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌ បានចែងយ៉ាងច្បាស់អំពីរបៀបនៃប្រកាសទោសបន្ថែមថា "ទោសបន្ថែមនឹងត្រូវប្រកាសបានលុះត្រាតែទោសនេះត្រូវបានបែងចែកយ៉ាងជាក់លាក់ចំពោះ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុដែលត្រូវចោទប្រកាន់"។ ទោសបន្ថែមគឺមាន ១៩ ចំណុចដែលមានចែងក្នុងមាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌ។ ដូច្នេះដើម្បីឱ្យកាន់តែយល់ច្បាស់យើងខ្ញុំសូមសរសេរទោសបន្ថែមទាំង ១៩ ចំណុចដែលមានចែងក្នុងមាត្រា ៥៣ មកបញ្ជាក់ដូចខាងក្រោមៈ

១. ការដកសិទ្ធិខ្លះជាពលរដ្ឋ។

២. ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ។

៣. ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ។

៤. ការព្យួរលិខិតបើកបរ។

---

[21] មាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[22] មាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

៥. ការហាមឃាត់ចំពោះអ្នកស្រុកនៅ។

៦. ការហាមឃាត់ចំពោះការចាកចេញពីដែនដីព្រះរាជាណាចក្រកម្ពុជា។

៧. ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិត ដែលជាជនបរទេស។

៨. ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬ ដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស។

៩. ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។

១០. ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស។

១១. ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ អចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

១២. ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត។

១៣. ការហាមឃាត់ចំពោះការកាប់កាន់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤. ការបណ្តេញចេញពីលទ្ធកម្មសារធារណៈ ។

១៥. ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស។

១៦. ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន។

១៧. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស។

១៨. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

១៩. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

ប៉ុន្តែមិនមែនគ្រប់ករណីទាំងអស់ចៅក្រមអាចរើសយកទោសបន្ថែមមួយ ឬ ច្រើនលើសពីមួយក្នុងចំណោមទោសបន្ថែមទាំង ១៩ ចំណុចដែលមានចែងក្នុងមាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌនោះ មកប្រកាសដើម្បីបន្ថែមទៅលើមូលទោសបាននោះទេ។ ជាទូទៅដើម្បីអាចប្រកាសទោសបន្ថែមបាន លុះត្រាតែទោសបន្ថែមនេះមានចែងក្នុងច្បាប់យ៉ាងជាក់លាក់ មានន័យថាចែងជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុដែលត្រូវប្រកាស ។

បើសិនជាមិនបានចែងជាក់លាក់ទេ នោះចៅក្រមមិនអាចប្រកាសអំពីទោសបន្ថែមដើម្បីបន្ថែមទៅលើមូលទោសបានឡើយ។ ដូច្នេះដើម្បីកាន់តែច្បាស់យើងខ្ញុំសូមលើកជាឧទាហរណ៍មួយមកបញ្ជាក់៖ មាត្រា ២០៧ នៃក្រមព្រហ្មទណ្ឌ ដែលចែងអំពីករណីមនុស្សឃាតដោយអចេតនា ហើយច្បាប់ចែងផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២ លានរៀល ទៅ ៦ លានរៀល។ ប៉ុន្តែដើម្បីចៅក្រមអាចប្រកាសអំពីទោស

បន្ថែម ទៅលើមូលទោស ដូចជាទោសពន្ធនាគារ ឬទោសពិន័យជាប្រាក់បាន លុះត្រាតែមានបទប្បញ្ញត្តិមួយទៀតចែងថា ចំពោះបទល្មើសទាក់ ទងជាមួយមនុស្សឃាតដោយអចេតនាចៅក្រមអាចប្រកាសទោសបន្ថែមមួយ ឬច្រើនបាន។ បើយោងលើករណីនេះមាត្រា ២០៨ នៃក្រមព្រហ្មទណ្ឌ ចែងថាទោសបន្ថែមតទៅនេះអាចត្រូវប្រកាសចំពោះបទល្មើសមនុស្សឃាតដោយអចេតនា ហើយច្បាប់ចែងមានចាប់ពីចំណុចទី ១ ដល់ចំណុចទី ៧។ ដូច្នេះបើយើងពិនិត្យមើលមាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌយើងចែងថាទោសបន្ថែមមាន ១៩ ចំណុច ប៉ុន្តែមាត្រា ២០៨ នៃក្រមព្រហ្មទណ្ឌ បានចែងថា ដើម្បីអនុវត្តទោសបន្ថែមចំពោះបទល្មើសមនុស្សឃាតដោយអចេតនាគឺយើងឃើញមានតែ ៧ ចំណុចតែប៉ុណ្ណោះ។ ហេតុនេះនៅពេលដែលមានច្បាប់ចែងជាក់លាក់បែបនេះ ចៅក្រមអាចប្រកាសទោសបន្ថែមមួយ ឬច្រើន ដែលមានចែងក្នុងមាត្រា ២០៨ នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសមនុស្សឃាតដោយអចេតនាបាន។ ប៉ុន្តែរបបនៃការប្រកាសទោសបន្ថែមនេះ ក្រមព្រហ្មទណ្ឌកម្ពុជាយើងក៏បានចែងបញ្ជាក់អំពីបញ្ហានេះជាច្រើននៅក្នុងបញ្ញត្តិមាត្រា ៩៩ និងមាត្រា ១០០ ។ ជាក់ស្ដែង មាត្រា ៩៩ និង មាត្រា ១០០ នៃក្រមព្រហ្មទណ្ឌ ចែងអំពីរបបទូទៅ និងចែងអំពីករណីពិសេស ប៉ុន្តែទាក់ទងនឹងទោសបន្ថែមនេះ គឺមានរបបគតិយុត្តិទូទៅ និងរបបគតិយុត្តិពិសេសមួយដូចមានចែងក្នុងមាត្រា ៩៩ និងមាត្រា ១០០។ មាត្រា ៩៩ បានចែងថា "កាលណាបទល្មើសមួយត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែង តែបទប្បញ្ញត្តិនៃមាត្រា ១០០ (ការជំនួសមូលទោសដោយទោសបន្ថែម) នៃក្រមនេះចេញ"[23] បានសេចក្តីថា ទោសបន្ថែមដូចបានលើកឡើងខាងលើ គឺទោសបន្ថែមនេះអនុវត្តដើម្បីបន្ថែមទៅលើមូលទោស។ ដូច្នេះបើកាលណាច្បាប់ចែងកំណត់អំពីទោសបន្ថែមមួយ ឬ ច្រើនទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស គឺមានន័យថា ចៅក្រមប្រកាសមូលទោសរួចហើយ ទើបគាត់ប្រកាសទោសបន្ថែមទៀត។ ប៉ុន្តែចំពោះករណីពិសេស គឺមានចែងក្នុងមាត្រា ១០០ នៃក្រមព្រហ្មទណ្ឌ ដែលពេលខ្លះចៅក្រមអាចប្រកាសទោសបន្ថែមនេះ ជំនួសឱ្យមូលទោសតែម្តង មានន័យថា ចៅក្រមមិនប្រកាសមូលទោសដូចជាទោសពន្ធនាគារ ឬទោសពិន័យជាប្រាក់ទេ ប៉ុន្តែគាត់សម្រេចជ្រើសរើសយកទោសបន្ថែមមួយ ឬច្រើនដែលមានចែងចំពោះបទល្មើសនោះមកជំនួសឱ្យទោសពន្ធនាគារ ឬទោសពិន័យជាប្រាក់តែម្តង ដោយផ្អែកលើឆន្ទានុសិទ្ធិរបស់គាត់ និងឈរលើគោលការណ៍ឯកត្តកម្មនៃទោសដែលមានចែងក្នុងមាត្រា ៩៦ បូករួមនឹងមាត្រា ១០០[24] តែត្រូវមានលក្ខខណ្ឌ ថាតើពេលណាដែលទោសបន្ថែមអាចត្រូវចៅក្រមយកទៅប្រកាសជំនួសឱ្យមូលទោសបាន។ នេះទាក់ទងទៅនឹងទោសបន្ថែម ក៏ប៉ុន្តែរបបគតិយុត្តិក្នុងករណីពិសេសនៃមាត្រា ១០០ នេះគឺប្រើប្រាស់ដូចគ្នាទៅនឹងទោស

[23] មាត្រា ៩៩ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[24] មាត្រា ១០០ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ជំនួសដែរ ព្រោះថាមាត្រា ១០០ បានចែងថា "តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន នៅក្នុងករណីណាមួយដូចខាងក្រោមៈ

១-កាលណាជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់។

២-កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣ (បី) ឆ្នាំ ។

កាលណាតុលាការសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬ ច្រើន តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ។" ក្នុងករណីនេះហើយដែលទោសបន្ថែមបានដើរតួនាទីមួយទៀតជាទោសជំនួសឱ្យមូលទោសដូចទោសជំនួសអញ្ចឹងដែរ។ យើងខ្ញុំសុំបញ្ជាក់បន្ថែមថា ចំពោះទោសបន្ថែមនេះ ជាទូទៅ បើយោងតាមអត្ថន័យនៃមាត្រា ៩៩ តុលាការ ឬចៅក្រមអាចប្រកាសក៏បាន មិនប្រកាសក៏បានដែរ ព្រោះថាមិនមែនជាកាតព្វកិច្ចរបស់ចៅក្រមត្រូវតែប្រកាសទេ ប៉ុន្តែក្នុងករណីពិសេស បើច្បាប់បានចែងថាត្រូវតែប្រកាសជាដាច់ខាត ដូចជាករណីទោសបន្ថែម ដែលអនុវត្តចំពោះនីតិបុគ្គល គឺចៅក្រមត្រូវតែប្រកាសទោសបន្ថែមមួយ ឬ ច្រើននោះអាស្រ័យទៅតាមច្បាប់។

### ២.២.២ ការប្រកាសទោសបន្ថែមទៅលើរូបវន្តជាអនីតិជន

ក្រៅពីទោសបន្ថែម ដែលត្រូវប្រកាសទៅលើរូបវន្តបុគ្គលជានីតិជនមាន ១៩ ចំណុច នោះក្រមព្រហ្មទណ្ឌបានបញ្ញត្តិនៅក្នុងមាត្រា ១៦១ នៃក្រមព្រហ្មទណ្ឌ ដែលចែងអំពី "ទោសបន្ថែម" ដើម្បីយកទៅប្រកាសទៅលើរូបវន្តបុគ្គលជាអនីតិជន ខុសពីនីតិជន។ ដើម្បីដឹងកាន់តែច្បាស់ថាខុសគ្នាប៉ុន្មានចំណុច សូមពិនិត្យមើលដូចតទៅៈ

#### ២.២.២.១ អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ

អនីតិជនប្រភេទនេះ ដោយសារតែច្បាប់មិនអនុញ្ញាតឱ្យប្រកាសនូវមូលទោសទៅលើអនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំរួចទៅហើយ ដូច្នេះចំពោះទោសបន្ថែមនេះទៀតសោតក៏ដូចគ្នាជាមួយមូលទោសដែរ គឺមិនអាចប្រកាស ទៅលើអនីតិជនប្រភេទនេះបានទេ។ ព្រោះថាទោសបន្ថែម គឺជាទោសបន្ថែមទៅលើមូលទោស ផ្ទុយទៅវិញបើគ្មានការប្រកាសមូលទោសទេ ស្មើនឹងគ្មានការប្រកាសទោសបន្ថែមដូចគ្នា។

#### ២.២.២.២ អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ

កាលណាតុលាការ គ្មានជម្រើសណាមួយក្រៅពីផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំតុលាការក៏អាចសម្រេចប្រើប្រាស់នូវទោសបន្ថែម សម្រាប់អនីតិជនប្រភេទនេះបានដែរ។ លើសពីនេះទៅទៀត លក្ខខណ្ឌនៃការប្រកាសទោសបន្ថែមនេះ ក៏ប្រើដូចនឹងលក្ខខណ្ឌនៃការប្រកាសទោសបន្ថែមសម្រាប់រូបវន្តបុគ្គលជានីតិជនផងដែរ។ ក៏ប៉ុន្តែខុសគ្នាត្រង់ថា ទោសបន្ថែមដែលអាចប្រកាសសម្រាប់អនីតិជនប្រភេទនេះបើយើងផ្អែកតាមមាត្រា ១៦១ នៃក្រមព្រហ្មទណ្ឌ ដែលចែងអំពី "ទោសបន្ថែម" មានត្រឹមតែ ៥ (ប្រាំ) ចំណុចតែប៉ុណ្ណោះ។ ដូច្នេះដើម្បីដឹងថាតើរបបនៃប្រកាសទោសបន្ថែមសម្រាប់អនីតិជនទាំង ៥ (ប្រាំ) ចំណុចនោះមានអ្វី

ខ្លះ? យើងសូមសរសេរបញ្ជាក់ដូចតទៅ៖ មាត្រា ១៦១ នៃក្រមព្រហ្មទណ្ឌ ចែងថា មានតែទោសបន្ថែមដូចមានខាងក្រោមនេះទេ ដែលអាចអនុវត្តទៅលើអនីតិជនបាន៖

១- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។

២- ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣- ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៤- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

៥- ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ។

**២.២.៣ ការប្រកាសទោសបន្ថែមទៅលើនីតិបុគ្គល**

តុលាការអាចប្រកាសទោសបន្ថែមមួយ ឬច្រើនបន្ថែមលើមូលទោសចំពោះនីតិបុគ្គល[25]។ ទោសបន្ថែមដែលត្រូវប្រកាសលើនីតិបុគ្គលអាចខុសគ្នាពីបទល្មើសមួយទៅបទល្មើសមួយទៀតអាស្រ័យទៅតាមភាពចំបាច់ និងកាលៈទេសៈនៃបទល្មើសនីមួយៗ។ ទោសបន្ថែមជារួមដែលអាចប្រកាសអនុវត្តលើនីតិបុគ្គលមានចំនួន ១៤ ចំណុច ដូចមានចែងក្នុងមាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌ[26]។ តែបញ្ញត្តិនេះបានអនុញ្ញាត្តិឱ្យមានការបង្កើតទោសបន្ថែមដទៃទៀតបានដោយបទប្បញ្ញត្តិដោយឡែក។ ចំពោះការប្រកាសទោសបន្ថែមលើនីតិបុគ្គល ក្រមព្រហ្មទណ្ឌបានចងកាតព្វកិច្ចចំពោះចៅក្រម ឬចាប់បង្ខំឱ្យចៅក្រមត្រូវតែប្រកាសទោសបន្ថែមទៅលើនីតិបុគ្គល មានន័យថាទោសបន្ថែមសម្រាប់នីតិបុគ្គលមិនមែនជាជម្រើសរបស់ចៅក្រមថាអាចប្រកាស ឬមិនប្រកាសដូចរូបវន្តបុគ្គលឡើយ។ ដូច្នេះនៅពេលដែលតុលាការសម្រេចផ្តន្ទាទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោសចំពោះនីតិបុគ្គលណាមួយហើយនោះចៅក្រមមានកាតព្វកិច្ចត្រូវតែប្រកាសទោសបន្ថែមដែលមានចែងក្នុងមាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌមួយ ឬច្រើនលើនីតិបុគ្គលនោះជាដាច់ខាត។

មាត្រា ១៦៩ បានកំណត់អំពីលក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម ដោយចែងថា "ទោសបន្ថែមអាចនឹងប្រកាសបានដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់"។ នេះជាអត្ថន័យនៃគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស ហើយដែលគោលការណ៍នេះបង្កប់នូវគោលការណ៍វិសេសភាពទៅតាមបទល្មើសនីមួយៗ(យោងតាមមាត្រា ៣ នៃក្រមព្រហ្មទណ្ឌ)។ ហើយមាត្រា ៦ នៃក្រមព្រហ្មទណ្ឌ ទោសណាមួយអាចត្រូវយកមកអនុវត្តបានលុះត្រាតែទោសនោះប្រកាសដោយតុលាការ។

---

[25] មាត្រា ១៦៩ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[26] មាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

## ២.៣ ការប្រកាសទោសជំនួស

ទោសជំនួស គឺទោសដែលគេដាក់ជំនួសមូលទោស ពោលគឺនៅពេលដែលតុលាការសម្រេចថាប្រកាស ដាក់ទោសជំនួសនេះហើយ គឺតុលាការមិនអាចផ្តន្ទាទោសទណ្ឌិតឱ្យជាប់ទោសពន្ធនាគារ និងទោសពិន័យជាប្រាក់បានឡើយ[27]។ ប៉ុន្តែនៅក្នុងលិខិតថ្កោលទោសគឺនៅតែមានបញ្ជាក់នូវបទល្មើសដែលជននោះបានប្រព្រឹត្ដដែល ទោះបីតុលាការបានផ្តន្ទាទោសជននោះដោយទោសជំនួសក៏ដោយ។ ទោសជំនួសត្រូវបានបែងចែកជាពីរប្រភេទ (មាត្រា ៧២ ដល់ មាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌ) គឺៈ

- ទោសការងារសហគមន៍ **(ចំណុច ២.៣.១)**
- ទោសស្តីបន្ទោស **(ចំណុច ២.៣.២)**។

### ២.៣.១ ការប្រកាសទោសការងារសហគមន៍

ទោសការងារសហគមន៍ គឺជាទោសមួយដែលគេតម្រូវឱ្យធ្វើការការងារជាប្រយោជន៍មួយ ដោយគ្មានកម្រៃនោះទេ ក៏ប៉ុន្តែជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនិតិបុគ្គល សាធារណៈផ្សេងទៀត ដល់សហគមន៍ ឬដល់អង្គការផ្សេងទៀតដែលមិនមែនរដ្ឋាភិបាល។ ទោសនេះអាចអនុវត្តទៅបាន គឺអាស្រ័យទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៧២ ដល់មាត្រា ៧៤ ក៏ដូចជាមាត្រា ៩៨ និងចាប់ពីមាត្រា ១០១ ទៅដល់មាត្រា ១០៣ នៃក្រមព្រហ្មទណ្ឌ ផងដែរ។ គឺមានន័យថា លក្ខខណ្ឌនេះបើប្រើចំពោះបទល្មើសធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសលើសពី ៣ ឆ្នាំ គឺមិនអាចប្រើទោសការងារសហគមន៍បានឡើយ។ ផ្ទុយទៅវិញប្រសិនបើផ្តន្ទាទោសដាក់ពន្ធនាគារដែលអតិបរមានោះតិចជាង ឬស្មើនឹង ៣ ឆ្នាំ ទើបតុលាការអាចប្រកាសទោសការងារសហគមន៍នេះបាន ក៏ប៉ុន្តែបន្ថែមទៅលើលក្ខខណ្ឌនេះគឺច្បាប់បានចែងថា ទោសការងារសហគមន៍អាចប្រកាសទៅបានលុះត្រាតែមានវត្តមានជនជាប់ចោទនៅពេលសវនាការ ហើយគាត់យល់ព្រមទទួលយកការងារសហគមន៍នេះផងដែរ ។ មាត្រា ១០១ នេះគឺចែងមិនឱ្យផ្ទុយនឹងនិយាមការងាររបស់អង្គការពលកម្មអន្តរជាតិនៃអង្គការសហប្រជាជាតិ ព្រោះការងារដែលបង្ខិតបង្ខំត្រូវបានហាមឃាត់។ ដូច្នេះលុះត្រាតែជនជាប់ចោទគាត់យល់ព្រមទទួលយកនូវការងារសហគមន៍នោះដោយខ្លួនឯងនាពេលសវនាការ ទើបតុលាការអាចប្រកាសទោសការងារសហគមន៍នេះបាន។ ហេតុនេះដើម្បីបញ្ជាក់ពីលក្ខខណ្ឌនេះទើបក្រមព្រហ្មទណ្ឌបានបញ្ជាក់បន្ថែមទៀត ថាមុនពេលដែលចៅក្រមប្រកាសសាលក្រម ឬ សាលដីកាពាក់ព័ន្ធនឹងទោសការងារសហគន៍ គឺតុលាការត្រូវសួរទៅជនជាប់ចោទជាមុននាពេលសវនាការ ថាតើជនជាប់បើនោះយល់ព្រមទទួលការងារសហគមន៍នេះដែរឬទេ? ត្រង់ចំណុចនេះគឺមានន័យថា ជនជាប់ចោទគាត់អាចប្រកែកមិនទទួលការងារសហគមន៍នោះបាន ដោយសុខចិត្តចូលអនុវត្តទោស

[27] មាត្រា ៩៨ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ក្នុងពន្ធនាគារ ។ ហើយចម្លើយរបស់ជនជាប់ចោទដែលឆ្លើយនាពេលសវនាការត្រូវតែកត់ត្រាចូលសាលក្រម ឬសាលដីកាដែលជាសេចក្តីសម្រេចរបស់តុលាការ។ ការប្រកាសទោសទោសការងារសហគមន៍នេះទៀតសោតគឺតុលាការត្រូវកំណត់អំពីថិរវេលាឱ្យបានច្បាស់លាស់ ថិរវេលានេះគឺមានចាប់ពី ៣០ (សាមសិប) ម៉ោង រហូតដល់ ២០០ (ម៉ោង)[28] ដោយមាត្រា ១០២ បានចែងថា "តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវបំពេញអំពីថិរវេលានៃការងារនិងរយៈពេលដែលត្រូវបំពេញ រយៈពេលនេះមិនអាចលើសពី ១ (មួយ) ឆ្នាំ ទេ"។ យើងខ្ញុំសូមបញ្ជាក់បន្ថែមថា ទោសការងារសហគមន៍នេះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដដែល។ម្យ៉ាងទៀតការអនុវត្តការងារសហគមន៍គឺត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ហើយចៅក្រមអ្នកកំណត់អំពីបែបបទនៃការអនុវត្តទោសការងារសហគមន៍នេះ[29] ជាពិសេសព្រះរាជអាជ្ញាគាត់គឺជាអ្នកចង្អុលបង្ហាញថាតើនីតិបុគ្គលមួយណាដែលត្រូវបានទទួលផលប្រយោជន៍ពីការងារសហគមន៍នោះ[30]។

ចំពោះការប្រកាសទោសការងារសហគមន៍លើអនីតិជនវិញ បើយោងតាមបទប្បញ្ញត្តិមាត្រា ១៦២ នៃក្រមព្រហ្មទណ្ឌ ទោសការងារសហគមន៍អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ ឆ្នាំ មានន័យថាអនីតិជនដែលមានអាយុ ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ទើបអាចប្រើប្រាស់ទោសការងារសហគមន៍បាន។ ហើយចំពោះថិរវេលាដែលអាចឱ្យអនីតិជននោះធ្វើការងារ មិនឱ្យលើសពី ១០០ (មួយរយ) ម៉ោងទេ បានសេចក្តីថា ថិរវេលានៃទោសការងារសហគមន៍ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ច្បាប់កំណត់ត្រឹមពាក់ កណ្តាលនៃថិរវេលារបស់នីតិជន ដូច្នេះពាក់កណ្តាលនៃ ២០០ (ពីររយ) ម៉ោង គឺស្មើនឹង ១០០ (មួយរយ) ម៉ោង។ មួយវិញទៀតការងារដែលត្រូវប្រកាសគឺត្រូវជ្រើសរើសការងារដែលសមស្របសម្រាប់អនិតិជននោះ ពិសេសគឺស្ថានភាពរបស់អនីតិជនដែលទាក់ទងនឹងការបណ្តុះបណ្តាល និងស្ថានភាពដែលអនុញ្ញាតឱ្យកែសម្រួលអនីតិជន កែប្រែ អប់រំអនីតិជននោះឱ្យចូលទៅរួមរស់នៅក្នុងសង្គមវិញ។

ហេតុនេះលក្ខខណ្ឌទាក់ទងនឹងទោសការងារសហគមន៍ចំពោះអនីតិជន គេត្រូវគិតជាពិសេសថាតើការងារនៅកន្លែងណាដែលមានលក្ខណៈជាការបណ្តុះបណ្តាល ដើម្បីឱ្យគាត់បានរៀនសូត្រ ដើម្បីឱ្យគាត់អប់រំកែប្រែខ្លួនឯង ដើម្បីចូលទៅរស់នៅក្នុងសង្គមវិញ ឬធ្វើសមាហរណកម្មចូល ទៅក្នុងសង្គមវិញដែលចំណុចនេះគឺមានសារៈសំខាន់ណាស់។

[28] មាត្រា ១០២ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[29] សារាចរណែនាំលេខ ០៣ កយ.សរ/១៤ របស់ក្រសួងយុត្តិធម៌ ស្តីពីការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍

[30] មាត្រា ១០៣ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

### **២.៣.២ ការប្រកាសទោសស្តីបន្ទោស**

ការប្រកាសស្តីបន្ទោស នេះក៏ជាទោសជំនួសមួយដែរ គឺជំនួសឱ្យមូលទោស ហើយការស្តីបន្ទោសនេះ តុលាការគ្រាន់តែធ្វើការស្តីបន្ទោសដល់ជនល្មើសដែលបានប្រព្រឹត្តបទល្មើស។ ផ្អែកតាមមាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌ[31] បើជនជាប់ចោទរងទោសដាក់ពន្ធនាគារដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសការស្តីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំង ៣(បី) ដូចតទៅ៖

-លក្ខខណ្ឌទី ១៖ **ភាពមិនចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់** មានន័យថា ទោសស្តីបន្ទោសនេះគឺប្រើសម្រាប់ស្ថានភាពបទល្មើសដែលមានលក្ខណៈមិនធ្ងន់ធ្ងរ ជាពិសេសពេលមានបទល្មើសរួចហើយ មិនសូវមានមតិរបស់សាធារណៈជន មិនសូវចាប់អារម្មណ៍ និងមិនប្រត្តិកម្មខ្លាំងទេ ពីព្រោះមិនប៉ះពាល់អ្វីខ្លាំងខ្លា ដែលបណ្តាលឱ្យមានភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈតទៅទៀតនោះទេ ដោយសារវាជាបទល្មើសតូចតាច

-លក្ខខណ្ឌទី ២៖ **ការខូចខាតត្រូវបានជួសជុលរួចហើយ** មានន័យថា ក្រោយពេលប្រព្រឹត្តបទល្មើសរួចហើយ ជនល្មើសបានជួសជុលព្យសនកម្ម ឬជួសជុសការខូចខាត ដូចជាចេញសងសំណងជំងឺចិត្តវិញជាដើម។

-លក្ខខណ្ឌទី ៣៖ **ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរស់នៅក្នុងសង្គមវិញ** បានសេចក្តីថាគាត់បានបង្ហាញពីឆន្ទៈថាគាត់មានវិប្បដិសារី មានការសោកស្តាយចំពោះកំហុស ដែលខ្លួនបានប្រព្រឹត្តបទល្មើសនោះ ហើយទើបតែបានប្រព្រឹត្តនូវបទល្មើសលើកទី១ ដែលជាបទល្មើសលហុជាដើម ហើយគាត់ធានាថាលើកក្រោយ គាត់មិនប្រព្រឹត្តបែបនេះទៀតនោះទេ ហើយគាត់សុខចិត្តរៀនសូត្រដើម្បីកែប្រែខ្លួនឯង ដើម្បីអាចធ្វើសមាហរណកម្មចូលទៅរួមរស់នៅក្នុងសង្គមវិញបាន។

### **២.៣.៣ ការមិនប្រកាសទោសជំនួសលើនីតិបុគ្គល**

យើងដឹងហើយថា ទោសដែលត្រូវយកមកប្រកាសទៅលើនីតិបុគ្គលគឺមានតែ ០២(ពីរ)ប្រភេទប៉ុណ្ណោះគឺទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោស និងទោសបន្ថែមទាំង ១៤ (ដប់បួន) ចំណុចដែលមានចែងក្នុងមាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌ។ ផ្ទុយទៅវិញគឺមិនមានទោសជំនួសចំពោះនីតិបុគ្គលនោះទេ ពីព្រោះមិនអាចប្រកាសឱ្យនីតិបុគ្គលដែលជាមនុស្សអរូបិយ៍ ទៅធ្វើការងារសហគមន៍ ឬក៏ស្តីបន្ទោសទៅលើ ក្រុមហ៊ុន អង្គការ សហជីប... បានឡើយ។ ហើយបើផ្អែកតាមមាត្រា ១៦៧ នៃក្រមព្រហ្មទណ្ឌក៏មិនមានចែងអំពីទោសជំនួសដែលត្រូវប្រើលើនីតិបុគ្គលដែរ។

---

[31] មាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

# ជំពូកទី២

# របបទូទៅនៃការប្រកាសព្ស័រទោស

# ជំពូកទី២

# របបនៃប្រកាសការព្យួរទោស

ការប្រកាសព្យួរទោស ជាផ្នែកមួយនៃការប្រកាសទោសតាមសេចក្ដីសម្រេចរបស់តុលាការដែលអាចបង្គាប់ឱ្យបង្អង់ប្រតិបត្តិនូវមូលទោសទៅលើជនជាប់ចោទ ប៉ុន្តែទោសនេះមិនត្រូវយកមកអនុវត្តទេ ប្រសិនបើជនជាប់ចោទដែលបានទទួលនូវការបង្អង់ប្រតិបត្តិទោសនេះ មិនបានប្រព្រឹត្តបទល្មើសជាថ្មីទៀតនៅក្នុងរយៈពេលសាកល្បងដែលមានកំណត់ចិរវេលាមួយជាក់លាក់ដោយតុលាការមានសមត្ថកិច្ច។

ជាគោលការណ៍ ការព្យួរទោសជាវិធានការពិសេសមួយដែលអនុញ្ញាតឱ្យតុលាការធ្វើការសម្របសម្រួលនូវភាពចាំបាច់នៃការបង្ក្រាបឯកត្តកម្មនៃទោសដោយយោងទៅតាមស្ថានភាពនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់ជនល្មើស។ វិធានការនេះត្រូវបានប្រគល់ជូនចៅក្រមដែលមានសមត្ថកិច្ចជំនុំជម្រះ ដើម្បីអនុវត្តក្នុងក្របខណ្ឌជាអត្ថប្រយោជន៍របស់ជនជាប់ចោទ និងសង្គម ប្រសិនបើចៅក្រមយល់ឃើញថា ជនជាប់ចោទណាម្នាក់មានមូលហេតុគួរបង្គាប់ឱ្យបង្អង់ប្រតិបត្តិទោស ដោយបង្គាប់ឱ្យជនជាប់ចោទនោះជាប់កាតព្វកិច្ចណាមួយក៏បាន ឬមិនចាំបាច់បង្គាប់ឱ្យជនជាប់ចោទនោះជាប់កាតព្វកិច្ចណាមួយក៏បាន អាស្រ័យលើស្ថានភាពនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់ជនល្មើស ព្រមទាំងស្ថានភាពដទៃទៀតដែលចាំបាច់ និងមានប្រយោជន៍ផ្លូវច្បាប់។

## ១. ការប្រកាសព្យួរទោសធម្មតា

ការប្រកាសព្យួរទោសធម្មតា គឺជាការព្យួរទោសដែលមិនមានដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពកាតព្វកិច្ចដោយឡែកមួយ ឬច្រើននោះទេ[32]។ ការព្យួរទោសធម្មតានេះ ក៏ជារបបមួយនៃការប្រកាសទោសផងដែរ ដែលតុលាការអាចយកមកអនុវត្តបន្ទាប់ពីធ្វើការផ្ដន្ទាទោសជាស្ថាពររួចហើយ។ ការកំណត់ថាជាការព្យួរទោសធម្មតា គឺការព្យួរទោសទូទៅមួយ ហើយនៅពេលដែលតុលាការប្រកាសអំពីការព្យួរទោសប្រភេទនេះគឺពុំមានភ្ជាប់មកជាមួយនឹងវិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែកណាមួយឡើយ នេះហើយគឺជាចំណុចដែលបង្ហាញឱ្យឃើញពីភាពខុសគ្នាជាចម្បងទៅនឹងការព្យួរទោសសាកល្បង។ ចំណុចមួយទៀតដែលខុសគ្នាគឺ ការព្យួរទោសធម្មតាអនុវត្តទៅលើចំណាត់ថ្នាក់នៃបទល្មើសទាំងអស់ ពោលតុលាការអាចប្រកាសការព្យួរទោសធម្មតាទាំងការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ហើយទោសដែលនាំឱ្យមានការព្យួរទោសធម្មតា គឺមូលទោសដែលអាចព្យួរបានទាំងទោសដាក់ពន្ធនាគារ និង ទោសពិន័យជាប្រាក់។ បន្ថែមលើនេះការព្យួរទោសធម្មតាអាចសម្រេចឱ្យមានការព្យួរទោសទាំងស្រុង និងដោយផ្នែក

[32] មាត្រា ២២៣ និង មាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ,នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

ចំពោះទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ការពិនិត្យលើលក្ខខណ្ឌ និងអានុភាពនៃការព្យួរទោសធម្មតា នោះត្រូវពិនិត្យទៅលើប្រភេទនៃបទល្មើស ។

### ១.១ ការព្យួរទោសចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

ការព្យួរទោសធម្មតានេះចៅក្រមអាចធ្វើទៅបានគឺទាល់តែបំពេញនូវលក្ខខណ្ឌចំនួន ២(ពីរ)៖ទីមួយ លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន (ចំណុច ១.១.១) និងទីពីរ លក្ខខណ្ឌទាក់ទងជា មួយនឹងទោសដែលអាចនាំឱ្យមានការព្យួរ (ចំណុច ១.១.២) និងនូវមានចំណុចបន្តបន្ទាប់ទៀត។

#### ១.១.១ លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន[33]

តុលាការអាចប្រកាសព្យួរទោសនេះបាន លុះត្រាតែជនជាប់ចោទមិនដែលមានការផ្តន្ទាទោសជាស្ថាពរពីមុនមកក្នុងរយៈពេល ៥ (ប្រាំ)ឆ្នាំ។ មានន័យថារហូតមកទល់ថ្ងៃដែលគាត់បានប្រព្រឹត្តបទល្មើសនេះ គឺគាត់មិនត្រូវបានតុលាការផ្តន្ទាទោសណាមួយជាស្ថាពរពីមុនមកទេនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ។

#### ១.១.២ លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលនាំឱ្យមានការព្យួរទោស[34]

លក្ខខណ្ឌការព្យួរទោសដែលអាចនាំឱ្យមានការព្យួរទោសនេះ សំដៅដល់ទោសដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារមានរយៈពេលតិចជាង ឬស្មើនឹង ៥ ឆ្នាំ មានន័យថាត្រឹម ៥ ឆ្នាំ តុលាការប្រកាសថាជនជាប់ចោទមានទោសត្រូវដាក់ពន្ធនាគារត្រឹម ៥ ឆ្នាំ ឬស្មើ ៥ ឆ្នាំ គឺតុលាការអាចជ្រើសរើសយកការព្យួរទោសនេះបាន។ ប៉ុន្តែប្រសិនបើផ្តន្ទាទោសលើសពី ៥ ឆ្នាំនោះមិនអាចធ្វើការព្យួរទោសបានឡើយ ។ ចំពោះការព្យួរទោសពិន័យប្រាក់ក្នុងក្រមព្រហ្មទណ្ឌពុំបានកំណត់អំពីចំនួនប៉ុន្មាននោះទេ ដូចនេះបើទោះបីជាការសម្រេចទោសពិន័យជាប្រាក់ប៉ុន្មានក៏ដោយក៏អាចធ្វើការព្យួរទោសបានដែរ។

#### ១.១.៣ ចំណុចផ្សេងៗទៀតពាក់ព័ន្ធនឹងការព្យួរទោសធម្មតា

ចំពោះចំណុចផ្សេងទៀតពាក់ព័ន្ធនឹងការព្យួរទោសធម្មតា គឺមាន ៤ ចំណុចដែលយើងនឹងធ្វើការបកស្រាយការព្យួរទោសមួយផ្នែក **ចំណុច ១.១.៣.១** ការដកហូតការព្យួរទោស **ចំណុច ១.១.៣.២** ការមិនដកហូតការព្យួរទោស **ចំណុច ១.១.៣.៣** និងការទុកជាអសារបង់នូវការផ្តន្ទាទោស **ចំណុច ១.១.៣.៤**។

##### ១.១.៣.១ ការព្យួរទោសមួយផ្នែក

ចំពោះការព្យួរទោសនេះ តុលាការអាចប្រកាសព្យួរទាំងស្រុងក៏បាន ឬ ប្រកាសព្យួរតែមួយផ្នែកក៏បាន ព្រោះតុលាការអាចសម្រេចថា ការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើមួយផ្នែកនៃទោសពន្ធនាគារ ដែលតុលាការគឺជា អ្នកកំណត់ចិរវេលា ឬលើមួយមួយផ្នែកនៃប្រាក់ពិន័យដែលតុលាការជាអ្នកកំណត់ចំនួនទឹកប្រាក់ មានន័យ

[33] មាត្រា ១០៦ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[34] មាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ថា បើសិនជាគាត់ចង់ប្រកាសឱ្យមានការព្យួរទោសមួយផ្នែកនោះគឺ ត្រូវតែកំណត់ឱ្យបានច្បាស់លាស់នូវផ្នែកនៃទោសដែលត្រូវព្យួរ ដូចជាប្រកាសព្យួរទោសទៅលើទោសដាក់ពន្ធនាគារ បើគាត់ចង់ព្យួរមួយផ្នែកនោះ គឺគាត់ត្រូវកំណត់ថារយៈពេលប៉ុន្មានដែលគាត់ឱ្យអនុវត្ត ហើយនឹងរយៈពេលប៉ុន្មានថ្ងៃ ប៉ុន្មានខែ ប៉ុន្មានឆ្នាំដែលគាត់ត្រូវព្យួរមិនឱ្យជាប់ពន្ធនាគារ នោះ[35]។ ដូចជាករណីមួយ តុលាការប្រកាសទោសចំពោះទណ្ឌិតណាមួយ ដោយត្រូវផ្តន្ទាទោសដាក់ក្នុងពន្ធនាគារចំនួន ១៦ (ដប់ប្រាំមួយ)ខែ ក្នុងករណីនេះប្រសិនបើតុលាការមិនចង់ឱ្យមានការព្យួរទោសទាំងស្រុងទេ តុលាការអាចព្យួរត្រឹមតែចំនួន ៨ (ប្រាំបី)ខែ នោះគឺត្រូវព្យួរទោសចំនួន ៨(ប្រាំបី) ខែ ចំណែកឯ ៨ (ប្រាំបី)ខែ ទៀតត្រូវអនុវត្តទោសក្នុងពន្ធនាគារ។ តុលាការត្រូវតែប្រកាស និងកំណត់ឱ្យបានច្បាស់លាស់នៅក្នុងសាលក្រមថាផ្តន្ទាទោសដាក់ពន្ធនាគារ ១៦ (ដប់ប្រាំមួយ)ខែ ប៉ុន្តែទោស ៨ (ប្រាំបី) ខែ ត្រូវព្យួរនេះគឺត្រូវកំណត់ឱ្យបានជាក់លាក់។

ចំពោះទោសពិន័យជាប្រាក់វិញក៏ដូចគ្នាដែរ បើកាលណាតុលាការប្រកាសទោសពិន័យជាប្រាក់បើតុលាការមិនប្រកាសទាំងស្រុងទេ ក៏អាចព្យួរមួយផ្នែកបានដូចគ្នា។ ហេតុនេះហើយបើព្យួរមួយផ្នែកត្រូវកំណត់ចំនួនទឹកប្រាក់ទៅតាមអ្វីដែលគាត់ត្រូវព្យួរ។

**១.១.៣.២ ការដកហូតការព្យួរទោស**

ប្រសិនបើក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតាហើយមានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ការព្យួរទោសធម្មតានេះត្រូវដកហូតដោយពេញច្បាប់។ ទោសទី ១ ត្រូវអនុវត្តដោយមិនអាចស្រូបចូលជាមួយទោសទី ២ បានឡើយ[36]។ ចំពោះការព្យួរទោសធម្មតា បើសិនជាក្នុងរយៈពេល ៥ ឆ្នាំ មិនទាន់ហួសរយៈពេល ៥ ឆ្នាំ ផងជននោះបានទៅប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមណាមួយទៀតនោះ ដូច្នេះករណីនេះបើសិនមានសាលក្រម ឬសាលដីកាក្រោយផ្តន្ទាទោសជាស្ថាពរ នោះទោសទី១ ដែលត្រូវបានផ្តន្ទាទោសមុននោះនឹងត្រូវដកហូតការព្យួរទោសដែលផ្តន្ទាទោសដោយកំណត់នៅក្នុងសាលក្រម ឬសាលដីកាមុន នោះការព្យួរទោសធម្មតានេះត្រូវដកហូតនោះគឺធ្វើដោយពេញច្បាប់ ពោលគឺសាលក្រមទី ១ ដែលកំណត់ទោសប៉ុន្មាននោះ គឺត្រូវដកហូតយកមកអនុវត្តទោសទាំងអស់វិញ ហើយសាលក្រមទី ២ ដែលបានកំណត់អំពីទោសនោះ គឺត្រូវយកមកអនុវត្តដោយបូកបញ្ចូលគ្នា ដោយមិនមានការស្រូបចូលគ្នានោះទេ។

[35] មាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[36] មាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

#### ១.១.៣.៣ ការមិនដកហូតការព្យួរទោស

ជាបដិប្បញ្ញត្តិទៅនឹងមាត្រា ១០៩ (ការដកហូតការព្យួរទោស) នៃក្រមព្រហ្មទណ្ឌ តុលាការអាចសម្រេចថាការផ្តន្ទាទោសថ្មីមិននាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតាដែលបានសម្រេចពីមុខនោះទេ។ សេចក្តីសម្រេចរបស់តុលាការ ត្រូវតែមានសំអាងហេតុជាពិសេស[37]។ យោងតាមអត្ថន័យនៃមាត្រា ១១០ ខាងលើនេះមានន័យថា ច្បាប់បានទុកសិទ្ធិឱ្យចៅក្រមក្នុងការសម្រេច បើសិនជាចៅក្រមយល់ឃើញថាការផ្តន្ទាទោសក្រោយនេះ ទោះបីជាស្ថិតនៅក្នុងកម្រិតរយៈពេល ៥ ឆ្នាំ ដែលជននេះបានប្រព្រឹត្តចំពោះសាលក្រមទី ១ ដែលបានកំណត់ព្យួររួចហើយក៏ដោយ ដូច្នេះមាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌ ឃើញថាត្រូវមានការដកហូតការព្យួរទោស។ ប៉ុន្តែមាត្រា ១១០ នៃក្រមព្រហ្មទណ្ឌនេះគឺបានចែងឱ្យចៅក្រមអាចមានសិទ្ធិសម្រេចមិនដកហូតការព្យួរទោសនោះបាន ដោយចែងយ៉ាងច្បាស់ នៅក្នុងសាលក្រម ហើយបើគាត់យល់ឃើញថាមិនគួរដកហូតការព្យួរទោស ចៅក្រមត្រូវតែសរសេរក្នុងសាលក្រមឱ្យបានច្បាស់លាស់ថាមិនដកហូតការព្យួរទោស ហើយចៅក្រមក៏ត្រូវមានសំអាងហេតុច្បាស់លាស់ថាហេតុអ្វីបានមិនដកហូតការព្យួរទោសនោះ។

#### ១.១.៣.៤ ការទុកជាអសារបង់នូវការផ្តន្ទាទោស

ចំពោះការព្យួរទោសនេះដែរ មាត្រា ១១១ នៃក្រមព្រហ្មទណ្ឌបានចែងថា "បើសិនផុតរយៈពេល ៥ ឆ្នាំបន្ទាប់ពីការផ្តន្ទាទោសចូលជាស្ថាពរពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយគ្មានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះទេ ការផ្តន្ទាទោសដោយមានការព្យួរទោសនេះត្រូវចាត់ទុកជាអសារបង់។ ទោសក៏មិនអាចយកមកអនុវត្តទៀតបានឡើយ"[38]។ ចំណុចនេះមានន័យថា គេលែងយកមកអនុវត្តតទៅទៀតហើយ ទោះបីជាទោសដាក់ពន្ធនាគារក្តី ទោសពិន័យជាប្រាក់ក្តី បើកាលណាការព្យួរទោសត្រូវបានប្រកាសទៅលើតែផ្នែកមួយនៃទោស នោះការផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ទាំងស្រុង ហើយទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ។ ចំណុចខាងលើនេះ គឺសម្រាប់តែទោសដែលទាក់ទងជាមួយនឹងការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម។

### ១.២ ការប្រកាសព្យួរទោសចំពោះបទលហុ

ចំពោះការព្យួរទោសក្នុងបទលហុវិញ គឺមានលក្ខណៈខុសប្លែកគ្នាខ្លះអំពីថិរវេលាដែលទាក់ទងជាមួយ នឹងការផ្តន្ទាទោសពីមុន។ នេះជាលក្ខខណ្ឌចាំបាច់ដែលផ្តល់ឱ្យតុលាការអាចសម្រេចប្រកាសអំពីការព្យួរទោសធម្មតានេះ។ លក្ខខណ្ឌនៅក្នុងការចោទប្រកាន់អំពីបទលហុនេះគឺមាន ២ ដែរ ហើយក៏មានចំណុចសំខាន់ផ្សេងៗទៀតដូចគ្នានឹងការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិមដែរ គឺខុសគ្នាត្រង់តែថិរវេលាតែប៉ុណ្ណោះ។

[37] មាត្រា ១១០ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[38] មាត្រា ១១១ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

**១.២.១ លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន**[39]

ចំណុចនេះ គឺមានខ្លឹមសារទាំងស្រុងទៅនឹងការព្យួរទោសករណីការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ប៉ុន្តែខុសគ្នាត្រង់រយៈពេល គឺត្រឹមតែ ១ ឆ្នាំ ប៉ុណ្ណោះ។ ដោយសារតែបទលហុជាប្រភេទមួយនៃបទល្មើសដែលមានលក្ខណៈតូចតាច ដូច្នេះរយៈពេលកំណត់ក៏តិចទៅតាមនឹងដែរ។ ចំពោះការកំណត់រយៈពេល ១ ឆ្នាំនេះមានន័យថា គិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើសនេះដោយការរាប់ថយក្រោយទៅក្នុងរយៈពេល ១ ឆ្នាំគឺគ្មានការផ្តន្ទាទោសដាក់ពន្ធនាគារ ជាស្ថាពរនៅឡើយ ដូច្នេះតុលាការអាចសម្រេចការព្យួរទោសធម្មតាចំពោះបទលហុនេះបានដោយឆន្ទានុសិទ្ធិ ឬ អាចតាមការស្នើសុំ។

**១.២.២ លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលនាំឱ្យមានការព្យួរទោស**[40]

ចំណុចនេះគឺសំដៅដល់រយៈពេលនៃទោសដែលត្រូវបានប្រកាសដោយតុលាការ ហើយចំពោះបទលហុទោសជាប់ពន្ធនាគារគឺមិនលើសពី ៦ ថ្ងៃ[41]។ ក្រៅពីនេះទោសពិន័យជាប្រាក់នៅក្នុងករណីបទលហុក៏ត្រូវបានកំណត់ថាជាលក្ខខណ្ឌនៃការព្យួរទោសផងដែរ ហើយមិនកំណត់ថាទោសពិន័យនោះមានចំនួនប៉ុន្មានក៏ដោយ។

**១.២.៣ ការដកហូតការព្យួរទោស**

ផ្អែកតាមមាត្រា ១១៤ នៃក្រមព្រហ្មទណ្ឌ បានចែងថា "ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយការផ្តន្ទាទោសជាស្ថាពរពីបទលហុដោយមានការព្យួរទោសធម្មតាផង រួចកើតមានការផ្តន្ទាទោសថ្មីជាស្ថាពរពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការព្យួរទោសធម្មតានេះ ត្រូវដកហូតដោយពេញច្បាប់។ ទោសទី ១ ត្រូវអនុវត្តដោយគ្មានការស្រូបជាមួយទោសទី ២ ឡើយ"[42]។ ដូច្នេះការព្យួរទោសក្នុងបទលហុ បើគាត់បានប្រព្រឹត្តបទល្មើសថ្មីទៀតទាំងបទឧក្រិដ្ឋក្តី បទមជ្ឈិមក្តី ឬបទលហុក្តី ក្នុងរយៈពេល ១ ឆ្នាំ គិតពីថ្ងៃដែលសាលក្រម ឬសាលដីកាមុនចូលជាស្ថាពរមក ដែលមានការព្យួរទោសពីបទលហុនេះ គឺការព្យួរទោសចំពោះបទលហុនៃសាលក្រមមុន ត្រូវដកហូតដោយពេញច្បាប់ ឬ ដោយស្វ័យប្រវត្ត។ ដូច្នេះសាលក្រមទី ១ ត្រូវយកមកអនុវត្តបូកជាមួយនឹងសាលក្រមទី ២ ពោល គឺទោសទាំងប៉ុន្មានដែលបានសម្រេចផ្តន្ទាទោសកំណត់ក្នុងសាលក្រមទី ១ និងសាលក្រមទី ២ បានកំណត់ គឺត្រូវអនុវត្តបូកបញ្ចូលគ្នាតែម្តង ដោយច្បាប់មិនអនុញ្ញាតឱ្យប្រើគោលការណ៍ស្រូបទោសបាននោះទេ។

---

[39] មាត្រា ១១២ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[40] មាត្រា ១១៣ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[41] មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[42] មាត្រា ១១៥ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

### ១.២.៤ ការមិនដកហូតការព្យួរទោស

ដូចគ្នានឹងការចោទប្រកាន់ចំពោះបទមជ្ឈិម និងបទឧក្រិដ្ឋដែរ ទាក់ទងជាមួយនឹងការមិនដកហូតអំពីការព្យួរទោសនេះ ប្រសិនបើជាចៅក្រមនោះយល់ឃើញថា ទោះបីជាទណ្ឌិតបានប្រព្រឹត្តបទល្មើសមួយទៀតក្នុងចិរវេលា ១ ឆ្នាំ បន្ទាប់ពីមានសាលក្រមព្យួរទោសលើកទី ១ រួចហើយក៏ដោយ ប្រសិនបើតុលាការយល់ឃើញថាមិនត្រូវដកហូតនូវការព្យួរទោសធម្មតានេះទេ នោះតុលាការត្រូវសរសេរដោយជាក់លាក់នៅក្នុងសាលក្រម និងមានចែងយ៉ាងច្បាស់នូវសំអាងហេតុជាពិសេសផងដែរ ព្រោះមកពីក្រមព្រហ្មទណ្ឌយើងបានចែងបញ្ជាក់ច្បាស់ថា៖ "ជាបដិប្បញ្ញត្តិនៃមាត្រា ១១៤ (ការដកហូតការព្យួរទោស) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិនអាចនាំឱ្យមានការដកហូត នូវការព្យួរទោសធម្មតានេះដែលសម្រេចពីមុនមកនោះទេ។ សេចក្តីសម្រេចនេះត្រូវតែមានសំអាងហេតុជាពិសេស"[43]។ **ឧទាហរណ៍៖** លោក រតនៈ ជាមនុស្សស្រវឹងខួប ហើយគាត់បានប្រព្រឹត្តបទល្មើសលហុមួយ ដូចមានចែងក្នុងមាត្រា ២៩៧ នៃក្រមព្រហ្មទណ្ឌ គឺបទស្រវឹងជាក់ស្តែង។ តុលាការក៏ផ្តន្ទាទោសពិន័យជាប្រាក់ចំពោះគាត់ តែត្រូវបានព្យួរទោស។ លុះក្រោយមកលោក រតនៈ ក៏បានខំប្រឹងកែខ្លួនដែរ តែកែមិនកើតដោយសារតែគាត់ជាមនុស្សជុសមេស្រាទៅហើយ (អត់ស្រាមិនបាន) ទើបគាត់ទៅប្រព្រឹត្ត **"បទស្រវឹងជាក់ស្តែង"** ម្តងទៀត ដោយលោក រតនៈ បានដើរស្រែកឡូឡាពេញផ្លូវសាធារណៈទាំងដែលខ្លួនស្រវឹងជោគជាំ។ ដូច្នេះក្នុងករណីនេះតុលាការអាចប្រកាសមិនដកហូតការព្យួរទោសរបស់គាត់បាន។

### ១.២.៥ ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស

ត្រង់ចំណុចនេះ មាត្រា ១១៦ នៃក្រមព្រហ្មទណ្ឌបានចែងបញ្ជាក់ថា "ប្រសិនបើក្នុងរយៈពេល ១ ឆ្នាំបន្ទាប់ពីការផ្តន្ទាទោសចូលជាស្ថាពរពីបទលហុ ដែលមានការព្យួរទោសធម្មតា ហើយក៏គ្មានការផ្តន្ទាទោសថ្មីណាមួយបានកើតឡើងពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុទេ ការផ្តន្ទាទោសដែលព្យួរនោះ ត្រូវទុកជាអសារបង់។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតហើយ"[44]។

ដូច្នេះបើហួសរយៈពេល ១ ឆ្នាំ ផុតពីសាលក្រមដែលបានសម្រេចព្យួរទោសស្តីពីបទលហុនោះបានកន្លងផុតទៅ គឺទោសនេះត្រូវបានទុកជាអសារបង់ ពោលគឺទោសនោះមិនអាចយកមកអនុវត្តទៀតបាននោះទេ។

## ២. ការប្រកាសព្យួរទោសសាកល្បង

ការប្រកាសព្យួរទោសសាកល្បង គឺជាការព្យួរទោសដែលអាចផ្តល់ឱ្យទណ្ឌិតដែលត្រូវទទួលរងទោសដាក់ពន្ធនាគារមានរយៈពេលពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ដោយដាក់ទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ

[43] មាត្រា ១១៥ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[44] មាត្រា ១១៦ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បង[45]។ ម្យ៉ាងទៀតបើយើងយោងតាមមាត្រា ១១៧ ចែងថា ការព្យួរទោសសាកល្បងមានអានុភាពដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បង។ យោងតាមអត្ថន័យនៃឃ្លានេះ បានសេចក្តីថា ការព្យួរទោសសាកល្បង គឺតុលាការត្រូវដាក់នៅក្រោមវិធានការត្រួតពិនិត្យ និងដាក់ឱ្យទណ្ឌិតបំពេញនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើននៅក្នុងចិរវេលាដែលតុលាការកំណត់ឱ្យសាកល្បងតាមច្បាប់។

### ២.១ លក្ខខណ្ឌនៃការព្យួរទោសសាកល្បង និងរយៈពេលនៃការសាកល្បង

ផ្អែកតាមមាត្រា ១១៧ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ គឺបានកំណត់អំពី "**លក្ខខណ្ឌនៃការព្យួរទោសសាកល្បង**" និងមាត្រា ១១៨ គឺបានកំណត់អំពី "**រយៈពេលនៃការសាកល្បង**" ដូចតទៅ៖

#### ២.១.១ លក្ខខណ្ឌនៃការព្យួរទោសសាកល្បង

នៅក្នុងនេះ ដើម្បីអាចព្យួរទោសសាកល្បងបាន ទាល់តែទណ្ឌិតនេះត្រូវបានតុលាការគាត់ប្រកាសទោសនៅចន្លោះពី ៦ ខែ ទៅ ៥ ឆ្នាំ មានន័យថាទោសដែលគាត់ត្រូវបានទទួលរងដូចជា តុលាការយល់ឃើញថា ដាក់គុកគាត់ ១ (មួយ) ឆ្នាំ ឬមួយក៏ ៤ (បួន) ឆ្នាំ បែបនេះគឺនៅចន្លោះពី ៦ ខែ ទៅ ៥ ឆ្នាំ។ ដូច្នេះតុលាការអាចជ្រើសរើសយកនូវការព្យួរទោសសាកល្បងបាន ពីព្រោះមាត្រា ១១៧ កថាខណ្ឌទី១ បានកំណត់ថា តុលាការអាចសម្រេចព្យួរទោសសាកល្បងនូវទោសដែលបានសម្រេចដាក់ពន្ធនាគារដែលមាន រយៈពេលពី ៦ ខែ ទៅ ៥ ឆ្នាំ។

#### ២.១.២ រយៈពេលនៃការសាកល្បង

ចំពោះចិរវេលាដែលតុលាការកំណត់ឱ្យសាកល្បងនោះ អាចកំណត់មិនឱ្យតិចជាងមួយឆ្នាំហើយក៏មិនឱ្យលើសពីបីឆ្នាំដែរ ដូច្នេះត្រូវនៅចន្លោះពី ១ ឆ្នាំ ទៅ ៣ ឆ្នាំ តុលាការអាចកំណត់ចិរវេលាឱ្យគាត់សាកល្បងគឺ៖

**ទីមួយ៖** បំពេញនូវកាតព្វកិច្ចដោយឡែកមួយ ឬ ច្រើនដែលតុលាការកំណត់។

**ទីពីរ៖** ស្ថិតនៅក្រោមវិធានការត្រួតពិនិត្យទាំងឡាយដែលច្បាប់បានកំណត់។

ដូច្នេះនៅក្នុងការព្យួរទោសសាកល្បងនេះ តុលាការត្រូវតែកំណត់ចិរវេលាថាប៉ុន្មានឆ្នាំដែលគាត់ត្រូវមានរយៈពេលសាកល្បង។ រយៈពេលនេះមិនអាចតិចជាង ១ ឆ្នាំ និងមិនលើសពី ៣ ឆ្នាំ នោះទេ[46]។

### ២.២ តួនាទីរបស់បុគ្គលដែលដាក់ឱ្យទណ្ឌិតអនុវត្តនូវការព្យួរទោសសាកល្បង

គោលការណ៍ស្តីពីការអនុវត្តរបបនៃការព្យួរទោសសាកល្បង ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ១១៧ ដល់ មាត្រា ១២៣ និងមាត្រា ១៦៥ មិនទាន់អនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយទេ ដែលជាហេតុធ្វើឱ្យការអនុវត្តនៃការព្យួរទោសសាកល្បង មិនទាន់បានល្អប្រសើរនៅឡើយ។

---

[45] មាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[46] មាត្រា ១១៨ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ដូច្នេះយើងខ្ញុំនឹងបកស្រាយអំពីតួនាទីរបស់ចៅក្រមជំនុំជម្រះក្នុងការដាក់ឱ្យទណ្ឌិតអនុវត្តនូវការព្យួរទោសសាកល្បង(ចំណុច ១.២.២) និងបកស្រាយអំពីតួនាទីរបស់ព្រះរាជអាជ្ញាក្នុងការដាក់ទណ្ឌិតឱ្យអនុវត្តនូវការព្យួរទោសសាកល្បង (ចំណុច ១.២.២)។

**២.២.១ តួនាទីរបស់ចៅក្រមជំនុំជម្រះ**

១. យោងតាមមាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌ ចៅក្រមគប្បីត្រូវពិចារណាសម្រេចព្យួរសាកល្បងនៃទោសឱ្យបានជាអតិបរិមានូវទោស ដែលមានសម្រេចដាក់ពន្ធនាគារ ក្នុងបទល្មើសមជ្ឈិម។

២. តុលាការត្រូវចេញសម្រង់សាលក្រមស្ដាពរចំនួនបីច្បាប់។ ចំនួនពីរច្បាប់ប្រគល់ជូនព្រះរាជអាជ្ញា និងមួយច្បាប់ទៀតប្រគល់ជូនឱ្យទៅទណ្ឌិតដើម្បីអនុវត្ត។

**២.២.២ តួនាទីរបស់ព្រះរាជអាជ្ញា**

១. ត្រូវដឹកនាំសម្របសម្រួល ការអនុវត្តសេចក្ដីសម្រេចព្យួរទោសសាកល្បងរបស់តុលាការគ្រប់ជាន់ថ្នាក់ឱ្យមានប្រសិទ្ធិភាព។

២. ត្រូវចាត់តាំងបុគ្គលនៅក្នុងមូលដ្ឋានដែលទណ្ឌិតរស់នៅ ឬ បំពេញកាតព្វកិច្ចឱ្យតាមដានសកម្មភាពរបស់ទណ្ឌិត។ បុគ្គលដែលគម្បីចាត់តាំងដូចជានគរបាលប៉ុស្ដិ៍រដ្ឋបាលសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីទទួលបន្ទុកអប់រំ និងស្ដានីតិសម្បទា...។

៣. ត្រូវណែនាំទណ្ឌិត ឱ្យទៅបង្ហាញខ្លួននៅចំពោះមុខបុគ្គលដែលត្រូវបានចាត់តាំងឱ្យតាមដាន។

៤. ត្រូវប្រគល់សម្រង់សាលក្រម ឬ សម្រង់សាលដីកាស្ដាពរដល់បុគ្គលដែលត្រូវបានចាត់តាំងឱ្យតាមដានទណ្ឌិត និងធ្វើការដឹកនាំសម្របសម្រួលការអនុវត្ត។

៥. ក្នុងករណីចាំបាច់ត្រូវបង្គាប់ទៅអង្គភាពនគរបាលយុត្តិធម៌ឱ្យចាត់វិធានការជួយតាមដានរាល់សកម្មភាពរបស់ទណ្ឌិត និងត្រូវធ្វើរបាយការណ៍តាមការកំណត់ពីការកត់សម្គាល់ឃើញរបស់ខ្លួនចំពោះសកម្មភាពរបស់ទណ្ឌិតជូនទៅព្រះរាជអាជ្ញា ដើម្បីស្នើសុំយោបល់ និងចាត់វិធានការ[47]។

## ២.៣ វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែកដែលអាចដាក់លើទណ្ឌិត

ការព្យួរទោសសាកល្បង បើផ្អែកតាមមាត្រា ១១៩ តើត្រូវអនុវត្តនូវវិធានការត្រួតពិនិត្យអ្វីខ្លះ?និងរៀបរាប់នៅចំណុច (២.៣.១) ចុះបើយើងផ្អែកតាមមាត្រា ១២០ តើត្រូវអនុវត្តនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនមានអ្វីខ្លះ?និងបកស្រាយនៅចំណុច (២.៣.២) ។

[47] សារាចរលេខ ០២ កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌

**២.៣.១ វិធានការត្រួតពិនិត្យដែលអាចដាក់លើទណ្ឌិត**

ចំពោះវិធានការត្រួតពីនិត្យមានទាំងអស់សរុប ៦ ចំណុច យើងសូមសរសេរជូននូវបទប្បញ្ញត្តិនៃមាត្រា ១១៩ តែម្តង គឺវិធានការត្រួតពិនិត្យដែលតម្រូវទៅលើទណ្ឌិតមានដូចតទៅ[48]៖

១.ទណ្ឌិតត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។

២. ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។

៣. ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬ ដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យនូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ។

៤. ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបរបស់ខ្លួនវិញ។

៥. ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបរបស់ខ្លួន។

៦. ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរនៅបរទេស។

ទាំងនេះ គឺជាវិធានការត្រួតពិនិត្យដែលតុលាការដាក់ទៅលើទណ្ឌិតមួយណាដែលត្រូវបានប្រកាសអំពីការព្យួរទោសសាកល្បង។

**២.៣.២ កាតព្វកិច្ចដោយឡែកដែលអាចដាក់លើទណ្ឌិត**

ចំពោះកាតព្វកិច្ចដោយឡែកវិញ មានចែងក្នុងបទប្បញ្ញត្តិនៃមាត្រា ១២០ រួមមានទាំងអស់គឺ ១៣ ចំណុច។ ខ្ញុំសូមសរសេរបង្ហាញជូននូវមាត្រា ១២០ ទាំងស្រុងតែម្តង[49]៖

១. បំពេញសកម្មភាពខាងវិជ្ជាជីវៈ។

២. ទទួលការបង្ហាត់បង្រៀន ឬ ទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ។

៣. រស់នៅក្នុងទីកន្លែងណាមួយជាកំណត់។

៤. ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬ ការព្យាបាល។

៥. បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ។

៦. ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើស តាមលទ្ធភាពនៃធនធានរបស់ខ្លួន។

៧. បញ្ជាក់ថាខ្លួនបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្តន្ទាទោស តាមលទ្ធភាពធនធានរបស់ខ្លួន។

៨. មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ ឬ សង្គមដែលអនុញ្ញាត ឬ សម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់។

៩. មិនត្រូវមានមុខនៅទីកន្លែងខ្លះ។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់។

---

[48] មាត្រា ១១៩ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[49] មាត្រា ១២០ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

១០. មិនត្រូវសេពគប់បនល្បែង។

១១. មិនត្រូវសេពគប់តៀមភេសជ្ជៈស្រវឹង។

១២. មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬ ជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ។

១៣. មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

នៅក្នុងសេចក្ដីសម្រេចតុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែកដែលតម្រូវទៅលើទណ្ឌិត។រីឯកាតព្វកិច្ចដោយឡែករួមទាំងអស់ចំនួន ១៣ ចំណុចខាងលើនេះ គឺតុលាការអាចប្រកាសយកមួយ ឬច្រើនទៅតាមអ្វីដែលគាត់យល់ឃើញថាគួរដាក់ឱ្យទណ្ឌិតនេះបំពេញ។ តែបើសិនជាគាត់មិនបំពេញបាននោះទេ គឺថាចៅក្រមអាចនឹងដកហូតអំពីការព្យួរទោសសាកល្បងនោះចោលវិញបាន ដូច្នេះហើយមាត្រា ១២០ នេះជាកាតព្វកិច្ចដោយឡែកដែលតុលាការរើសយកមកដាក់ដោយក្នុងនោះគាត់ត្រូវមើលថា តើអ្វីដែលពាក់ព័ន្ធជាមួយនឹងជនហ្នឹងដែលគាត់បានប្រព្រឹត្តបទល្មើស។ ករណីនេះមិនមែនចេះតែដាក់ទាំងអស់ តាមតែចិត្តចង់នឹងឃើញដាក់ទៅលើគេនោះទេ តែគាត់អាចរើសដាក់មួយ ឬច្រើនលើសពីមួយបាន។ យើងសូមកត់សម្គាល់បន្ថែមថា កាតព្វកិច្ចនេះគឺដាក់តែទៅលើនីតិជនដែលគាត់ប្រព្រឹត្តបទល្មើសប៉ុណ្ណោះ ពីព្រោះ បទប្បញ្ញត្តិនៃមាត្រា ១២០ នេះគឺចែងតែចំពោះនីតិជន។

ឯចំពោះអនីតិជនវិញគឺ កាតព្វកិច្ចដោយឡែកនោះវាមានចែងក្នុងបញ្ញត្តិមាត្រា ១៦៥[50] ដែលមានលក្ខណៈខុសគ្នាអំពីកាតព្វកិច្ចដោយឡែកដែលដាក់ចំពោះនីតិជន។ សម្រាប់មាត្រា ១៦៥ នៃក្រមព្រហ្មទណ្ឌនេះគឺមានតែ ៩(ប្រាំបួន) ចំណុច តែប៉ុណ្ណោះ ដែលបានកំណត់អំពីកាតព្វកិច្ចដោយឡែកដែលតុលាការអាចដាក់ចំពោះអនីតិជននៅក្នុងករណីដែល អនីតិជនត្រូវបានទទួលនូវការព្យួរទោសសាកល្បង។ មាត្រា ១៦៥ បានចែងថា "នៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះដែលអាចអនុវត្តទៅលើអនីតិជនៈ

១. ទទួលការបង្ហាត់បង្រៀន ឬ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

២. ស្ថិតនៅទីកន្លែងមួយជាកំណត់។

៣. ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬ ព្យាបាល។

៤. ជួសជុលព្យសនកម្មដែលបណ្ដាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន។

៥. បង្ហាញភស្តុតាងបញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយតាមលទ្ធភាពនៃធនធានរបស់ខ្លួនបន្ទាប់ ពីការផ្ដន្ទាទោស។

៦. មិនត្រូវបង្ហាញមុខទៅទីកន្លែងខ្លះ។

៧. មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង។

---

[50] មាត្រា ១៦៥ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

៨. មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬ ជនរងគ្រោះនៃបទល្មើស។

៩. មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ៉។

កាតព្វកិច្ចទាំង ៩ (ប្រាំបួន) ចំណុចខាងលើ គឺជាកាតព្វកិច្ចដោយឡែកដែលត្រូវអនុវត្តចំពោះអនីតិជន។

## ២.៤ ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ

យុត្តាធិការ គឺជាតុលាការ ឬ ស្ថាប័នទទួលបន្ទុកចាត់ការរឿងក្តី។ យោងតាមមាត្រា ១២១ នៃក្រមព្រហ្មទណ្ឌបានបញ្ញត្តិថា នៅគ្រប់ពេលវេលាតុលាការអាចកែប្រែកាតព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិត មានន័យថា នៅពេលដែលកាតព្វកិច្ចណាមួយលែងសមស្របសម្រាប់ទណ្ឌិតទៀតហើយ តុលាការអាចកែប្រែកាតព្វកិច្ចនោះឱ្យសមស្របទៅតាមស្ថានភាពជាក់ស្តែងចំពោះទណ្ឌិត។តុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌ ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ជាក់ស្តែងមាត្រា ៥០០ ស្តីពី "ការលំបាកទាក់ទងនឹងការអនុវត្តទោស" ដោយបានចែងថា "ការលំបាកទាំងឡាយ ដែលទាក់ទងនឹងការអនុវត្តទោស ត្រូវតែលើកជូនតុលាការជាន់ដំបូង ឬតុលាការជាន់ខ្ពស់ ដែលបានសម្រេចផ្តន្ទាទោសនោះដោះស្រាយ។ តុលាការទទួលបណ្តឹង តាមពាក្យប្តឹងរបស់អយ្យការ ឬរបស់ភាគីពាក់ សម្រេចនៅពេលសវនាការសាធារណៈក្រោយពីបានស្តាប់អយ្យការ ភាគីពាក់ព័ន្ធ និង ជាយថាហេតុមេធាវីរបស់ភាគីនេះ។ ការអនុវត្តទោសអាចត្រូវព្យួរដោយតុលាការ។"

### ២.៤.១ ការដកហូតការព្យួរទោសសាកល្បង និងការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់

នៅក្នុងក្រមព្រហ្មទណ្ឌ ក៏មានចែងអំពី"ការដកហូតការព្យួរទោសសាកល្បង[51]" និង "ការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់[52]" ដែលមានខ្លឹមសារដូចតទៅនេះ៖

#### ២.៤.១.១ ការដកហូតការព្យួរទោសាកល្បង

ការព្យួរទោសសាកល្បង អាចត្រូវបានដកហូតដោយតុលាការនៅក្នុងករណីដូចខាងក្រោមនេះ៖

**ទីមួយ៖** ប្រសិនបើក្នុងរយៈពេលសាកល្បងទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យ ឬកាតព្វកិច្ចដោយឡែកទេ។

**ទីពីរ៖** ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាថ្មីម្តងទៀត។

តុលាការអាចបង្គាប់ឱ្យដកហូតការព្យួរទោសសាកល្បងនេះទាំងស្រុង ឬមួយផ្នែក។ នៅក្នុងករណីនេះ ទោសត្រូវយកមកអនុវត្តទាំងស្រុង ឬមួយផ្នែក។តុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌដែលមានចែង

---

[51] មាត្រា ១២២ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[52] មាត្រា ១២៣ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ដោយក្រមនីតិវិធីព្រហ្មទណ្ឌ[53]។ ដូច្នេះ ការព្យួរទោសសាកល្បងមានន័យថាតុលាការអាចដកហូតការព្យួរទោសសាកល្បងបាន ប្រសិនបើមានបណ្ដឹងប្ដឹងដោយព្រះរាជអាជ្ញាទាក់ទងជាមួយការមិនគោរពកាតព្វកិច្ចរបស់គាត់ ពីព្រោះថា ពេលដែលគាត់ធ្វើកិច្ចការនៅក្រោមវិធានការត្រួតពិនិត្យក្តី ឬការបំពេញនូវកាតព្វកិច្ចដោយឡែកក្តី ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញាទាំងអស់។ ហើយបើសិនជាគាត់មិនគោរពនូវកាតព្វកិច្ចណាមួយ ឬក៏មិនបំពេញនូវវិធានការត្រួតពិនិត្យណាមួយនោះទេ គឺ ព្រះរាជអាជ្ញាគាត់អាចប្ដឹងសុំទៅចៅក្រមដើម្បីឱ្យដកហូតនូវការព្យួរទោសសាកល្បងចោលទៅវិញព្រោះថាក្នុងរយៈពេលសាកល្បងនេះ គាត់ត្រូវធ្វើឱ្យអស់នូវកាតព្វកិច្ចដោយឡែក ឬវិធានការត្រួតពិនិត្យនេះ។ ដូច្នេះ ព្រះរាជអាជ្ញាតាមដានហើយនៅក្នុងចិរវេលាដូចជារយៈពេលដែលតុលាការកំណត់ឱ្យសាកល្បងនោះមាន ២ ឆ្នាំស្រាប់តែគាត់អត់បានបំពេញនូវកាតព្វកិច្ចណាមួយ ឬក៏គាត់មិនគោរពនូវវិធានការត្រួតពិនិត្យណាមួយទេ ។ ករណីបែបនេះ ទើបធ្វើឱ្យព្រះរាជអាជ្ញាប្ដឹងទៅចៅក្រមដើម្បីឱ្យតុលាការធ្វើការសម្រេចដកហូតអំពីការព្យួរទោសសាកល្បងវិញ។ ករណីមួយទៀត គឺក្នុងរយៈពេលសាកល្បងនេះ បើគាត់បានប្រព្រឹត្តបទឧក្រិដ្ឋ បទមជ្ឈិមណាមួយជាថ្មីទៀត ពីព្រោះមិនទាន់ហួសរយៈពេលកំណត់ផងគាត់ក៏ទៅប្រព្រឹត្តបទល្មើសតទៅទៀត វាក៏ជាមូលដ្ឋាននៅក្នុងការប្ដឹងសុំរបស់ព្រះរាជអាជ្ញា ដើម្បីឱ្យធ្វើការដកហូតនូវការព្យួរទោសសាកល្បងនេះដែរ។ សម្រាប់បណ្ដឹងសុំឱ្យដកហូតការព្យួរទោសសាកល្បងនេះគឺត្រូវធ្វើឡើងដោយគោរពទៅតាមលក្ខខណ្ឌ ដូចដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌពិសេសមាត្រា ៥០០ ជាដើម។

### ២.៤.១.២ ការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់

ការផ្តន្ទាទោស ត្រូវចាត់ទុកថាជាអសារបង់ ប្រសិនបើមុនការផុតរយៈពេលសាកល្បងការផ្តន្ទាទោសមិនមែនជាកម្មវត្ថុនៃពាក្យសុំដកហូតដែលមានសេចក្តីសម្រេចដកហូតទេ នេះគឺវាបានសេចក្តីថា អំឡុងពេលការសាកល្បង ដែលតុលាការកំណត់ហើយនោះ ទណ្ឌិតក៏បានបំពេញចប់សព្វគ្រប់ និងគាត់មិនបានប្រព្រឹត្តបទល្មើសថ្មីអ្វីទៀតទេ ហេតុដូច្នេះហើយការអនុវត្តទោសនេះគឺត្រូវចាត់ទុកជាអសារបង់ទៅវិញ បានន័យថា ចៅក្រមមិនយកទោសនោះទៅអនុវត្តលើគាត់ទៀតទេ គឺស្មើនឹង គាត់ត្រូវបានរួចខ្លួនផុតពីការផ្តន្ទាទោសរបស់ច្បាប់ព្រហ្មទណ្ឌទៀតហើយ ។

[53] មាត្រា ១២៤ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

# ជំពូកទី៣

# របបដោយឡែកនៃការប្រកាសទោសព្រហ្មទណ្ឌ

# ជំពូកទី៣

# របបដោយឡែកនៃការប្រកាសទោសព្រហ្មទណ្ឌ

## ១. របបពាក់កណ្តាលសេរីភាព

របបពាក់កណ្តាលសេរីភាព គឺជារបបនៃការអនុវត្តទោសដែលអនុញ្ញាតឱ្យទណ្ឌិតអាចចេញពីពន្ធនាគារទៅបំពេញសកម្មភាពវិជ្ជាជីវៈនៅក្នុងរយៈពេលមានកំណត់។[54]ដែលជារបបមួយដូចដែលយើងបានយល់ អំពីការពន្យល់នៅក្នុងទ្រឹស្តី ដែលទាក់ទងជាមួយនឹងរបបទូទៅនៃការប្រកាសទោស គឺសុទ្ធតែក្នុងគោលដៅ កែសម្រួលទណ្ឌិត និងធនាថាអាចធ្វើសមាហរណកម្មទណ្ឌិតឱ្យចូលទៅរួមរស់នៅក្នុងសង្គមវិញ បានន័យថា នៅពេលដែលគាត់បានអនុវត្តទោសក្តី ឬទណ្ឌិតក្តី តែសង្គមមិនចង់ផ្តាច់ទំនាក់ទំនងគ្រួសារ វិជ្ជាជីវៈ ការងារ និងទំនាក់ទំនងក្នុងការសិក្សានៅក្នុងសង្គមនោះឡើយ ទាំងអស់នេះសុទ្ធតែជាគោលគំនិតនៃរបបពាក់កណ្តាលសេរីភាព។ ក្នុងនោះដែលយើងសូមធ្វើការបែងចែក របបពាក់កណ្តាលសេរីភាពនៃជា ២ ផ្នែកធំៗ លក្ខខណ្ឌ និងបែបបទនៃរបបពាក់កណ្តាលសេរីភាព នៅចំណុច (១.១) និងចំណុចផ្សេងៗទៀតនៃរបបពាក់កណ្តាលសេរីភាព ចំណុច (១.២) និងធ្វើការបកស្រាយជូនខាងក្រោមនេះ ៖

### ១.១ លក្ខខណ្ឌ និងបែបបទនៃរបបពាក់កណ្តាលសេរីភាព

នៅក្នុងរបបពាក់កណ្តាលសេរីភាព អាចអនុវត្តបានលុះត្រាតែមានបំពេញនូវលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ១២៧ ចំណុច (១.១.១) និងមាត្រា ១២៨ នៃក្រមព្រហ្មទណ្ឌ បានចែងអំពីបែបបទនៃរបបពាក់កណ្តាលសេរីភាព ចំណុច (១.១.២) ជាមុនសិនមុនឈានដល់ការបកស្រាយទៅដល់ចំណុចដែលតុលាការសម្រេចអំពីរបបពាក់កណ្តាលសេរីភាពចំពោះទណ្ឌិត និងយកមកអនុវត្តបាន។

#### ១.១.១ លក្ខខណ្ឌនៃរបបពាក់កណ្តាលសេរីភាព[55]

នៅក្នុងមាត្រា ១២៧ នៃក្រមព្រហ្មទណ្ឌ បានកំណត់យ៉ាងច្បាស់ថា កាលណាបើតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ៦ (ប្រាំមួយ) ខែ នោះតុលាការអាចសម្រេចថា ទោសដែលត្រូវអនុវត្តអាចដាក់ស្ថិតក្រោមរបបពាក់កណ្តាលសេរីភាពបានដើម្បីអនុញ្ញាតឱ្យទណ្ឌិតអាចបំពេញនូវសកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ការបណ្តុះបណ្តាល ពិនិត្យព្យាបាលជម្ងឺ ឬជួយឧបត្ថម្ភដល់សេចក្តីត្រូវការរបស់គ្រួសារ។ ដូចនេះមានបទល្មើសមួយចំនួន អាស្រ័យទៅលើសាលក្រមរបស់តុលាការ បើកាលណាតុលាការប្រកាសសម្រេចដាក់ពន្ធនាគារមិនលើសពី ៦(ប្រាំមួយ) ខែទេ នោះទោសអាចអនុវត្តនៅក្រោមរបបពាក់កណ្តាលសេរីភាពបាន។

---

[54] សន្ធានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេងរៀងទី ១៩៨

[55] មាត្រា ១២៧ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ចំណុចនេះ មានបទល្មើសភាគច្រើនជាបទល្មើសមជ្ឈិម ដែលតុលាការប្រកាសទោសមិនលើសពី ៦ (ប្រាំមួយ)ខែ ហើយក្រៅពីនោះក៏អាចមាននូវបទល្មើសឧក្រិដ្ឋមួយចំនួនផងដែរ ដែលស្ថិតក្នុងស្ថានភាពជាស្ថានសម្រាលទោសដែលនាំឱ្យតុលាការ ឬចៅក្រម អាចប្រើនូវរបបពាក់កណ្ដាលសេរីភាពបាន ពិសេសសម្រាប់អនីតិជន។

**១.១.២ បែបបទនៃរបបពាក់កណ្ដាលសេរីភាព**

ទណ្ឌិតដែលស្ថិតនៅក្រោម របបពាក់កណ្ដាលសេរីភាព ត្រូវបានអនុញ្ញាតឱ្យចាកចេញពីពន្ធនាគារក្នុងរយៈពេលជាកំណត់។ ហើយតុលាការ កំណត់នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពី ថ្ងៃ និងម៉ោង(ពេលវេលា) ដែលទណ្ឌិតត្រូវបានអនុញ្ញាតឱ្យចាកចេញពីពន្ធនាគារ និងទៅបំពេញកិច្ចការណាមួយតាមការយល់ឃើញរបស់តុលាការ។

ដោយសារតែបុរសម្នាក់ជាមេគ្រួសារដែលត្រូវរ៉ាប់រងបន្ទុកនៃគ្រួសារ ស្រាប់តែមានថ្ងៃមួយសមាជិកនៃគ្រួសាររបស់គាត់ឈឺ ដូច្នេះគាត់ក៏បានសម្រេចចិត្តស្នើទៅតុលាការ បន្ទាប់មកតុលាការបានពិនិត្យទៅលើស្ថានភាពនោះរួចមក ថាវាជាការជួយឧបត្ថម្ភដល់សេចក្ដីត្រូវការរបស់គ្រួសារគាត់ តុលាការក៏អនុញ្ញាតឱ្យទណ្ឌិតនោះចេញទៅរកចំណូលក្នុងរយៈពេលកំណត់ណាមួយដែលតុលាការបានកំណត់។ ក្នុងករណី បុរសជាមេគ្រួសារនោះជាអ្នករត់ម៉ូតូឌុប ដូច្នេះក្នុងករណីនេះតុលាការអាចយករបបពាក់កណ្ដាលសេរីភាពនេះមកអនុវត្ត មានន័យថា ពេលថ្ងៃឱ្យគាត់ទៅរត់ឌុប៦ព្រឹក ដល់ពេលយប់ ឬនៅម៉ោង ១៨ល្ងាច ត្រូវចូលមកក្នុងពន្ធនាគារវិញ ក៏ប៉ុន្តែពេលថ្ងៃ គាត់អាចទៅរត់ឌុប ឬអាចទៅធ្វើអ្វីផ្សេងបាន តាមការកំណត់របស់តុលាការ។

**១.២ ចំណុចផ្សេងៗទៀតនៃរបបពាក់កណ្ដាលសេរីភាព**

ក្រៅអំពីលក្ខខណ្ឌ និងបែបបទនៃរបបពាក់កណ្ដាលសេរីភាព ដូចដែលបានពន្យល់ជូនខាងលើរួចហើយមក គឺនៅមានចំណុចដែលពាក់ព័ន្ធផ្សេងទៀតដែលសំខាន់នៅក្នុងរបបនេះ ដូចជាការគិតបញ្ចូលនូវរយៈពេលនៃរបបពាក់កណ្ដាលសេរីភាពនៅក្នុងទោស (ចំណុច ១.២.១) និងការរៀបចំ និងការលុបចោលនៃរបបពាក់កណ្ដាលសេរីភាព ចំណុច (១.២.២) ខណៈដែលបុគ្គលដែលមាននូវកាតព្វកិច្ចនៅក្នុងការអនុវត្ត ហើយមិនគោរពតាមទេនោះ គេនឹងមាននូវវិធានការដែលត្រូវដកហូតមកវិញ ហើយបុគ្គលត្រូវបានចូលទៅអនុវត្តទោសក្នុងពន្ធនាគារវិញ ចំណុច (១.២.៣) ។

**១.២.១ ការគិតបញ្ចូលរយៈពេលនៃរបបពាក់កណ្ដាលសេរីភាពនៅក្នុងទោស**

រយៈពេលនៃរបបពាក់កណ្ដាលសេរីភាពត្រូវគិតបញ្ចូល ទៅក្នុងចិរវេលានៃទោសដែលកំពុងតែអនុវត្តនោះព្រោះនៅក្នុងរយៈពេលនៃរបបពាក់កណ្ដាលសេរីភាព ករណីដូចជាការអនុញ្ញាតឱ្យទណ្ឌិតអាចបំពេញ

សកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ការបណ្តុះបណ្តាល ពិនិត្យព្យាបាលជម្ងឺ ឬជួយឧបត្ថម្ភដល់សេចក្តីត្រូវការរបស់គ្រួសារ ទាំងនេះគឺជារយៈពេលនៃការអនុវត្តទោសរួចទៅហើយ។

**១.២.២ ការរៀបចំ និងការលុបចោលនៃរបបពាក់កណ្តាលសេរីភាព**

នៅគ្រប់វេលាទាំងអស់ តុលាការអាចរៀបចំរយៈពេលនៃ របបពាក់កណ្តាលសេរីភាព ឬក៏លុបចោលនូវរបបពាក់កណ្តាលសេរីភាពទៅ តាមបណ្តឹងរបស់ព្រះរាជអាជ្ញា បានសេចក្តីថា តុលាការអាចបន្ថែម ឬបន្ថយរយៈពេលនៃរបបពាក់កណ្តាលសេរីភាព ឬមួយក៏ឈប់ប្រើប្រាស់នូវរបបពាក់កណ្តាលសេរីភាពនេះតទៅទៀត ចំពោះរឿងក្តីមួយបានគ្រប់ពេលវេលា ប្រសិនបើមានការប្តឹងសុំពីព្រះរាជអាជ្ញា ឬចៅក្រមអយ្យការ ឬភាគីពាក់ព័ន្ធ[56]។

តុលាការ ត្រូវបានទទួលដំណឹងនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌចំណុចនេះ អាចដូចទៅនឹងករណីដែលមានចែង នៅក្នុងមាត្រា ៥៩៦ ពាក់ព័ន្ធទៅនឹងបទបញ្ញត្តិស្តីពីការអនុវត្តទោសមួយចំនួន។ មាត្រានេះបានចែងថា ចំពោះវិវាទទាក់ទងនឹងការអនុវត្តទោសដែលមានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌ តុលាការទទួលដំណឹងពីព្រះរាជអាជ្ញា តាមរយៈពាក្យសុំធម្មតា។ អយ្យការឱ្យដំណឹងអំពីកាលបរិច្ឆេទនៃសវនាការទៅដល់ភាគីពាក់ព័ន្ធ។ វាក៏អាចពាក់ព័ន្ធទៅដល់មាត្រា ៥០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌផងដែរ ព្រោះមាត្រានេះបានចែងអំពីការលំបាកទាក់ទងនឹងការអនុវត្តទោស ដោយបានបញ្ញត្តិច្បាស់ថា តុលាការទទួលបណ្តឹងតាមពាក្យប្តឹងរបស់អយ្យការ ឬរបស់ភាគីពាក់ព័ន្ធ។ តុលាការនេះសម្រេចនៅពេលសវនាការសាធារណៈក្រោយពីបានស្តាប់ចម្លើយរបស់ព្រះរាជអាជ្ញា ឬតំណាងអយ្យការ ភាគីពាក់ព័ន្ធ និងយថាហេតុមេធាវីរបស់ភាគីនោះ។

**១.២.៣ ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត**

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និង ឃុំខ្លួនចំពោះទណ្ឌិតណាដែលមិនព្រមវិលត្រឡប់មកចូលទៅក្នុងពន្ធនាគារវិញ នៅពេលដែលផុតកំណត់រយៈពេលនៃរបបពាក់កណ្តាលសេរីភា[57] ពីព្រោះការអនុវត្តនូវរបបនេះត្រូវស្ថិតនៅក្រោមការតាមដានរបស់ព្រះរាជអាជ្ញា បានន័យថា បើតុលាការកំណត់ថាដល់ពេលត្រូវចូលក្នុងពន្ធនាគារវិញហើយ ស្រាប់តែដល់ថ្ងៃមិនឃើញទណ្ឌិតនោះទៅដល់ ថែមទាំងមិនមានមូលហេតុសមស្រប នោះព្រះរាជអាជ្ញាអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនទណ្ឌិតដែលគេចខ្លួននោះ ដើម្បីយកមកអនុវត្តទោសក្នុងពន្ធនាគារវិញ។ ទាំងអស់នេះ គឺជាទំនាក់ទំនងជាមួយនឹងគោលបំណងនៃការបង្កើតឱ្យមានឡើងនូវរបបពាក់កណ្តាលសេរីភាព។

---

[56] មាត្រា ៥០០ នៃក្រមនីតិព្រហ្មទណ្ឌ ,នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

[57] មាត្រា ១៣១ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

## ២. របបនៃការបែងចែកទោសជាប្រភាគ

ការបែងចែកទោសជាប្រភាគ គឺជាការបែងចែកទោសជាផ្នែកៗណាមួយតាមរយៈកំណត់ណាមួយ ដែលអាចឱ្យទណ្ឌិតនៅក្រៅពន្ធនាគារ ឬនៅក្នុងពន្ធនាគារ ហើយវាក៏ជាប្រភេទនៃស្ថានសម្រាលទោស មួយដែលតុលាការយល់ថា ទោសនោះត្រូវអនុវត្តជាប្រភាគ ដោយមូលហេតុធ្ងន់ធ្ងរដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម[58]។ ដើម្បីអាចឆ្លើយតបទៅនឹងរបបនេះបានលុះត្រាតែមានលក្ខខណ្ឌ និងបែបបទនៃការបែងចែកនូវទោសជាប្រភាគនេះជាមុនសិន (ចំណុច ២.១) បន្ទាប់មកយើងនឹងធ្វើការប្រៀបធៀបគ្នារវាងរបបទាំងពីរ គឺភាពដូចគ្នា និងខុសគ្នារវាងការបែងចែកទោសជាប្រភាគ ជាមួយនឹងរបបពាក់កណ្តាលសេរីភាព (ចំណុច ២.២) ដោយស្វែងយល់ពីលក្ខណៈពិសេសរបស់វា។

### ២.១ លក្ខខណ្ឌ និងបែបបទនៃការបែងចែកទោសជាប្រភាគ

នៅគ្រប់របបដោយឡែកទាំងអស់នៅក្នុងរបបការប្រកាសទោស ដើម្បីទទួលបាននូវរបបនីមួយៗដាច់ខាតត្រូវតែបំពេញនូវលក្ខខណ្ឌ ក៏ដូចជាបែបបទដើម្បីទទួលបាននូវរបបណាមួយដែលតម្រូវ។ ជាក់ស្តែងដូចជារបបនៃការបែងចែកទោសជាប្រភាគ ក៏មិនខុសពីរបបការមុនៗដែរ ពោលគឺត្រូវបំពេញនូវលក្ខខណ្ឌដូចមានបញ្ញត្តិក្នុងច្បាប់ ចំណុច (២.១.១) ហើយចំពោះលក្ខខណ្ឌ គឺមិនមានលក្ខណៈគ្រប់គ្រាន់អាចយកទៅអនុវត្តបានទេ ពោលត្រូវតែមានបែបបទដើម្បីបញ្ជាក់អំពីនីតិវិធីនៃរយៈពេលទៀតទើបគេអាចយកមកអនុវត្តបាន និងពន្យល់នៅ ចំណុច (២.១.២)។

#### ២.១.១ លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ

ដើម្បីអាចឱ្យទណ្ឌិតទទួលបាននូវលក្ខខណ្ឌមួយនេះបានលុះត្រាតែទណ្ឌិត មានទទ្បីករណ៍ ឬមូលហេតុធ្ងន់ធ្ងរណាមួយជាក់លាក់ ហើយជាករណីចំបាច់ក្នុងការអនុវត្តនៃការបែងទោសជាប្រភាគ ដូច្នេះទណ្ឌិតអាចស្នើសុំការអនុវត្តនូវរបបនេះបាន ដោយអនុលោមតាមក្រមព្រហ្មទណ្ឌបានកំណត់យ៉ាងច្បាស់ហើយថា "កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ១(មួយ) ឆ្នាំ តុលាការអាចសម្រេចថាទោសនោះត្រូវអនុវត្តជាប្រភាគ ដោយសារតែមូលហេតុធ្ងន់ធ្ងរដែលមានលក្ខណៈ ជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម"[59]។ មានបទល្មើសមួយចំនួន គឺអាស្រ័យទៅលើសាលក្រមរបស់តុលាការ បើថាតុលាការសម្រេចដាក់ពន្ធនាគារមិនលើសពី ១(មួយ) ឆ្នាំទេ ទោសនោះអាចអនុវត្តនៅក្រោមការបែងចែកទោសជាប្រភាគ។ ពាក់ពន្ធនិងចំណុចនេះវាមានបទល្មើសភាគច្រើន ជាបទល្មើសមជ្ឈិម ដែលតុលាការប្រកាសទោសមិនលើសពី ១(មួយ)

---

[58] សន្ធានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី បោះពុម្ពថ្ងៃទី...ខែ... ឆ្នាំ ២០១១ លេខរៀងទី១០

[59] មាត្រា ១៣២ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ឆ្នាំឡើយ ក្រៅពីនេះ ក៏វាមាននូវបទល្មើសឧក្រិដ្ឋមួយចំនួនដែលស្ថិតនៅក្នុងស្ថានភាពសម្រាលទោសផងដែរ ដែលតុលាការអាចប្រើរបបពាក់កណ្ដាលសេរីភាព ជាពិសេស សម្រាប់អនីតិជន។

### ២.១.២ បែបបទនៃការបែងចែកទោសជាប្រភាគ

បែបបទនៃការបែងចែកទោសជាប្រភាគនេះ ដោយអនុលោមតាមក្រមព្រហ្មទណ្ឌ មាត្រា ១៣៣ចែងថា "ប្រភាគនៃទោសនីមួយៗមិនត្រូវតិចជាង ១(មួយ)ខែទេ។ ចិរវេលាសរុបនៃការអនុវត្តទោសមិនអាចលើសពី២(ពីរ)ឆ្នាំឡើយ ដោយរាប់បញ្ចូលទាំងការផ្អាកការអនុវត្តទោស។ តុលាការកំណត់ក្នុងសេចក្ដីរបស់ខ្លួនអំពីបែបបទនៃការបែងចែកទោសជាប្រភាគ"[60]។ ដូច្នេះក្នុងឃ្លានេះមានន័យថា ចំណុចនៃរូបមន្តក្នុងបែងចែកទោសជាប្រភាគ គឺទោសដាក់ពន្ធធនាគារនីមួយៗ ត្រូវបែងចែកមិនឱ្យតិចជាង ១(មួយ)ខែឡើយ ហើយចិរវេលាដែលត្រូវអនុវត្តគឺ មិនត្រូវឱ្យលើសពី ២(ពីរ) ឆ្នាំទេ ដោយត្រូវបូកបញ្ចូលទាំងរយៈពេលនៃការផ្អាកការអនុវត្តទោសផងដែរ។[61] ហេតុនេះនៅត្រង់ចំនុចនេះយើងអាចនិយាយបានថារយៈពេលដែលនៅក្រៅពន្ធធនាគារដែលស្ថិតក្នុងការអនុវត្តទោសប្រភេទនេះមិនត្រូវបានរាប់បញ្ចូលជាមួយទោសដែលនៅក្នុងពន្ធនាគារនោះទេ ដោយធ្វើយ៉ាងណាទាំងការនៅក្នុង និងក្រៅពន្ធនាគារ របបនៃការបែងចែកទោសជាប្រភាគមិនឱ្យលើស ២(ពីរ) ឆ្នាំឡើយ។

## ២.២ ភាពដូចគ្នារវាងការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្ដាលសេរីភាព

ចំណុចដែលគួរពិចារណារវាង ការបែងចែកទោសជាប្រភាគ ឬរបបពាក់កណ្ដាលសេរីភាពក្ដី សុទ្ធតែមានគោលដៅធ្វើយ៉ាងណាមិនឱ្យទណ្ឌិតដែលស្ថិតនៅក្នុងរយៈពេលនៃការអនុវត្តទោសនោះ ត្រូវកាត់ផ្ដាច់ចេញពីទំនាក់ទំនងគ្រួសារ ទំនាក់ទំនងវេជ្ជសាស្ត្រ ទំនាក់ទំនងវិជ្ជាជីវៈ ឬទំនាក់ទំនងសង្គមឡើយ។ បើយោងតាមការបកស្រាយខាងលើយើងឃើញថារបបទាំងពីរមានលក្ខណៈដូចគ្នានូវចំណុចមួយចំនួនដូចជា លក្ខខណ្ឌដែលទទួលបាន(ចំណុច ២.២.១) ការកែប្រែ នៃការបែងចែកទោស (ចំណុច ២.២.២) និងការចាប់ខ្លួនទណ្ឌិត(ចំណុច ២.២.៣) ដែលយើងនិងបកស្រាយនូវភាពដូចគ្នាទាំងពីរនេះដូចតទៅ៖

### ២.២.១ លក្ខខណ្ឌដែលទទួលបាន

យើងអាចញែកបានថា របបទាំងពីរនេះសុទ្ធតែមានលក្ខខណ្ឌ ហើយចំពោះលក្ខខណ្ឌដែលអាចឱ្យទណ្ឌិតទទួលបាននោះលុះត្រា ការបែងចែកទោសទាំង ២(ពីរ) នោះគឺសុទ្ធតែស្ថិតនៅក្នុងស្ថានភាពដែលត្រូវបានផ្ដន្ទាទោសមិនអាចលើសពី ៦ (ប្រាំមួយ) ខែ ចំពោះ របបពាក់កណ្ដាលសេរីភាព និង ១ (មួយ) ឆ្នាំ ចំពោះការបែងចែកទោសជាប្រភាគ។

---

[60] មាត្រា ១៣៣ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[61] ដោយយោងតាមប្រសាសន៍ **ឯកឧត្ដម ហ៊ី សោភា** ប្រធានក្រុមការងារចូលរួមតាក់តែង និងការពារ សេចក្ដីព្រាងក្រមព្រហ្មទណ្ឌ កាលពីថ្ងៃ ២២ ខែ កក្កដា ឆ្នាំ ២០១១ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ស្ដីពី «ក្រមព្រហ្មទណ្ឌ»

### ២.២.២ ការកែប្រែនៃការបែងចែកទោស

ប្រសិនបើយើងក្រឡេកមើលទៅតាមក្រមព្រហ្មទណ្ឌ មាត្រា ១៣៤ និងមាត្រា ១៣០ គឺមានអត្ថន័យដូចតែគ្នាទេ គ្រាន់តែនៅក្នុងរបបពាក់កណ្ដាលសេរីភាព បានប្រើពាក្យ "ការរៀបចំ និងការលុបចោល" ចំណែកឯ ការបែងចែកទោសជាប្រភាគគេប្រើនូវពាក្យ «ការកែប្រែ» ។ តែបើតាមអត្ថន័យពិតប្រាកដ ឬស៊ីជម្រៅគឺ ការរៀបចំ និងការលុបចោល និងដូចតែគ្នាទៅនឹងការកែប្រែទេ ព្រោះមាត្រា ១៣៤ បានចែងថា នៅក្នុងគ្រប់វេលាតុលាការអាចរៀបចំបែបបទនៃការបែងចែកទោសជាប្រភាគ ឬលុបចោលនូវរបបនៃការបែងចែកទោសជាប្រភាគ ផ្អែកតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា។

ហេតុដូច្នេះ ហើយទើបតុលាការ អាចបន្ថែម ឬបន្ថយរយៈពេល នៃការបែងចែកទោសជាប្រភាគ តទៅទៀតចំពោះរឿងក្ដីមួយបានគ្រប់ពេល នេះប្រសិនបើជាមានការប្ដឹងសុំអំពីព្រះរាជអាជ្ញា បានន័យថានៅគ្រប់ករណីក្នុងពេលវេលានៃការអនុវត្តរបបពាក់កណ្ដាលសេរីភាពក្ដី ក៏ដូចជាការបែងចែកទោសជាប្រភាគក្ដី អាចត្រូវបានតុលាការកែប្រែទៅតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ជាពិសេស គឺទាក់ទងជាមួយនឹងឥរិយាបទរបស់គាត់ កាលបើព្រះរាជអាជ្ញាពិនិត្យទៅឃើញថា ដូចជាមិនសូវល្អនោះទេ បើទុកគាត់ឱ្យនៅបន្តក្រៅបន្តទៀត វាប្រឈមនឹងហានិភ័យគ្រោះថ្នាក់។ ឬក៏ស្ថានភាពនៃគោលការណ៍ឯកត្តកម្មនៃទោសនេះ ការអនុវត្តត្រូវក្រោមការតាមដានរបស់ព្រះរាជអាជ្ញា ដូច្នេះគឺអាចប្ដឹងសុំលុបរបបពាក់កណ្ដាលសេរីភាព ឬប្ដឹងសុំលុបចោលរបបនៃការបែងចែកទោសជាប្រភាគ នោះចោលតែម្ដងទៅ។

### ២.២.៣ ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ការចាប់ និងឃុំខ្លួនទណ្ឌិត អាចធ្វើឡើងដោយការបង្គាប់របស់ព្រះរាជអាជ្ញាបាន ប្រសិនបើ ថាទណ្ឌិតនោះមិនវិលត្រឡប់ នៅពេលផុតកំណត់រយៈពេលនៃការផ្អាកការអនុវត្តទោស[62] ពីព្រោះថាការអនុវត្តនូវរបបនេះ គឺត្រូវស្ថិតនៅក្រោមការតាមដានរបស់ព្រះរាជអាជ្ញា បានន័យថាដូចគ្នានឹងករណីនៃរបបពាក់កណ្ដាលសេរីភាពដែរ ប្រសិនបើដល់ពេលគេអនុញ្ញាតឲ្យគាត់នៅក្រៅឃុំ ក៏ប៉ុន្តែនៅពេលផុតរយៈពេលនៅក្រៅឃុំ ជននោះត្រូវចូលមន្ទីរឃុំឃាំងវិញទៅហើយ តែគាត់បែរជាមិនចូលទៅក្នុងវិញ។ បើដូច្នេះមែននោះ ព្រះរាជអាជ្ញាគាត់នឹងចេញបញ្ជាឱ្យចាប់ខ្លួន និងឃុំខ្លួនទណ្ឌិតដែលមិនបាន វិលត្រឡប់មកវិញតាមការកំណត់ កាលបើគ្មានមូលហេតុត្រឹមត្រូវ ដែលអាចទទួលយកបាន ។

[62] មាត្រា ១៣៥ នៃក្រមពហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

## ២.៣ ភាពខុសគ្នារវាងការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្ដាលសេរីភាព

តាមពិតទៅរបបទាំង ២(ពីរ)នេះមិនសូវជាមានភាពខុសគ្នាប៉ុន្មានទេ ប៉ុន្តែដើម្បីឱ្យមានភាពច្បាស់លាស់ យើងខ្ញុំនិងលម្អិតនូវភាពខុសគ្នារវាង របបនៃការបែងចែកទោសជាប្រភាគ ទៅនឹងរបបពាក់កណ្ដាលសេរីភាព ហើយយើងឃើញថាចំណុចមួយចំនួនដែលធ្វើឱ្យមាន ភាពខុសគ្នារវាងរបបពាក់កណ្ដាលសេរីភាព និង ការបែងចែកទោសជាប្រភាគ នោះមានត្រង់ ៖

**ចំណុច១ ៖** នៅក្នុងមាត្រា ១៣២ នៃក្រមព្រហ្មទណ្ឌ បានចែងយ៉ាងច្បាស់ថា កាលណាបើតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ១ឆ្នាំ បានន័យថា បើប្រកាសទោសជាប់ពន្ធនាគារ មិនលើសពី ១(មួយ) ឆ្នាំទេ ដូច្នេះអាចអនុវត្តដោយធ្វើទៅ តាមប្រព័ន្ធនៃការបែងចែកទោសជាប្រភាគបាន។ ចំណែកឯ របបពាក់ កណ្ដាលសេរីភាព គឺទោសដែលតុលាការបានប្រកាសនោះ គឺមិនលើសពី ៦ខែ ទេ។

**ចំណុច២៖** ចំពោះទោសជាប្រភាគនៅក្នុងបែបបទនៃការនូវក្រៅពន្ធនាគារ គឺមានលក្ខណៈ មិនតិចជាង ១ (មួយ) ខែនោះទេ ឬមិនឱ្យលើសពី ២(ពីរ)ឆ្នាំ ។ រីឯរបបពាក់កណ្ដាលសេរីភាពវិញនោះ តុលាការកំណត់ជាថ្ងៃដែលនៅក្រៅឃុំ ហើយពេលវេលាដែលត្រូវទៅដល់ទីកន្លែងឃុំឃាំងវិញ ជាក់ស្ដែងដូចជា ម៉ោង ៦ (ប្រាំមួយ) ចេញពីពន្ធធនាគារ ហើយនៅម៉ោង ១៨ (ដប់ប្រាំបី) ត្រូវចូលក្នុងពន្ធនាគារវិញ តែត្រូវបានចេញជារៀងរាល់ថ្ងៃ។ មូលហេតុដោយសារតែ នៅក្នុងក្រមព្រហ្មទណ្ឌមាត្រា ១៣២ បានបញ្ជាក់អំពីមូលហេតុធ្ងន់ធ្ងរដែលមានលក្ខណៈជាវេជ្ជសាស្ត្រ គ្រួសារ ឬជាលក្ខណៈជាសង្គម ទាំងនេះគឺទាក់ទង និងមូលហេតុ។

**ចំណុច៣៖** បើយើងពិនិត្យទៅលើរយៈនៃការនៅក្រៅឃុំនៃរបបទាំងពីរនេះវិញ យើងឃើញថា របបនៃការបែងចែកទោសជាប្រភាគ មិនត្រូវបានគិតអំពីរយៈពេលនៃការ នៅក្នុងពន្ធនាគារ និងនៅក្រៅពន្ធនាគារបញ្ចូលគ្នាទេដែលវាមានលក្ខណៈខុសគ្នាអំពី របបពាក់កណ្ដាលសេរីភាព ដែលរយៈពេលនៃការនៅក្រៅពន្ធនាគារ ចាត់ទុកថាបានអនុវត្តទោសដូចនៅក្នុងពន្ធនាគារផងដែរ ថ្វីត្បិតតែរយៈពេលនៃការនៅក្រៅមន្ទីរឃុំឃាំងមានរយៈពេលតិចជាងទោសជាប្រភាគក៏ដោយ។

## ៣. របបនៃការផ្អាកការប្រកាសទោស

របបនៃការផ្អាកការប្រកាសទោស បានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ការផ្អាកការប្រកាសទោស គឺជាការផ្អាកការប្រកាសទោស ដែលធ្វើឡើងដោយតុលាការ និងប្រកាសនូវទោសណាមួយ ដើម្បីយកមកអនុវត្ត ។ បន្ទាប់ពីបានយល់នូវខ្លឹមសារនៃការផ្អាកការប្រកាសទោសរួចមក យើងនឹងស្វែងយល់នូវលក្ខខណ្ឌនៃការផ្អាកការប្រកាសទោស (៣.១) សវនាការពិនិត្យរឿងដែលបង្អង់(៣.២) និងភាពខុសគ្នារវាង ការផ្អាកការប្រកាសទោស និងការផ្អាកសវនាការនាពេលសព្វថ្ងៃ(៣.៣) ដូចខាងក្រោម ៖

### ៣.១ លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស

លក្ខខណ្ឌដែលមាននាំឱ្យមានការផ្អាកនូវ របបនៃការផ្អាកការប្រកាសទោស វាទាក់ទងនិងលក្ខខណ្ឌធំៗ ចំនួន ២ (ពីរ) បទល្មើសដែលត្រូវចោទប្រកាន់ (៣.១.១) និងជនជាប់ចោទត្រូវតែមានវត្តមាននៅពេលសវនាការ (៣.១.២) ដូច្នេះយើងនិងធ្វើការបកស្រាយតទៅដូចខាងក្រោម ៖

#### ៣.១.១ បទល្មើសដែលត្រូវចោទប្រកាន់

ការផ្អាកការប្រកាសទោស អាចប្រកាសបានតែចំពោះបទល្មើសមជ្ឈិមប៉ុណ្ណោះ គឺមិនអាចអនុវត្តចំពោះ បទល្មើសដ៏ទៃទៀតបានឡើយ មានន័យថា លុះត្រាតែតុលាការបានធ្វើការចោទប្រកាន់អំពីបទមជ្ឈិម ហើយ ឈានដល់ការប្រកាសលើជនល្មើសថា ពិតជាមានពិរុទ្ធភាព ប៉ុន្តែក្នុងន័យនេះ មិនមែនមានន័យថាចៅក្រមអាច ប្រកាសទោសម្តងនោះទេ គឺគាត់អាចផ្អាកការប្រកាសទោសដោយផ្អែកលក្ខខណ្ឌ ៣ (បី) យ៉ាង[63] នោះគឺ

-ភាពច្របូកច្របល់នៃ បទល្មើសត្រូវបានបញ្ឈប់

-ជនជាប់ចោទបង្ហាញការធានាក្នុងការចូលរួមរស់នៅក្នុងសង្គមវិញ

-ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត។

##### ៣.១.១.១ ភាពច្របូកច្របល់ នៃបទល្មើសត្រូវបានបញ្ឈប់

ភាពច្របូកច្របល់ នៃបទល្មើសត្រូវបានបញ្ឈប់មានន័យថា ត្រង់ចំណុចនេះយើងផ្តោតទៅលើតែ បទ ល្មើសណាដែលស្រាលៗ តែប៉ុណ្ណោះ ជាពិសេស គឺបទល្មើសដែលបង្កត្រឹមតែ កម្រិតស្រាល ដូចជាការប៉ះពាល់ ត្រឹមទ្រព្យសម្បត្តិអ្នកដ៏ទៃ ដែលវាមិនធ្វើឱ្យមានភាពរីករាលទៅដល់សង្គម ឬ មិនបង្កការភ័យខ្លាចដល់ចិត្តសាស្ត្រ ឬ រន្ធត់ទៅដល់មនុស្សក្នុងសហគមន៍ ឬទៅដល់ភូមិ ឃុំ ហើយបទល្មើសទាំងនោះត្រូវបានកើតឡើង ប៉ុន្តែហើយវា ក៏ត្រូវបានបញ្ឈប់ភ្លាមៗផងដែរ ។

##### ៣.១.១.២ ជនជាប់ចោទបង្ហាញការធានាក្នុងការចូលរួមរស់នៅក្នុងសង្គមវិញ

ជនជាប់ចោទបង្ហាញការធានាក្នុងការចូលរួមរស់នៅក្នុងសង្គមវិញ គឺចំណុចនេះវាពាក់ព័ន្ធនិងកិរិយា មាយាទរបស់ជនជាប់ចោទ ថាក្រោយពីបានប្រព្រឹត្តនូវកំហុសណាមួយ ជននោះបានធានាសន្យាថា និងកែប្រែ ខ្លួន ដើម្បីឱ្យក្លាយជាពលរដ្ឋល្អដែលរស់នៅក្នុងសង្គម ឬគេអាចនិយាយបានថា បុគ្គលដែលបានប្រព្រឹត្តនូវបទ ល្មើសណាមួយហើយ ចេះកែប្រែចរិកមាយាទ និងសន្យាថាមិនបង្កនូវបទល្មើសណាមួយដែលធ្វើឱ្យប៉ះពាល់ដល់ សង្គម ទាំងនេះហើយហៅថា ការធានាក្នុងការចូលរួមរស់នៅក្នុងសង្គមវិញ ។

[63] មាត្រា ១២៤ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

#### ៣.១.១.៣ ជនជាប់ចោទសុំរយៈពេលដើម្បីជុសជុលការខូចខាត

ជនជាប់ចោទសុំរយៈពេលដើម្បីជុសជុលការខូចខាត សំដៅដល់ជនណាម្នាក់ដែលបានប្រព្រឹត្តបទល្មើសណាមួយ ដែលត្រូវបានប្រកាសផ្តន្ទាទោសជននោះ ប៉ុន្តែក្នុងករណីដែលជននោះមិនទាន់មានលទ្ធភាពក្នុងការសងទេ គឺគាត់អាចស្នើសុំរយៈពេលសមរម្យណាមួយដើម្បីទៅរកប្រាក់ ឬ ទៅរកស៊ីក្នុងគោលបំណងដើម្បីទទួលបានប្រាក់យកទៅសងសំណងការខូចខាតនោះ ។

### ៣.១.២ ជនជាប់ចោទត្រូវតែមានវត្តមាននៅពេលសវនាការ

យោងទៅតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១២៥ បានចែងថា "ការផ្អាកការប្រកាសទោសអាចត្រូវបានបង្គាប់បាន លុះត្រាតែជនជាប់ចោទមានវត្តមានក្នុងសវនាការ។ តុលាការអាចកំណត់នៅក្នុងសាលក្រម ឬសាលដីកានូវកាលបរិច្ឆេទដែលត្រូវសម្រេចអំពីទោស ។ សេចក្តីសម្រេចអំពីទោសត្រូវតែធ្វើឡើងយ៉ាងយូរបំផុត ១ (មួយ) ឆ្នាំ ក្រោយចេញសេចក្តីសម្រេចផ្អាក"[64]។

ដូច្នេះដើម្បីអាចធ្វើការសម្រេចផ្អាកការប្រកាសទោសនេះបាន លុះត្រាតែបំពេញនូវលក្ខខណ្ឌដែលបានលើកឡើងខាងលើនេះ ទើបតុលាការអាចសម្រេចបង្គាប់ផ្អាកការប្រកាសទោសនេះទៅបាន។ ជាពិសេសគ្រប់សាលក្រម ឬសាលដីកា ដែលសម្រេចអំពីការផ្អាកការប្រកាសទោសនេះ គឺតុលាការត្រូវសម្រេចកំណត់អំពីកាលបរិច្ឆេទឱ្យបានច្បាស់ ថាតើត្រូវបើកសវនាការជាថ្មីនៅថ្ងៃណា ខែណា ឆ្នាំណា ម៉ោងប៉ុន្មាន ដើម្បីសម្រេចអំពីទោសនោះ។ ត្រង់ចំណុចរយៈពេលដែលកំណត់នេះ មាត្រា ១២៥ កថាខណ្ឌទី៣ ក៏បានចែងកំណត់យ៉ាងច្បាស់អំពីរយៈពេលនេះដែរ គឺមានរយៈពេលយ៉ាងយូរបំផុតត្រឹម ១(មួយ) ឆ្នាំ ក្រោយពីសម្រេចផ្អាក។

## ៣.២ សវនាការពិនិត្យរឿងដែលបង្អង់

ផ្អែកតាមមាត្រា ១២៦ នៃក្រមព្រហ្មទណ្ឌបានចែងថា "នៅពេលសវនាការពិនិត្យរឿងដែលបង្អង់ តុលាការសម្រេចអំពីទោស"[65] មាត្រានេះចែងមកមានន័យថា ដោយសារតែមានមូលដ្ឋានដែលជាលក្ខខណ្ឌនៃមាត្រា ១២៤ និងមាត្រា ១២៥ ទើបតុលាការដែលបង្អង់រឿងក្តីនោះទុកសិន លុះដល់កាលបរិច្ឆេទដែលតុលាការបានកំណត់ក្នុងសាលក្រម ឬសាលដីកានោះ ទើបតុលាការយករឿងដែលបង្អង់នោះមកសម្រេចអំពីទោសឡើងវិញ ។

## ៣.៣ ភាពខុសគ្នារវាងការផ្អាកការប្រកាសទោស និងការផ្អាកសវនាការពេលសព្វថ្ងៃ

សូមបញ្ជាក់អំពីការផ្អាកការប្រកាសទោស ជាមួយនិងការផ្អាកសវនាការនាពេលសព្វថ្ងៃនៅក្នុងតុលាការនៃព្រះរាជាណាចក្រកម្ពុជាយើង គឺតុលាការបានបើកសវនាការហើយតែគាត់មិនបានប្រកាសសេចក្តី

---

[64] មាត្រា ១២៥ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[65] មាត្រា ១២៦ នៃក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

សម្រេចនៃសាលក្រមភ្លាមៗនៅក្នុងថ្ងៃសវនាការនោះទេ គឺក្រោយពីថ្ងៃសវនាការចន្លោះពី ១ សប្តាហ៍ ទៅ ៣ សប្តាហ៍ ឬលើសពីនេះ ទើបតុលាការប្រកាសអំពីសេចក្តីសម្រេចនៃសាលក្រម។ ចំពោះការដាក់កាលបរច្ឆេទសវនាការរបស់តុលាការ មិនមែនគ្រប់ករណីឱ្យតែតុលាការដាក់កាលបរិច្ឆេទសុទ្ធតែបានបើកសវនាការនោះទេ អាចមានករណីខ្លះត្រូវបានស្នើសុំពន្យាពេលសវនាការពីដើមបណ្តឹង ជនជាប់ចោទ ឬមេធាវីជាដើម។ ទាំងនេះគឺជាករណីផ្សេងខុសដាច់ដោយឡែកពីគ្នា ឬអាចនិយាយបានថាវាផ្ទុយគ្នាទៅនិងការផ្អាកការប្រកាសទោស ដែលមានចែងនៅក្នុងស្មារតីនៃក្រមព្រហ្មទណ្ឌ ចាប់ពីមាត្រា ១២៤ ដល់មាត្រា ១២៦ ព្រោះការផ្អាកការប្រកាសទោសតាមបទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ គឺជារបបមួយនៅក្នុងនីតិវិធីព្រហ្មទណ្ឌ ក៏ដូចជាក្រមព្រហ្មទណ្ឌរបស់កម្ពុជាយើងផងដែរ។ ក្នុងករណីនេះដែរ នៅពេលតុលាការបើកសវនាការ តុលាការយល់ឃើញថា ត្រូវសម្រេចឱ្យជនជាប់ចោទមានពិរុទ្ធគាត់ក៏ផ្អាកការប្រកាសទោស តាមលក្ខខណ្ឌដោយមានកំណត់ចែងក្នុងមាត្រា ១២៤ ដែលមាន ៣ ចំណុចដូចដែលបានលើកឡើងពីខាងលើដែលឬយ៉ាងណា ។ លុះ ៨ (ប្រាំបី) ខែក្រោយមក ទើបតុលាការបើកសវនាការដើម្បីសម្រេចអំពីទោស ដូច្នេះនៅពេលបើកសវនាការនោះតុលាការត្រូវសម្រេចអំពីទោសផងដែរនៅពេលនោះ ហើយតុលាការនឹង ពិនិត្យអំពីឥរិយាបថរបស់ជនជាប់ចោទថា តើគាត់បានធ្វើអ្វីខ្លះ ដើម្បីបង្ហាញថាគាត់បានចូលរួមរស់នៅក្នុងសង្គមវិញនោះ? តើគាត់បានធ្វើអ្វីខ្លះទាក់ទងជាមួយនិងការជួសជុលការខូចខាត? ហេតុនេះ ប្រសិនបើជាឃើញថាមានស្ថានភាពដូចដែលបានលើកឡើងខាងលើនោះ តុលាការអាចជ្រើសរើសទោសដែលផ្តល់នូវស្ថានសម្រាល ឬ មួយក៏គាត់ ប្រកាសទោសជំនួស ត្រង់នេះមានន័យថា គាត់អត់ប្រកាសទោសជាប់ពន្ធនាគារ ឬក៏ទោសពិន័យជាប្រាក់ទេ តែគាត់ប្រកាសទោសជំនួសដែលជាទោសស្តីបន្ទោស ឬទោសការងារសហគមន៍ ។

សរុបសេចក្តីមក របបដោយឡែកទាំង៣នេះ ពិតជាមានគោលបំណងល្អ វិធីសាស្ត្រថ្មីមួយក្នុងការទុកលទ្ធភាពដល់ទណ្ឌិត ដែលអាចអនុញ្ញាតឱ្យទណ្ឌិតមានក្នុងការចេញទៅធ្វើអ្វីមួយក្នុងពេលកំណត់ណាមួយដែលមានការយល់ព្រមពីតុលាការ ឬព្រះរាជអាជ្ញា។ ចំពោះរបបដោយឡែកនេះ បើធៀបនិងក្រមព្រហ្មទណ្ឌចាស់ វាមានភាពល្អប្រសើរខ្លាំង ដែលមិនធ្លាប់មានពីមុនមក ហេតុនេះតាមនីតិករយើងព្យាយាមក្នុងការបង្កើតឱ្យមានរបបនេះឡើង គឺធ្វើយ៉ាងណាឱ្យទណ្ឌិតបានចូលទៅរួមរស់ក្នុងសង្គមវិញ ដែលអនុវត្តតាមវិធានការអប់រំ កែប្រែនិងសម្រួលទណ្ឌិតឱ្យក្លាយទៅជាពលរដ្ឋល្អ ដើម្បីក្លាយទៅជាជនដែលមានប្រយោជន៍ទៅដល់សង្គម។ ហេតុនេះ ក្រៅពីគោលការណ៍ឯកត្តកម្មនៃទោស ហើយក៏មានបង្កើតនូវរបបទាំងនេះឡើងដើម្បីបម្រើដល់គោលដៅនៃទោសព្រហ្មទណ្ឌឬមួយក៏បម្រើដល់គោលបំណងនៃទោសព្រហ្មទណ្ឌ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងតាមសិក្សាស្រាវជ្រាវកន្លងមកទៅលើប្រធានបទស្តីពី របបនៃការប្រកាសទោស យើងឃើញថា របបនៃការប្រកាសទោស គឺមានសារៈសំខាន់ណាស់សម្រាប់ប្រកាសទោសចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើស និងការពិន័យចំពោះបុគ្គលដែលបានធ្វើខុស។ ក្នុងការប្រកាសទោសចំពោះបុគ្គល ឬ នីតិបុគ្គលក្តី គឺជាឆន្ទានុសិទ្ធិរបស់ចៅក្រមក្នុងការសម្រេច ដែលជាយុត្តាធិការរបស់ចៅក្រមក្នុងការប្រកាសទោស យើងដឹងហើយថាគ្មានបុគ្គលណាម្នាក់ត្រូវបានយកមកអនុវត្តទោសបានឡើយ ប្រសិនជាបុគ្គលនោះមិនត្រូវបានប្រកាសទោសដោយតុលាការ។ ដូចនេះ ក្នុងរបបនៃការប្រកាសទោស ដើម្បីកំណត់អំពីអត្ថិភាពនៃបទល្មើសដែលបុគ្គលនោះបានប្រព្រឹត្តិ និងផ្តន្ទាទោសបានដោយយោងតាមការប្រកាសអំពីទោសរបស់បុគ្គលនោះដែលត្រូវទទួល។ ក្នុងគោលគារណ៍នៃការប្រកាសទោស ដែលជាឆន្ទានុសិទ្ធិរបស់ចៅក្រមទៅលើការដាក់ទោសលើជនល្មើសណាមួយពោលគឺ ផ្អែកតាមគោលការណ៍ ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការឯកត្តកម្មនៃទោស។ គោលការណ៍ទាំងពីរនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រកាសទោសចំពោះបុគ្គលដែលបានប្រព្រឹត្តិបទល្មើស ព្រោះថាគោលការឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលជាការទទួលខុសត្រូវចំពោះតែអំពើដែលខ្លួនបានធ្វើ ឬប្រព្រឹត្តប៉ុណ្ណោះ គឺមិនអនុញ្ញាត្តិឱ្យ នណាម្នាក់ទទួលទោសជំនួសនោះទេ។ ម្យ៉ាងទៀត ក្នុងគោលការណ៍ឯកត្តកម្មនៃទោស ជាគោលការណ៍មូលដ្ឋានក្នុងការបញ្ញតិសម្រាប់ចៅក្រមលើកយកមកពិចារណាមុននឹងធ្វើការផ្តន្ទាទោស។ មូលហេតុចាំបាច់ក្នុងការប្រកាសទោស គឺសំខាន់ក្នុងការយកបុគ្គលដែលទទួលខុសមកផ្តន្ទាទោសតាមច្បាប់ដែលបានបញ្ញតិ ដោយស្របតាម រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៨ កថាខណ្ឌទី៦ បានចែងថា៖ "ជនជាប់ចោទណាក៏ដោយត្រូវចាត់ទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ" ដែលជាការធានាឱ្យបាននូវការការពារសិទ្ធិស្របច្បាប់របស់បុគ្គលគ្រប់រូប។ នៅក្នុងគោលការណ៍របបនៃការប្រកាសមានទាំងគោលការណ៍បន្ធូរបន្ថយ ក៏ដូចជាការអនុគ្រោះចំពោះទណ្ឌិតដែលបានប្រព្រឹត្តនូវបទល្មើសមជ្ឈិម ព្រមទាំងលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់។ ការបន្ធូរបន្ថយ ឬ អនុគ្រោះដល់ទណ្ឌិតមានគោលការណ៍មួយចំនួនរួមមាន ការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បង។ ទន្ទឹមនឹងនេះផងដែល ក្នុងគោលការណ៍របបនៃការប្រកាសក៏មាននូវរបបពាក់កណ្តាលសេរីភាព ដែលមើលទៅដូចជាការសម្រាលទោសមួយ សម្រាប់ទណ្ឌិតក្នុងការអនុវត្តទោសរបស់ខ្លួន។ ការបង្កើតគោលការណ៍ ឬបទបញ្ញត្តិទាក់ទងនឹងការប្រកាសទោស គឺផ្តល់នូវបទបញ្ញត្តិមូលដ្ឋានក្នុងការសម្រេចទោសចំពោះទណ្ឌិត ដែលជាឆន្ទានុសិទ្ធិរបស់ចៅក្រម និងស្របតាមច្បាប់កំណត់យ៉ាងជាក់លាក់។ អាស្រ័យដូចនេះ របបនៃការប្រកាសទោស មានសារៈប្រយោជន៍ចំពោះការអនុវត្តចំពោះជនដែលបានប្រព្រឹត្តិបទល្មើសបាន ព្រោះថាបុគ្គលដែលអាចអនុវត្តទោស ឬផ្តន្ទាទោសបានត្រូវធ្វើឡើងដោយចៅក្រម ឬតុលាការ ស្រមតាមមាត្រា ៦ នៃក្រមព្រហ្មទណ្ឌ។

ជាចុងបញ្ចប់ យើងខ្ញុំសូមសន្និដ្ឋានថា របបនៃការប្រកាសទោសព្រហ្មទណ្ឌ ដែលផ្អែកលើក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាននូវរបបជាច្រើនដែលមានសារៈសំខាន់សម្រាប់ទណ្ឌិត។ មិនត្រឹមតែប៉ុណ្ណោះ នៅក្នុងការប្រកាស

ផ្តន្ទាទោសព្រហ្មទណ្ឌ ក៏មាននូវរបបដោយឡែកផ្សេងទៀតដែលអាចជំនួសឱ្យការជាប់ពន្ធនាគារបានផងដែរ កាលដែលតុលាការយកនូវទោសណាមួយមកជំនួសឱ្យទោសពន្ធនាគារ ពិតណាស់ច្បាស់ជាបានផ្តល់សេរីភាព និងលទ្ធភាពជាច្រើនដល់ទណ្ឌិត ក្នុងការអបរំ ទូន្មាន និងកែប្រែ ដើម្បីឱ្យទណ្ឌិតបានដឹងនូវអំពើដែលខ្លួនប្រព្រឹត្ត និងលែងហ៊ានប្រព្រឹត្តអំពើបែបនេះទៀត។ ចំពោះការចែងនូវរបបផ្សេងទៀតក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ គឺក្នុងគោលបំណងធ្វើយ៉ាងណាដើម្បីកែប្រែជនដែលបានប្រព្រឹត្តបទល្មើសនោះឱ្យក្លាយជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម និង ធ្វើសមាហរណកម្មឱ្យចូលមករួមរស់ជាមួយសង្គមជាតិវិញ ដោយគេជឿថាការប្រើនូវរបបនេះ ក៏ជាគំរូមួយសម្រាប់ប្រជាពលរដ្ឋដទៃ មិនឱ្យប្រព្រឹត្តបទល្មើសដូចជននេះ ព្រោះអាចធ្វើឱ្យខ្លួនប្រឈមនឹងទោសព្រហ្មទណ្ឌបាន។ ការប្រើនូវរបបដោយឡែកដូចជា របបនៃការព្យួរទោស របបពាក់កណ្តាលសេរីភាព ក៏ដូចជា ការបែងចែកទោសជាប្រភាគ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះទណ្ឌិត និងសង្គម ព្រោះថា ការប្រកាសរបបទាំងនេះចំពោះទណ្ឌិតដែលបានផ្តន្ទាទោសហើយ គឺទណ្ឌិតមានលទ្ធភាពក្នុងការកែប្រែ និងធ្វើសមាហរណកម្មមករួមរស់ជាមួយសង្គមវិញ ហើយថែមទាំងមិនបានកាត់ទំនាក់ទំនងរវាងទណ្ឌិត និងសង្គមទៀតផង។ ម្យ៉ាងវិញទៀត រដ្ឋមិនសូវចំណាយច្រើនទៅលើទណ្ឌិតទាំងនេះ ព្រោះការប្រកាសនូវរបបទាំងនេះគឺមិនត្រូវអនុវត្តទោសក្នុងពន្ធនាគារនោះទេ ដូច្នេះការចំណាយរបស់រដ្ឋទៅលើទណ្ឌិតនៅមន្ទីរឃុំឃាំងក៏បានកាត់បន្ថយច្រើនដែរ។

# អនុសាសន៍

# អនុសាសន៍

ផ្អែកតាមការបកស្រាយកន្លងមកខាងលើយើងឃើញថា នៅក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ នេះមាននូវរបបដោយឡែក ថ្មីៗជាច្រើនដែលត្រូវប្រើក្នុងវិស័យព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសការប្រកាសទោសព្រហ្មទណ្ឌតែម្តង ដែលជាវិធានការចុងក្រោយដែលឈានដល់ការផ្តន្ទាទោសព្រហ្មទណ្ឌ ចំពោះជនល្មើសដែលបានប្រព្រឹត្តបទល្មើសដែលមានចែងជាក់លាក់ក្នុងក្រមព្រហ្មទណ្ឌ។ ហើយនៅក្នុងរបបដោយឡែកទាំងនេះមានដូចជា ការប្រកាសទោស ការប្រកាសព្យួរទោស របបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ហើយដែលមានគោលបំណងដើម្បីជាផលប្រយោជន៍ចំពោះសង្គមខ្មែរ ដោយច្បាប់យល់ថាវាមានលក្ខណៈលើកលែងច្រើនជាងបទប្បញ្ញត្តិច្បាប់ដែលមានពីមុនមក។ ថ្វីត្បិតតែមាននូវរបបទាំងនេះក៏ដោយ ក៏ប៉ុន្តែការអនុវត្តជាក់ស្តែងក្នុងសង្គមខ្មែរនៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនោះទេ ជាពិសេសរបបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគ ដែលមកដល់សព្វថ្ងៃនេះនៅមិនទាន់ឃើញអនុវត្តនៅឡើយទេ នៅតាមតុលាការជាន់ទាប និង ជាន់ខ្ពស់ទូទាំងប្រទេសកម្ពុជា។ ចំណែកឯការព្យួរទោសសាកល្បងក៏ពុំសូវឃើញមានក្នុងការអនុវត្តជាក់ស្តែងដែរ ប៉ុន្តែមិនមែនមានន័យថាមិនមាននោះទេ គ្រាន់តែមានតិចតួចក្នុងការអនុវត្តសព្វថ្ងៃ។ ចំពោះការបង្កើតនូវរបបទាំងនេះពិតជាមានគោលដៅ និងគោលបំណងយ៉ាងពិតប្រាកដ ដែលនៅក្នុងអ្វីដែលនីតិករបង្កើតតែបែរជាគ្មានការអនុវត្តទៅវិញ ចំណុចនេះហាក់បីដូចជាច្បាប់ចែងគ្មានន័យ។ ការដែលធ្វើឱ្យការអនុវត្តមិនអាចធ្វើទៅបានមានដូចជា ពាក់ព័ន្ធនឹងបច្ចេកវិទ្យា ស្ថានភាពទីកន្លែង ពេលវេលា ការឃ្លាំមើល ហើយអ្វីដែលសំខាន់នោះគឺមន្ត្រីមូលដ្ឋានដែលត្រូវជួយសហការ។ ហើយម្យ៉ាងទៀតក៏ព្រោះតែ របបទាំងនេះគឺជារបបដោយឡែកថ្មី ដែលក្រសួងយុត្តិធម៌មិនទាន់បានចេញនូវសេចក្តីណែនាំឬសារាចរពាក់ព័ន្ធទៅនិងការអនុវត្តរបបទាំង៣ នេះនៅឡើយ ដែលហេតុធ្វើឱ្យចៅក្រមមិនហ៊ានប្រើនូវយុត្តិសាស្ត្រទាំងនេះ ហើយអ្វីដែរសំខាន់គឺការប្រកាសបែបនេះធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋ ព្រោះប្រជាពលរដ្ឋខ្លះមិនសូវបានយល់ដឹងពីច្បាប់។

ជាចុងបញ្ចប់ យើងខ្ញុំសង្ឃឹមថាប្រព័ន្ធយុត្តាធិការនៃប្រទេសកម្ពុជាយើងនឹងអាចអនុវត្តនូវរបបនៃការប្រកាស ព្យួរទោសសាកល្បង របបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគ នេះឱ្យបានល្អប្រសើរ ព្រោះវិធានទាំងនេះវាមានលក្ខណៈល្អប្រសើចំពោះសង្គម និងទណ្ឌិត គឺថារបបទាំងនេះមានការអប់រំកែប្រែ និងធ្វើឱ្យទណ្ឌិតបានដឹងនូវកំហុសរបស់ខ្លួន ហើយមានការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន និងធ្វើសមាហរណកម្មមកចូលរួមរស់ក្នុងសង្គមវិញ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២,ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ក្រមនីតិវិធីព្រហ្មទណ្ឌ ,នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- សារាចរលេខ ០១ កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពី ការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ
- សារាចរលេខ ០២ កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពី ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បង
- សារាចរលេខ ០៣ កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពី ការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍
- ប្រកាសលេខ ០៩០ កយ.ប្រក/២១ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងយុត្តិធម៌ ស្តីពី បែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមវិញនៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ

## ២. សៀវភៅមេរៀនច្បាប់

- សៀវភៅនីតិព្រហ្មទណ្ឌ រៀបរៀងដោយ ឯកឧត្តម ហ៊ី សោភា ឆ្នាំ២០០៦
- មេរៀននីតិព្រហ្មទណ្ឌខ្មែរ រៀបរៀងដោយសហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ

## ៣. វចនានុក្រម

- សន្ទានុក្រមពាក្យច្បាប់ខ្មែរ-អង់គ្លេស-បារាំង ផ្នែកព្រហ្មទណ្ឌ របស់ទីស្តីការគណៈរដ្ឋមន្ត្រី បោះពុម្ពលើកទី១ ឆ្នាំ២០១១
- វចនានុក្រមខ្មែរ សម្តេចសង្ឃ ជួន ណាត

# បញ្ជីឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- **ឧបសម្ព័ន្ធទី២** ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
- **ឧបសម្ព័ន្ធទី៣** ក្រមនីតិព្រហ្មទណ្ឌ ឆ្នាំ២០០៧
- **ឧបសម្ព័ន្ធទី៤** សារាចរណែនាំលេខ ០១.កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌
- **ឧបសម្ព័ន្ធទី៥** សារាចរណែនាំលេខ ០២.កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌
- **ឧបសម្ព័ន្ធទី៦** សារាចរណែនាំលេខ ០៣.កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌
- **ឧបសម្ព័ន្ធទី៧** ប្រកាសលេខ ០៩០ កយ.ប្រក/២១ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងយុត្តិធម៌
- **ឧបសម្ព័ន្ធទី៨** សាលក្រមព្រហ្មទណ្ឌ សម្រេចអំពីការព្យួរទោសធម្មតា (ទាំងស្រុង)
- **ឧបសម្ព័ន្ធទី៩** សាលក្រមព្រហ្មទណ្ឌ សម្រេចអំពីការព្យួរទោសធម្មតា (មួយផ្នែកចំពោះទោសពន្ធនាគារ)
- **ឧបសម្ព័ន្ធទី១០** សាលក្រមព្រហ្មទណ្ឌ សម្រេចអំពីការព្យួរទោសសាកល្បង
- **ឧបសម្ព័ន្ធទី១១** សាលក្រមព្រហ្មទណ្ឌ សម្រេចចំពោះនីតិបុគ្គល
- **ឧបសម្ព័ន្ធទី១២** ដីកាបង្គាប់ឱ្យចាប់ និងឃុំខ្លួន

ឧបសម្ព័ន្ធទី ១

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភា

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រង សង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និង ចូលជាសមាជិកសហជីពនេះ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីព នឹងមានកំណត់ ក្នុង ច្បាប់ ។

**មាត្រា ៣៧.-**

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្ត នៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

**មាត្រា ៣៨.-**

ច្បាប់ធានារ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គល ណាមួយឡើយ ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជា ពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណា មួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណា មួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដែលធ្វើ អ្នករួមប្រព្រឹត្ត និង អ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយ

ក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាកស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋរបស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤០.-**

សេរីភាពក្នុងការធ្វើដំណើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋ ត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន ។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទ ត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងលើរូបបុគ្គល ត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។

## ជំពូកទី ១១ ថ្មី
## អំពីអំណាចតុលាការ

**មាត្រា ១២៨.‑ ថ្មី ( មាត្រា ១០៩ ចាស់ )**

អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការ ធានារក្សាអនាគត និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្ដប់ទៅលើរឿងក្ដីទាំងអស់ រួមទាំងរឿងក្ដីរដ្ឋបាលផង ។

អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្ដីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ។

**មាត្រា ១២៩.‑ ថ្មី ( មាត្រា ១១០ ចាស់ )**

ការជំរះក្ដីផ្ដល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ។

មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្ដី ។ ចៅក្រមត្រូវបំពេញការកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន ។

**មាត្រា ១៣០.‑ ថ្មី ( មាត្រា ១១១ ចាស់ )**

គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ ។

**ឧបសម្ព័ន្ធទី ២**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមព្រហ្មទណ្ឌ

# និង

# វិសោធនកម្មក្រមព្រហ្មទណ្ឌ

# នៃព្រះរាជាណាចក្រកម្ពុជា



រៀបចំចងក្រងដោយ

លោក ឡោ ក្រឹម

ឆ្នាំ២០១៨

ប៉ុន្តែ ក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ។

**មាត្រា ៥.-** ការបកស្រាយច្បាប់ព្រហ្មទណ្ឌ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសមិសភាពបានឡើយ ។

**មាត្រា ៦.-** ការប្រកាសទោស

គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការទេ ។

**មាត្រា ៧.-** លក្ខខណ្ឌនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ដែនអនុវត្តច្បាប់កម្ពុជាក្នុងលំហ ត្រូវបានកំណត់ដោយបទប្បញ្ញត្តិនៃក្រមនេះ លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិ ។

**មាត្រា ៨.-** អវត្តមាននៃនិទណ្ឌភាពក្នុងបទល្មើសធ្ងន់ធ្ងរខាងនីតិមនុស្សធម៌អន្តរជាតិ

បទប្បញ្ញត្តិនៃក្រមនេះ ពុំអាចនាំឱ្យមានការបង្កើតនូវស្ថានភាពយុត្តិនិសេធចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរ ដែលកំណត់ដោយច្បាប់ដោយឡែកទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ ។

## ជំពូកទី ២

## ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

**មាត្រា ៩.-** ការអនុវត្តច្បាប់ដែលលុបចោលបទល្មើស

បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម ។ អំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀតឡើយ ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះ ត្រូវបញ្ចប់ ។

ចោទប្រកាន់ត្រូវតែមានបណ្តឹងពីជនរងគ្រោះ ឬពីសិទ្ធិវន្ត ឬបណ្តឹងហិហារជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត ។

**មាត្រា ២២.-** សមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើស ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបើបទល្មើសនោះជា :

១-បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា ។

២-បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា ។

៣-បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ។

៤-បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

៥-បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៣.-** ការមិនចោទប្រកាន់ត្រួតគ្នា និងទោស

ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះអំពើល្មើសដដែល ហើយក្នុងករណីដែលមានការផ្តន្ទាទោស បុគ្គលនោះបានបង្ហាញថាខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល ។

## មាតិកាទី ២
## ការទទួលខុសត្រូវព្រហ្មទណ្ឌ
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ២៤.-** គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ។

**មាត្រា ៣៥.-** ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង

-គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់ ។

**មាត្រា ៣៦.-** អានុភាពនៃកម្លាំង ឬការបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ ដែលបុគ្គលនេះ មិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន ។

**មាត្រា ៣៧.-** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយទេ ។

## ជំពូកទី ៣

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

**មាត្រា ៣៨.-** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។

**មាត្រា ៣៩.-** វិធានការអនុវត្តចំពោះអនីតិជន

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ។

ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ។

**មាត្រា ៤០.-** ប្រភេទនៃវិធានការ

វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមានដូចតទៅ :

១-ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្ដិសមនឹងទំនុកចិត្ត ។

២-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ។

៤-ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។

៥-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ។

**មាត្រា ៤១.-** ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន ។ បុគ្គលនេះធ្វើរបាយការណ៍ស្ដីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្ដល់ព័ត៌មាន ដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ ។

## ជំពូកទី ៤
## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

**មាត្រា ៤២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍ របស់នីតិបុគ្គលនោះ ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុស ត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ ។

## មាតិកាទី ៣
## ទោស
## ជំពូកទី ១
## ប្រភេទនៃទោស
## ផ្នែកទី ១
## មូលទោស

**មាត្រា ៤៣.-** មូលទោស

មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ ។

ការពិន័យត្រូវគិតជាប្រាក់រៀល ។

**មាត្រា ៤៤.-** អប្បបរមា និងអតិបរមានៃមូលទោស

កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពី អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ ។

កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និង អតិបរមា នៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល ។

ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែង ដែលមាននៅក្នុងខែនោះ ។

ទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ ត្រូវគិត ១២ (ដប់ពីរ) ខែ ។

**មាត្រា ៥០.-** លក្ខខណ្ឌដោយឡែកនៃការបញ្ចប់ទោស

ជាគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ ត្រូវតែដោះលែងឱ្យមានសេរីភាពវិញនៅមុនថ្ងៃឈប់សម្រាកនោះ ។

**មាត្រា ៥១.-** ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួល ។

**មាត្រា ៥២.-** ផលនៃទោសពិន័យ

ប្រាក់ពិន័យដែលទទួលបាន ត្រូវបង់ចូលថវិការដ្ឋ ។

## ផ្នែកទី ២

## ទោសបន្ថែម

**មាត្រា ៥៣.-** ប្រភេទនៃទោសបន្ថែម

ទោសបន្ថែមរួមមាន :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤-ការព្យួរលិខិតបើកបរ ។

៥-ការហាមឃាត់ចំពោះការស្នាក់នៅ ។

៦-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

៧-ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

៩-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

១០-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

១១-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

១២-ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

១៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

១៥-ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

១៦-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

១៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

១៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែក អាចបង្កើតទោសបន្ថែមផ្សេងៗទៀត ។

**មាត្រា ៥៥.-** លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម

ទោសបន្ថែម នឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវចោទប្រកាន់ ។

ទោសបន្ថែម អាចប្រកាសក៏បាន មិនប្រកាសក៏បាន ។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់ ។

ផុតទោសពន្ធនាគារ លើកលែងតែមានសេចក្តីសម្រេចផ្ទុយរបស់តុលាការ។

## ផ្នែកទី ៣

## ទោសជំនួស

### កថាភាគទី ១

### ការងារសហគមន៍

**មាត្រា ៧២.-** និយមន័យនៃការងារសហគមន៍

កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍ ។

ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប) ម៉ោង ទៅ ២០០ (ពីររយ) ម៉ោង នូវការងារគ្មានកម្រៃ ជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគម ឬដល់អង្គការមិនមែនរដ្ឋាភិបាល ។

**មាត្រា ៧៣.-** អ្នកមិនទទួលប្រយោជន៍នៃការងារសហគមន៍

នៅក្នុងគ្រប់ករណីទាំងអស់ ការងារសហគមន៍មិនអាចបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលទេ ។

**មាត្រា ៧៤.-** របបគតិយុត្តនៃការងារសហគមន៍

ការងារសហគមន៍ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជាអាទិ៍ការងារនៅពេលយប់ អនាម័យ សន្តិសុខ ហើយនិងការងាររបស់ស្ត្រី ។

ការងារសហគមន៍អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈ ។

**មាត្រា ៧៥.-** គោលការណ៍ជួសជុលការខូចខាតដល់អ្នកដទៃ

រដ្ឋត្រូវតែចេញសោហ៊ុយជួសជុលការខូចខាតដែលបង្កដល់អ្នកដទៃដោយទណ្ឌិតនៅក្នុងពេលដែលកំពុងអនុវត្តការងារសហគមន៍ ។ រដ្ឋត្រូវធ្វើឧបាទេសកម្មដោយពេញច្បាប់ ទៅក្នុងសិទ្ធិជនរងគ្រោះ ។

## កថាភាគទី ២
## ការស្តីបន្ទោស

**មាត្រា ៧៦.-** របបគតិយុត្តនៃការស្តីបន្ទោស

កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំងបីដូចតទៅនេះ :

-ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់

-ការខូចខាតត្រូវបានជួសជុលរួចហើយ និង

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ ។

## ជំពូកទី ២
## ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស
## ផ្នែកទី ១
## ស្ថានទម្ងន់ទោស
## កថាភាគទី ១
## និយមន័យនៃស្ថានទម្ងន់ទោសដោយឡែកខ្លះៗ

**មាត្រា ៧៧.-** ក្រុមមានការចាត់តាំង

ក្រុមមានការចាត់តាំង គឺជាការប្រមូលផ្តុំដែលបានបង្កើតឡើង ឬជាសន្ធិដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬប្រព្រឹត្តបទល្មើសមួយ ឬច្រើន ។

**មាត្រា ៧៨.-** ការគិតទុកជាមុន

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនសកម្មភាពប្រព្រឹត្តបទល្មើស ។

**មាត្រា ៩៥.-** ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោស

កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់ស្ថានសម្រាលទោស អាចប្រកាសទោសដាក់ពន្ធនាគារ ក្នុងចន្លោះរវាង ១៥ (ដប់ប្រាំ) និង ៣០ (សាមសិប) ឆ្នាំ ។

## ជំពូកទី ៣

## របបនៃការប្រកាសទោស

### ផ្នែកទី ១

### របបទូទៅ

**មាត្រា ៩៦.-** គោលការណ៍ឯកត្តកម្មនៃទោស

តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ ។

**មាត្រា ៩៧.-** ការប្រកាសមូលទោស

នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាស :

-ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ

-ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ

-ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ។

**មាត្រា ៩៨.-** ការប្រកាសទោសជំនួស

ទោសការងារសហគមន៍ជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសទោសការងារសហគមន៍នោះ មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

ការស្តីបន្ទោសជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសការស្តីបន្ទោស មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

**មាត្រា ៩៩.-** ការប្រកាសទោសបន្ថែមលើមូលទោស

កាលណាបទល្មើសមួយត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ១០០ (ការជំនួសមូលទោសដោយទោសបន្ថែម) នៃក្រមនេះ ចេញ ។

**មាត្រា ១០០.-** ការជំនួសមូលទោសដោយទោសបន្ថែម

តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយឬច្រើន នៅក្នុងករណីណាមួយដូចខាងក្រោម :

១-កាលណាជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់ ។

២-កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣ (បី) ឆ្នាំ ។

កាលណាតុលាការសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ ។

**មាត្រា ១០១.-** វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារសហគមន៍

ទោសការងារសហគមន៍នឹងអាចប្រកាសបាន លុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយយល់ព្រមធ្វើការងារនេះ ។ តុលាការនៅមុនពេលប្រកាសសាលក្រម ឬសាលដីកា ត្រូវប្រាប់ជនជាប់ចោទថាសាមីខ្លួនមានសិទ្ធិប្រកែកមិនព្រមធ្វើការងារនេះ ។ ចម្លើយរបស់ជនជាប់ចោទ ត្រូវតែមានចុះនៅក្នុងសាលក្រម ឬសាលដីកា ។

**មាត្រា ១០២.-** ថិរវេលា និងអំឡុងពេលនៃការងារសហគមន៍

តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវកំណត់អំពីថិរវេលានៃ

ការងារ និងរយៈពេលដែលត្រូវបំពេញ ។ រយៈពេលនេះមិនអាចលើសពី ១ (មួយ) ឆ្នាំ ទេ ។

**មាត្រា ១០៣.-** បែបបទនៃការអនុវត្តទោសការងារសហគមន៍

បែបបទនៃការអនុវត្តទោសការងារសហគមន៍ ត្រូវកំណត់ដោយព្រះរាជអាជ្ញា ។

ព្រះរាជអាជ្ញាចង្អុលប្រាប់ឈ្មោះនីតិបុគ្គល ដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ ។

ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។

## ផ្នែកទី ២
## ការព្យួរទោសធម្មតា
### កថាភាគទី ១
### បទប្បញ្ញត្តិរួម

**មាត្រា ១០៤.-** ការប្រកាសការព្យួរទោស

នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងផ្នែកនេះ តុលាការអាចបង្គាប់ថា ត្រូវព្យួរការអនុវត្តនូវមូលទោស ។

**មាត្រា ១០៥.-** របបនៃការព្យួរទោស

ដើម្បីអនុវត្តបទប្បញ្ញត្តិស្ដីពីការព្យួរទោស ត្រូវគិតតែអំពីការផ្ដន្ទាទោសជាស្ថាពរខាងបណ្ដឹងអាជ្ញាប៉ុណ្ណោះ ។

### កថាភាគទី ២
### ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

**មាត្រា ១០៦.-** លក្ខខណ្ឌទាក់ទងនឹងការផ្ដន្ទាទោសពីមុន

ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ការព្យួរទោសធម្មតាអាចត្រូវផ្ដល់ឱ្យបាន ប្រសិនបើជនជាប់ចោទមិនទាន់មានការផ្ដន្ទាទោស

ជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ មុនអំពើល្មើស ។

**មាត្រា ១០៧.-** ទោសអាចនាំឱ្យមានការព្យួរទោស

ការព្យួរទោសធម្មតា ត្រូវអនុវត្តទៅលើទោសដូចតទៅ :

១-ទោសដាក់ពន្ធនាគារ កាលបើទោសដែលប្រកាសនោះតិចជាង ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ។

២-ទោសពិន័យជាប្រាក់ ។

**មាត្រា ១០៨.-** ការព្យួរទោសមួយផ្នែក

តុលាការអាចសម្រេចថា ការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើមួយផ្នែកនៃទោសពន្ធនាគារ ដែលតុលាការជាអ្នកកំណត់ថិរវេលា ឬលើមួយផ្នែកនៃប្រាក់ពិន័យដែលតុលាការជាអ្នកកំណត់ចំនួនទឹកប្រាក់ ។

**មាត្រា ១០៩.-** ការដកហូតការព្យួរទោស

ប្រសិនបើក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយមានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ការព្យួរទោសធម្មតានេះ ត្រូវដកហូតចេញដោយពេញច្បាប់ ។

ទោសទី ១ ត្រូវអនុវត្តដោយមិនអាចស្រូបចូលជាមួយទោសទី ២ បានឡើយ ។

**មាត្រា ១១០.-** ការមិនដកហូតការព្យួរទោស

ជាបដិប្បញ្ញត្តិទៅនឹងមាត្រា ១០៩ (ការដកហូតការព្យួរទោស) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិននាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតាដែលបានសម្រេចពីមុននោះទេ។ សេចក្តីសម្រេចរបស់តុលាការត្រូវតែមានសំអាងហេតុជាពិសេស ។

**មាត្រា ១១១.-** ការទុកជាអសារបង់នូវការផ្តន្ទាទោស

ប្រសិនបើរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ

ឬបទមជ្ឈិម ដោយមានការព្យួរទោសជម្មតា ហើយគ្មានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀត ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះទេ ការផ្តន្ទាទោសដោយមានព្យួរនេះត្រូវចាត់ទុកថាជាអសារបង់ ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

កាលណាបើការព្យួរទោសត្រូវបានប្រកាសទៅលើតែផ្នែកមួយនៃទោសនោះ ការផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ទាំងស្រុង ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

## កថាភាគទី ៣
## ការចោទប្រកាន់ចំពោះបទលហុ

**មាត្រា ១១២.–** លក្ខខណ្ឌទាក់ទងទៅនឹងការផ្តន្ទាទោសពីមុន

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសជម្មតាអាចត្រូវបានប្រកាស ប្រសិនបើជនជាប់ចោទ មិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារជាស្ថាពរនៅឡើយ នៅក្នុងរយៈពេល ១ (មួយ) ឆ្នាំ មុនបទល្មើសនេះ ។

**មាត្រា ១១៣.–** ទោសអាចនាំឱ្យមានការព្យួរទោស

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសជម្មតាត្រូវអនុវត្តទៅលើទោសដូចតទៅនេះ :

១-ទោសដាក់ពន្ធនាគារ ។

២-ទោសពិន័យជាប្រាក់ ។

**មាត្រា ១១៤.–** ការដកហូតការព្យួរទោស

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយការផ្តន្ទាទោសជាស្ថាពរពីបទលហុដោយមានការព្យួរទោសជម្មតាផង រួចកើតមានការផ្តន្ទាទោសថ្មីជាស្ថាពរពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការព្យួរទោសជម្មតានេះ ត្រូវដកហូតចេញដោយពេញច្បាប់។ ទោសទី ១ ត្រូវអនុវត្តដោយគ្មានស្រួបជាមួយទោសទី ២ ឡើយ ។

**មាត្រា ១១៥.-** ការមិនដកហូតការព្យួរទោស

ជាបដិប្បញ្ញត្តិនៃមាត្រា ១១៤ (ការដកហូតការព្យួរទោស) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្ដន្ទាទោសថ្មីមិនអាចនាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតានេះដែលសម្រេចពីមុននោះទេ។ សេចក្ដីសម្រេចនេះត្រូវតែមានសំអាងហេតុជាពិសេស។

**មាត្រា ១១៦.-** ការចាត់ទុកជាអសារបង់នូវការផ្ដន្ទាទោស

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីការផ្ដន្ទាទោសជាស្ថាពរពីបទលហុដែលមានការព្យួរទោសធម្មតា គ្មានការផ្ដន្ទាទោសថ្មីណាមួយបានកើតឡើងពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការផ្ដន្ទាទោសដែលព្យួរនោះ ត្រូវទុកជាអសារបង់ ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

## ផ្នែកទី ៣
## ការព្យួរទោសសាកល្បង

**មាត្រា ១១៧.-** និយមន័យ និងលក្ខខណ្ឌនៃការព្យួរទោសសាកល្បង

តុលាការអាចសម្រេចព្យួរសាកល្បងនូវទោសដែលបានសម្រេចដាក់ពន្ធនាគារដែលមានរយៈពេលពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ។

ការព្យួរទោសសាកល្បង មានអានុភាពដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បង ។

**មាត្រា ១១៨.-** រយៈពេលនៃការសាកល្បង

តុលាការកំណត់រយៈពេលនៃការសាកល្បង។ រយៈពេលនេះមិនអាចតិចជាង ១ (មួយ) ឆ្នាំ និងមិនលើសពី ៣ (បី) ឆ្នាំ ទេ ។

**មាត្រា ១១៩.-** វិធានការត្រួតពិនិត្យ

វិធានការត្រួតពិនិត្យដែលតម្រូវទៅលើទណ្ឌិត មានដូចតទៅ :

១-ទណ្ឌិតត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែល

ព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ ។

២-ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ ។

៣-ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ នូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ ។

៤-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន ។

៥-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន ។

៦-ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស ។

**មាត្រា ១២០.-** កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត

កាតព្វកិច្ចដោយឡែកដែលអាចតម្រូវទៅលើទណ្ឌិតមានដូចតទៅ :

១-បំពេញសកម្មភាពខាងវិជ្ជាជីវៈ ។

២-ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

៣-រស់នៅក្នុងទីកន្លែងណាមួយជាកំណត់ ។

៤-ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬការព្យាបាល ។

៥-បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ ។

៦-ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើស តាមលទ្ធភាពនៃធនធានរបស់ខ្លួន ។

៧-បញ្ជាក់ថាខ្លួនបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្តន្ទាទោស តាមលទ្ធភាពធនធានរបស់ខ្លួន ។

៨-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈឬសង្គមដែលអនុញ្ញាត ឬសម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់ ។

៩-មិនត្រូវមានមុខនៅទីកន្លែងខ្លះ។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់ ។

១០-មិនត្រូវសេពគប់បនល្បែង ។

១១-មិនត្រូវសេពគប់តៀមភេសជ្ជៈស្រវឹង ។

១២-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ ។

១៣-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន តុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែកដែលតម្រូវទៅលើទណ្ឌិត ។

**មាត្រា ១២១.-** ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ

នៅគ្រប់ពេលវេលា តុលាការអាចកែប្រែកាតព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិតបាន ។

តុលាការត្រូវបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលបានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១២២.-** ការដកហូតការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បងអាចត្រូវដកហូតដោយតុលាការ នៅក្នុងករណីដូចខាងក្រោមនេះ :

១-ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យ ឬកាតព្វកិច្ចដោយឡែកទេ ។

២-ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាថ្មីទៀត ។

តុលាការអាចបង្គាប់ឱ្យដកហូតការព្យួរទោសសាកល្បងនេះទាំងមូល ឬមួយផ្នែក ។ នៅក្នុងករណីនេះ ទោសត្រូវយកមកអនុវត្តទាំងមូល ឬមួយផ្នែក ។

តុលាការត្រូវបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលមានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១២៣.-** ការផ្ដន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់

ការផ្ដន្ទាទោសត្រូវចាត់ទុកជាអសារបង់ ប្រសិនបើមុនការផុតរយៈពេលសាកល្បង ការផ្ដន្ទាទោសមិនមែនជាកម្មវត្ថុនៃពាក្យសុំដកហូតដែលមានសេចក្ដីសម្រេចដកហូតទេ ។

## ផ្នែកទី ៤
## ការផ្អាកការប្រកាសទោស

**មាត្រា ១២៤.-** លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស

ក្នុងករណីចោទប្រកាន់ពីបទមជ្ឈិម តុលាការក្រោយពីបានប្រកាសថា ជនជាប់ចោទមានពិរុទ្ធ អាចផ្អាកការប្រកាសទោស ប្រសិនបើលក្ខខណ្ឌដូចតទៅនេះ ត្រូវបានបំពេញ :

-ភាពច្របូកច្របល់នៃសណ្ដាប់ធ្នាប់សាធារណៈ ដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ និង

-ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត ។

**មាត្រា ១២៥.-** សេចក្ដីសម្រេចនៃការផ្អាកការប្រកាសទោស

ការផ្អាកការប្រកាសទោសអាចត្រូវបង្គាប់បាន លុះត្រាតែជនជាប់ចោទមានវត្តមានក្នុងសវនាការ ។

តុលាការកំណត់នៅក្នុងសាលក្រម ឬសាលដីកានូវកាលបរិច្ឆេទដែលត្រូវសម្រេចអំពីទោស ។

សេចក្ដីសម្រេចអំពីទោសត្រូវតែធ្វើឡើងយ៉ាងយូរបំផុត ១ (មួយ) ឆ្នាំ ក្រោយសេចក្ដីសម្រេចផ្អាក ។

**មាត្រា ១២៦.-** សវនាការពិនិត្យរឿងដែលបង្អង់

នៅពេលសវនាការពិនិត្យរឿងដែលបង្អង់នេះ តុលាការសម្រេចអំពីទោស ។

## ផ្នែកទី ៥
## របបពាក់កណ្ដាលសេរីភាព

**មាត្រា ១២៧.-** លក្ខខណ្ឌនៃរបបពាក់កណ្ដាលសេរីភាព

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ៦ (ប្រាំមួយ) ខែ តុលាការអាចសម្រេចថា ទោសត្រូវអនុវត្តក្រោមរបបពាក់កណ្ដាលសេរីភាព ដើម្បីអនុញ្ញាតឱ្យទណ្ឌិតអាចបំពេញសកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ឬការបណ្ដុះបណ្ដាល ឬការពិនិត្យព្យាបាលជំងឺ ឬជួយឧបត្ថម្ភដល់សេចក្ដីត្រូវការរបស់គ្រួសារ ។

**មាត្រា ១២៨.-** បែបបទនៃរបបពាក់កណ្ដាលសេរីភាព

ទណ្ឌិតដែលស្ថិតនៅក្រោមរបបពាក់កណ្ដាលសេរីភាព ត្រូវបានអនុញ្ញាតឱ្យចាកចេញពីពន្ធនាគារ ក្នុងរយៈពេលជាកំណត់ ។

តុលាការកំណត់នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីថ្ងៃ និងម៉ោងដែលទណ្ឌិតត្រូវបានអនុញ្ញាតឱ្យមានអវត្តមាននៅក្នុងពន្ធនាគារ ។

**មាត្រា ១២៩.-** ការគិតបញ្ចូលរយៈពេលនៃពាក់កណ្ដាលសេរីភាពទៅក្នុងទោស

រយៈពេលនៃពាក់កណ្ដាលសេរីភាព ត្រូវគិតបញ្ចូលទៅក្នុងថិរវេលានៃទោសដែលកំពុងអនុវត្ត ។

**មាត្រា ១៣០.-** ការរៀបចំ និងការលុបចោលនៃរបបពាក់កណ្ដាលសេរីភាព

នៅគ្រប់ពេល តុលាការអាចរៀបចំរយៈពេលនៃពាក់កណ្ដាលសេរីភាព ឬក៏លុបចោលនូវរបបពាក់កណ្ដាលសេរីភាព តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ។

តុលាការត្រូវបានទទួលដំណឹងនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១៣១.-** ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មកពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃពាក់កណ្ដាលសេរីភាព ។

## ផ្នែកទី ៦

## ការបែងចែកទោសជាប្រភាគ

**មាត្រា ១៣២.-** លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ១ (មួយ) ឆ្នាំ តុលាការអាចសម្រេចថា ទោសនោះត្រូវអនុវត្តជាប្រភាគ ដោយមូលហេតុធ្ងន់ធ្ងរដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម។

**មាត្រា ១៣៣.-** បែបបទនៃការបែងចែកទោសជាប្រភាគ

ប្រភាគនៃទោសនីមួយៗ មិនត្រូវតិចជាង ១ (មួយ) ខែ ទេ ។ ថិរវេលាសរុបនៃការអនុវត្តទោសមិនអាចលើសពី ២ (ពីរ) ឆ្នាំ ទេ ដោយរាប់បញ្ចូលទាំងការផ្អាកការអនុវត្តទោស ។

តុលាការកំណត់ក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីបែបបទនៃការបែងចែកទោសជាប្រភាគ ។

**មាត្រា ១៣៤.-** ការកែប្រែរបបនៃការបែងចែកទោសជាប្រភាគ

នៅគ្រប់ពេលវេលា តុលាការអាចរៀបចំបែបបទនៃការបែងចែកទោសជាប្រភាគ ឬលុបចោលរបបនៃការបែងចែកទោសជាប្រភាគ តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ។

តុលាការត្រូវបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១៣៥.-** ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មក

## ជំពូកទី ៦
## ទោសដែលអាចអនុវត្តចំពោះអនីតិជន
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦០.-** មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

**មាត្រា ១៦១.-** ទោសបន្ថែម

មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន :

១-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

២-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

**មាត្រា ១៦២.-** ទោសការងារសហគមន៍

ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ប៉ុន្តែ ថិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោង ។

ការងារសហគមន៍ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ ។

**មាត្រា ១៦៣.-** ការមិនអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល

បទប្បញ្ញត្តិស្តីពីការមិនរាងចាល មិនអនុវត្តទៅលើអនីតិជនទេ ។

**មាត្រា ១៦៤.-** ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស

ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន ។

កាលបើតុលាការបានសម្រេចឱ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោស លើអនីតិជនពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសជាប់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៣ (បី) ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងតិចជាង ២ (ពីរ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយត្រឹម ១ (មួយ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

**មាត្រា ១៦៥.-** កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោសសាកល្បង

នៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះដែលអាចអនុវត្តទៅលើអនីតិជន :

១-ទទួលការបង្ហាត់បង្រៀន ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

២-ស្ថិតនៅទីកន្លែងមួយជាកំណត់ ។

៣-ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬព្យាបាល ។

៤-ជួសជុលព្យសនកម្មដែលបណ្តាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន ។

៥-បង្ហាញភស្តុតាង បញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធានរបស់ខ្លួន បន្ទាប់ពីការផ្តន្ទាទោស ។

៦-មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ ។

៧-មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង ។

៨-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស ។

៩-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។ធ

## ផ្នែកទី ២
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦៦.-** លក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ

អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន ។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែង

សម្រាប់អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

របបឃុំឃាំងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ។

## ជំពូកទី ៧
## ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល
### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦៧.–** ទោសដែលត្រូវវងដោយនីតិបុគ្គល

ទោសជាយថាប្រភេទដែលត្រូវរងដោយនីតិបុគ្គលមានដូចតទៅ :

១-ទោសពិន័យក្នុងឋានៈជាមូលទោស ។

២-ទោសបន្ថែមដែលរៀបរាប់នៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមនេះ ។

### ផ្នែកទី ២
### ទោសបន្ថែម

**មាត្រា ១៦៨.–** ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល

ទោសបន្ថែមត្រូវអនុវត្តទៅលើនីតិបុគ្គលមានដូចតទៅ :

១-ការរំលាយចោល ។

២-ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ។

៣-ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ ។

៦-ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ដែលកំណត់ដោយធនាគារ ។

៧-ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់ ។

៨-ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស ។

៩-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលបានប្រើប្រាស់ដោយសាធារណជន ។

១០-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស ។

១១-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

១២-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

១៣-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

១៤-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែកអាចបង្កើតទោសបន្ថែមដទៃទៀតបាន ។

**មាត្រា ១៦៩.-** លក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម

ទោសបន្ថែមអាចនឹងប្រកាសបានដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់ ។

**មាត្រា ១៧០.-** ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល

សេចក្ដីសម្រេចដែលបង្គាប់ឱ្យរំលាយនីតិបុគ្គល នាំឱ្យមានការបញ្ជូននីតិបុគ្គលនេះទៅតុលាការមានសមត្ថកិច្ច ដើម្បីធ្វើការជម្រះបញ្ជី ។

**មាត្រា ១៧១.-** ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ

ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការមិនអាចលើសពី ៥ (ប្រាំ) ឆ្នាំ ទេ ។ សេចក្ដីសម្រេចដាក់ការត្រួតពិនិត្យតាមដានរបស់តុលាការនាំឱ្យមានការចាត់តាំងអាណត្តិគាហកតុលាការដែលតុលាការបញ្ជាក់បេសកកម្ម ។

ជារៀងរាល់ ៦ (ប្រាំមួយ) ខែ យ៉ាងតិច អាណាព្យាបាលតុលាការធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាអំពីដំណើរការនៃបេសកកម្មរបស់ខ្លួន ។

ក្រោយពីបានឃើញរបាយការណ៍របស់អាណាព្យាបាលតុលាការ ព្រះរាជអាជ្ញាអាចប្តឹងទៅតុលាការដែលបានប្រកាសឱ្យធ្វើការដាក់ក្រោមការតាមដានរបស់តុលាការ ។ តុលាការអាចប្រកាសនូវទោសថ្មីមួយ ។

តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់យោបល់របស់តំណាងអយ្យការ អាណាព្យាបាលតុលាការ និងជាយថាហេតុ មេធាវីរបស់នីតិបុគ្គលនោះ ។

**មាត្រា ១៧២.-** ការហាមឃាត់ចំពោះការធ្វើសកម្មភាព

ការហាមឃាត់ចំពោះការធ្វើសកម្មភាព អាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់ថិរវេលា ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

តុលាការបញ្ជាក់អំពីសកម្មភាពដែលត្រូវហាមឃាត់ ។

**មាត្រា ១៧៣.-** ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ

ទោសបណ្តេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួម ដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងគ្រប់លទ្ធកម្មសាធារណៈដែលរៀបចំ ដោយ :

១-រដ្ឋ ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិ ។

៣-គ្រឹះស្ថានសាធារណៈ ។

៤-សហគ្រាសដែលទទួលសម្បទានពីរដ្ឋឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែលត្រួតពិនិត្យដោយរដ្ឋឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទោសនេះ អាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់ថិរវេលាមួយមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

**មាត្រា ១៧៤.-** ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ

ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ឱ្យធ្វើការដាក់ប្រាក់សន្សំ

**ឧបសម្ព័ន្ធទី ៣**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ក្រមនីតិវិធីព្រហ្មទណ្ឌ
នៃ
ព្រះរាជាណាចក្រកម្ពុជា
ឆ្នាំ ២០១១
www.elibraryofcambodia.org

**មាត្រា ៨.** – មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា

កាលណាច្បាប់ដោយឡែកបានចែងដោយជាក់លាក់ នោះបណ្តឹងអាជ្ញាក៏អាចផុតរលត់បានដែរ :

១-ដោយការសម្របសម្រួលជាមួយរដ្ឋ ។

២-ដោយការដកពាក្យប្តឹង នៅក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ។

៣-ដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល ។

**មាត្រា ៩.** – ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់

បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតអាជ្ញាយុកាលបានទេ ។

**មាត្រា ១០.** – អាជ្ញាយុកាលនៃបទល្មើស

លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ៩ (ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់) នៃក្រមនេះចេញ ចិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចតទៅគឺ :

-១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ

-៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម

-១ (មួយ) ឆ្នាំ ចំពោះបទលហុ

**មាត្រា ១១.** – ការផ្តាច់រយៈពេលនៃអាជ្ញាយុកាល

ចិរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស ។ អាជ្ញាយុកាលត្រូវផ្តាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ ។ ការបញ្ចប់កិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរនីមួយៗ នាំឱ្យចាប់ផ្តើមគិតចិរវេលាថ្មីនៃអាជ្ញាយុកាលតាមការវែកញែកនៃមាត្រា ១០ (អាជ្ញាយុកាលនៃបទល្មើស) នៃក្រមនេះ ។ ចិរវេលាថ្មីអាចយកទៅជំទាស់បាន ចំពោះជនគ្រប់រូបដែលទាក់ទិននៅក្នុងរឿងនេះ ។

**មាត្រា ១២.** – អាជ្ញាអស់ជំនុំ

ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ ។

# គន្ថីទី ៨

# នីតិវិធីប្រតិបត្តិ

## មាតិកាទី ១

## បទប្បញ្ញត្តិទូទៅ

### ជំពូកតែមួយ

### បទប្បញ្ញត្តិទូទៅ

**មាត្រា ៤៩៦.** – ការអនុវត្តទោស និងទណ្ឌកម្មរដ្ឋប្បវេណី

ការអនុវត្តទោស និងការបង្ខិតបង្ខំរូបកាយត្រូវធ្វើតាមគំនិតផ្ដើមរបស់អយ្យការ ។

ការអនុវត្តទណ្ឌកម្មរដ្ឋប្បវេណីត្រូវតែធ្វើតាមគំនិតផ្ដើមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ។

**មាត្រា ៤៩៧.** – សេចក្ដីសម្រេចស្ថាពរ

អយ្យការធ្វើការអនុវត្តទោស នៅពេលដែលសេចក្ដីសម្រេចរបស់តុលាការ បានក្លាយទៅជាស្ថាពរ ។

រយៈពេលសម្រាប់ប្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា មិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ ។

**មាត្រា ៤៩៨.** – ការប្រមូលប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី

ការប្រមូលប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធីត្រូវធ្វើដោយភ្នាក់ងាររតនាគារ នៅក្រោមនិរាទរបស់អយ្យការ ។ ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធីដែលប្រមូលបាននេះ ត្រូវបង់ចូលថវិការដ្ឋ ។

គ្រប់សេចក្ដីសម្រេចផ្ដន្ទាទោសជាស្ថាពរ មានតំលៃជាបញ្ជាឱ្យបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី ។

**មាត្រា ៤៩៩.** – ការសុំកងកម្លាំងសាធារណៈ

ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា អាចសុំកងកម្លាំងសាធារណៈ ដើម្បីធានារ៉ាប់រងការអនុវត្តទោស ។

**មាត្រា ៥០០.** – ការលំបាកទាក់ទងនឹងការអនុវត្តទោស

ការលំបាកទាំងឡាយដែលទាក់ទងនឹងការអនុវត្តទោស ត្រូវតែលើកជូនតុលាការជាន់ដំបូង ឬតុលាការជាន់ខ្ពស់ ដែលបានសម្រេចផ្ដន្ទាទោសនោះ ដោះស្រាយ ។

តុលាការទទួលបណ្ដឹង តាមពាក្យប្ដឹងរបស់អយ្យការ ឬរបស់ភាគីពាក់ព័ន្ធ ។ តុលាការនេះសម្រេចនៅពេលសវនាការសាធាណៈ ក្រោយពីបានស្ដាប់អយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុមេធាវីរបស់ភាគីនេះ ។

ការអនុវត្តទោសអាចត្រូវបានព្យួរដោយតុលាការ ។

**មាត្រា ៥០១.- ពាក្យសុំឱ្យស្រួបទោសបញ្ចូលគ្នា**

ពាក្យសុំឱ្យស្រួបទោសបញ្ចូលគ្នា ត្រូវលើកនៅមុខតុលាការដែលបានសម្រេចចុងក្រោយគេ ។

តុលាការនេះទទួលបណ្ដឹង តាមពាក្យប្ដឹងរបស់អយ្យការ ឬរបស់ភាគីពាក់ព័ន្ធ ។ តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្ដាប់អយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុមេធាវីរបស់ភាគីនេះ ។

## មាតិកាទី ២
## ការប្រតិបត្តការឃុំខ្លួនបណ្ដោះអាសន្ន និងទោសដកហូតសេរីភាព
### ជំពូកទី ១
### វិធាននានាទាក់ទងនឹងការឃុំខ្លួន

**មាត្រា ៥០២.- ការគណនាថិរវេលានៃការដាក់ពន្ធនាគារ**

ទោសដាក់ពន្ធនាគារក្នុង ១ (មួយ) ថ្ងៃ មានថិរវេលា ២៤ (ម្ភៃបួន) ម៉ោង ។

ទោសដាក់ពន្ធនាគារ ក្នុង ១ (មួយ) ខែ មានថិរវេលា ៣០ (សាមសិប) ថ្ងៃ ។

ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមលេខរៀងនៃថ្ងៃក្នុងខែទី ១ (មួយ) ទៅលេខរៀងនៃថ្ងៃក្នុងខែមួយទៀត ។

ទណ្ឌិតដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយ ត្រូវដោះលែងនៅក្នុងចន្លោះពីម៉ោង ៦ (ប្រាំមួយ) ព្រឹក ដល់ម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច ។

**មាត្រា ៥០៣.- ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន**

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដែលបានប្រកាស ឬជាយថាហេតុនៃថិរវេលាសរុបនៃទោសដែលត្រូវទទួលរង បន្ទាប់ពីការស្រួបទោសបញ្ចូលគ្នា ។

**មាត្រា ៥០៤.- ការរៀបចំពន្ធនាគារ**

ការរៀបចំ និងរបបផ្ទៃក្នុងនៃពន្ធនាគារ និងមណ្ឌលឃុំខ្លួន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងដែលគ្រប់គ្រងពន្ធនាគារ ។

ប្រកាសនេះកំណត់ផងដែរ អំពីលក្ខខណ្ឌនៃការបែងចែកទណ្ឌិតទៅតាមពន្ធនាគារ និងមណ្ឌលឃុំខ្លួននានា អំពីបែបបទអនុវត្តទោសដកហូតសេរីភាព និងអំពីរបបឃុំខ្លួន ។

**ឧបសម្ព័ន្ធទី ៤**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ ៖ ០១.កយធ.សរ/០៤

**សារាចរ**

**ស្តីពី**

**ការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវចោទឲ្យនៅក្រោម**
**ការត្រួតពិនិត្យតាមផ្លូវតុលាការ**

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា ២២៣ ដល់ មាត្រា ២៣០ មិនទាន់អនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តមិនទាន់បានល្អប្រសើរ។

ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

**ក-ចៅក្រមស៊ើបសួរ**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមគោលការណ៍នេះ ដោយយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់អំពីកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ឲ្យបានសមស្រប និងឲ្យមានតុល្យភាពទៅនឹងស្ថានភាពសង្គម ក្នុងការសម្រេចមិនឃុំខ្លួនជនត្រូវចោទ ហើយដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

២-ត្រូវគិតអំពីវិធានការនៃការត្រួតពិនិត្យ និងឃ្លាំមើលដើម្បីធានាថា ជនត្រូវចោទនឹងអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានត្រឹមត្រូវ។

ករណីនេះ ចៅក្រមស៊ើបសួរគប្បីចាត់តាំងបុគ្គលណាមួយដែលមានសមត្ថកិច្ច អាចជួយតាមឃ្លាំមើល និងធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាតាមការកំណត់។

ក្នុងករណីចាំបាច់ដើម្បីធានាដល់ការឃ្លាំមើលជនត្រូវចោទ គប្បីដាក់កាតព្វកិច្ចឲ្យជនត្រូវចោទចូលបង្ហាញខ្លួនតាមការកំណត់ នៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ដែលស្ថិតនៅជិតលំនៅដ្ឋានស្នាក់នៅជាក់លាក់ណាមួយរបស់ជនត្រូវចោទ។

៣-ត្រូវផ្តល់ដីកាសម្រេចដាក់ជនត្រូវចោទ ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះមួយច្បាប់ ឲ្យដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬគ្រប់បុគ្គលដែលត្រូវបានចាត់តាំងក្នុងមូលដ្ឋានដែលជនត្រូវចោទត្រូវទៅរស់នៅ ដើម្បីអនុវត្តកាតព្វកិច្ច ក្រៅពីជូនដំណឹងដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

៤-ត្រូវណែនាំជនត្រូវចោទ ដែលត្រូវបានដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឲ្យយកដីកាសម្រេចនេះ ទៅបង្ហាញដល់ប្រធានអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬបុគ្គលដែលត្រូវបានចាត់តាំង ក្នុងមូលដ្ឋានដែលខ្លួនត្រូវទៅរស់នៅ។

៥-ត្រូវពិចារណាលើរបាយការណ៍ ឬព័ត៌មានរបស់អង្គភាព ឬបុគ្គលដែលត្រូវបានចាត់តាំងពាក់ព័ន្ធនឹងជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចតាមបទប្បញ្ញត្តិ នៃមាត្រា ២២៧-២២៨-២២៩ និង ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ខ-ព្រះរាជអាជ្ញា**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមគោលការណ៍នេះ ដោយយកចិត្តទុកដាក់ពិនិត្យឲ្យបានហ្មត់ចត់អំពីកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់ជនត្រូវចោទឲ្យបានសមស្រប និងឲ្យមានតុល្យភាពទៅនឹងស្ថានភាពសង្គម ក្នុងការស្នើសុំដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

២-បន្ទាប់ពីទទួលបានដីកាបង្គាប់ ដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវចាត់វិធានការដូចខាងក្រោម ៖

-ណែនាំជនត្រូវចោទអំពីរបៀបដែលត្រូវអនុវត្តកាតព្វកិច្ច ដូចបានកំណត់ក្នុងដីកាបង្គាប់របស់ចៅក្រមស៊ើបសួរ

-ណែនាំដល់អង្គភាព ឬបុគ្គលដែលត្រូវបានចាត់តាំងដោយចៅក្រមស៊ើបសួរឲ្យត្រួតពិនិត្យ តាមដាននិងធ្វើរបាយការណ៍តាមការកំណត់ ។

៣-ក្នុងករណីចៅក្រមស៊ើបសួរ បង្គាប់ឲ្យជនត្រូវចោទទៅបង្ហាញខ្លួន នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ត្រូវបង្គាប់ទៅអង្គភាពនោះឲ្យចាត់វិធានការដូចខាងក្រោម ៖

-រៀបចំឲ្យមានសៀវភៅសម្រាប់ចុះវត្តមានជនត្រូវចោទ ដែលត្រូវមកបង្ហាញខ្លួនតាមការកំណត់របស់ចៅក្រមស៊ើបសួរ

-ចាត់ភ្នាក់ងាររបស់ខ្លួនឲ្យតាមឃ្លាំមើលសកម្មភាពរបស់ជនត្រូវចោទ ក្នុងការបំពេញកាតព្វកិច្ច

-ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ជនត្រូវចោទ (វត្តមាន និងសកម្មភាព) ក្នុងការបំពេញកាតព្វកិច្ចតាមការកំណត់ជូនទៅព្រះរាជអាជ្ញា។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤

អង្គ វង្សវឌ្ឍនា

ចម្លងជូន ៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

**ឧបសម្ព័ន្ធទី ៥**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ : ០២[illegible]/១៤

**សារាចរ**
**ស្តីពី**
**ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បង**

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការអនុវត្តរបបនៃការព្យួរទោសសាកល្បង ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ១១៧ ដល់ មាត្រា ១២៣ និងមាត្រា ១៦៥ មិនទាន់អនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តនៃការព្យួរទោសសាកល្បង មិនទាន់បានល្អប្រសើរ។

ដើម្បីអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

**ក-ចៅក្រមជំនុំជម្រះ**

១-យោងតាមមាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌ ចៅក្រមគប្បីត្រូវពិចារណាសម្រេចព្យួរសាកល្បងនៃទោស ឲ្យបានជាអតិបរិមានូវទោស ដែលបានសម្រេចដាក់ពន្ធនាគារ ក្នុងបទល្មើសមជ្ឈិម។

២-តុលាការត្រូវចេញសម្រង់សាលក្រមស្ការពរចំនួនបីច្បាប់។ ចំនួនពីរច្បាប់ប្រគល់ជូនព្រះរាជអាជ្ញា និងមួយច្បាប់ទៀតប្រគល់ឲ្យទៅទណ្ឌិតដើម្បីអនុវត្ត។

**ខ-ព្រះរាជអាជ្ញា**

១-ត្រូវដឹកនាំសម្របសម្រួល ការអនុវត្តសេចក្តីសម្រេចព្យួរទោសសាកល្បងរបស់តុលាការគ្រប់ជាន់ថ្នាក់ ឲ្យមានប្រសិទ្ធភាព។

២-ត្រូវចាត់តាំងបុគ្គលនៅក្នុងមូលដ្ឋានដែលទណ្ឌិតរស់នៅ ឬ បំពេញកាតព្វកិច្ច ឲ្យតាមដានសកម្មភាពរបស់ទណ្ឌិត។ បុគ្គលដែលគប្បីចាត់តាំង ដូចជានគរបាលប៉ុស្តិ៍រដ្ឋបាល សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីទទួលបន្ទុកអប់រំ និងស្ការនីតិសម្បទា...។

៣-ត្រូវបង្គាប់ណែនាំដល់ទណ្ឌិត ឲ្យទៅបង្ហាញខ្លួននៅចំពោះមុខបុគ្គលដែលត្រូវបានចាត់តាំងឲ្យតាមដាន។

៤-ត្រូវប្រគល់សម្រង់សាលក្រម ឬ សម្រង់សាលដីកាស្ដាពរដល់បុគ្គលដែលត្រូវបាន ចាត់តាំងឲ្យតាមដានទណ្ឌិត និងធ្វើការដឹកនាំសម្របសម្រួលការអនុវត្ត។

៥-ក្នុងករណីចាំបាច់ ត្រូវបង្គាប់ទៅអង្គភាពនគរបាលយុត្តិធម៌ ឲ្យចាត់វិធានការជួយតាមដានរាល់សកម្មភាពរបស់ទណ្ឌិត និងត្រូវធ្វើរបាយការណ៍តាមការកំណត់ ពីការកត់សម្គាល់ឃើញរបស់ខ្លួនចំពោះសកម្មភាពរបស់ទណ្ឌិតជូនទៅព្រះរាជអាជ្ញា ដើម្បីស្នើសុំយោបល់ ឬ ចាត់វិធានការ។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី.២.២..ខែមករា.. ឆ្នាំ.២០១៤..

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍនា

<u>ចម្លងជូន</u> ៖
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- តុលាការ និងមហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
- សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធទី ៦**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងយុត្តិធម៌

លេខ : ០៧៣ អយក.០០៣/០៤

**សារាចរ**

**ស្តីពី**

**ការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍**

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការអនុវត្តទោសការងារសហគមន៍ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ៧២ ដល់មាត្រា ៧៥ មាត្រា ៥៨ មាត្រា ១០១ ដល់ ១០៣ និងមាត្រា ១៦២ មិនទាន់អនុវត្តបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តទោសការងារសហគមន៍ មិនទាន់មានប្រសិទ្ធិភាព និងមិនទាន់មានភាពរលូន។

ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

**ក-ចៅក្រមជំនុំជម្រះ**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមបទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌស្តីពីទោសការងារសហគមន៍ ចំពោះទណ្ឌិតណាដែលតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើ ៣ (បី) ឆ្នាំ ។

២-តុលាការត្រូវប្រគល់សម្រង់សាលក្រម ជូនព្រះរាជអាជ្ញាមួយច្បាប់ និងប្រគល់ឲ្យទៅទណ្ឌិតមួយច្បាប់។

**ខ-ព្រះរាជអាជ្ញា**

១-ត្រូវសហការជាមួយអង្គការរដ្ឋ សមាគមន៍ ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកសាង និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះនីតិបុគ្គល និងប្រភេទការងារ ដែលមានតម្រូវការផ្តល់ការងារឲ្យទណ្ឌិតធ្វើ។ បញ្ជីនេះត្រូវដាក់បង្ហាញជូនតុលាការដើម្បីជ្រើសរើសការងារ ឲ្យទណ្ឌិតដែលយល់ព្រមទទួលយក។

២-ការផ្តល់ការងារសហគមន៍ដល់អនីតិជន ត្រូវពិភាក្សាបន្ថែមជាមួយមន្ត្រីសង្គមកិច្ចអំពីការងារដែលមានលក្ខណៈជាការងារបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។

៣-ត្រូវរៀបចំបែបបទនៃការអនុវត្តទោសការងារសហគមន៍ សម្រាប់នីតិបុគ្គលដែលទទួលទណ្ឌិតឲ្យធ្វើការងារ ដោយឲ្យនីតិបុគ្គលនោះ បំពេញនូវកាតព្វកិច្ចដូចតទៅ ៖

-ណែនាំដល់ទណ្ឌិតអំពីការបំពេញកាតព្វកិច្ច និងអប់រំទណ្ឌិតឲ្យយកចិត្តទុកដាក់ក្នុងការកសាងខ្លួនចូលក្នុងសង្គមវិញ

-គ្រប់គ្រងតាមដានសកម្មភាពរបស់ទណ្ឌិត ក្នុងពេលបំពេញកាតព្វកិច្ច

-ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ទណ្ឌិតជូនដល់ព្រះរាជអាជ្ញា

-ត្រូវចុះហត្ថលេខាលើកំណត់ហេតុទទួលស្គាល់ អំពីការអនុវត្តការងាររបស់ទណ្ឌិត

៤-ត្រូវយកចិត្តទុកដាក់តាមដានត្រួតពិនិត្យការអនុវត្តការងាររបស់ទណ្ឌិតដែលមានដូចខាងក្រោម ៖

-គ្រប់គ្រង តាមដាន រក្សាទុករបាយការណ៍ កំណត់ហេតុអំពីការអនុវត្តការងារសហគមន៍

-តាមដានការអនុវត្តរបស់ទណ្ឌិតទៅតាមលក្ខខណ្ឌរបស់សាលក្រម

-ណែនាំទណ្ឌិតអំពីការអនុវត្តការងារសហគមន៍ និងកាតព្វកិច្ចដែលត្រូវអនុវត្ត

-ណែនាំដល់នីតិបុគ្គលដែលទទួលទណ្ឌិត អំពីបែបបទអនុវត្តការងារគ្រប់គ្រង

-ចេញដីកាសម្រេចបញ្ចប់ការអនុវត្តទោសរបស់ទណ្ឌិត ដែលបានអនុវត្តទោសការងារសហគមន៍ដោយជោគជ័យ។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី..២២..ខែ..ឧសភា..ឆ្នាំ..២០១៤

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍនះ

**ចម្លងជូន ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
-ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធទី ៧**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ :០៥០.កយ.ប្រក/២២

# ប្រកាស
## ស្តីពី
## បែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមវិញ នៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីយុត្តិធម៌អនីតិជន
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌

មហាវិថីសម្តេចសុធារស.ខណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

# សម្រេច

**ប្រការ១ .-**

ប្រកាសនេះ កំណត់អំពីបែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមវិញនៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ក្នុងគោលបំណងដើម្បីធានាការអនុវត្តការដោះលែងដោយមានលក្ខខណ្ឌឱ្យមានប្រសិទ្ធភាព សំដៅធ្វើសមាហរណកម្មទណ្ឌិតនោះឱ្យចូលទៅរួមរស់នៅក្នុងសង្គមវិញ។

**ប្រការ២ .-**

ការដោះលែងដោយមានលក្ខខណ្ឌ គឺជាសមត្ថកិច្ចរបស់ប្រធានសាលាដំបូងនៃទីកន្លែងឃុំខ្លួនទណ្ឌិត។ ប្រធានសាលាដំបូងសម្រេចអំពីការដោះលែងដោយមានលក្ខខណ្ឌ តាមដីកាសម្រេច ដោយមានសំអាងហេតុ បន្ទាប់ពីទទួលបានយោបល់ពីគណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌ ស្របតាមមាត្រា៥១៤ មាត្រា៥១៥ និងមាត្រា៥១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ប្រធានសាលាដំបូង មិនជាប់ជំពាក់នឹងយោបល់របស់គណៈកម្មការជាតិនោះទេ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការដោះលែងដោយមានលក្ខខណ្ឌ ព្រមទាំងការបញ្ចប់ការដោះលែងដោយមានលក្ខខណ្ឌ មានចែងចាប់ពីមាត្រា ៥១២ ដល់មាត្រា ៥២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ប្រការ៣ .-**

នៅក្នុងដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ ប្រធានសាលាដំបូងត្រូវកំណត់អំពីបែបបទនៃការអនុវត្ត និងរយៈពេលនៃការសាកល្បងដែលមិនអាចលើសពីថិរវេលានៃទោសដែលនៅសល់មិនទាន់បានទទួលរងឡើយ។

ប្រធានសាលាដំបូងសម្រេចដោះលែងទណ្ឌិត ដោយមានភ្ជាប់លក្ខខណ្ឌជាកាតព្វកិច្ចមួយ ឬច្រើនដូចខាងក្រោម ៖

- បំពេញសកម្មភាពខាងវិជ្ជាជីវៈ។
- ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ។
- រស់នៅក្នុងទីកន្លែងណាមួយជាកំណត់។
- ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬការព្យាបាល។
- បញ្ជាក់អំពីការចូលរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ។
- ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើស តាមលទ្ធភាពនៃធនធានរបស់ខ្លួន។
- បញ្ជាក់អំពីការបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្តន្ទាទោស តាមលទ្ធភាពធនធានរបស់ខ្លួន។
- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ ឬសង្គមដែលសម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការត្រូវបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់។
- មិនត្រូវមានវត្តមាននៅទីកន្លែងមួយចំនួនដែលត្រូវបានហាមឃាត់។ ក្នុងករណីនេះ តុលាការត្រូវបញ្ជាក់អំពីទីកន្លែងដែលត្រូវបានហាមឃាត់។
- មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ។

- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

ក្រៅពីការអនុវត្តកាតព្វកិច្ចខាងលើ ទណ្ឌិតអាចត្រូវដាក់ឱ្យស្ថិតក្រោមវិធានការត្រួតពិនិត្យរបស់អាជ្ញាធរមានសមត្ថកិច្ច ដោយត្រូវគោរពកាតព្វកិច្ចមួយឬច្រើន ដូចខាងក្រោម៖

- ត្រូវគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬការកោះហៅរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។
- ត្រូវមកទទួលនូវការពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។
- ត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ នូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរួមរស់នៅក្នុងសង្គមវិញ។
- ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន។
- ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន។
- ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស។

ក្នុងករណីទណ្ឌិតមិនអនុវត្តតាមដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ ប្រធានសាលាដំបូងអាចដកហូតដីកាសម្រេចនោះ និងអាចបង្គាប់ឱ្យចាប់ខ្លួនទណ្ឌិតនោះមកអនុវត្តទោសដែលនៅសេសសល់។

**ប្រការ៤ ..**

ព្រះរាជអាជ្ញានៃសាលាដំបូងដែលបានចេញដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ ប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនតាមច្បាប់ ដើម្បីធានាដល់ការអនុវត្តដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ ព្រមទាំងអាចចាត់វិធានការចាំបាច់នានា ដើម្បីឃ្លាំមើល តាមដាន និងត្រួតពិនិត្យការអនុវត្តដីកាសម្រេចនោះ។ ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចដែនដីពាក់ព័ន្ធ ត្រូវផ្តល់កិច្ចសហការចាំបាច់នានា ដើម្បីធានាដល់ការអនុវត្តដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ។

ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ច ត្រូវដឹកនាំសម្របសម្រួលអាជ្ញាធរដែនដី និងមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការអនុវត្តដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ ឱ្យមានប្រសិទ្ធភាព។

ក្នុងករណីចាំបាច់ ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ច អាចចាត់តាំងបុគ្គល ឬអង្គភាពនៅមូលដ្ឋាននៃទីកន្លែងដែលទណ្ឌិតនឹងទៅរស់នៅ ឬទៅបំពេញការងារ ឬទៅបំពេញកាតព្វកិច្ច ដើម្បីឃ្លាំមើល តាមដាន និងត្រួតពិនិត្យការអនុវត្តកាតព្វកិច្ចរបស់ទណ្ឌិតនោះ។

បុគ្គលដែលអាចត្រូវបានចាត់តាំង រួមមាន មន្ត្រីនគរបាលយុត្តិធម៌ នគរបាល កងរាជអាវុធហត្ថ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មេភូមិ មន្ត្រីសង្គមកិច្ច និងមន្ត្រីទទួលបន្ទុកអប់រំនិងស្តារនីតិសម្បទា។

**ប្រការ៥ ..**

បុគ្គលដែលត្រូវបានចាត់តាំងដោយព្រះរាជអាជ្ញាដូចមានកំណត់ក្នុងប្រការ៤ ត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង និងតាមដានការបំពេញកាតព្វកិច្ចរបស់ទណ្ឌិត
- ណែនាំទណ្ឌិតដែលត្រូវបានដោះលែង អំពីកាតព្វកិច្ចដែលត្រូវអនុវត្តដូចមានកំណត់ក្នុងដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ

- អប់រំទណ្ឌិតនោះឱ្យយកចិត្តទុកដាក់ កែប្រែ និងកសាងខ្លួនដើម្បីធ្វើសមាហរណកម្មចូលទៅរួមរស់នៅក្នុងសង្គមវិញ
- រាយការណ៍ ឬធ្វើរបាយការណ៍អំពីសកម្មភាពរបស់ទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ជូនដល់ព្រះរាជអាជ្ញា។

**ប្រការ៦ ៉**

គណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌ ត្រូវបានប្រគល់ភារកិច្ច ដើម្បីសហការជាមួយស្ថាប័នសាធារណៈ ស្ថាប័នឯកជន អង្គការមិនមែនរដ្ឋាភិបាល ឬស្ថាប័នពាក់ព័ន្ធផ្សេងទៀត សំដៅជួយដល់ការធ្វើសមាហរណកម្មទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌឱ្យចូលទៅរួមរស់នៅក្នុងសង្គមវិញ។

**ប្រការ៧ ៉**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការអគ្គាធិការដ្ឋានកិច្ចការតុលាការ និងប្រធានគ្រប់អង្គភាពចំណុះក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៥កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២១

រដ្ឋមន្ត្រី

កើត រិទ្ធ

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
- សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី ៨**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ: [redacted]

ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ: [redacted]

ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥

**សំណុំរឿងស៊ើបសួរ**

លេខ: [redacted]

ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧

**សំណុំរឿងជំនុំជម្រះ**

លេខ: [redacted]

ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

**តាមនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ដោយមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ដែលមាន៖**

/ **ជនជាប់ចោទ** ឈ្មោះ ក ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរអគ្គនាយក ក្រុមហ៊ុន A ទីកន្លែងកំណើតនៅភូមិចំប៉ី ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ២២ ផ្លូវបុរីសន្តិភាព១ ភូមិចោមចៅ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ ខ (ស្លាប់) ម្តាយឈ្មោះ គ (រស់) ប្រពន្ធឈ្មោះ ឃ មានកូនចំនួន ០៧ នាក់ ជានីតិជន ។ (ដីកាបង្គាប់ឲ្យចាប់ខ្លួន លេខ [redacted] ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨)

ជាប់ចោទពីបទ ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៣ និងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ** លោក [redacted] លោក [redacted] និងលោក [redacted] ជាមេធាវីនៃក្រុមមេធាវីជាតិ &អន្តរជាតិ មានការិយាល័យស្ថិត នៅផ្ទះលេខ ៣១$CE_0E_1$ ផ្លូវលេខ៣៤៨ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ។

**ដើមបណ្តឹងរដ្ឋប្បវេណី** ក្រុមហ៊ុន B ទីស្នាក់ការនៅផ្ទះលេខ ១៥A ផ្លូវលេខ៥១៤ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ តំណាងដោយឈ្មោះ ង ជាអគ្គនាយក ។

**មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី** លោក [redacted] ជាមេធាវីនៃ ការិយាល័យមេធាវី លឹម អែន អាសូស៊ីអេត្ស ដែលមានការិយាល័យនៅផ្ទះលេខ៤៥៤០ ផ្លូវលេខ១០០៣ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីអំឡុងឆ្នាំ២០១៣ ឈ្មោះ ក ជា អគ្គនាយក ក្រុមហ៊ុន A បានមកទំនាក់ទំនងជនរងគ្រោះថា ក្រុមហ៊ុនគាត់មានគំរោងវិនិយោគលើផ្លូវជាតិលេខ៥ ចាប់ពីស្ពានព្រែកក្ដាម រហូតដល់ព្រំដែនកម្ពុជា-ថៃ ហើយកំពុងស្វែងរកដៃគូម៉ៅការសាងសង់លើគំរោងវិនិយោគខាងលើនេះ ដោយមិនចាំបាច់ដេញថ្លៃ ។ ដោយមានការជឿទុកចិត្ត ជនរងគ្រោះឈ្មោះ ខ ជាអគ្គនាយក ក្រុមហ៊ុន B បានចុះកិច្ចព្រមព្រៀងជាមួយនឹងឈ្មោះ ក នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៣ លើគម្រោងផ្លូវជាតិលេខ៥ ចម្ងាយ ១៥៥.៤៥០ គីឡូម៉ែត្រ ទទឹង៣០ម៉ែត្រ ចាប់ពីខេត្តបាត់ដំបង ដល់ទីក្រុងប៉ោយ ប៉ែត ព្រំដែនកម្ពុជា-ថៃ ក្នុងតម្លៃសរុប ៦២១.៨០០.០០០ $ (ប្រាំមួយរយម្ភៃមួយលានប្រាំបីសែនដុល្លារអាមេរិក) ។ ក្រោយចុះកិច្ចព្រមព្រៀងរួចឈ្មោះ ក តម្រូវឱ្យជនរងគ្រោះប្រគល់ប្រាក់ចំនួន ១០០.០០០ $ (ដប់ម៉ឺនដុល្លារអាមេរិក) ឱ្យខ្លួនទើបក្រុមហ៊ុនជនរងគ្រោះទទួលបានគម្រោងសាងសង់ផ្លូវខាងលើ ហើយជនរងគ្រោះក៏យល់ព្រម ។ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ ឈ្មោះ ក បានចរចារជាមួយក្រុមហ៊ុនជនរងគ្រោះ ដើម្បីទទួលបានគំរោងសាងសង់ផ្លូវជាតិលេខ ៥ ប្រវែង២២២ គីឡូម៉ែត្រ ដោយមិនដេញថ្លៃ ហើយតម្រូវឱ្យជនរងគ្រោះប្រគល់ប្រាក់ចំនួន ២០០.០០០$ (ម្ភៃម៉ឺនដុល្លារអាមេរិក) ទៀត ។ ក្រោយពីចុះកិច្ចព្រមព្រៀងរួច ជនរងគ្រោះបានទំនាក់ទំនងទៅឈ្មោះ ដើម្បីស្នើរកឯកសារពាក់ព័ន្ធ និងគំរោងសាងសង់ផ្លូវជាតិលេខ ៥ និងលិខិតអនុញ្ញាតពីរាជរដ្ឋាភិបាលព្រមទាំងបញ្ជាក់ពីពេលវេលាដើម្បីអនុវត្តគំរោងសាងសង់នេះ ប៉ុន្តែឈ្មោះ ក ចេះតែរកលេសពន្យារពេលរហូត ។ ដោយមានការសង្ស័យ ជនរងគ្រោះក៏បានទំនាក់ទំនងទៅក្រសួងពាក់ព័ន្ធទើបដឹងថា ការពិតរដ្ឋាភិបាលមិនអនុញ្ញាតឱ្យ ក្រុមហ៊ុន A លើគម្រោងពង្រីងផ្លូវសផុល និងថែទាំផ្លូវជាតិលេខ៥ តាមរូបភាព BOT តាំងពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ មកម្ល៉េះ ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ [redacted] ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០២០ ។

## នាពេលសវនាការ

-តាមអំណានពាក្យបណ្ដឹង ឈ្មោះ ខ បានឆ្លើយថា ៖ កាលពីកំឡុងឆ្នាំ២០១៣ ឈ្មោះ ក បានមកទំនាក់ទំនងជាមួយក្រុមហ៊ុនខ្លួន ដោយបានអះអាងថា ក្រុមហ៊ុនរបស់ខ្លួនទទួលបានគំរោងវិនិយោគលើផ្លូវជាតិលេខ ៥ ពីស្ពានព្រែកក្ដាម រហូតដល់ព្រំដែន កម្ពុជា-ថៃ និងកំពុងស្វែងរកអ្នកសាងសង់ ដើម្បីម៉ៅការសាងសង់លើគំរោងវិនិយោគនេះ ដោយមិនដេញថ្លៃ ។ លុះដល់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៣ ក៏ឈានដល់ការចុះកិច្ចព្រមព្រៀងស្ដីពីការសាងសង់ ផ្លូវជាតិលេខ៥ ចំងាយ ១៥៥,៤៥០គីឡូម៉ែត្រ ទទឹង ៣០ម៉ែត្រ ចាប់ពីខេត្តបាត់ដំបង ដល់ទីក្រុងប៉ោយប៉ែតព្រំដែនកម្ពុជា-ថៃ ដែលមានតំលៃសរុប ៦២១.៨០០.០០០ ដុល្លាអាមេរិក ។ ក្រោយពីចុះកិច្ចព្រមព្រៀងរួចរាល់ហើយ ឈ្មោះ ក តំរូវអោយខ្លួនប្រគល់ប្រាក់ចំនួន ១០០.០០០ ដុល្លារអាមេរិក អោយទៅគាត់ទើបក្រុមហ៊ុនខ្លួនទទួលបានគំរោងសាងសង់ផ្លូវខាងលើ ពេលនោះក្រុមហ៊ុនខ្លួន ក៏បានប្រគល់ប្រាក់ចំនួន ១០០.០០០ ដុល្លារ ទៅឱ្យឈ្មោះ ក ដោយបានធ្វើលិខិតប្រគល់ទទួលប្រាក់ត្រឹមត្រូវ។ បន្ទាប់មកទៀតឈ្មោះ ក បានមកខ្ចីប្រាក់ខ្លួនចំនួន ១៨.០០០ ដុល្លារ បន្ថែម ហើយនៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៤ ឈ្មោះ ក បានមកចរចារជាមួយក្រុមហ៊ុនខ្លួន ដើម្បីទទួលបានគំរោងសាងសង់ផ្លូវជាតិលេខ៥ ប្រវែង ២២២ គីឡូម៉ែត្រទៀត ដោយមិនដេញថ្លៃ និងតំរូវឱ្យខ្លួនប្រគល់ប្រាក់ចំនួន ២០០.០០០ ដុល្លារ ទៀត តែខ្លួនមិនមានប្រាក់គ្រប់ចំនួនក៏ប្រគល់-ទទួលប្រាក់បានតែ ៦០.០០០

ដុល្លារអាមេរិក ប៉ុណ្ណោះ។ ក្រោយពីបានចុះកិច្ចព្រមព្រៀង និងប្រគល់ទទួលប្រាក់ទាំងពីរលើករួចមក ខ្លួនតែងតែទំនាក់ទំនងឈ្មោះ ក ដើម្បីសួររកឯកសារពាក់ព័ន្ធនឹងគំរោងសាងសង់ផ្លូវជាតិលេខ៥ និងលិខិតអនុញ្ញាតពីរាជរដ្ឋាភិបាល និងបញ្ជាក់ពីពេលវេលា ដើម្បីអនុវត្តគំរោងសាងសង់នេះ ប៉ុន្តែឈ្មោះ ក តែងតែរកលេសពន្យារពេលផ្តល់ឯកសារទាំងនេះរហូតមកទល់បច្ចុប្បន្ន ។ ដោយសាររង់ចាំការបង្ហាញឯកសារអស់រយៈពេលជាច្រើនឆ្នាំ ខ្លួនក៏បានទំនាក់ទំនងសួរក្រសួងពាក់ព័ន្ធទើបដឹងថា គ្មានគំរោងសាងសង់ផ្លូវជាតិលេខ៥ ទេ ខ្លួនក៏ទាក់ទងទៅឈ្មោះ ក តែគាត់មិនទទួលទូរស័ព្ទ និងគេចវេសរហូត ។ ទង្វើ និងសកម្មភាពរបស់ឈ្មោះ ក និងបក្ខពួក គឺជាការឆបោកដោយប្រើល្បិចកល់អះអាងថា ខ្លួនជាម្ចាស់គំរោងសាងសង់ផ្លូវជាតិលេខ៥ និងបានចុះកិច្ចព្រមព្រៀងម៉ៅការសាងសង់ផ្លូវជាមួយខ្លួន ដើម្បីជាមធ្យាបាយឲ្យខ្លួនជឿជាក់ ក្នុងការប្រគល់ប្រាក់ទៅអោយគាត់តែ ប៉ុណ្ណោះ ក្រោយពេលទទួលបានប្រាក់ហើយក៏គេចវេសរហូត ធ្វើឲ្យក្រុមហ៊ុនខ្លួនខាតបង់ពេលវេលា និងបាត់បង់ផលប្រយោជន៍យ៉ាងធំធេង ។ ដូនេះសូមតុលាការ ជួយរកយុត្តិធម៌ជូនខ្លួន ដោយចាប់ជនល្មើស និងបក្ខពួកមកផ្តន្ទាទោស តាមផ្លូវច្បាប់ និងសុំទាមទារប្រាក់ដែលបានបង់ចំនួន ១៨០.០០០ ដុល្លារអាមេរិក ព្រមទាំងសំណងជំងឺចិត្តលើការខូចខាតចំនួន ១០០.០០០ ដុល្លារអាមេរិក ដោយក្តីអនុគ្រោះ ។

-តាមអំណានចម្លើយ នៅតំណាក់កាលតំណាងអយ្យការលោកមេធាវី [redacted] ជាមេធាវីតំណាងឲ្យឈ្មោះ ខ បានឆ្លើយថា៖ កាលពីអំឡុងឆ្នាំ២០១៣ ឈ្មោះ ក ជាអគ្គនាយក ក្រុមហ៊ុន A បានមកទំនាក់ទំនងកូនក្តីខ្លួនថា ក្រុមហ៊ុនគាត់មានគម្រោងវិនិយោគលើផ្លូវជាតិលេខ៥ ចាប់ពីស្ពានព្រែកក្តាម រហូតដល់ព្រំដែនកម្ពុជា-ថៃ ហើយកំពុងស្វែងរកដៃគូម៉ៅការសាងសង់លើគំរោងវិនិយោគខាងលើនេះដោយមិនចាំបាច់ដេញថ្លៃ ។ ដោយមានការជឿទុកចិត្ត កូនក្តីខ្លួនក៏បានចុះកិច្ចព្រមព្រៀងជាមួយនឹងឈ្មោះ ក នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៣ លើគម្រោងផ្លូវជាតិលេខ៥ ចម្ងាយ ១៥៥.៤៥០ គីឡូម៉ែត្រ ទទឹង ៣០ ម៉ែត្រ ចាប់ពីខេត្តបាត់ដំបង ដល់ទីក្រុងប៉ោយប៉ែត ព្រំដែនកម្ពុជា-ថៃ ។ ដោយក្រុមហ៊ុនកូនក្តីខ្លួនហេតុតែចង់បានទទួលគំរោងសាងសង់ផ្លូវជាតិ លេខ៥ ពុំចាំបាច់ដេញថ្លៃនោះ ឈ្មោះ ក ក៏តម្រូវឲ្យកូនក្តីខ្លួនបង់ប្រាក់ចំនួន ១០០.០០០$ (ដប់ម៉ឺនដុល្លារអាមេរិក) ជាបន្តបន្ទាប់ ហើយឈ្មោះ ក ក៏បានខ្ចីប្រាក់ពីកូនក្តីខ្លួនបន្ថែមទៀត ហើយនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ ឈ្មោះ ក បានមកចរចារឲ្យក្រុមហ៊ុនកូនក្តីខ្លួនទទួលសាងសង់ផ្លូវជាតិលេខ៥ ចម្ងាយ ២២២ គីឡូម៉ែត្រ បន្ថែមទៀត ដោយមិនដេញថ្លៃ តែតម្រូវឲ្យក្រុមហ៊ុនកូនក្តីខ្លួនប្រគល់ប្រាក់ឲ្យគាត់ចំនួន ២០ ម៉ឺនដុល្លារអាមេរិក ប៉ុន្តែពេលនោះកូនក្តីខ្លួនប្រគល់ប្រាក់ឲ្យគាត់បានតែចំនួន ៦ ម៉ឺនដុល្លារអាមេរិក ប៉ុណ្ណោះ ឈ្មោះ ក ក៏ទទួលយកទៅ ។ ចាប់តាំងពីពេលនោះមក ខាងក្រុមហ៊ុនកូនក្តីខ្លួនរង់ចាំការងារសាងសង់នោះយូរពេក កូនក្តីខ្លួនក៏បានទាក់ទងទៅឈ្មោះ ក សួរនាំអំពីបញ្ហានេះ តែគាត់បែរជាគេចវេស មិនព្រមលើកទូរស័ព្ទ កូនក្តីខ្លួនក៏ទាក់ទងទៅក្រសួងពាក់ព័ន្ធទើបដឹងថា រដ្ឋាភិបាលពុំបានអនុញ្ញាតឲ្យក្រុមហ៊ុន ក ថែទាំ ជួសជុលសាងសងផ្លូវជាតិលេខ៥ ដូចការអះអាងរបស់ឈ្មោះ ក ឡើយ ។ លើសពីនេះ យោងលិខិតលេខ [redacted] ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ របស់ [redacted] ក៏បានបញ្ជាក់ និងសម្រេចមិនឯកភាពឲ្យវិនិយោគ ករណីសំណើសុំបញ្ជាក់ពីគោលការណ៍វិនិយោគរបស់ ក្រុមហ៊ុន A លើគម្រោងពង្រីកជួសជុល និងថែទាំផ្លូវជាតិលេខ៥ តាមរូបភាព BOT ។ តែឈ្មោះ ក បែរជាមកលួងលោមបោកបញ្ឆោតប្រើល្បិចទុច្ចរិតមកចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនកូនក្តីខ្លួនក្នុងឆ្នាំ២០១៣ នេះបញ្ជាក់ពីចេតនាឆបោករបស់ឈ្មោះ ក មកលើកូនក្តីខ្លួនទាំងស្រុង ។ ក្នុងនាមជាមេធាវី

ការពារសិទ្ធិដើមបណ្ដឹងសូមទាមទារសំណង ១៨០.០០០ ដុល្លារអាមេរិក និងសំណងការខូចខាត និងជំងឺចិត្តចំនួន ១០០.០០០ ដុល្លារអាមេរិក និងផ្ដន្ទាទោសជនល្មើសតាមច្បាប់ ។

√ -តាមអំណានពាក្យបណ្ដឹង ជនជាប់ចោទឈ្មោះ ក បានឆ្លើយថា៖ កន្លងមកខ្លួនបានបង្កើតក្រុមហ៊ុនមួយដែលមាននាមករណ៍ថា " ក្រុមហ៊ុន A ហៅកាត់ A ក្នុងគោលបំណងចូលរួមកសាងប្រទេសជាតិ ស្របតាមគោលនយោបាយគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលមាន សម្ដេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី ។ ក្រោយពីបង្កើតក្រុមហ៊ុនត្រឹមត្រូវតាមច្បាប់រួចហើយ ខ្លួនបានស្នើសុំការអនុញ្ញាតពីរាជរដ្ឋាភិបាល ដើម្បីវិនិយោគកសាងផ្លូវជាតិលេខ ៥ តាមប្រព័ន្ធ B.O.T នៅព្រះរាជាណាចក្រកម្ពុជា ។ នៅពេលនោះរាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធបានចេញលិខិតជូនមកឱ្យក្រុមហ៊ុនខ្លួនមានលេខ និងកាលបរិច្ឆេទ ដូចយោងខាងលើ ។ ដោយហេតុថា ខ្លួនបានទទួលលិខិតដូចជម្រាបជូនខាងលើ ក៏មានលោក ខ ជាប្រធាន មកសុំចុះកិច្ចព្រមព្រៀងទទួលយកគម្រោង ទៅធ្វើការសាងសង់ដែលមានប្រវែង ១៥៥ គីឡូម៉ែត្រ គិតចាប់ពីខេត្តបាត់ដំបងទៅដល់ក្រុងប៉ោយប៉ែត ព្រំប្រទល់កម្ពុជាថៃ ដោយក្រុមហ៊ុនខ្លួន សំណូមពរឱ្យគាត់ជួយចេញប្រាក់សោហ៊ុយឱ្យមកក្រុមហ៊ុនខ្លួនចំនួន ១០០.០០០ ដុល្លារ (ដប់ម៉ឺនដុល្លារអាមេរិក) ជាប្រាក់ទទួលយកគម្រោងម៉ៅការសាងសង់ និងដើម្បីក្រុមហ៊ុនខ្លួនយកទៅដោះស្រាយសោហ៊ុយនៃការរត់ការឯកសារផ្សេងៗ ពាក់ព័ន្ធលើគម្រោងដែលនៅសេសសល់មិនទាន់បានបញ្ចប់ជាមួយស្ថាប័នពាក់ព័ន្ធ ។ លោក ខ ក៏បានឯកភាពគ្នាចុះកិច្ចព្រមព្រៀងប្រគល់ និង ទទួលគម្រោង តែលោក បានចាយប្រាក់មកឱ្យខ្លួនតែចំនួន ៨០.០០០ ដុល្លារ (ប្រាំបីម៉ឺនដុល្លារអាមេរិក) ប៉ុណ្ណោះ (ប្រាក់នេះខ្លួនទទួលពីលោក គ និងលោក ឃ ) ។ ដោយប្រាក់ចំនួន ៨០.០០០ ដុល្លារ (ប្រាំបីម៉ឺនដុល្លារអាមេរិក) នេះ ខ្លួនធ្វើការមិនគ្រប់គ្រាន់ ខ្លួនក៏សំណូមពរទៅលោក ខ ស្នើសុំជួយប្រាក់បន្ថែមចំនួន ៥០.០០០ ដុល្លារ (ប្រាំម៉ឺនដុល្លារអាមេរិក) ទៀត លោក ខ ក៏ចេញមូលប្បទានប័ត្រឱ្យខ្លួនចំនួន ១០.០០០ ដុល្លារ (មួយម៉ឺនដុល្លារអាមេរិក) ហើយលោក ខ ក៏សំណូមពរមកខ្លួនវិញថា បើសិនជា បង ក ត្រូវការប្រាក់យកទៅធ្វើការបន្ថែមទៀត លុះត្រាតែយល់ព្រមប្រគល់គម្រោងផ្លូវប្រវែង ២២២ គីឡូម៉ែត្រ បន្ថែមទៀត ទើបខ្លួននឹងប្រគល់លុយបន្ថែមទៀត ។ ខ្លួន ក ក៏បានប្រជុំពិភាក្សាជាមួយសមាជិកភាគហ៊ុនដែលពាក់ព័ន្ធលើផ្លូវប្រវែង ២២២ គីឡូម៉ែត្រនេះ ហើយសមាជិកភាគហ៊ុនទាំងអស់ក៏បានឯកភាព ខ្លួនក៏បានយល់ព្រមជាមួយលោក ខ ធ្វើកិច្ចព្រមព្រៀងប្រគល់គម្រោងផ្លូវប្រវែង ២២២ គីឡូម៉ែត្រ នេះ ឱ្យទៅលោក ខ ទទួលយកទៅគ្រប់គ្រងបន្ថែមដោយខ្លួនបានសំណូមពរឱ្យលោក ខ ជួយចេញប្រាក់សោហ៊ុយសម្រាប់ធ្វើការងារនេះបញ្ចប់បន្ថែមទៀត ចំនួន ២០០.០០០ ដុល្លារ (ម្ភៃម៉ឺនដុល្លារអាមេរិក) ហើយលោក ខ ក៏បានឯកភាពតាមសំណូមពររបស់ក្រុមហ៊ុនខ្លួន (CKA) ។ លុះនៅថ្ងៃទី១២ ខែកម្ភៈ ឆ្នាំ២០១៤ លោក ខ បានចាយប្រាក់មកឱ្យខ្លួនតែចំនួន ៦០.០០០ ដុល្លារ (ប្រាំមួយម៉ឺនដុល្លារអាមេរិក) ទេនៅខ្វះចំនួន ១៤០.០០០ ដុល្លារ (ដប់បួនម៉ឺនដុល្លារអាមេរិក) ទៀត លោក ខ នឹងប្រគល់ឱ្យខ្លួននៅពេលដែលទទួលបានឯកសារពីក្រសួងសាធារណការ និងដឹកជញ្ជូន ឬពីរាជរដ្ឋាភិបាលបន្ត ។ លុះដល់ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៤ ខ្លួនបានទទួលលិខិតពីក្រសួងសាធារណៈការ និង ដឹកជញ្ជូន ហើយខ្លួនបានទំនាក់ទំនងទៅលោក ខ ឱ្យអនុវត្តតាមលិខិតខាងលើ តែគាត់បានឆ្លើយឯកភាពប្រគល់ប្រាក់ចំនួន ១៤០.០០០ ដុល្លារ (ដប់បួនម៉ឺនដុល្លារអាមេរិក) ដើម្បីធ្វើការបន្ត ប៉ុន្តែគាត់គ្រាន់តែអះអាងមាត់ទទេតែប៉ុណ្ណោះ រហូតមកដល់បច្ចុប្បន្នគាត់មិនបានប្រគល់ប្រាក់ឱ្យខ្លួនដដែល រីឯលិខិតរបស់ក្រសួងក៏គាត់មិនបានគោរព

តាមលិខិតខាងនេះដដែល ទើបដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ គាត់បានប្រាប់ខ្លួនថា គាត់គ្មានលទ្ធភាពបន្តការងារនេះទេ ព្រោះរកដៃគូមិនបានហើយសុខចិត្តប្រគល់ការងារគំរោងសាងសង់នេះឱ្យខ្លួនវិញ ដោយគ្រាន់តែសុំសហការណ៍បន្ត ដើម្បីទទួលបានប្រាក់ ចំនួន ៥០.០០០.០០០ ដុល្លារ (ហាសិបលានដុល្លារអាមេរិក) តែប៉ុណ្ណោះ រីឯប្រាក់ដែលបានចាយវាយកន្លងមក មិនទាមទារយកវិញទេ ទុកជាការជួយជ្រោមជ្រែងគ្នា ។ ជាក់ស្តែងលោក [redacted] ជាអ្នកសរសេរលិខិតនេះដោយខ្លួនឯង ដោយដាក់ថា លិខិតជូនដំណឹងទៅវិញ ប៉ុន្តែក្នុងលិខិតនេះមានអត្ថន័យគ្រប់គ្រាន់ត្រង់ថា លោក ណា និងក្រុមហ៊ុនខ្លួនបានឯកភាពគ្នា សហការគ្នារកដៃគូវិនិយោគដើម្បីទទួលបានផលប្រយោជន៍ទាំងអស់គ្នា ។ ប៉ុន្តែនៅឆ្នាំ២០១៦ នេះ បែរជាឈ្មោះ ណា មកប្តឹងខ្លួនពីបទឆបោកខ្លួនគាត់ទៅវិញ ហេតុនេះខ្លួនសូមបដិសេធនូវពាក្យបណ្តឹងរបស់ឈ្មោះ ណា ចោលទាំងស្រុង ព្រោះរឿងនេះមិនមែនជារឿងព្រហ្មទណ្ឌ ពីបទឆបោក ទេតែវាជារឿងពាណិជ្ជកម្ម (កិច្ចសន្យារវាងពាណិជ្ជករ និងពាណិជ្ជករ) ។ អំពើរបស់លោក ណា ខាងលើនេះ គឺជាការប្រព្រឹត្តបទល្មើស ប្តឹងបរិហារបង្កាច់កេរ្តិ៍ មកលើខ្លួនដែលមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួនទេ គឺថែមទាំងប៉ះពាល់ដល់ផលប្រយោជន៍រដ្ឋាភិបាល និងផលយោជន៍ជាតិទាំងមូលយ៉ាងធ្ងន់ធ្ងរ ទៀតផង ។ ហេតុដូច្នេះ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន និងក្នុងគោលបំណងអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ផងសូមតុលាការមេត្តាពិនិត្យ និងសម្រេចតាមសំណូមពររបស់ខ្លួនក្នុងកម្មវត្ថុខាងលើដោយក្តីអនុគ្រោះ ។

-ជនជាប់ចោទឈ្មោះ ក បានឆ្លើយថា៖ ខ្លួនសូមបញ្ជាក់ថារាល់ការធ្វើវិនិយោគទៅលើផ្លូវជាតិលេខ ៥ នេះខ្លួនបានធ្វើការស្នើសុំទៅ CDC ហើយ CDC ក៏ស្វាគមន៍ឱ្យខ្លួនធ្វើការវិនិយោគបានទៅលើផ្លូវជាតិលេខ៥ បានដោយអាស្រ័យទៅលើក្រុមហ៊ុនរបស់ខ្លួនមានដើមទុន ។ ការធ្វើផ្លូវជាតិលេខ៥ នៅអំឡុងឆ្នាំ២០១៣ ខ្លួនបានស្នើសុំរាជរដ្ឋាភិបាលផ្តល់ការទុកចិត្តឱ្យក្រុមហ៊ុនខ្លួនធ្វើការវិនិយោគ ។ ប៉ុន្តែ ជាអកុសលដោយសារក្រុមហ៊ុនខ្លួនឈ្មោះគ្នាពេក ការវិនិយោគនោះក៏បានធ្លាក់ទៅលើក្រុមហ៊ុនដទៃ ។ ក្រោយមកក៏មានគ្នាច្រើនដើម្បីចូលរួមវិនិយោគដូចជា៖ ជាមួយភាគីក្រុមហ៊ុនថៃ ហើយខ្លួនក៏បានមកចាប់ដៃគូជាមួយលោក ណា ដើម្បីធ្វើការរកស៊ីជាមួយគ្នា ។ លោក ណា បានមកវិនិយោគជាមួយក្រុមហ៊ុនរបស់ខ្លួន មិនមែនមានន័យថាគាត់មិនដឹងអ្វីសោះនោះទេ ។ គាត់បានមើលឃើញឯកសារពីរាជរដ្ឋាភិបាលឆ្លើយតបមកខ្លួនជាបន្តបន្ទាប់ៗ និងជាជំហានៗ ។ លោក ណា ថា បានទទួលព័ត៌មានពីរាជរដ្ឋាភិបាលថា មិនអនុញ្ញាតឱ្យខ្លួនវិនិយោគនោះ គឺមិនត្រឹមត្រូវនោះទេ ។ ធម្មតាបើសិនខ្លួនបានដាក់ស្នើសុំទៅរាជរដ្ឋាភិបាល ហើយរាជរដ្ឋាភិបាលមិនអនុញ្ញាតនោះ រាជរដ្ឋាភិបាលនឹងធ្វើការឆ្លើយតបមកក្រុមហ៊ុនរបស់ខ្លួនតាមនីតិវិធីដែលកំណត់ដោយច្បាប់ ។ ប៉ុន្តែខ្លួនមិនទាន់ទទួលបានការជូនដំណឹងពីរដ្ឋាភិបាលអំពីការមិនអនុញ្ញាតឱ្យខ្លួនវិនិយោគនោះទេ ។ មួយវិញទៀតអ្វីដែលលោក ណា ថាបានទៅស៊ើបសួរដឹងថា រាជរដ្ឋាភិបាលមិនអនុញ្ញាតឱ្យក្រុមខ្លួនធ្វើការសាងសង់ក៏មិនពិតដែរ ។ ធម្មតាបើសិនជារាជរដ្ឋាភិបាលមិនអោយ រាជរដ្ឋាភិបាលត្រូវឆ្លើយតបមកក្រុមហ៊ុនខ្លួនជាលាយលក្ខណ៍អក្សរយ៉ាងច្បាស់លាស់ ។ ការវិនិយោគក្នុងឆ្នាំនេះមានទំហំដល់ទៅជាង ២.០០០ លានឯណោះ ហើយខ្លួនខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ។ ខ្លួនសូមសង្ខេបទៅចុះ ផ្លូវជាតិលេខ ៥ ចាស់ ខ្លួនបានស្នើសុំ ហើយរាជរដ្ឋាភិបាល ឯកឧត្តម [redacted] បានប្រាប់ថា បើសិនជាពន្យារពេលក្រុមហ៊ុន JICCA នឹងសិក្សាចប់មុន ។ ក្រុមហ៊ុនខ្លួន និងក្រុមហ៊ុន JICCA បានសិក្សាប្រណាំងគ្នា ហើយខ្លួនមានប្រៀបជាង តែជាអកុសលខ្លួនបានបាក់បែកគ្នាជាមួយឯកឧត្តម [redacted] ជាដៃគូរដោយបានប្តឹងផ្តល់គ្នារហូតដល់ CDC ហើយ CDC បានប្រាប់ឱ្យក្រុមហ៊ុនខ្លួនធ្វើការផ្សះផ្សារគ្នាឱ្យត្រូវសិនចាំដាក់ពាក្យ ។ ក្រោយមកខ្លួនក៏ចាប់ដៃគូរជាមួយឈ្មោះ

៣ ដោយមិនបានចាំថា ពេលណាទេ ។ ពេលនោះ រាជរដ្ឋាភិបាលបានឱ្យជម្រើសខ្លួនពីរថា បើសិនជាលោកធ្វើការនោះយឺត រាជរដ្ឋាភិបាលឱ្យទៅ JICCA លោកអាចសុំវិនិយោគគម្រោងថ្មីផ្លូវជាតិលេខ៥ថ្មីចាប់ពីព្រែកក្ដាម ។ ខ្លួនក៏បានស្នើសុំ ហើយក៏ទទួលបានទៀត ។ រដ្ឋាភិបាលក៏បានឆ្លើយតបមកទៀត ដូចក្នុងលិខិតដែលមាននៅមេធាវី ដែលលិខិតនេះខ្លួនបានស្នើសុំទៅខុទ្ទកាល័យរបស់សម្ដេចតេជោអន្តរាគម៍មក CDC និងក្រសួងសាធារណការ ។ ខ្លួនក៏យករឿងនេះប្រាប់លោក ៣ ថា "បង! បើសិនជាអាចាស់មិនបានយើងធ្វើអាថ្មី" ។ គាត់ថា "ថ្មីក៏ធ្វើដែរ" ។ ឈ្មោះ ៣ បានចុះកុងត្រា និងទៅរកដៃគូរបស់គាត់សាងសង់រយៈពេល ១ ឆ្នាំកន្លះ អត់បាន ។ គាត់ក៏បានប្រគល់គម្រោងនោះមកខ្លួនវិញ ហើយគាត់ថា លុយដែលបានដាក់ទុនមកនេះ គាត់សុំភាគហ៊ុនជាមួយខ្លួន ។ បើសិនជាទុនវិនិយោគនេះបាន ២.០០០ លាន គាត់ស្នើសុំ ៥០ លាន ដោយគាត់បានធ្វើលិខិតជាលាយលក្ខណ៍អក្សរដោយខ្លួនគាត់ទាំងអស់ ។ ខ្លួនក៏ឯកភាពតាមគាត់ថា បើសិនជាការវិនិយោគនេះទទួលបានប្រាក់ ២.០០០ លាន ខ្លួននឹងឱ្យវិញ ៥០ លាន គាត់បានផ្ទៀងផ្ទាត់ហើយ ។ លោក ៣ យកគម្រោងនេះទៅពីរឆ្នាំ ហើយតាមពិតខ្លួនទេដែលត្រូវខូចខាតពេលវេលា និងថវិកាទៀត ។ ពាថ្ងៃក្រោយ ខ្លួនក៏ទៅថៃរកក្រុមហ៊ុនដៃគូរឱ្យជួយ ខ្លួនត្រឡប់មកវិញស្រាប់តែឮថាគាត់ប្ដឹងខ្លួនតែម្ដង នេះជារឿងពិត ។ តាមការពិតខ្លួនគ្មានចេតនា ឆបោក គាត់នោះទេ ។ កន្លងមក ខ្លួនមិនដែលបានទទួលលិខិតបដិសេធពីរាជរដ្ឋាភិបាលថា មិនអនុញ្ញាតឱ្យសាងសង់នោះទេ ។ ខ្លួនបានស្នើសុំទៅរដ្ឋាភិបាលលើគម្រោងនោះតាំងពីដើមឆ្នាំ២០១០ ហើយកាលនោះខ្លួនបានសាងសង់ជាមួយក្រុមហ៊ុនដទៃនៅឡើយទេ តែបានឈ្លោះបែកបាក់គ្នា ។ បន្ទាប់ពីបែកបាក់ជាមួយដៃគូចាស់ ខ្លួនក៏ចាប់ដៃគូជាមួយលោក ៣ នេះ ។ ការចាប់ដៃគូរជាមួយលោក ៣ . នេះមិនមែនបានន័យថា ខ្លួនយកបាតដៃទទេគាត់ជឿខ្លួននោះទេ គឺដោយសារខ្លួនមានឯកសារពីរាជរដ្ឋាភិបាលជាបន្តបន្ទាប់ទើបឈ្មោះ ៣ ជឿជាក់ ។ ដូចបានបញ្ជាក់អញ្ចើងក្រោយមករាជរដ្ឋាភិបាលបានឱ្យក្រុមហ៊ុន JICCA និងក្រុមហ៊ុនខ្លួនសិក្សា ដើម្បីធ្វើការវិនិយោគ និងវាយតម្លៃថា ធ្វើទៅចំណេញ ឬមិនចំណេញ ។ បន្ទាប់ពីបានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនខ្លួន លោក ៣ បានដាក់ទុនវិនិយោគជាមួយខ្លួនចំនួន ១៥ ម៉ឺន ហើយការប្រគល់ប្រាក់នេះរយៈពេល ៣ដង ទើបអស់ ។ ប្រាក់នេះ ខ្លួនពុំដែលបានទទួលដោយផ្ទាល់ដែនោះទេ គឺលោក ខេមរា ជាអ្នកទទួល ។ នៅក្នុងទឹកប្រាក់ ១៥ ម៉ឺន ខ្លួនបានឱ្យលោក មករា ខ្ចីចំនួន ៥ម៉ឺន ត្រឡប់ទៅវិញ ដូចនេះ ខ្លួនទទួលបានជាក់ស្ដែងតែ ១០ ម៉ឺនប៉ុណ្ណោះ ដើម្បីវិនិយោគ ។ នៅពេលលោក ៣ ដឹងពីគម្រោងផ្លូវថ្មី គាត់ក៏ឯកភាពលើគម្រោងនេះ ។ ខ្លួនថា បើសិនធ្វើផ្លូវថ្មីយើងខ្វះពី ៤០ ទៅ ៥០ ម៉ឺនដុល្លារ សូមជួយដាក់ទុន ២០ ម៉ឺនសម្រាប់គម្រោងនេះ ហើយខ្លួននឹងចេញ ៣០ ម៉ឺនទៅលើគម្រោងនេះ ព្រោះខ្លួនជាម្ចាស់គម្រោង ។ បន្ទាប់មក គាត់ឱ្យខ្លួនបានតែ ៦ ម៉ឺនប៉ុណ្ណោះ ដូចមាននៅក្នុងលិខិតដែលខ្លួនបានចារ ដោយនៅខ្វះ ១៤ ម៉ឺនទៀត ។ ក្រោយពេលទទួលគម្រោងរួច គាត់ក៏ទៅរកដៃគូរវិនិយោគផ្សេងទៀត តែរកមិនបានគាត់ក៏ប្រគល់គម្រោងនេះមកឱ្យខ្លួនវិញ ។ ខ្លួនក៏សុខចិត្តទទួលយកគម្រោងនេះវិញ ហើយលុយដែលដាក់ជាមួយគ្នាគាត់សូមដាក់ជាភាគហ៊ុន ដោយក្រុមហ៊ុនគាត់សុំ ៥០ លាន ។ ក្រោយមក ខ្លួនទៅប្រទេសថៃបីថ្ងៃហើយត្រឡប់មកវិញក៏ត្រូវឈ្មោះ ៣ ប្ដឹងខ្លួន ដោយហេតុថា គាត់ខលទៅខ្លួនអត់ចូល ។ ដូចបានបញ្ជាក់អញ្ចើងថា គម្រោងនេះរាជរដ្ឋាភិបាលអនុញ្ញាតឱ្យខ្លួនឱ្យតែមានដើមទុន ។ ហើយបច្ចុប្បន្នគម្រោងផ្លូវជាតិលេខ ៥ នៅនឹងក្រុមហ៊ុនខ្លួនវិនិយោគហើយកំពុងប្រឈមមុខជាមួយរាជរដ្ឋាភិបាល ។ ខ្លួនស្នើសុំគម្រោងសាងសង់ផ្លូវជាតិលេខ៥ តាំងពីយូរមកហើយ តែចេះតែពន្យារដោយរងចាំដោះស្រាយជាមួយលោក ៣ ឱ្យរួចរាល់សិន ។ ខ្លួនស្នើទៅរាជរដ្ឋាភិបាលដើម្បីទទួលបានសិទ្ធិផ្ដួសផុលផ្លូវជាតិលេខ៥ តាំងពីឆ្នាំ២០១០ ។ ហើយការអនុញ្ញាតសិក្សាគម្រោងនេះគឺនៅអំឡុងខែកុម្ភៈ ឆ្នាំ២០១០ ។ ខ្លួនមិនធ្លាប់

ទទួលបានការបដិសេធទៅលើការវិនិយោគសាងសង់ និងជួសជុលគម្រោងផ្លូវជាតិលេខ៥ ទាល់តែសោះ ។ ប្រាក់ចំនួន ១៥ ម៉ឺន ជាប្រាក់ដាក់ហ៊ុនវិនិយោគជាមួយគ្នាទៅលើគម្រោងដែលបានសិក្សា ។ ក្រោយពីទទួលបានលុយ ១៥ ម៉ឺនដុល្លារ ខ្លួនបានយកមកចាត់ចែងជាមួយវិស្វករ និងកម្លាំងពលកម្ម ។ ឯកសារជាភស្តុតាងខ្លួនបានឱ្យលោក ណ តែមិនបានដាក់ក្នុងសំណុំរឿងទេ ។ នៅក្នុងការវិនិយោគផ្លូវជាតិលេខ៥ ខ្លួនមិនទាន់បានបញ្ចប់គម្រោងសិក្សាលើគម្រោងនេះនៅឡើយទេ ។ ចំពោះការអនុវត្តគម្រោងនេះ តាំងពីឆ្នាំ២០១៣ មកដល់បច្ចុប្បន្ន គឺមិនទាន់បានដំណើរការអនុវត្តគម្រោងនៅឡើយ ហើយក៏ពុំមានការលាក់លៀមគាត់ដែរ តែគាត់បែរជាមកប្ដឹងខ្លួនទៅវិញ ។ បើផ្អែកលើឯកសារ គាត់បានយកគម្រោងរបស់ខ្លួនទៅជាង២ឆ្នាំ ធ្វើឱ្យខ្លួនខូចខាតពេលវេលាការងារ តែខ្លួនឈរលើទស្សនៈខ្មែរដូចគ្នាទើបខ្លួនមិនរករឿងប្ដឹងផ្ដល់អ្វីទៅគាត់ ។ ក្រោយមកគាត់គ្មានសមត្ថភាពក៏ផ្ដល់គម្រោងមកឱ្យខ្លួនវិញ ហើយបានទាមទារចំណែក ៥០ លានដុល្លារទៀត ។ ក្រុមហ៊ុនខ្លួនមិនមែនមានធ្វើតែកសិកម្មទេ ហើយក្រុមហ៊ុនខ្លួនមានសិទ្ធិជំនួញអ្វីក៏បាន ឱ្យតែមានសមត្ថភាព និងមានដើមទុន ។ ចំពោះគម្រោងទៅលើការសាងសង់ផ្លូវ ក្រុមហ៊ុនខ្លួនមិនដែលបានសាងសង់ផ្លូវណាពីមុនឡើយ ។ ផ្លូវជាតិលេខ៥ចាស់ គឺចាប់ពីព្រែកក្ដាម ទៅដល់ប៉ោយប៉ែត មាន ៣៧៧,៥៧ គីឡូ ចំពោះផ្លូវជាតិលេខ៥ថ្មីមាន ៣៥០ គីឡូ ។ មុនចុះគម្រោងលោក ណ បានដឹងរាល់ឯកសារដែលខ្លួនបានបង្ហាញ ហើយលោក ណ ក៏បានចុះទៅមើលគម្រោងដល់ប៉ោយប៉ែតផងដែរ ។ កិច្ចព្រមព្រៀងដំបូងខ្លួនបានចុះជាមួយលោក ណ នៅថ្ងៃ១៤ ខែកញ្ញា ឆ្នាំ២០១៣ ពិតប្រាកដមែន ដោយលោក ណ ជាអ្នករៀបចំ ។ ចំពោះលិខិតដែលលោក ណ សួរទៅរាជរដ្ឋាភិបាលថា បញ្ចប់គម្រោងនេះនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ ជារឿងមិនពិតទេ ។ កិច្ចព្រមព្រៀងចុងក្រោយបង្អស់ដែលខ្លួនបានចុះជាមួយលោក ណ គឺជាលិខិតជូនដំណឹងចុះខែសីហា ឆ្នាំ២០១៣ ពិតប្រាកដមែន ។ ឯកសារទាំងអស់លោក ណ ជាអ្នករៀបចំ ហើយគាត់បានដឹងទាំងអស់នូវរាល់ឯកសារដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ ។ មកដល់ពេលនេះ ខ្លួនមិនដែលទទួលបានលិខិតបដិសេធទៅលើគម្រោងពីរាជរដ្ឋាភិបាលទាល់តែសោះ ។ ហើយរហូតដល់ឆ្នាំ២០១៤ រាជរដ្ឋាភិបាលក៏នៅតែចាំទៅលើគម្រោងដែលខ្លួនទទួលអនុវត្តនេះ ។

-សាក្សីឈ្មោះ ទ៦ បានឆ្លើយថា៖ ខ្លួនជាអភិបាលរងស្រុកពាមជរ ។ លោក ក ជាអ្នកអនុវត្តគម្រោងស្ពានប្រឡាយមួយខ្សែឈ្មោះប្រលាយទួលដូង ។ លោក ក ៖ ស្ពានបានប្រហែល៨គីឡូ ហើយកំពុងតែស្រោចស្រប់ទៅលើផ្ទៃដីប្រមាណជាង ១.០០០ ហិកតា ។ ប្រជាពរដ្ឋទទួលផលមាន ៥០០ គ្រួសារ ។ ពេល លោក ក ជាប់ឃុំក្បាលម៉ាស៊ីនដឹកនាំការងារនេះបានស្ទះដោយសារគ្មានអ្នកដឹកនាំ ហើយគម្រោងមួយទៀតដែលលោក ក កំពុងធ្វើនោះគឺចាក់ដីបំពេញផ្សារ ត្រូវការលោក ក ដើម្បីដឹកនាំ ព្រោះគម្រោងនេះលោក ក ជាអ្នកធ្វើ ព្រមទាំងបានផ្ដល់ផលប្រយោជន៍ច្រើនដល់ពលរដ្ឋ ។ ដូចនេះ ខ្លួនស្នើសុំឱ្យតុលាការមេត្តាឱ្យលោក [redacted] នៅក្រៅឃុំដើម្បីអនុវត្តគម្រោងនេះបន្ត ។

-សាក្សីឈ្មោះ ខ្ញ បានឆ្លើយថា៖ ខ្លួនជាប្រធានក្រុមប្រឹក្សាស្រុកពាមជរ ។ លោក ក ជាប្រធានការងារឃុំកំពុងប្រាសាទ និងជាប្រធានក្រុមការងារឃុំក្រាំងត្រយ៉ូង ដែលមានប្រជាជនជាងមួយម៉ឺននាក់ដែលមានជាង ១៣ ភូមិ ហើយឈ្មោះ ក នេះបានជួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានច្រើនណាស់ដើម្បីជាប្រយោជន៍ដល់ពលរដ្ឋ ។ តែឥឡូវនេះពេលដែលលោក ក ត្រូវឃុំខ្លួន គម្រោងទាំងអស់បែរជាស្ទះទាំងអស់ ។ ខ្លួនគ្រាន់សំណូមពរឱ្យតុលាការអនុញ្ញាតឱ្យគាត់នៅក្រៅឃុំ ដើម្បីឱ្យគាត់ទៅជួយធ្វើគម្រោងនានារបស់គាត់ឱ្យបានចប់អស់ដើម្បីជាប្រយោជន៍ដល់ពលរដ្ឋនៅស្រុកពាមជរនោះ ។

**សេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី**

ក្រោយពីបានសួរដេញដោលនាពេលសវនាការ ឃើញថានៅក្នុងរឿងក្តីនេះកន្លងមកយើងឃើញថា លោក ក ពិតជាចេតនាទុច្ចរិតក្នុងការឆបោកកូនក្តីរបស់ខ្លួនពិតប្រាកដមែន ព្រោះក្រុមហ៊ុនគាត់មិនមែនជាក្រុមហ៊ុនផ្តោតសំខាន់ទៅលើការសិក្សាគម្រោងធ្វើផ្លូវអ្វីនោះទេ គាត់គ្មានគ្រឿងចក្រ និងឧបករណ៍សម្រាប់ធ្វើការសាងសងទៅលើគម្រោងធ្វើការសាងសង់ផ្លូវអ្វីនោះទេ ។ តាមពិតទៅក្រុមហ៊ុនគាត់ផ្តោតសំខាន់តែទៅលើវិស័យកសិកម្ម ក៏ប៉ុន្តែគាត់បែរជាទៅស្នើសុំធ្វើគម្រោងវិនិយោគសាងសង់ផ្លូវដែរប្រាសចាកពីទិសដៅរបស់ក្រុមហ៊ុនគាត់ ។ ទីពីរ ក្រុមហ៊ុនរបស់គាត់គ្មានទេឧបករណ៍សាងសង់ដូចជាគ្រឿងចក្រអាបុល ឬវិស្វករអីទេ គឺអត់ទាំងអស់ ប៉ុន្តែគាត់បែរជាទៅស្នើសុំវិនិយោគពីរាជរដ្ឋាភិបាល ។ ទី៣ ចំណាររបស់សម្តេចចារថា មិនអនុញ្ញាតឱ្យក្រុមហ៊ុនគាត់សាងសង់តាំងពីឆ្នាំ២០១០ ហើយ២០១១ ទើបគេចេញលិខិតថាមិនអនុញ្ញាតឱ្យទេ ប៉ុន្តែឆ្នាំ២០១៣ គាត់បែរជាទៅដើរយកលុយពីគេរហូតជាង ១០ នាក់ ។ ខាងនគរបាលព្រហ្មទណ្ឌបានស្នើសុំទៅរាជរដ្ឋភិបាលថា តើបានអនុញ្ញាតគម្រោងឱ្យគាត់ឬអត់? គេថាអត់បានឱ្យគម្រោងនោះទេ ។ ផ្អែកលើលិខិតនានាបង្ហាញថា គាត់បានយកបប្រាក់ពីគេគ្រប់គ្នា ទាំងដែលគាត់គ្មានសិទ្ធិលើគម្រោងនេះ ។ ពេលកូនក្តីខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសួរ គាត់ក៏បានចេញលិខិតជូនដំណឹងឱ្យមកកូនក្តីខ្លួន ។ ក្នុងលិខិតនោះគាតសន្យា ឱ្យ ៥០ លានដុល្លារ នៅពេលដែលក្រុមហ៊ុនវិនិយោគជោគជ័យ ។ លិខិតនេះគាត់ធ្វើ ដើម្បីឱ្យលោក ណា ស្ងប់អារម្មណ៍ ព្រោះគាត់បានអាងទៅលើគម្រោងនោះមានទំហំទឹកប្រាក់ ៧០ លានដុល្លារទាំងដែលគាត់គ្មានលុយសម្រាប់អនុវត្តគម្រោងផង ។ ចំពោះឯកសារវិញគាត់ជាអ្នកធ្វើបែរជាចោទថា លោក ណា ជាអ្នកចេញ ។ អម្បាញ់មិញគាត់ថែមទាំងចោទថា កុងត្រានេះខ្លួន [redacted] ជាអ្នកធ្វើ ខ្លួន [redacted] ទើបចេញធ្វើមេធាវីឆ្នាំ២០១៦ ចំណែកឯកសារគាត់ធ្វើតាំងពីឆ្នាំ២០១៣ ។ ស្ថានភាពទាំងអស់នេះបង្ហាញពីចេតនាទុច្ចរិតរបស់គាត់ ។ បញ្ហាសំខាន់មួយទៀតពាក់ព័ន្ធនឹងការអនុវត្តគម្រោងផ្លូវជាតិលេខ៥ ចាស់ និងថ្មី ចំពោះបញ្ហានេះផ្លូវជាតិលេខ៥មានតែមួយទេ ពីភ្នំពេញទៅប៉ោយប៉ែត គាត់បែរជាថា មានចាស់មានថ្មី ។ តើមានចាស់មានថ្មីមកពីណា? ទើបខ្លួនស្ទបែងចែកជាគីឡូនូវអ្វីដែលគាត់លើកឃើញថា បូកសរុបទៅជិត ៥០០ គីឡូ តែធាតុពិតផ្លូវជាតិលេខ៥ មានប្រវែងតែ ៤០០ គីឡូជាងប៉ុណ្ណោះ ។ គាត់ថា គម្រោងផ្លូវជាតិលេខ៥ គាត់នៅតែមានទៀត តើមានមកពីណា? បើគម្រោងសាងសង់ផ្លូវជាតិលេខ ៥ នេះ គេសាងសង់ជិតចប់ហើយ ។ សរុបមកភស្តុតាងទាំងអស់នេះបង្ហាញយ៉ាងច្បាស់អំពីចេតនាទុច្ចរិតរបស់ជនជាប់ចោទក្នុងការឆបោកពិតប្រាកដមែន ។ ហើយខ្លួនសូមបញ្ជាក់ទៅលើសាក្សីទាំងពីរនេះពួកគាត់ពុំមានទាក់ទងអ្វីជាមួយរឿងនេះទេ ។ ខ្លួនទទួលស្គាល់ថាជនជាប់ចោទបានសាងសង់ប្រឡាយទឹកនៅមូលដ្ឋាន ប៉ុន្តែសុទ្ធជាប្រាក់ដែលគាត់យកពីគេ និងឆបោកគេ ហើយខ្លួនបានស្រាវជ្រាវច្បាស់ណាស់ ។ ជាចុងក្រោយខ្លួនសូមឱ្យតុលាការផ្តន្ទាទោស និងសម្រេចឱ្យសងកូនក្តីខ្លួនចំនួន ១៣ ម៉ឺនដុល្លារ ព្រោះគាត់បានសងចំនួនពីរម៉ឺនដុល្លាររួចហើយ ។

**សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ**

ក្រោយពីបានសួរដេញដោលនាពេលសវនាការ ក្រោយពីបានស្តាប់អំណានចម្លើយ ស្តាប់ចម្លើយសមត្ថកិច្ច ស្តាប់ចម្លើយរបស់ជនជាប់ចោទ មានភាពស៊ីសង្វាក់ជាមួយវត្ថុតាង បង្ហាញថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់ពិតមែន ។ ដូចនេះតំណាងអយ្យការសុំតម្កល់សេចក្តីចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសុំតុលាការសម្រេចតាមច្បាប់ ។

**សេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

ក្រោយពីបានសួរដេញដោលនាពេលសវនាការ ឃើញថា ជាបឋមខ្លួនជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ ក. ពាក់ព័ន្ធនឹងបទល្មើសឆបោកនេះ គឺកូនក្តីរបស់ខ្លួនត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះតាមលិខិតបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៥៦២ ចុះថ្ងៃទី២៨ ខែ មេសា ឆ្នាំ២០២០ អ្វីដែលជាអង្គហេតុនៃការចោទប្រកាន់នៅក្នុងដីកាបង្ហាញថា កូនក្តីរបស់ខ្លួនបានប្រើប្រាស់នូវឧបាយកលទុច្ចរិតក្នុងការឆបោក ដើម្បីបោកប្រាក់យកពីដើមបណ្តឹងយកមកប្រើប្រាស់ តាមការចោទប្រកាន់នេះជាការចោទប្រកាន់មួយដែលមិនត្រឹមត្រូវ និងបំពានដោយអយុត្តិធម៌ ព្រោះរឿងនេះវាជាវិវាទរដ្ឋប្បវេណីសុទ្ធសាធដែលទាក់ទងទៅនឹងការមិនអនុវត្តកាតព្វកិច្ច ។ខ្លួនសូមលើកឡើងបីចំណុចដូចជា៖ ទីមួយមានការចុះកិច្ចព្រមព្រៀង និងការទទួលប្រាក់ ។ ទីពីរការព្រមព្រៀងរបស់គូភាគីជាឆន្ទៈដែលមានក្នុងកិច្ចព្រមព្រៀងនេះឯង ទីបីការចុះកិច្ចព្រមព្រៀង លោក ក. ជាការអនុវត្តកាតព្វកិច្ចរវាងគូភាគី ។ បើយើងមើលទៅលើកិច្ចព្រមព្រៀងដំបូងគឺលោក ខ បានដឹងថាក្រុមហ៊ុនកូនក្តីខ្លួនមានសិទ្ធិសាងសង់ទៅលើគម្រោងនេះ ហើយឈ្មោះ ខ ជាអ្នករៀបចំឯកសារទាំងអស់ ។ ខ្លឹមសារដែលបានចុះកិច្ចព្រមព្រៀងនេះ គឺកូនក្តីខ្លួនបានទទួលប្រាក់ពី លោក ខ ចំនួន ៣ ដង ។ លើកទី១ ថា ឱ្យ ១០ម៉ឺន តែជាក់ស្តែងបានតែ ៨ ម៉ឺនតែប៉ុណ្ណោះ ដូចអ្វីដែលយើងបានឃើញនៅក្នុងឯកសារសំណុំរឿងដែលមានលិខិតជាភាសាអង់គ្លេសចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៣ ។ លើកទី២ បានតែ១ម៉ឺនដុល្លារប៉ុណ្ណោះ និងលើកទី៣ បានត្រឹមតែ ៦ម៉ឺនដុល្លារប៉ុណ្ណោះ ។ បញ្ហាទាំងអស់នេះយើងឃើញថា នៅក្នុងកិច្ចព្រមព្រៀងចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៣ មិនមែនជាឯកសារធម្មតានោះទេ វាជាកិច្ចព្រមព្រៀងមួយដែលមានការព្រមព្រៀងគ្នាជាក់លាក់ ហើយកូនក្តីខ្លួនក៏បានកិបនូវឯកសារឧបសម្ព័ន្ធឱ្យដើមបណ្តឹងពិនិត្យផងដែរ ។ គម្រោងនេះក៏លោក ក បានបន្តរហូតមិនបានបញ្ឈប់នោះឡើយ ។ កូនក្តីខ្លួនក៏បានព្រមព្រៀងជាមួយគាត់ដែរថា នៅពេលដែលកូនក្តីអនុវត្តគម្រោងទទួលបានជោគជ័យនឹងផ្តល់ជូនដូចមានចែងនៅក្នុងកិច្ចសន្យានោះ ។ បើសិនពិនិត្យមើលទៅលើកិច្ចព្រមព្រៀងនេះទៀត យើងពិនិត្យឃើញថា នៅក្នុងនេះលិខិតលេខ [redacted] ដែលបានឆ្លើយឆ្លងជាមួយខុទ្ទកាល័យរបស់សម្តេច ហើយមានលិខិតមួយទៀតលេខ [redacted] ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤ ចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍ជនបទ ចំពោះលិខិតមួយទៀតលេខ ៥៩៩ ដែលជូនទៅរដ្ឋមន្ត្រីពិនិត្យ ។ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ក្រសួងសាធារណការនិងដឹកជញ្ជូនបានចេញលិខិតជូនដំណឹងមកឱ្យកូនក្តីខ្លួនគឺលេខ [redacted] ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ដែលមានខ្លឹមសារ ជាកម្មវត្ថុករណីសំណើសុំគោលការណ៍សាងសង់គម្រោងផ្លូវ BOT ពីព្រែកក្តាមទៅប៉ោយប៉ែត ។ នៅឆ្នាំ២០១៥ ក្រុមប្រឹក្សាអភិវឌ្ឍន៍ក៏បានចេញលិខិតឆ្លើយឆ្លងគាំទ្រគម្រោងវិនិយោគរបស់ក្រុមហ៊ុនកូនក្តីខ្លួន ។ ឈ្មោះ ខ ក៏បានដឹងច្បាស់ផងដែរអំពីដំណើរការលើគម្រោងនេះ ហើយឈ្មោះ ខ ក៏បានរកដៃគូវិនិយោគផងដែរ ដោយសារគាត់ឃើញនូវចំនួនលុយដែលចំណេញ និងគាត់បានទុកចិត្តទៅលើក្រុមហ៊ុនកូនក្តីខ្លួនទើបគាត់ចូលរួម ។ ក្រោយមក គាត់បែរជាយកគម្រោងទៅទុកចោលរយៈពេល២ឆ្នាំ ទើបយកមកឱ្យកូនក្តីខ្លួនវិញថា ធ្វើមិនកើតទេ ហើយដាក់ពាក្យបណ្តឹង និងទម្លាក់កំហុសមកលើកូនក្តីខ្លួនទៅវិញ ។ មួយវិញទៀត ចេតនាកូនក្តីខ្លួនក៏មិនចង់បានលុយរបស់លោក ខ នោះដែរ ហើយគាត់ក៏បានសន្យាសងទៅលោក ខ ឱ្យចប់អស់ដែរ ។ ដូច្នេះការចោទប្រកាន់នានាកន្លងមកសុទ្ធតែមានការមិនច្បាស់លាស់ទាំងអស់ ហើយតាមមាត្រា ៣៨ និង ៣៥១ បានចែងថា វិមតិសង្ស័យត្រូវបានជាផលប្រយោជន៍ដល់កូនក្តីខ្លួន មួយទៀតធាតុផ្សំដែលចោទប្រកាន់មកលើកូនក្តីរបស់ខ្លួនអត់មាន ។ ដូច្នេះគាត់គ្មានចេតនាឆបោក នោះទេ ដូចមាននៅក្នុងឯកសារកិច្ចព្រមព្រៀងដែលមាននៅក្នុងសំណុំរឿង ។ សរុបមកខ្លួនស្នើសុំលោកចៅក្រម និងលោកស្រីតំណាងអយ្យការមេត្តាធ្វើការពិចារណាឱ្យកូនក្តីរបស់ខ្លួនបាននៅក្រៅឃុំភ្លាមៗ ។ ម្យ៉ាងទៀតផ្អែក

តាមការសន្និដ្ឋានលើអង្គសេចក្តីសូមលោកចៅក្រម និងលោកស្រីតំណាងអយ្យការ លើកលែងកូនក្តីខ្លួនឈរលើមូលដ្ឋានវិមតិសង្ស័យ និងគ្មានធាតុផ្សំនៃបទល្មើស និងអនុញ្ញាតឲ្យកូនក្តីរបស់ខ្លួននៅក្រៅឃុំព្រោះរឿងនេះវាជាររដ្ឋប្បវេណីសុទ្ធសាធ ។

-សំដីចុងក្រោយរបស់ជនជាប់ចោទ៖ សំណូមពរតុលាការមេត្តាអនុញ្ញាតិខ្លួនបាននៅក្រៅឃុំ ហើយខ្លួនសន្យាថានឹងសងប្រាក់ទៅដើមបណ្តឹងរដ្ឋប្បវេណីឲ្យអស់ ។ ម្យ៉ាងទៀត ខ្លួនក៏មានជំងឺប្រចាំកាយ និងត្រូវចុះទៅធ្វើការងារច្រើនទៀតដូចជាចុះជួយមូលដ្ឋានជាដើម ។

ក្រោយពីសួរដេញដោលក្នុងអង្គសវនាការ

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាងនិងពិចារណាលើសំណុំរឿងត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ [redacted] ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនជនជាប់ចោទ ឈ្មោះ ក ទៅជំនុំជម្រះ ពីបទឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៣ និងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

-តាមកិច្ចព្រមព្រៀង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៣ បង្ហាញថា ជនជាប់ចោទឈ្មោះ ក ពិតជាបានចុះកិច្ចព្រមព្រៀងជាមួយភាគីដើមបណ្តឹងរដ្ឋប្បវេណី លើគម្រោងផ្លូវជាតិលេខ៥ ចម្ងាយ ១៥៥.៤៥០ គីឡូម៉ែត្រ ទទឹង ៣០ ម៉ែត្រ ចាប់ពីខេត្តបាត់ដំបងដល់ទីក្រុងប៉ោយប៉ែតព្រំដែនកម្ពុជា-ថៃ ពិតមែន ។

-តាមកិច្ចព្រមព្រៀង ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ បង្ហាញថា ជនជាប់ចោទឈ្មោះ ក ពិតជាបានចុះកិច្ចព្រមព្រៀងជាមួយភាគីដើមបណ្តឹងរដ្ឋប្បវេណី លើគម្រោងផ្លូវជាតិលេខ៥ គិតចាប់ពីព្រែកក្តាម រហូតដល់បាត់ដំបង ពិតមែន ។

-ជនជាប់ចោទបានទទួលស្គាល់ថា ជនជាប់ចោទបានទទួលប្រាក់ពីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៥០.០០០ (មួយរយហាសិបពាន់) ដុល្លារអាមេរិក នៅក្នុងអង្គហេតុនេះ ។ ប៉ុន្តែជនជាប់ចោទបានលើកឡើងថា កន្លងមក ជនជាប់ចោទបានសងទៅដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣០.០០០ (សាមសិបពាន់) ដុល្លារអាមេរិក រួចហើយ ។

-តាមលិខិតលេខ [redacted] ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឃើញថា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាពិតជាបានបដិសេធសំណើសុំគោលការណ៍វិនិយោគរបស់ ក្រុមហ៊ុន ក លើគម្រោងពង្រីកជួសជុល និងថែទាំផ្លូវជាតិលេខ៥ តាមរូបភាព BOT តាំងពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ មែន ។

-តាមពាក្យបណ្តឹង ចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងដែលមានក្នុងសំណុំរឿងមានភាពស៊ីសង្វាក់ក្នុងការបញ្ជាក់ថា កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៣ និងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ នៅចំណុចរាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ ក ពិតជាបានអះអាងដោយវំលោភលើឋានៈ

ពិតប្រាកដ ដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណីយល់ព្រមចុះកិច្ចព្រមព្រៀង និងប្រគល់ប្រាក់ជាបន្តបន្ទាប់ទៅជនជាប់ចោទ ។ តាមរយៈអំពើនេះ ជនជាប់ចោទពិតជាបានបង្កការខូចខាតនូវផលប្រយោជន៍ជាប្រាក់ចំពោះដើមបណ្តឹងរដ្ឋប្បវេណីមែន ។

-តាមមាត្រា ៣៧៧ នៃក្រមព្រហ្មទណ្ឌ អំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬគតិយជននូវការប្រគល់មូលនិធិតម្លៃ ទ្រព្យសម្បត្តិអ្វីមួយ ការផ្តត់ផ្គង់សេវា និងការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឡូចពីកាតព្វកិច្ច គឺជាបទល្មើស឵ឆបោក ។

-អំពើរបស់ឈ្មោះ ក ដែលបានអះអាងដោយរំលោភលើឋានៈពិតប្រាកដ ហើយតាមរយៈនូវអំពើនេះ ជនជាប់ចោទបានទទួលនូវការប្រគល់ប្រាក់ជាបន្តបន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណី ហើយបានបណ្តាលឱ្យដើមបណ្តឹងរដ្ឋប្បវេណីខូចខាតនូវផលប្រយោជន៍ជាបទល្មើស ឆបោក ។

-ជនត្រូវចោទជានីតិជន នាពេលប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពដែលអាចយល់ដឹងអំពីលទ្ធផលតាមផ្លូវច្បាប់ចំពោះអំពើរបស់ខ្លួនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ។

-មានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទ ឈ្មោះ ក ពីបទ ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៣ និងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការមានភាពសមហេតុផលគប្បីតុលាការលើកយកមកពិចារណា ។

-ជនជាប់ចោទជាបុគ្គលដែលបានចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍន៍សហគមន៍ ដោយទទួលបាននូវការគោរព និងស្រលាញ់ពីសំណាក់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ។ ជនជាប់ចោទទើបនឹងប្រព្រឹត្តបទល្មើសជាលើកដំបូង និងមា នឆន្ទៈទូទាត់សងទៅភាគីដើមបណ្តឹងរដ្ឋប្បវេណីនូវទឹកប្រាក់ដែលខ្លួនបានទទួល ។ ហេតុដូចនេះ តុលាការ យល់ឃើញថា គប្បីផ្តល់ស្ថានសម្រាលដល់ជនជាប់ចោទ ។

-ដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារប្រាក់ដែលបានបង់ចំនួន ១៣០.០០០ (មួយរយសាមសិបពាន់) ដុល្លារអាមេរិក និងទាមទារសំណងជំងឺចិត្តចំនួន ១០០.០០០ (មួយរយពាន់) ដុល្លារអាមេរិក ។ ជនជាប់ចោទបានទទួលស្គាល់ទឹកប្រាក់ចំនួន ១៥០.០០០ (មួយរយហាសិបពាន់) ដុល្លារអាមេរិក និងបានបញ្ជាក់ថា ជនជាប់ចោទបានសងទៅដើមបណ្តឹងរដ្ឋប្បវេណីដល់ទៅចំនួន ៣០.០០០ (សាមសិបពាន់) ដុល្លារអាមេរិក ដោយពុំមានភស្តុតាងបញ្ជាក់អំពីការសង ។ ហេតុនេះ គប្បីតុលាការសម្រេចអំពីសំណងទៅ លើប្រាក់ដែលបានបាត់បង់តាមភស្តុតាងដែលមានជាក់ស្តែង និងអំពីសំណងជំងឺចិត្តតាមស្ថានភាពជាក់ស្តែង ។

**<u>ហេតុដូច្នេះទីនិច្ឆ័យសេចក្តី</u>**

✓ ១-ផ្តន្ទាទោស ឈ្មោះ ក ភេទប្រុស អាយុ ៤៧ ឆ្នាំ ដែលមានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារកំណត់ ១ (មួយ) ឆ្នាំ តែទោសនេះត្រូវព្យួរទាំងស្រុង តាមបញ្ញត្តិស្តីពីការព្យួរទោសធម្មតានៃក្រមព្រហ្មទណ្ឌ ពីបទឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៣ និងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យ ឈ្មោះ ក សងប្រាក់ដែលបាត់បង់ចំនួន ១៣០.០០០ (មួយរយសាមសិបពាន់) ដុល្លារអាមេរិក និងជំងឺចិត្តចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ទៅដើមបណ្តឹងរដ្ឋប្បវេណី ច្រានចោលការទាមទារ

លើសពីនេះ ។

សាលក្រមនេះជំនុំជម្រះពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ ក និង ប្រកាសជាសាធារណៈនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ទុកសិទ្ធប្ដឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រាក្រឡាបញ្ជី [redacted] | ហត្ថលេខា និងត្រាចៅក្រម [redacted] |

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃ សុក្រ ១១ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃ សុក្រ ១១ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០

**ចៅក្រមជំនុំជម្រះ**

[redacted]

**ឧបសម្ព័ន្ធទី ៩**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ: [redacted]

ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២

សំណុំរឿងព្រហ្មទណ្ឌ

លេខ: [redacted]

ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

សំណុំរឿងស៊ើបសួរ

លេខ: [redacted]

ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១

សំណុំរឿងជំនុំជម្រះ

លេខ: [redacted]

ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២

**នាមនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនា ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២

វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក នាសាលសវនាការទី៤ ជាន់ទី១

ដោយមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨៨ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖**

១-ឈ្មោះ *ក* ហៅ *ក* ភេទប្រុស អាយុ ៣៨ឆ្នាំ (កើតថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៨៣) ជនជាតិខ្មែរ មុខរបរ បុគ្គលិកក្រុមហ៊ុនឯកជន កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៣៥២៨៩៧ (០១) ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ទីកន្លែងកំណើតនៅសង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ អាសយដ្ឋានមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ បេ៦ ផ្លូវបេតុង សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ *ង* មានកូនចំនួន ០២នាក់ ឪពុកឈ្មោះ *ច* "រស់" ម្តាយឈ្មោះ *ឆ* "ស្លាប់" ជានីតិជន ទោសពីមុនគ្មាន ។ (ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ [redacted] ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១) (ម១)

២-ឈ្មោះ *ខ* ភេទប្រុស អាយុ ២៩ឆ្នាំ (កើតថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៩២) ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០៦១៤៩១៣៧១ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ ទីកន្លែងកំណើតឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅផ្ទះលេខ២៧V ភូមិដំណាក់ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។ (ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ [redacted] ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២២) (PJ)

៣-ឈ្មោះ *គ* ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ នៅផ្ទះ ទីកន្លែងកំណើតនៅសង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅផ្ទះលេខ A១៤៩៩ ផ្លូវបេតុង ភូមិដំណាក់ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ *ល* ; មានកូនចំនួន ០៣នាក់ ឪពុកឈ្មោះ *ឋ* "ស្លាប់" ម្តាយឈ្មោះ *ល* ; "ស្លាប់" ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ **ស៊ីសំណូកនៃនិយោជិត និងរំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌ មានចែងនិងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧៨ ,មាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ។

**មេធាវីការពារសិទ្ធិជនជាប់ចោទ** លោក [redacted] អត្តលេខ [redacted] មានការិយាល័យមេធាវី ទីតិរង្ស មាន

អាសយដ្ឋានស្ថិតនៅផ្ទះលេខ ១០-B2 $E_0E_1$ ផ្លូវលេខ ២១១ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ក ។

-ដើមបណ្តឹងរដ្ឋប្បវេណី ក្រុមហ៊ុន DAC

តំណាងដោយលោក ឃ ។

-ដើមបណ្តឹងរដ្ឋប្បវេណី ក្រុមហ៊ុន HDC

តំណាងដោយលោកស្រី ង ។

មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី លោក [redacted] អត្តលេខ [redacted] មានការិយាល័យក្រុមមេធាវី នីតិ មានអាសយដ្ឋានស្ថិតនៅអាគារ K Space ជាន់ទី៨ លេខ២០ ផ្លូវលេខ២៨៩ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**អង្គហេតុនៃរឿងមានដូចតទៅ**

ក្រុមហ៊ុន DAC និង ក្រុមហ៊ុន HDC ជាក្រុមហ៊ុនដែលនាំចូលរថយន្តពីប្រទេសកូរ៉េមកចែកចាយនៅប្រទេសកម្ពុជាដែលមានការចុះបញ្ជីត្រឹមត្រូវតាមច្បាប់ ។ កាលពីអំឡុងឆ្នាំ២០១៨ រហូតមកដល់ឆ្នាំ២០២០ ដំណើរការអាជីវកម្ម ក្រុមហ៊ុន DAC និង ក្រុមហ៊ុន HDCចេះតែខាតមិនទទួលបានប្រាក់ចំណេញ ដោយមានការសង្ស័យឈ្មោះ ឃ ជាប្រធាន ក្រុមហ៊ុន DAC និងលោកស្រី ង ជាប្រធាន ក្រុមហ៊ុន HDC បានធ្វើការស្រាវជ្រាវរកឃើញថា ក្រោមការគ្រប់គ្រងរបស់ឈ្មោះ ខ និងឈ្មោះ ក ជាប្រធានផ្នែកលក់ និងឈ្មោះ គ ជាអ្នកគ្រប់គ្រងទូទៅបានសហការគ្នាទៅតាមតួនាទីនិងភារកិច្ចរបស់ខ្លួនបានលក់រថយន្តចំនួន ១.៥០០ (មួយពាន់ប្រាំរយ) គ្រឿង ឱ្យទៅអតិថិជនខុសពីតម្លៃដែលក្រុមហ៊ុនកំណត់ និងបានទទួលប្រាក់ពីអតិថិជនខុសពីគោលការណ៍របស់ក្រុមហ៊ុនចំនួន ២៧០.០០០ (ពីរសែនប្រាំពីរម៉ឺន) ដុល្លារអាមេរិក ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២៥៧ អ.យ.ផ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ ។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៣៥០ "ប" ផ.ផ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ ។

**នាពេលសវនាការ**

-តាមចម្លើយជនជាប់ចោទឈ្មោះ ក បានឆ្លើយនៅដំណាក់កាលអយ្យការថា៖ នៅក្នុងអំឡុងខែកញ្ញា ឆ្នាំ២០១៥ ខ្លួនបានចូលបម្រើការងារនៅ ក្រុមហ៊ុន DAC មានតួនាទីជាប្រធានផ្នែកលក់បានប្រាក់ខែ ៦៥០ (ប្រាំមួយរយហាសិប) ដុល្លារអាមេរិក ក្នុងមួយខែ ។ ដំបូងខ្លួននៅផ្នែកលក់ម៉ូតូ បីឆ្នាំក្រោយមកគឺនៅឆ្នាំ២០១៨ ក្រុមហ៊ុនបានប្តូរខ្លួនឱ្យមកជាប្រធានផ្នែកលក់រថយន្តវិញ ដោយនៅទីនោះមានគ្នាចំនួន ០៣នាក់គឺឈ្មោះ ខ ឈ្មោះ គ និងរូបខ្លួន ។ ក្រុមហ៊ុនបានកំណត់តម្លៃរថយន្តនីមួយៗសម្រាប់ការលក់ជាស្រេចដោយរូបខ្លួនចាំតែលក់តែប៉ុណ្ណោះ តែបើមានអតិថិជនតថ្លៃ ពួកខ្លួនបានត្រឹមតែយកសំណូមពររបស់អតិថិជនទៅរាយការណ៍ជូនជនជាតិកូរ៉េដែលជាប្រធានរបស់ពួកខ្លួន សម្រាប់ពួកខ្លួនមិនមានសិទ្ធិកំណត់តម្លៃលក់អ្វីទាំងអស់ ។ ប្រសិនបើមានរថយន្តមកដល់ថ្មីៗ ពួកខ្លួនពិនិត្យទៅឃើញថា មានរថយន្តណាស្អាតល្អ ខ្លួនជូនដំណឹងទៅអតិថិជនឱ្យមកមើល បើអតិថិជនណាមកមើលហើយពេញចិត្តទិញយករថយន្តនោះបានជាទឹកចិត្តអតិថិជនច្រើនឱ្យលុយទឹកតែមកពួកខ្លួនចាយមិនមែនជាលុយស៊ីសំណូកក្រោមតុអីទេ ។ មកដល់ខែមិថុនា ឆ្នាំ២០២០ ខ្លួនបានដាក់ពាក្យសុំឈប់ការងារពីក្រុមហ៊ុនដោយមូលហេតុក្រុមហ៊ុនបញ្ជូនខ្លួនទៅបំពេញការងារនៅអង្គស្នួល ក្រុមហ៊ុនក៏បានអនុញ្ញាតឱ្យឈប់បម្រើតាមការស្នើសុំ ។ ពាក់ព័ន្ធអង្គហេតុដែលក្រុមហ៊ុនចោទ ថាខ្លួនបានក៏បកេង ឆបោក និងទទួលយកលុយសំណូកពីអតិថិជន ខ្លួនសូម

បដិសេធ ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេហើយក្នុងពេលដែលខ្លួននៅបម្រើការងារនៅក្រុមហ៊ុន ក៏ក្រុមហ៊ុនមិនដែលប្ដឹងខ្លួន និងឈ្មោះ ខ ដែរគឺនៅសល់តែឈ្មោះ ក ទេ ។ ក្រោយមកឈ្មោះ ខ ទៅទិញរថយន្តនៅក្រុមហ៊ុនក៏មានបញ្ហាទំនាស់គ្នាជាមួយឈ្មោះ ក ហើយឈ្មោះ ខ បានបង្ហោះសារក្នុងគ្រុបខ្លួនទាំងបីនាក់ដែលបាននិយាយគ្នាក្នុងអំឡុងពេលនៅបំរើការងារចូលទៅក្នុងគ្រុបក្រុមហ៊ុនកូរ៉េ ក៏ត្រូវបានជនជាតិកូរ៉េខឹងប្ដឹងដោយទាំងរូបខ្លួនតែម្ដង កន្លងមកជនជាតិកូរ៉េជាប្រធានធ្លាប់បានណែនាំថា កុំឱ្យពួកខ្លួនទទួលលុយពីអតិថិជនក្រៅផ្លូវការ ហើយពួកខ្លួនក៏ឈប់ទទួលដែរ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ក បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្លួនបានដឹងពីបទចោទប្រកាន់មកលើខ្លួន គឺបទ ស៊ីសំណូកនៃនិយោជិត និងរំលោភលើទំនុកចិត្ត ចំពោះការចោទប្រកាន់នេះគឺខ្លួនសុំបដិសេធចោលទាំងស្រុង ។ ចំពោះចម្លើយដែលខ្លួនបានឆ្លើយនៅអយ្យការចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ គឺខ្លួនសូមរក្សាទុកទាំងស្រុង ដោយពុំមានកែប្រែទេ ។ ខ្លួនបានចូលបម្រើការងារនៅក្នុង ក្រុមហ៊ុន ១AC កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៥ មានតួនាទីជាអាយធី និងជាប្រធានផ្នែកលក់ម៉ូតូតាមបណ្ដាខេត្តនានា បានទទួលប្រាក់ខែចំនួន ៦៥០ (ប្រាំមួយរយហាសិប) ដុល្លារអាមេរិក ។ រហូតដល់ឆ្នាំ២០១៨ ក្រុមហ៊ុនបានប្ដូរខ្លួនឱ្យមកជាប្រធានផ្នែកលក់រថយន្តវិញដោយមានគ្នាបីនាក់គឺឈ្មោះ ខ ឈ្មោះ ក និងរូបខ្លួន ។ រាល់តម្លៃរថយន្តនីមួយៗខ្លួនពុំមានសិទ្ធិកំណត់ទេ គឺខាងក្រុមហ៊ុនជាអ្នកកំណត់តម្លៃមកឱ្យខ្លួនលក់ គឺខាងខ្លួនទាំងបីនាក់ចាំតែទទួលលុយប៉ុណ្ណោះ ប្រសិនបើខាងអតិថិជនតថ្លៃ ពួកខ្លួនបានត្រឹមតែយកសំណូមពររបស់អតិថិជនទៅរាយការណ៍ជូនជនជាតិកូរ៉េ ដែលជាប្រធានរបស់ពួកខ្លួនដើម្បីពិចារណា ។ រាល់ពេលដែលខ្លួនទាំងបីនាក់លក់រថយន្តទៅឱ្យអតិថិជនម្ដងៗ គឺខាងអតិថិជនក៏បានឱ្យលុយទឹកតែ (ទឹកចិត្តរបស់អ្នកទិញ) មកឱ្យខ្លួនទាំងបីនាក់ចាយដែរ ហើយក្រុមហ៊ុនក៏បានដឹងដែរគឺគាត់មិនជំទាស់រាល់ការឱ្យរបស់អតិថិជនមកពួកខ្លួនដែរ ។ រាល់ពេលដែលអតិថិជនទិញរថយន្តពីក្រុមហ៊ុនម្ដងៗពីរទៅបីគ្រឿង គឺខាងអតិថិជនបានឱ្យថ្លៃទឹកតែសរុបជូន ១៥០ ដុល្លារអាមេរិក ទៅ ២០០ ដុល្លារអាមេរិក តាមទឹកចិត្តរបស់អតិថិជន ហើយខាងក្រុមហ៊ុនក៏បានដឹងដែរប៉ុន្តែគាត់ក៏មិនដែលជំទាស់អ្វីដែរ ព្រោះវាជាទឹកចិត្តរបស់អតិថិជន ។ ខ្លួនសំណូមពរសុំតុលាការជួយរកយុត្តិធម៌ដល់ខ្លួនផង ព្រោះខ្លួនពុំបានកិបកេងលុយរបស់ក្រុមហ៊ុនទេ ម្យ៉ាងទៀតខ្លួនគឺជាមេគ្រួសារមានកូនតូចៗក្នុងបន្ទុកដែលត្រូវរកស៊ីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ។

-ជនជាប់ចោទឈ្មោះ ក បានឆ្លើយថា៖ ខ្លួនសូមបដិសេធបទចោទប្រកាន់ទាំងស្រុងរបស់ភាគីក្រុមហ៊ុនមកលើខ្លួន ។ ខ្លួនចូលបំរើការងារនៅក្នុងក្រុមហ៊ុននេះ តាំងពីអំឡុងខែកញ្ញា ឆ្នាំ២០១៥ នៅផ្នែកព័ត៌មានវិទ្យា បន្ទាប់មកនៅឆ្នាំ២០១៨ ក្រុមហ៊ុនក៏បានផ្ទេរខ្លួនអោយធ្វើការផ្នែកលក់ឡានមួយទឹកជាមួយឈ្មោះ ក ដែលចូលធ្វើការមុនខ្លួន ។ ក្នុងការបំពេញការងារនៅផ្នែកលក់ ដោយការឃើញពីការលំបាកគ្នាទៅវិញទៅមក (បើរសោរទៅចាក់អោយអតិថិជនមើលឡាន និងជួយរើសឡានអោយអតិថិជន) ពួកខ្លួនក៏ចែករំលែកប្រាក់ដែលអតិថិជនអោយជាមួយគ្នា នៅពេលអតិថិជនអោយលុយតឹបមកពួកខ្លួន ពួកខ្លួនមិនបានគំរាមកំហែងទារប្រាក់ពីអតិថិជននោះទេ ។ ចំពោះការចោទប្រកាន់ក្រុមហ៊ុនថា ពួកខ្លួនបានធ្វើឱ្យក្រុមហ៊ុនបានខាតបង់ប្រាក់រឿងនេះគឺមិនពិតទេ ហើយក៏មិនទាក់ទងជាមួយខ្លួនដែរ ពីព្រោះតម្លៃលក់ឡានមួយទឹក ក្រុមហ៊ុនជាអ្នកកំណត់តម្លៃដោយខ្លួនឯងទាំងអស់ ដោយថ្នាក់ដឹកនាំជនជាតិកូរ៉េជាអ្នកកំណត់តម្លៃ និងសម្រេចលក់រថយន្តទៅឱ្យភ្ញៀវដោយខ្លួនគាត់ ចំណែកពួកខ្លួនគ្រាន់តែជាអ្នកនាំពាក្យ ពេលដែលក្រុមហ៊ុនចេញតម្លៃលក់ឡាន ដោយពាំនាំតម្លៃមកប្រាប់អតិថិជន ដោយយើងមានជា Facebook Messenger មានអតិថិជនជាអ្នកទិញឡានយកទៅលក់បន្ត (Dealer) ទាំងអស់នៅក្នុង Group ឆាត ហើយអតិថិជនធ្វើការតវ៉ាតម្លៃទៅតាមប្រភេទឡាននីមួយៗដែលគេបានពិនិត្យ ។ រាល់ឆាតតថ្លៃលើតម្លៃលក់រថយន្តគឺគេឆាតក្នុង Group នោះទាំងអស់ ហើយខ្លួនបានពាំនាំតម្លៃនោះជូនថ្នាក់ដឹកនាំជនជាតិកូរ៉េសម្រេចថា លក់បាន ឬមិនបាន ចំពោះតម្លៃដែល

អតិថិជនតម្លៃនោះ ។ ជាឧទាហរណ៍ ពេលណាអតិថិជនតវ៉ា ឡានដែលក្រុមហ៊ុនកំណត់លក់ក្នុងតម្លៃ ៣០.០០០ (បីម៉ឺន) គាត់តវ៉ាមក ២៩.០០០ (ពីរម៉ឺនប្រាំបួនពាន់) ខ្លួនក៏គ្មានសិទ្ធិសម្រេចដែរ គឺបានតែពាំនាំការតវ៉ារបស់អតិថិជនទៅថ្នាក់លើ បើថ្នាក់លើថា លក់មិនបានទេ ខ្លួនក៏ប្រាប់អតិថិជនវិញដែលថា លក់មិនបាន បើមេថា លក់បាន ខ្លួនក៏ប្រាប់ថា លក់បាន ។ នៅពេលលក់ឡានជូនអតិថិជនមានឯកសារក្នុងនោះក៏មានហត្ថលេខាខ្លួនជាប្រធានផ្នែកលក់ និងហត្ថលេខារបស់ថ្នាក់ដឹកនាំកូរ៉េផងដែរ ។ ខ្លួនបានឈប់ពីក្រុមហ៊ុន នៅខែមិថុនា ឆ្នាំ២០២០ មកម្ល៉េះ ។ ទាក់ទងនឹងការខាតបង់ប្រាក់របស់ក្រុមហ៊ុន ថ្នាក់ដឹកនាំកូរ៉េ ក៏ធ្លាប់បានប្រជុំជាមួយបុគ្គលិកដោយគាត់តែងលើករឿងថា គាត់មានបទពិសោធន៍ក្មេងខ្ចីក្នុងការលក់ឡានមួយទឹកនៅស្រុកខ្មែរ ព្រោះក្រុមហ៊ុនគាត់មិនដែលលក់ឡានមួយទឹកទេ ហើយគាត់ក៏ទទួលស្គាល់រាល់ការខាតបង់របស់ក្រុមហ៊ុនដែរ ព្រោះភាគីខាងកូរ៉េជាអ្នកកម្ម៉ង់ឡានពីអាមេរិក និងពីកូរ៉េ យកមកលក់ដោយខ្លួនឯង ដូច្នេះហើយការបូកដកគុណចែកថ្លៃដឹកជញ្ជូនរបស់ក្រុមហ៊ុនគឺគ្មានការពាក់ព័ន្ធជាមួយពួកខ្លួនទេ ពួកខ្លួនគ្មានដឹងរឿងអ្វីទាំងអស់ ។ ពួកខ្លួនដឹងតែលក់ឡានទៅតាមតម្លៃដែលថ្នាក់លើបានដាក់តែប៉ុណ្ណោះ (ឯកសារនៅក្នុង Computer ខ្លួន ដោយសារខ្លួនជាប់ឃុំមិនអាចដាក់ជូនតុលាការបាន) ។ ក្នុងពេលខ្លួនបំរើការងារផ្នែកលក់ក្រុមហ៊ុនមិនដែលចែងច្បាប់ថា ហាមបុគ្គលិកទទួលប្រាក់ពីអតិថិជនទេ ហើយច្បាប់នេះក្រុមហ៊ុនទើបតែចែងនៅក្នុងខែឧសភា ឆ្នាំ២០២០ ថា បើបុគ្គលិកណាមួយទទួលយកប្រាក់ទឹកតែពីអតិថិជន ក្រុមហ៊ុនអាចប្តឹងទៅមន្ត្រីមានសមត្ថកិច្ច ឬតុលាការ ។ បន្ទាប់មកនៅខែមិថុនា ខ្លួនក៏បានលាឈប់ពីក្រុមហ៊ុនតែម្តង ដោយមូលហេតុក្រុមហ៊ុនបញ្ជូនខ្លួនទៅធ្វើការនៅសាខាផ្សេងនៅស្រុកអង្គស្នួល ហើយខ្លួនក៏ដឹងពីចេតនារបស់ក្រុមហ៊ុនដែលចង់បញ្ឈប់ខ្លួនដោយគ្មានសំណង ព្រោះខ្លួនបំរើការងារនៅក្រុមហ៊ុននេះជិត៥ឆ្នាំដែរ ដោយសារវិបត្តិកូវីត ។ ខ្លួនក៏យល់ពីផលលំបាកក្រុមហ៊ុនដោយសារបញ្ហាកូវីតដែរ ហើយការលាឈប់នេះក៏ដោយស្ម័គ្រចិត្តដែរ គ្រាន់តែមានការអន់ចិត្តដែលមានការផ្ទេរខ្លួនចេញ ។ ខ្លួនទទួលស្គាល់ថា ខ្លួនបានទទួលប្រាក់កម្រៃពីអតិថិជនមែន ប៉ុន្តែគ្មានការបង្ខិតបង្ខំទេ គឺអតិថិជនស្ម័គ្រចិត្តឱ្យដោយខ្លួនឯង ។ ចំពោះឈ្មោះ ក បានឆ្លើយថា លុយទទួលពីអតិថិជន បានរហូតដល់ ២៧០.០០០ (ម្ភៃប្រាំពីរម៉ឺន) ដុល្លារអាមេរិកនោះ ខ្លួនសូមបដិសេធ ព្រោះលុយនេះ ខ្លួនមិនដឹងថា គាត់បានទិន្នន័យនេះពីណាមកនោះទេ ។ ខ្លួនទទួលលុយទឹកតែពីអតិថិជនប្រហែលជាពីរម៉ឺនដុល្លារអាមេរិកជាង ដូចជាចម្លើយដែលខ្លួនបានឆ្លើយនៅសមត្ថកិច្ចដែរ លុយនេះ គឺចែកគ្នាមិនស្មើរទេ ។ ដោយសារឈ្មោះ ក . ជាមេ ធ្វើការមុនខ្លួន ហើយក៏ឈប់ធ្វើការក្រោយខ្លួនដែរ ដូច្នេះ គាត់ទទួលបានលុយលើសខ្លួនទៅទៀត ។ ឧទាហរណ៍ ភ្ញៀវ អោយ ២០០ ដុល្លារអាមេរិក គាត់ដកតែ១០០ ដុល្លារចែកគ្នា គាត់ទុក ១០០ ដុល្លារខ្លួនឯងក៏មាន ។ ចំពោះការចោទប្រកាន់ពីក្រុមហ៊ុនថា ទាល់តែក្រុមហ៊ុនណាឱ្យលុយពួកខ្លួន បានពួកខ្លួនលក់រថយន្តអោយក្រុមហ៊ុននោះគឺមិនពិតទេ គឺរាល់អតិថិជនទាំងអស់គឺមានសិទ្ធិស្មើរគ្នា អោយតែអតិថិជនណាហ៊ានឱ្យតម្លៃខ្ពស់ គឺខាងខ្លួនលក់អោយទាំងអស់ លើកលែងតែករណីគិតទៅលើអតិថិជនដែល ល្អ (ម៉ូយល្អ) ហ៊ានទិញឡានទាំងឡានចាស់ ទាំងឡានថ្មី ចំណែកអតិថិជនថ្មី ហ៊ានទិញតែឡានថ្មី ទោះបីជាគាត់ឱ្យតម្លៃខ្ពស់បន្តិចក៏យើងលក់ឱ្យម៉ូយចាស់ដែរ ។ ដូច្នេះ ពេលខ្លះវាពិបាកណាស់ក្នុងការកំណត់តម្លៃដោយសារតែបញ្ហាកំណត់អតិថិជនថ្មី និងអតិថិជនចាស់ ប៉ុន្តែតម្លៃលក់តំបូង និងចុងក្រោយក៏នៅតែក្រុមហ៊ុនជាអ្នកកំណត់តម្លៃដដែល ។ ចំពោះការទទួលប្រាក់ថ្លៃលក់ឡានពីអតិថិជន ខ្លួនមិនមែនជាអ្នកទទួលប្រាក់ដោយផ្ទាល់នោះទេ គឺមានបុគ្គលិកគណនីរបស់ក្រុមហ៊ុនជាអ្នកទទួលប្រាក់ ។ ពេលចែកប្រាក់គ្នាខ្លួនធ្លាប់ធ្វើបញ្ជីស្នាមដែរ តែក៏ឈប់ធ្វើវិញដោយយើងចែកលុយគ្នាផ្ទាល់ ។ ការធ្វើបញ្ជីស្នាមនាពេលនោះដោយសារពេលខ្លះអតិថិជនទាល់តែគាត់លក់ឡានដែលទិញពីក្រុមហ៊ុនដាច់ ទើបគាត់ឱ្យលុយចាយ ។ ចំពោះឆាតដែលឈ្មោះ [illegible] ទម្លាក់ចូលក្នុង Group ថ្នាក់ដឹកនាំ ខ្លួនទទួលស្គាល់ជាការពិត ។ នៅដំណាក់កាលសមត្ថកិច្ចខ្លួនឆ្លើយថា ខ្លួនទទួលបានប្រាក់ពីអតិថិជនចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ចំពោះការឡើងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា ខ្លួនឆ្លើយនៅដំណាក់កាលសមត្ថកិច្ចមានរូបភាពក្នុងការទទួលប្រាក់ពីអតិថិជនចំនួនពីររូប

ភាព ទីមួយអតិថិជនណាព្រមធ្វើតាមខ្លួន ខ្លួននិងលក់ឡានឲ្យភ្លាម និងពីរថា ខ្លួនប្រាប់អតិថិជនកុំទិញឡានដែលក្រុមហ៊ុនបានកំណត់តម្លៃ ដោយអោយភាគីអ្នកទិញស្នើរមកខ្លួន ចាំខ្លួនចរចារជា មួយថ្នាក់លើនោះ គឺមិនពិតទេ ខ្លួនមិនដែលបានឆ្លើយចម្លើយនេះទេ ។ ខ្លួនសូមបញ្ជាក់ថា ក្រុមហ៊ុនពីមុនលក់ម៉ូតូ បន្ទាប់មកនៅចុងឆ្នាំ២០១៨ ក៏ប្តូរមកលក់ឡានមួយទឹកវិញ ហើយខ្លួនលាឈប់នៅខែ ឧសភា ឆ្នាំ២០២០ ។ ពេលលក់ឡានឲ្យអតិថិជនខ្លួនមិនដែលដាក់លក្ខខណ្ឌ ឬគំរាមកំហែងអតិថិជន នោះទេ គឺគ្រប់ Dealer អ្នកនាំចូលឡាននៅស្រុកខ្មែរជាទំនៀមទំលាប់តែងតែឲ្យប្រាក់កម្រៃជើងសារជានិច្ច ហើយមិនមែនមានតែខ្លួនទេ ដែលទទួលបានប្រាក់ផ្នែកម្រៃជើងសារ សូម្បីតែបុគ្គលិកដែលនៅផ្នែកលក់ជាមួយខ្លួនក៏ទទួលបានផលប្រយោជន៍តិចតួចពីភ្ញៀវដែរ ។ ពេលមានឡានមកដល់ថ្មីៗ យើងតែងតែថតរូបឡានផ្ញើរទៅឲ្យគាត់មើល ហើយយើងក៏ជួយមើលឡានអោយគាត់ដែរ ដូចជាឡានណាដែលស្អាត ឬមិនស្អាត គឺយើងប្រាប់គាត់តាមត្រង់ ហើយការទទួលផលប្រយោជន៍តិចតួចពីភ្ញៀវនេះ ថ្នាក់ដឹកនាំជនជាតិកូរ៉េ ក៏គាត់ដឹងដែរ ពីព្រោះគាត់ធ្លាប់និយាយថា យើងនៅស្ងៀមៗ ចឹងអតិថិជនយកលុយមកញាត់ហោប៉ៅក៏យើងមិនដឹងធ្វើយ៉ាងម៉េចដែរ ។ គាត់ក៏ដឹងដែរថា ពួកខ្លួនបានទទួលលុយពីអតិថិជន ហើយក្នុងអំឡុងពេលដែលខ្លួនទទួលលុយពីអតិថិជន ក្រុមហ៊ុនក៏មិនទាន់មានច្បាប់ចែងមិនអោយទទួលប្រាក់ពីអតិថិជនដែរ បើមានខ្លួនក៏មិនហ៊ានល្មើសច្បាប់ក្រុមហ៊ុនដែរ ។ ក្រុមហ៊ុនដឹងថា ពួកខ្លួនយកលុយពីអតិថិជន តែក្រុមហ៊ុនមិនដែលហាម ឬហៅខ្លួនមកព្រមានដែរ រហូតដល់ខែឧសភា ឆ្នាំ២០២០ ក្រុមហ៊ុនបានចេញច្បាប់ ហើយក្រុមហ៊ុនហៅបុគ្គលិកផ្នែកលក់ទាំងអស់មកណែនាំ ។ ចំណុចដែលក្រុមហ៊ុនថា ក្រុមហ៊ុនបានខាតបង់ប្រាក់នោះ ពួកខ្លួនទាំងបីនាក់រាល់ពេលប្រជុំធ្លាប់ប្រាប់ក្រុមហ៊ុនដែរថា ក្រុមហ៊ុនបាននាំឡានចូលខុសតម្រូវទីផ្សារ ហើយឡានដែលនាំចូលមកបែបនេះគឺលក់មិនបានថ្លៃទេ ដោយសារពេលអតិថិជនមកមើលឡានតែងតែបង្អាប់ឡាន ហើយអតិថិជនមិនទិញទេ ហើយភាគីខាងកូរ៉េ តែងតែអោយពួកខ្លួនទៅសុំអង្វរអតិថិជនឲ្យជួយទិញឡាន ក្នុងតម្លៃណាក៏បានឲ្យតែស្នើរមកក៏អាចធ្វើការចរចារបានដែរ ដូច្នេះនៅពេលអតិថិជនឲ្យតម្លៃថោក យើងយកទៅប្រាប់ថ្នាក់ដឹកនាំ គាត់ថា ឲ្យថោកម្លេះដូច្នេះគាត់មិនព្រមលក់ ហើយដល់ពេលចរចារចុះឡើង គេអត់ទិញ ក៏ឲ្យពួកខ្លួនហៅគេមកទិញវិញ ដូច្នេះការខាតបង់ប្រាក់គឺមកពីក្រុមហ៊ុនទេ មិនមែនពួកខ្លួនទេ ពីព្រោះពួកខ្លួនគ្មានសិទ្ធិសម្រេចទេ ។

-តាមចម្លើយជនជាប់ចោទឈ្មោះ ក បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ អយ្យការ និងចៅក្រមស៊ើបសួរមានលក្ខណៈប្រហាក់ប្រហែលគ្នាថា៖ ខ្លួនបានចូលបម្រើការងារនៅក្នុង ក្រុមហ៊ុន A កាលពីថ្ងៃអំឡុងឆ្នាំ២០១៥ មានតួនាទីជាអាយធី ក្រោយមកក៏បានប្តូរទៅផ្នែកទីផ្សារនៅឆ្នាំ២០១៦ រហូតដល់ឆ្នាំ២០១៧ ទើបផ្លាស់ទៅផ្នែកលក់ (រថយន្ត) វិញ ដោយទទួលបានប្រាក់ខែចំនួនប្រហែល ៤៨០ ដុល្លារអាមេរិក ក្នុងតួនាទីជាប្រធានផ្នែកលក់រហូតនៅខែកក្កដា ឆ្នាំ២០២០ ទើបខ្លួនលាឈប់ពីក្រុមហ៊ុនខាងលើ ។ ចំពោះការលក់រថយន្តឲ្យទៅឃ្លាំងលក់រថយន្ត (DEALER) អំឡុងពេលខ្លួនបំពេញតួនាទីជាប្រធានផ្នែកលក់គឺក្រុមខ្លួនជូនដំណឹងទៅឃ្លាំងលក់រថយន្តមុន ០១ ថ្ងៃ ពេលដែលរថយន្តចូលស្តុក ។ លុះពេលរថយន្តចូលស្តុកថ្នាក់លើជនជាតិកូរ៉េបានកំណត់តម្លៃលក់មកឲ្យពួកខ្លួនដែលជាបុគ្គលិកខ្មែរ រួចពួកខ្លួនប្រកាសតម្លៃលក់បន្តទៅឃ្លាំងរថយន្ត ។ លុះពេលឃ្លាំងលក់រថយន្តមានបំណងចង់ទិញរថយន្ត ពួកគេនឹងធ្វើការចរចារតម្លៃជាមួយផ្នែកលក់របស់ពួកខ្លួន ហើយខ្លួននឹងរាយការណ៍បន្តទៅថ្នាក់លើជនជាតិកូរ៉េ ។ ក្រោយពីមានការអនុញ្ញាតពីថ្នាក់លើទើបខ្លួនធ្វើកុងត្រាលក់ជាមួយឃ្លាំងលក់រថយន្ត ។ ចំពោះតម្លៃនៃការលក់ក្រោយពីថ្នាក់លើដាក់តម្លៃឲ្យខ្លួនហើយ គឺខ្លួនបានដាក់តម្លៃលើសប្រហែល ៥% ដើម្បីទុកគម្លាតឲ្យភាគីឃ្លាំងលក់រថយន្តចរចារ ព្រោះគោលការណ៍របស់ក្រុមហ៊ុនមិនអាចលក់ក្រោមតម្លៃដែលថ្នាក់លើដាក់ឲ្យបានទេ លុះត្រាតែមានករណីពិសេស (មានការអនុញ្ញាតពីថ្នាក់លើ) ។ ចំពោះភាពមិនប្រក្រតីនៅពេលក្រុមរបស់ខ្លួនធ្វើប្រតិបត្តិការលក់ជាមួយឃ្លាំងរថយន្តមានក្នុងរូបភាពដូចជា៖ រូបភាពទី១ ពេលខ្លះរថយន្តដែលមានក្នុងស្តុកគឺមានចំនួនតិចជាងចំនួនដែលឃ្លាំងរថយន្តចង់បាន ដូច្នេះសម្រាប់ឃ្លាំងលក់រថយន្តណាដែលបានឲ្យកម្រៃជើងសារក្រៅ (ប្រាក់ក្រោមតុ) មក

ខាងផ្នែកលក់របស់ខ្លួន គឺខ្លួននឹងសម្រេចចិត្តលក់ជូនឃ្លាំងលក់រថយន្តមួយនោះ ។ រូបភាពទី២ ឃ្លាំងលក់រថយន្តបានស្នើសុំទិញក្នុងតម្លៃក្រោមការកំណត់របស់ក្រុមហ៊ុន រួចពឹងពាក់ឲ្យផ្នែកលក់របស់ខ្លួនទៅសម្រួលតម្លៃជាមួយថ្នាក់លើជនជាតិកូរ៉េ ។ ក្រោយពីធ្វើការបានសម្រេចផ្នែកលក់របស់ខ្លួននឹងទទួលបានប្រាក់កម្រៃជើងសារក្រៅ (ប្រាក់ក្រោមតុ) ពីឃ្លាំងលក់រថយន្តចន្លោះពី ១០០ ដុល្លារអាមេរិក ទៅ ២០០ ដុល្លារអាមេរិក សម្រាប់រថយន្ត ០១គ្រឿង ហើយពួកខ្លួនចែកគ្នា ០១ខែម្តង ។ ខ្លួនមានក្រុមការងារចំនួន ០៣នាក់ មានឈ្មោះ ខ. ឈ្មោះ ក និងខ្លួន ដែលបានទទួលប្រាក់សំណូកកម្រៃជើងសារក្រៅ (ប្រាក់ក្រោមតុ) ពីឃ្លាំងលក់រថយន្តដោយមិនបានឲ្យខាងក្រុមហ៊ុនដឹងរឿងនេះទេ ។ ដោយសារខ្លួនមិនមែនជាអ្នកធ្វើផ្ទាល់ជាមួយឃ្លាំង ដូច្នេះឃ្លាំងដែលធ្លាប់បានឲ្យប្រាក់សំណូកកម្រៃជើងសារមកឲ្យក្រុមខ្លួន គឺខ្លួនចាំបានតែឃ្លាំងចំនួន ០៦ប៉ុណ្ណោះ ដែលមានឈ្មោះ 818, KEAU CHEMDA, 988, 88888, Chay 168 និង USA ។ គិតចាប់ពីពួកខ្លួនទទួលប្រាក់សំណូកកម្រៃជើងសារក្រៅជាមួយឃ្លាំងលក់រថយន្តមកគឺប្រតិបត្តិការលើរថយន្តប្រហែល ១៥០០គ្រឿង ដែលគិតជាទឹកប្រាក់ប្រហែល ២៧០,០០០ (ម្ភៃប្រាំពីរម៉ឺន) ដុល្លារអាមេរិក ។ លុះអំឡុងខែមេសា ឆ្នាំ២០២០ ទើបក្រុមហ៊ុនដឹងរឿងក្រុមខ្លួនទទួលសំណូកពីឃ្លាំងលក់រថយន្ត ហើយនៅអំឡុងខែកក្កដា ឆ្នាំ២០២០ ខ្លួនក៏លាឈប់តែម្តង ។ មុនពេលលាឈប់ខ្លួនក៏បានធ្វើលិខិតសារភាពកំហុសជូនទៅក្រុមហ៊ុនផងដែរ ក្រោយពីមានការចរចារគ្នារវាងក្រុមហ៊ុនជាមួយខ្លួន ភាគីក្រុមហ៊ុនបានកំណត់ឲ្យខ្លួនទូទាត់ប្រាក់ចំនួន ៥០.០០០ (ប្រាំបួនម៉ឺន) ដុល្លារអាមេរិក ទៅក្រុមហ៊ុនវិញដើម្បីបញ្ចប់រឿងហើយខ្លួនក៏បានស្នើសុំសងត្រឹមតែ ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ទៅតាមលទ្ធភាពរបស់ខ្លួនដែលមាន ហើយខាងក្រុមហ៊ុនក៏បានព្រមព្រៀងផ្ទាល់មាត់ជាមួយខ្លួនដែរ ។

-ជនជាប់ចោទឈ្មោះ មាស ណារិទ្ធ បានឆ្លើយថា៖ ខ្លួនបានចូលបំរើការងារនៅ ក្រុមហ៊ុន DAC តាំងអំឡុងខែមីនា ឆ្នាំ២០១៥ បន្ទាប់មកនៅឆ្នាំ២០១៨ ក្រុមហ៊ុន ក៏ចាប់ផ្តើមបើកលក់ឡានមួយទឹក ដោយមានអ្នកគ្រប់គ្រងជាជនជាតិកូរ៉េឈ្មោះ លយ់ ខ្លួនជាប្រធានផ្នែកលក់និងធ្វើការដោយផ្ទាល់ជាមួយឈ្មោះ លយ ។ នៅឆ្នាំ២០១៨ ក្រុមហ៊ុនបានចាប់ផ្តើមរកស៊ីលក់ឡាន ដោយចែកជាពីរផ្នែក ដោយផ្នែកទីមួយយើងលក់ឲ្យអ្នកជិះផ្ទាល់ និងផ្នែកទីពីរយើងលក់ឲ្យអ្នកទិញយកទៅលក់បន្ត (Dealer) ។ ខ្លួនជាប្រធានផ្នែកលក់ទាំងពីរផ្នែក ហើយការចោទប្រកាន់របស់ក្រុមហ៊ុនមកលើខ្លួននេះ គឺចោទប្រកាន់ទៅលើផ្នែកទីពីរ (Dealer) ។ គ្រប់ពេលដែលខ្លួនលក់ឡានអោយអ្នកទិញ (Dealer) បានសម្រេចទៅលើតម្លៃចរចារអស់ហើយ Dealer មួយចំនួនបានអោយលុយខ្លួនជាថ្លៃលើកទឹកចិត្តជាលុយធីប ឧទាហរណ៍ ដូចជាពេលភ្ញៀវចតឡាន ហើយសន្តិសុខជួយអាយ៉ៃឡាន ភ្ញៀវក៏ឲ្យប្រាក់បែបនោះឯង ។ ខ្លួនបានទទួលលុយធីបពីភ្ញៀវមែន ប៉ុន្តែរាល់ការសម្រេចតម្លៃលក់ឡាន មិនមែនខ្លួនជាអ្នកសម្រេចទេ គឺថ្នាក់លើជាអ្នកសម្រេច ដោយខ្លួនគ្រាន់តែនាំពាក្យតែប៉ុណ្ណោះ ។ ឧទាហរណ៍ នៅពេលដែលក្រុមហ៊ុនដាក់ឡានលក់មួយទឹកតម្លៃ ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ខ្លួននាំពាក្យពីថ្នាក់លើខ្លួនជាជនជាតិកូរ៉េ ដាក់ទៅអ្នកទិញ តម្លៃ ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ហើយពេលអ្នកទិញចរចារ ថា ២៥.០០០ ( ពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ខ្លួនក៏គ្មានសិទ្ធិសម្រេចដែរ ហើយខ្លួនស្នើ ដោយចរចារទៅអ្នកទិញបន្ថែមទៀតថា អត់បានទេ ហើយយើងធ្វើការចរចារចុះឡើងៗ រហូតចុងក្រោយអ្នកទិញសម្រេចថា មិនបានទេ បានត្រឹមតែ ២៨.០០០ (ពីរម៉ឺនប្រាំបីពាន់) ដុល្លារអាមេរិក ទេ ដូច្នេះ ខ្លួនយកតម្លៃ ២៨.០០០ (ពីរម៉ឺនប្រាំបីពាន់) ដុល្លារអាមេរិក ដាក់ទៅថ្នាក់លើជាជនជាតិកូរ៉េ ដើម្បីសួរគាត់ថា តើយើងអាចលក់តម្លៃនេះបាន ឬអត់ ? ដោយយើងរៀបរាប់ប្រាប់គាត់ពីដំណើររឿង និងពីអតិថិជន (ជាអតិថិជនថ្មី ឬអតិថិជនចាស់ (ម៉ូយ) ហើយបើថ្នាក់លើ Ok តម្លៃ ២៨.០០០ (ពីរម៉ឺនប្រាំបីពាន់) លក់បាន ទើបខ្លួនមានសិទ្ធិយកតម្លៃនេះមកដាក់លក់ឲ្យអតិថិជនវិញ ដូច្នេះ ពេលអ្នកទិញ ទិញរថយន្តហើយ ទើបគាត់ឲ្យលុយធីប មកខ្លួន ។ ខ្លួនសូមបញ្ជាក់ជូនតុលាការថា គ្រប់ឡានទាំងអស់ដែលលក់ចេញ ខ្លួនគ្មានសិទ្ធិសម្រេចតម្លៃលក់នោះទេ

។ ប៉ុន្តែខ្លួនទទួលស្គាល់ថា ទង្វើរនេះពិតជាខុសជាមួយច្បាប់ក្រុមហ៊ុន ក៏ដូចជាច្បាប់ទូទៅ ដែលខ្លួនយកលុយធីបពីអ្នកទិញ ប៉ុន្តែរាល់ការទទួលលុយធីបពីភ្ញៀវខាងក្រុមហ៊ុនក៏បានដឹងលឺដែរ ប៉ុន្មានគាត់បិទភ្នែក បើកភ្នែក ដោយសារទង្វើរនេះគឺនៅទីណាក៏មានដែរ នៅពេលយើងលក់ឡាន និងជួយមើលឡានអោយអតិថិជននោះ ។ បន្ទាប់មកនៅឆ្នាំ ២០២០ មានករណី Covid 19 ផ្ទុះឡើង ធ្វើឲ្យសេដ្ឋកិច្ចក្រុមហ៊ុនធ្លាក់ចុះ ដូច្នេះថ្នាក់លើមិនសប្បាយចិត្ត ហើយក្រុមហ៊ុនបានស៊ើបសួរ និងបានកាត់បន្ថយបុគ្គលិក ។ ខ្លួនមានកំហុសមួយទៀត គឺនិយាយដើមមេ ដោយនិយាយអាក្រក់ៗពីមេ ដោយថា មេនេះឆេវឆាវ ស្រែកដាក់បុគ្គលិក ជាដើម ដោយខ្លួននិយាយក្នុង Group ដោយមានគ្នាចំនួន បីនាក់ មានខ្លួន, ឈ្មោះ ក និងឈ្មោះ ខ ។ បន្ទាប់មកក្រុមហ៊ុនក៏មានការកាត់បន្ថយបុគ្គលិក ហើយក៏ធ្វើឲ្យឈ្មោះ ខ មិនពេញចិត្តនៅពេលក្រុមហ៊ុនកាត់ឈ្មោះគាត់ ហើយខ្លួនក៏បានផ្តាច់ទំនាក់ទំនងជាមួយឈ្មោះ ខ ភ្លាមៗដែរ ស្រាប់តែឈ្មោះ ខ យកអត្ថបទដែលខ្លួនបានសរសេរនិយាយដើមមេក្នុងឆាតដាក់ចូលក្នុង Group ថ្នាក់លើ ។ ថ្នាក់លើជាជនជាតិកូរ៉េ គាត់មានការខឹងសម្បារក៏ធ្វើការប្តឹងផ្តល់តែម្តង ។ ខ្លួនសូមបញ្ជាក់ថា ខ្លួនមិនបានលក់រថយន្តខុសតម្លៃក្រុមហ៊ុនកំណត់ទេ តម្លៃលក់រថយន្តលើកទីមួយ និងចុងក្រោយ គឺថ្នាក់លើជាជនជាតិកូរ៉េជាអ្នកកំណត់ទាំងអស់ ។ ចំណែករឿងទទួលប្រាក់ពី Dealer ខ្លួនពិតជាបានទទួលមែន ដោយនៅពេលចប់ប្រតិបត្តិការណ៍ទិញលក់ ទើប Dealer អោយប្រាក់ដោយសុទ្ធចិត្ត ដោយ Dealer ខ្លះអោយប្រាក់ ១០០ (មួយរយ) ដុល្លារ ឬ ២០០ (ពីររយ) ដុល្លារអាមេរិក ។ ពេលបានលុយពីភ្ញៀវ ពួកខ្លួនយកលុយចែកគ្នាពានាក់ស្មើរគ្នា ។ ចំពោះការលក់ឡានចំនួន ១.៥០០ គ្រឿង ខ្លួនបានលក់ចេញពិតមែន តែមិនមែនឡានទាំង ១.៥០០ គ្រឿង ខ្លួនទទួលបានប្រាក់ធីបពីអតិថិជនទាំងអស់នោះទេ ។ មូលហេតុដែលក្រុមហ៊ុនថា ក្រុមហ៊ុនបានខាតបង់ប្រាក់ ខ្លួនក៏មិនដឹងដែរ ដោយសារតម្លៃគឺក្រុមហ៊ុនជាអ្នកកំណត់ក្នុងការលក់ ប៉ុន្តែឡានមួយទឹកដែលក្រុមហ៊ុនយកមកលក់ គឺមានគុណភាពផ្សេងគ្នា ហើយការលក់ឡាននេះគឺក្រុមហ៊ុនទទួលបានការអនុគ្រោះពន្ធ ៣០ ភាគរយពីរដ្ឋ ដូច្នេះការលក់ឡានរបស់ក្រុមហ៊ុនគឺមានតម្លៃទាបជាងទីផ្សារពិតប្រាកដមែន ។ ចំពោះការលក់ឡាននេះ មានគ្រឿងខ្លះចំណេញ និងគ្រឿងខ្លះខាត (ខាត៣០% ចំណេញ ៧០%) ដោយសារការទិញខុសឡាន ដោយសារឡានមួយទឹកមានប្រភេទឡានត្រូវពណ៌ ឡានត្រូវឆ្នាំ ឡានដែលត្រូវ Option ដូច្នេះយើងជាក្រុមហ៊ុនធំ យើងមិនមែនទិញឡានមួយគ្រឿងទេ គឺយើងសហការណ៍ជាមួយដៃគូរនៅក្រៅស្រុកទិញឡានជាកញ្ចប់ ដូច្នេះយើងទិញតម្រូវកូតាអ្នកផ្គត់ផ្គង់ឡានអោយយើង ដើម្បីសម្រេចកូតាអោយគ្រប់ចំនួនបាន យើងមិនអាចកំណត់ឡាន ១.០០០គ្រឿង ត្រូវជាពណ៌សទាំងអស់បានទេ (ឡានមួយចំនួនគុណភាពទាប ខុសតម្រូវការទីផ្សារ) ។ ការលក់ឡាន គឺយើងប្រកាសជាសាធារណៈឲ្យទិញមើល ជាឧទាហរណ៍ យើងកំណត់តម្លៃឡានពណ៌ស មួយគ្រឿងនេះតម្លៃ ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក បើអតិថិជនណាហ៊ាន គាត់នឹងទទួលបានឡានមួយគ្រឿងនេះភ្លាម តែបើឡាននេះគេមកមើលឃើញថា គុណភាពស្មើរគេមិនហ៊ានដល់មួយម៉ឺនគ្រប់គ្នា អ្នកខ្លះដេញថ្លៃអោយតម្លៃឡាន ៩.៥០០ (ប្រាំបួនពាន់ប្រាំរយ), ៩.៧០០ (ប្រាំបួនពាន់ប្រាំពីររយ) ឬ ៩.៨០០ (ប្រាំបួនពាន់ប្រាំបីរយ) ដុល្លារអាមេរិក ខ្លួនជាអ្នកពិនិត្យមើលលើអ្នកទិញដែលដេញថ្លៃទាំងនោះ អ្នកណាហ៊ានអោយតម្លៃខ្ពស់ជាងគេ យកមកធ្វើរបាយការណ៍ជូនថ្នាក់លើថាមានមនុស្ស១០នាក់ហ៊ានអោយតម្លៃប៉ុននេះ ហើយបុគ្គលនោះហ៊ានឲ្យតម្លៃ ៩.៨០០ (ប្រាំបួនពាន់ប្រាំបីរយ) ដុល្លារអាមេរិក ដោយខ្លួនក៏រៀបរាប់ពីគុណភាពឡានផងដែរ ហើយថ្នាក់លើពិនិត្យ និងសម្រេចលក់ ឬមិនព្រមលក់ ។ ខ្លួនសូមបញ្ជាក់ថា នៅពេលដែលដេញថ្លៃឡាន គឺមានGroup អ្នកដេញថ្លៃក្នុងហ្នឹង ហើយក៏មានថ្នាក់ដឹកនាំកូរ៉េនៅក្នុងនោះដែរ ខ្លួនមិនអាចធ្វើរបាយការណ៍សារររើសអតិថិជន ហើយកុហកថ្នាក់លើបានទេ ជនជាតិកូរ៉េ គឺគាត់មើលដឹងទាំងអស់ថាមានបុគ្គលណាខ្លះហ៊ានឲ្យតម្លៃប៉ុន្មានទៀត ប៉ុន្តែពេលខ្លះយើងលក់ឲ្យអ្នកដេញថ្លៃទាប ដោយសារគាត់ជាម៉ូយចាស់ គាត់ម៉ៅឡានយកទាំងអស់ ហើយអ្នកហ៊ានអោយតម្លៃខ្ពស់ជាម៉ូយថ្មី គាត់រើសយកឡានតែថ្មីៗ ដូច្នេះថ្នាក់លើគាត់ក៏ពិចារណាដែរលើចំណុចនេះ ។ ចំណែកលុយទាំង ២៧០.០០០ (ម្ភៃប្រាំពីរម៉ឺន) ដុល្លារអាមេរិក ដែលក្រុមហ៊ុនទាមទារ

ពីខ្លួននោះ គឺក្រុមហ៊ុនយកលុយ ២០០ ដុល្លារ គុណនឹងឡាន ១៥០០ គ្រឿងតែម្តង ។ មុនពេលខ្លួនលាឈប់ពីក្រុមហ៊ុន នៅឆ្នាំ២០២០ ខ្លួនធ្លាប់សរសេរលិខិតសុំទោសទៅក្រុមហ៊ុន ខ្លួនទទួលស្គាល់ និងព្រមទទួលស្គាល់ការចោទប្រកាន់ក្រុមហ៊ុនមកលើខ្លួន ។ ចំពោះចម្លើយដែលខ្លួនបានឆ្លើយនៅសមត្ថកិច្ចថា ទីមួយតម្លៃក្រុមហ៊ុនកំណត់ ខ្លួនទៅប្រាប់គេថា កុំទិញនៅតម្លៃប៉ុណ្ណឹង ខ្លួនអាចចរចារជាមួយខាងក្រុមហ៊ុនបាន ហើយលុយដែលសល់ប្រគល់មកឲ្យខ្លួន ជាថ្នូរមកវិញអ្នកទិញណាធ្វើតាមខ្លួន អ្នកទិញនោះនឹងទទួលបានការលក់ឡានជូនមុនគេ ជាលិខិតខ្លួនសរសេរពិតមែន ប៉ុន្តែខ្លួនសូមជម្រាប លោកចៅក្រមថា លិខិតនេះខ្លួនធ្វើដោយសារខ្លួនមានសំពាធផ្លូវចិត្ត ដោយសារខ្លួនគិតថា ខ្លួនមិនអាចឈ្នះក្រុមហ៊ុនបានទេ ខ្លួនឈប់ពីការងារទៅខ្លួនមានប្រពន្ធកូន ០៣នាក់ ត្រូវចិញ្ចឹម ហើយប្រពន្ធខ្លួនគ្មានការងារធ្វើនោះទេ ដូច្នេះក្រុមហ៊ុនអាចដាក់ខ្លួនក្នុង Black List មិនអាចអោយខ្លួនស្វែងរកការងារថ្មីបាន ដូច្នេះការដាក់ពាក្យធ្វើការរបស់ខ្លួនមិនអាចត្រូវក្រុមហ៊ុនផ្សេងជ្រើសរើសនោះទេ ដូច្នេះខ្លួនសុខចិត្តទទួលយកកំហុសគ្រប់យ៉ាង ឆ្លើយនៅអ្វីដែលក្រុមហ៊ុនចង់បាន ខ្លួនសូមជម្រាបម្តងទៀតថា ថ្ងៃដែលក្រុមហ៊ុនចោទប្រកាន់រូបខ្លួន ប្រសិនបើថ្ងៃនោះលោក ក និងលោក ខ មកសារភាពក៏មិនមានរឿងដល់ថ្ងៃនេះដែរ ។ ដូច្នេះមានតែខ្លួនម្នាក់ទេ ដែលព្រមសារភាព និងទទួលកំហុសសងប្រាក់ទៅក្រុមហ៊ុន នៅអ្វីដែលក្រុមហ៊ុនបានធ្វើការចោទប្រកាន់មកលើខ្លួន ដោយក្នុងគំនិតខ្លួន នៅគិតផ្លូវសម្រាប់ខ្លួនឯងត្រូវតែស្វែងរកការងារផ្សេងធ្វើទៀត បើខ្លួនបដិសេធមិនព្រមធ្វើតាមក្រុមហ៊ុន ក្រុមហ៊ុនមានសិទ្ធិ Black List ខ្លួនក្នុងការស្វែងរកការងារថ្មីទៀត ទើបខ្លួនព្រមចរចារជាមួយក្រុមហ៊ុននៅថ្ងៃនោះ ហើយខាងក្រុមហ៊ុនថា ខ្លួនបានសារភាពហើយ ខាងក្រុមហ៊ុនមិនចោទប្រកាន់ខ្លួនធ្ងន់ធ្ងរទេ ប៉ុន្តែពីរនាក់ទៀតគាត់បានគេចវេស ដូច្នេះ ខ្លួនក៏យល់ព្រមសងក្រុមហ៊ុនចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក នោះថ្ងៃនោះតែម្តង ។ ក្រុមហ៊ុនស្នើរសុំឲ្យខ្លួនចូលមកឆ្លើយសារភាពនៅនៅសមត្ថកិច្ចដោយសារពីរនាក់ទៀតគាត់បានគេចវេស ។ ចំណែកនៅក្នុងសារ ដែលមានខ្លឹមសារថា "ខ្ញុំនឹងចាប់ផ្តើមគណនាការងារនេះជារៀងរាល់ថ្ងៃដើម្បីពិនិត្យមើលយានដ្ឋានដែលចូលរួម ប្រសិនបើគាត់មិនយល់ព្រមតាមតម្រូវការរបស់យើង យើងគ្រាន់តែលក់តាមតម្រូវការក្រុមហ៊ុន" ខ្លឹមសារនេះមានន័យដូចលោកមេធាវីដើមបណ្តឹងនិយាយពិតមែន ។ ឡានចំនួន ១.៥០០ គ្រឿង ជាឡានលក់អោយអតិថិជនទិញប្រើប្រាស់ និងអតិថិជនទិញយកទៅលក់បន្ត ។ ការងារទិញលក់រថយន្តនេះ នៅពេលមានការតថ្លៃពីអតិថិជន គឺត្រូវឆ្លងយោបល់មេជានិច្ច ចំណែកកូនចៅខ្លួនទាំងពីរនាក់នេះគឺឆ្លងខ្លួន ហើយខ្លួនរាយការណ៍ទៅមេបន្ត បើខ្លួនមិននៅកន្លែងគាត់អាចឆ្លងទៅមេផ្ទាល់បាន ។ នៅពេលអតិថិជនតថ្លៃទិញឡាន ខ្លួនមិនដែលដាក់លក្ខខណ្ឌអោយអតិថិជនអោយខ្លួនប៉ុណ្ណេះ បានខ្លួនលក់ឡានអោយនោះទេ ។ ខ្លួនសូមបញ្ជាក់ថា ចំពោះលិខិតដែលខ្លួនទទួលស្គាល់ ក៏ដូចជាលិខិតសុំទោសជាមួយក្រុមហ៊ុន មានទឹកប្រាក់ចំនួន ២៧០.០០០ (ម្ភៃប្រាំពីរម៉ឺន) ដុល្លារអាមេរិក ទទួលខុសត្រូវគ្នា ០៣នាក់នេះ គឺនៅពេលដែល ពីរនាក់ទៀតគាត់មិនមកសារភាពកំហុស ហើយខ្លួនបានឆ្លើយសារភាពថា នៅពេលលក់ឡានបាន បានទទួលប្រាក់ពីភ្ញៀវ ១០០ ទៅ ២០០ ដុល្លារអាមេរិក ក្រុមហ៊ុន ក៏សម្រេចថា យក ២០០ គុណចំនួនឡាន ១.៥០០ គ្រឿងតែម្តង ប៉ុន្តែចំនួនប្រាក់ទទួលជាក់ស្តែងទទួលមិនបានចំនួននេះ ទេ ។ ឡានរបស់ក្រុមហ៊ុនទាំងអស់លក់មិនបានតម្លៃស្មើរគ្នាទេ ការលក់គឺអាស្រ័យលើគុណភាពឡាន ប៉ុន្តែបើសរុបពីការលក់ឡានទាំងអស់គឺមិនមានខាតទេ ។ នៅពេលធ្វើប្រតិបត្តិការលក់ឡានខ្លួនបានធ្វើជាតារាង Excel គណនាអំពីចំណូលពីប្រាក់ដែលភ្ញៀវអោយពីការលក់ឡានមែន ការធ្វើតារាងនេះគឺខ្លួនធ្វើដោយខ្លួនឯង មានចំនួនប្រហែល ២៧០.០០០ (ម្ភៃប្រាំពីរម៉ឺន) ដុល្លារអាមេរិក ។ ចំពោះការធ្វើតារាងឃើញទឹកប្រាក់ចំនួន ២៧០.០០០ (ម្ភៃប្រាំពីរម៉ឺន) ដុល្លារអាមេរិក គឺខ្លួនធ្វើដោយខ្លួនឯងគ្មានអ្នកណាដឹងទេ ហើយការបូកបញ្ជីចេញបែបនេះដោយសារតែខ្លួនមិនមែនជាអ្នកទទួលប្រាក់ដោយផ្ទាល់ពីអតិថិជន គឺឈ្មោះ ក និងឈ្មោះ ខ ភាគច្រើនជាអ្នកទទួលប្រាក់ពីអតិថិជន ហើយយកមកឲ្យខ្លួន ហើយខ្លួនយកមកគ្រប់គ្រងដើម្បីធ្វើការបែងចែកលុយ និងចំណាំដោយខ្លួនឯង ខ្លួនមិនដែលយកបញ្ជីនេះមកផ្ទៀងផ្ទាត់ជាមួយអ្នកណានោះទេ បញ្ជីនេះខ្លួនធ្វើនៅក្នុង Computer

របស់ក្រុមហ៊ុន ។ ការប្រគល់ប្រាក់មិនបានធ្វើតាមធនាគារ ឬប្រតិបត្តិការអ្វីផ្សេងនោះទេ គឺប្រគល់ដោយផ្ទាល់ដៃ ។ លុយដែលខ្លួនទទួលបានពីក្រុមហ៊ុនចំនួន ២៧០.០០០ (ម្ភៃប្រាំពីរម៉ឺន) ដុល្លារអាមេរិក ចែកនឹងបី គឺទទួលបាន ប្រាំបួនម៉ឺនដុល្លារអាមេរិកជាង ។ ខ្លួន និងឈ្មោះ ក និងឈ្មោះ គ គឺចូលបំរើការស្មើរគ្នា គ្មានអ្នកណាចូលបំរើការមុនក្រោយនោះទេ ។ បុគ្គលិកផ្សេងៗនៅក្នុងក្រុមហ៊ុនក៏ទទួលបានប្រាក់ពីភ្ញៀវដែរ មិនមែនមានតែពួកខ្លួន បីនាក់ទេ ។ ការទទួលប្រាក់ពីភ្ញៀវនេះ ថ្នាក់ដឹកនាំកូរ៉េក៏ដឹងរឿងនេះដែរ គ្រាន់តែគាត់បើកភ្នែកបិទភ្នែក ហើយថ្នាក់ដឹកនាំកូរ៉េក៏ធ្លាប់ប្រាប់ថា គាត់ធ្លាប់ធ្វើការ ទើបគាត់ដឹង កាលជនជាតិកូរ៉េជិនាន់មុនពេលលក់ឡានក៏មានអតិថិជនហៅគាត់ឲ្យលុយដែរ ហើយបើយើងមិនទទួលប្រាក់ក៏ពិបាកដែរ ។ ការទទួលប្រាក់ពីភ្ញៀវនេះ ថ្នាក់ដឹកនាំកូរ៉េមិនបានហាម ឬហៅមកធ្វើការណែនាំនោះទេ ដោយសារគាត់យល់ថា មិនមានការខាតបង់ដល់ក្រុមហ៊ុនទេ ហើយការប្ដឹងរបស់ក្រុមហ៊ុននេះគឺដោយសារតែឈ្មោះ ខ យកសារដែលខ្លួននិយាយដើមអាក្រក់ៗពីគាត់ ទើបគាត់ខឹងក៏ដាក់ពាក្យបណ្ដឹងតែម្ដង ។ ចំពោះការឆ្លើយរបស់ឈ្មោះ ក ថា ទទួលបានប្រាក់ចំនួន ពីរម៉ឺនដុល្លារជាង ខ្លួនមិនដឹងទេ នេះជាសិទ្ធិរបស់គាត់ក្នុងការឆ្លើយ ។

-តាមអំណានចម្លើយសាក្សីឈ្មោះ ឃ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្លួនបានចូលបម្រើការងារនៅក្នុង ក្រុមហ៊ុន JAC តាំងពីថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៦ រហូតមកដល់បច្ចុប្បន្ន ដោយមានតួនាទីជាផ្នែកលក់ ដែលជាផ្នែកលក់ឲ្យអតិថិជនយករថយន្តទៅប្រើប្រាស់ ទទួលបានប្រាក់ខែចំនួន ៣០០ ដុល្លារអាមេរិក ។ រាល់តម្លៃរថយន្តទាំងអស់គឺខាងក្រុមហ៊ុនបានកំណត់តម្លៃឲ្យក្រុមការងារជាអ្នកលក់ ហើយពួកខ្លួនគឺបានលក់រថយន្តតាមការកំណត់របស់ក្រុមហ៊ុន ។ ប្រសិនបើអតិថិជនសុំបញ្ចុះតម្លៃរថយន្តណាមួយខាងក្រុមការងារខ្លួននឹងរាយការណ៍បន្តទៅប្រធានក្រុមហ៊ុនប្រសិនបើប្រធានក្រុមហ៊ុនឯកភាពខាងក្រុមការងារខ្លួននឹងលក់ជូនអតិថិជន ។ នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនគឺមិនតម្រូវឲ្យបុគ្គលិកទាំងអស់ទទួលកម្រៃជើងសារពីអតិថិជននោះទេ ទោះបីជាអតិថិជនឲ្យក៏ខ្លួនមិនហ៊ានទទួលដែរ ។

-តាមចម្លើយរបស់មេធាវីឈ្មោះ អេង សុធា បានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការ និងចៅក្រមស៊ើបសួរមានលក្ខណៈប្រហាក់ប្រហែលគ្នាថា៖ ក្រុមហ៊ុនកូនក្ដីខ្លួនជាក្រុមហ៊ុននាំចូលរថយន្តពីប្រទេសកូរ៉េមកចែកចាយនៅប្រទេសកម្ពុជា ដែលមានការចុះបញ្ជីត្រឹមត្រូវតាមច្បាប់កម្ពុជា ។ ក្រុមហ៊ុនកូនក្ដីខ្លួនបានចុះកិច្ចសន្យាការងារជាមួយឈ្មោះ ខ ឈ្មោះ ក ដែលមានតួនាទីជាប្រធានផ្នែកលក់ និងឈ្មោះ គ ជាអ្នកគ្រប់គ្រងទូទៅរបស់ក្រុមហ៊ុន ។ ក្នុងដំណើរការលក់នេះក្រុមហ៊ុនកូនក្ដីខ្លួនបានធ្វើការកំណត់តម្លៃរថយន្តនីមួយៗជាស្រេចសម្រាប់លក់ទៅឲ្យអតិថិជន (កាវ៉ាស់) ហើយបានប្រគល់កិច្ចការលក់នេះទៅឲ្យឈ្មោះ ខ ឈ្មោះ ក ដែលមានតួនាទីជាប្រធានផ្នែកលក់ និងឈ្មោះ គ ជាអ្នកគ្រប់គ្រងទូទៅរបស់ក្រុមហ៊ុនក្នុងការអនុវត្តកិច្ចការនេះ ។ កន្លងមកឈ្មោះ ខ ឈ្មោះ ក និងឈ្មោះ គ ពួកគេតែងតែស្នើមកក្រុមហ៊ុនថា រថយន្តមិនអាចលក់តាមតម្លៃកំណត់របស់ក្រុមហ៊ុនបានទេ លុះត្រាណាតែលក់ថោកជាងការកំណត់ទើបលក់បានដោយសារបញ្ហារថយន្ត បញ្ហាកាវ៉ាស់មិនហ៊ានទិញ និងបញ្ហាជាច្រើនទៀត ។ ពីដំបូងក្រុមហ៊ុនកូនក្ដីខ្លួនមានការសង្ស័យខ្លះដែរ តែដោយគិតថាពេលខ្លះការលក់អាចនឹងជួបរឿងបែបនេះក៏ទុកបញ្ហានេះមួយឡែក ។ ប៉ុន្តែបញ្ហាទាំងនេះតែងកើតឡើងញឹកញាប់ឡើងៗ ហើយទន្ទឹមនឹងនោះផងដែរការលក់ដូចជាមិនមានការរីកចម្រើនខ្លាំងក្លាក្រុមហ៊ុនចាប់ផ្ដើមសង្ស័យ និងបានធ្វើការតាមដានកិច្ចការលក់របស់ពួកគេ ។ លុះដល់អំឡុងខែមេសា ឆ្នាំ២០២០ ដោយសារតែមានទំនាស់ផ្ទៃក្នុងរបស់ពួកគេជាពិសេសទៅលើការបែងចែកផលប្រយោជន៍មិនស្មើគ្នា ពួកគេបានបង្ហោះឯកសារសំងាត់ដែលពួកគេបានជជែកគ្នាក្នុងក្រុមរបស់ពួកគេមានគ្នាបីនាក់មានឈ្មោះ ខ ឈ្មោះ ក និងឈ្មោះ គ (នៅក្នុងបណ្ដាញសង្គមមានឈ្មោះជាភាសាអង់គ្លេសថា Line ដែលពួកគេបានដាក់

ឈ្មោះក្រុមថា 3 Only) ដែលអត្ថន័យនៅក្នុងការជជែកនោះសុទ្ធតែបង្ហាញពីយុត្តិសាស្ត្រ និងចេតនាទុច្ចរិតក្នុងការគិតគេងលុយរបស់ក្រុមហ៊ុនក្ងន់ក្ដីខ្លួនចូលមកក្រុមថ្នាក់ដឹកនាំទើបក្រុមហ៊ុនដឹងថាកន្លងមកពួកគេបានប្រើឧបាយកលទុច្ចរិតជាច្រើនក្នុងអំឡុងពេលលក់នោះ ដែលធ្វើឱ្យក្រុមហ៊ុនមានការខូចខាតផលប្រយោជន៍ជាច្រើន ហេតុនេះក្រុមហ៊ុនបានសម្រេចបញ្ឈប់ឈ្មោះ ខ. ឈ្មោះ ក ពីការងារ ។ ក្នុងចំណោមពួកគេទាំងបីនាក់នេះមានម្នាក់ឈ្មោះ គ. បានចូលខ្លួនមកក្រុមហ៊ុនដើម្បីដោះស្រាយ និងសារភាពនូវទោសកំហុសទាំងអស់ចំពោះមុខក្រុមហ៊ុនហើយទទួលស្គាល់ថា ពួកទាំងបីនាក់ពិតជាបានប្រើឧបាយកលទុច្ចរិតមែន ហើយទឹកប្រាក់ដែលពួកគេទទួលបានពីការប្រើឧបាយកលទុច្ចរិតមានសរុបទាំងអស់មានចំនួន ២៧០,០០០ (ម្ភៃប្រាំពីរម៉ឺន) ដុល្លារអាមេរិក ។ តាមរយៈចម្លើយសារភាពរបស់ឈ្មោះ ក និងឯកសារផ្ទៃក្នុងរបស់ពួកគេដែលបានជជែកគ្នាបានបង្ហាញថា នៅពេលពួកគេចុះទៅជួបអតិថិជនដើម្បីលក់រថយន្តពួកគេបានប្រើឧបាយកលទុច្ចរិតដូចជា ពួកគេបានស្នើឱ្យអតិថិជន (កាវ៉ាស់) ទិញរថយន្តពីក្រុមហ៊ុនកុំឱ្យទិញតាមតម្លៃដែលក្រុមហ៊ុនបានកំណត់ គឺឱ្យទិញតាមតម្លៃដែលពួកគេបានស្នើសុំទៅក្រុមហ៊ុនហើយតម្លៃដែលនៅសល់ក្រោយពីពួកគេបានស្នើសុំក្រុមហ៊ុនរួចត្រូវប្រគល់ឱ្យទៅពួកគេវិញ (ក្នុងមួយគ្រឿងពួកគេយកពីអតិថិជនបានចាប់ពី ១០០ ដុល្លារអាមេរិក រហូតដល់ ១០០០ ដុល្លារអាមេរិកក៏មាន) ជាថ្នូរមកវិញចំពោះអតិថិជនគឺអតិថិជនណាដែលព្រមតាមពួកគេ ពួកគេនឹងលក់រថយន្តឱ្យបានមុនគេ ។ បើអតិថិជនណាដែលមិនព្រមតាមពួកគេ គឺពួកគេមិនលក់រថយន្តឱ្យទេ ។ អតិថិជនមួយចំនួនគាត់គិតថា រថយន្តរបស់ក្រុមហ៊ុនក្ងន់ក្ដីខ្លួនស្អាតល្អហើយទិញបានថោក ជាពិសេសបើមានរថយន្តផ្សេងៗមកទៀតគាត់នឹងទទួលបានការបញ្ជាទិញបានមុនអ្នកផ្សេងក៏ធ្វើតាមការកំណត់របស់ពួកគេ ។ បើសិនជាពួកគេមិនមានឧបាយកលប្រើថ្នូរបែបនេះទេ អតិថិជនមិនប្រគល់ប្រាក់ទៅឱ្យពួកគេឡើយ ហើយប្រាក់ទាំងអស់នោះក្រុមហ៊ុននឹងទទួលបានទាំងអស់ ពោលគឺក្រុមហ៊ុននឹងអាចលក់រថយន្តទៅតាមតម្លៃដែលក្រុមហ៊ុនបានកំណត់ ។ ជាមួយគ្នានេះផងដែរដោយសារតែពួកគេបានទទួលសំណូកពីកាវ៉ាស់នីមួយៗធ្វើឱ្យការលក់រថយន្តរបស់ក្រុមហ៊ុនក្ងន់ក្ដីខ្លួនពុំមានលក្ខណៈទូលំទូលាយ ធ្វើឱ្យអ្នកខ្លះចង់ទិញតែទិញមិនបាន ដោយសារតែពួកគេមិនទទួលបានប្រយោជន៍ពីការលក់របស់ពួកគេ (រកចំណូលក្រៅដែលក្រុមហ៊ុនមិនអនុញ្ញាត) ។ អំពើទទួលសំណូកពីអតិថិជន (កាវ៉ាស់) នេះធ្វើឱ្យប៉ះពាល់ដល់កម្រិតនៃការលក់របស់ក្រុមហ៊ុនយ៉ាងខ្លាំង ធ្វើឱ្យបាត់បង់ទំនុកចិត្តពីអតិថិជន ជាពិសេសទៅលើកិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ក្រុមហ៊ុននឹងក្ងន់ក្ដីខ្លួនថាលក់មិនមានតម្លាភាព និងមានអំពើពុករលួយក្នុងក្រុមហ៊ុន ។ សំណូមពរសុំតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ សុំទាមទារប្រាក់សរុបចំនួន ២៧០,០០០ (ម្ភៃប្រាំពីរម៉ឺន) ដុល្លារអាមេរិក និងទាមទារសំណងជម្ងឺចិត្តការខាតបង់ពេលវេលា និងសេវាកម្មច្បាប់ចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ។

### សេចក្ដីសន្និដ្ឋានរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្ដឹងរដ្ឋប្បវេណី

ក្រោយពីបានសួរដេញដោលក្នុងសវនាការ ឃើញថា ជនជាប់ចោទពិតជា បុគ្គលិកបំរើការអោយ ក្រុមហ៊ុន DAC និង ក្រុមហ៊ុន HDC ពិតមែន ដោយជនជាប់ចោទទាំងបីនាក់នេះ មានតួនាទីជាអ្នកគ្រប់គ្រងផ្នែកលក់ និងជាប្រធានផ្នែកលក់ ។ ក្នុងអំឡុងពេលនៃការអនុវត្តផ្នែកលក់ ផ្អែកតាមភស្តុតាងក្នុងសំណុំរឿងឃើញថា ជនជាប់ចោទទាំងបីនាក់មានចេតនាទុច្ចរិតបង្កើតជាក្រុមចាត់តាំងមានគ្នាពនាក់ ហើយនៅក្នុងក្រុមចាត់តាំងនេះអ្នកទាំងបីនាក់នេះបានរៀបចំសេនារិយោច្បាស់លាស់មួយសម្រាប់ទទួលប្រាក់ ពីអតិថិជនដោយ ជនជាប់ចោទចាប់ផ្ដើមនិយាយបញ្ចុះបញ្ចូលជាមួយ Dealer ណាដែលជិតស្និតជាមួយគាត់ ដោយនិយាយបញ្ចុះបញ្ចូលថា ពេលក្រុមហ៊ុនដាក់តម្លៃភ្លាមកុំទាន់ទិញតាមតម្លៃក្រុមហ៊ុនដាក់ឱ្យ ដោយចាំទិញក្នុងតម្លៃណាមួយផ្សេង ចាំក្រុមរបស់គាត់យកតម្លៃនោះទៅចរចារជាមួយក្រុមហ៊ុន ។ ដូច្នេះនៅពេលទទួលបានប្រាក់ ពួកគាត់យកប្រាក់មកចែកគ្នា ដូចមានភស្តុតាងបញ្ជាក់ដូចជា ចម្លើយសារភាពរបស់ឈ្មោះ ក .. និង ចម្លើយសារភាព

របស់ឈ្មោះ ក នៅដំណាក់កាលសមត្ថកិច្ច លុយនេះមិនមែនជាលុយកម្រៃជើងសារដែលគាត់ត្រូវទទួលបាននោះទេ វាជាលុយដែលទទួលបានដោយទុច្ចរិត ។ តាមពិតតម្លៃឡានដែលក្រុមហ៊ុនបានដាក់លក់ គឺអាចធ្វើការលក់បានជូនអតិថិជន ប៉ុន្តែជនជាប់ចោទបែរជាមិនលក់ទៅវិញ ដោយលក់ឲ្យតែអតិថិជនដែលស្តាប់តាមគាត់ បើមិនស្តាប់តាមគាត់មិនលក់ឡានឲ្យទេ ដោយប្រាប់ថា ឡានមិនមានជាដើម ។ បើសិនគាត់លក់ឡាន គាត់អាចមិនទទួលបានប្រាក់ទើបគាត់ប្រើមធ្យោបាយបែបនេះដើម្បីទទួលបានប្រាក់នេះ ។ ទីពីរ លុយដែលគាត់ទទួលបានពីការលក់ឡានគឺពួកគាត់បានធ្វើការចែកប្រាក់ស្មើរគ្នាជាបី ដោយម្នាក់ៗទទួលបានប្រាក់ប្រហែល ៩០.០០០ (ប្រាំបួនម៉ឺន) ដុល្លារអាមេរិក ។ នៅក្នុងសារឆ្លើយឆ្លងរបស់ជនជាប់ចោទ ក៏បានបង្ហាញពីចេតនាឆបោកប្រាក់របស់ក្រុមហ៊ុនដែរ ដូចមានភស្តុតាងដែលខ្លួនបានដាក់ជូនលោកចៅក្រមរួចហើយ ដោយជនជាប់ចោទបាននិយាយថា កុំជួយគាត់ទៅលើតម្លៃខ្លាំងពេក, ប្រសិនបើក្រុមហ៊ុនខាត យើងចំណេញ គឺ OK, ខ្ញុំមិនតឹងតែងលើប្រាក់ចំណេញទេ ឲ្យតែយើងទទួលបាននៅអ្វីដែលយើងចង់បាន, ប្រសិនបើអញ្ចឹង យើងមិនអាចទ្រាំទ្របានទេ សូម្បីគាត់ទិញពីយើងច្រើន យើងគួរឲ្យគាត់ពេលណាដែលមានយាន្តដ្ឋានណាមួយឲ្យតម្លៃយើង, ខ្ញុំនឹងចាប់ផ្តើមគណនាអំពីការងារនេះជារៀងរាល់ថ្ងៃដើម្បីពិនិត្យលើយានដ្ឋានដែលចូលរួម ប្រសិនណាបើគាត់មិនយល់ព្រមតាមតម្រូវការរបស់យើង យើងនឹងគ្រាន់តែលក់តាមតម្លៃក្រុមហ៊ុន នេះបានបង្ហាញ ឲ្យឃើញពីចេតនាទុច្ចរិតរបស់ជនជាប់ចោទ ក្នុងការបោកបញ្ឆោតក្រុមហ៊ុនឲ្យលក់តាមតម្លៃបញ្ចុះបញ្ចូលរបស់គាត់ ដោយអ្នកណាឲ្យលុយគាត់គាត់លក់អោយអ្នកនោះ ។ តាមអ្វីដែលខ្លួនបង្ហាញជូនតុលាការខាងលើ គឺបង្ហាញអំពីចេតនាទុច្ចរិតរបស់ជនជាប់ចោទក្នុងអំពើឆបោក ប៉ុន្តែក្នុងដីកាសម្រេចបញ្ជូនរឿងមកជម្រះរបស់ចៅក្រមស៊ើបសួរ មិនបានបញ្ជូនរឿងពីបទ ឆបោក ទេ បែរជាបញ្ជូនរឿងពីបទ រំលោភលើទំនុកចិត្ត ទៅវិញ ដូច្នេះ ខ្លួនស្នើសុំតុលាការកែប្រែបទចោទប្រកាន់ពីបទរំលោភលើទំនុកចិត្តមកបទល្មើស ឆបោកវិញឲ្យស្របតាមអង្គហេតុ ។ ទីពីរ ចំពោះបទល្មើស ស៊ីសំណូកនៃនយោជិក យើងពិនិត្យមើលទៅលើលក្ខខណ្ឌចំនួន ៣ ,ទីមួយ ជនជាប់ចោទគឺជាបុគ្គលិកក្រុមហ៊ុន ទីពីរ ជនជាប់ចោទបានទទួលសំណូក ដោយជនជាប់ចោទបានសារភាពថា បានទទួលប្រាក់ពីអតិថិជនមែន, ទីបី ទទួលសំណូកហើយដោយមានការសន្យាអោយធ្វើកិច្ចការណាមួយ ឬមិនអោយធ្វើកិច្ចការនាមួយ អនុលោកតាមមាត្រា ២៧៨ បានចែងពីធាតុផ្សំពីបទល្មើសនេះ ជារួមជនជាប់ចោទពិតជាបានទទួលប្រាក់សំណូកពី Dealer មែន ។ ចំពោះសំណង ក្រុមហ៊ុនទាមទារចំនួន ២៧០.០០០ (ម្ភៃប្រាំពីរម៉ឺន) ដុល្លារអាមេរិក តាមតារាង Excel របស់ជនជាប់ចោទឈ្មោះ គ ដោយសារលុយនេះក្រុមហ៊ុនបានខាតបង់ ដោយសារអំពើឆបោករបស់ជនជាប់ចោទទាំងបី ។ ជារួម ផ្អែកតាមអង្គហេតុ និងភស្តុតាងក្នុងសំណុំរឿងឃើញថា មានភស្តុតាងគ្រប់គ្រាន់ដែលបញ្ជាក់ថា ជនជាប់ចោទទាំងបីនាក់ពិតជាបានប្រព្រឹត្តអំពើឆបោក និងស៊ីសំណូកនយោជិក ពិតប្រាកដមែន ស្នើសុំលោកចៅក្រមផ្តន្ទាទោសជនជាប់ ចោទ និងបង្គាប់ឲ្យជនជាប់ចោទរួមគ្នាសងសំណងការខូចខាតចំនួន ២៧០.០០០ (ម្ភៃប្រាំពីរម៉ឺន) ដុល្លារអាមេរិក និងជំងឺចិត្តចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ។

**សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ**

ក្រោយពីបានសួរដេញដោលក្នុងសវនាការ និងក្រោយពីបានពិនិត្យភស្តុតាងផ្សេងៗ ព្រមទាំងចម្លើយ ពាក់ព័ន្ធផ្សេងទៀត ឃើញថា មានធាតុផ្សំបទល្មើសគ្រប់គ្រាន់ អាចដាក់បន្ទុកបានទៅលើជនជាប់ចោទឈ្មោះ ក , ឈ្មោះ ខ និងឈ្មោះ គ ពីបទ ស៊ីសំណូកនៃនិយោជិត និងរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧៨ មាត្រា ៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ។ ហេតុដូចនេះ តំណាងអយ្យការសូមតម្កល់សេចក្តីចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ [redacted] ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ ទុកជាបានការ និងប្តឹងសុំតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីដេញដោលក្នុងសវនាការឃើញថា នៅអំឡុងឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ កូនក្តីខ្ញុំឈ្មោះ ក បានបំរើការងារនៅក្រុមហ៊ុនលក់រថយន្ត ហើយក្នុងអំឡុងពេលដែលបំពេញតួនាទីជាប្រធានផ្នែកលក់ កូនក្តីខ្ញុំបានលក់រថយន្តឲ្យអតិថិជនជាច្រើន ដោយក្នុងចំណោមអតិថិជនទាំងអស់មានអតិថិជនខ្លះបានឲ្យប្រាក់ជា លុយធីប, ប្រាក់ទឹកតែមកកូនក្តីខ្ញុំតិចតួច ហើយប្រាក់នេះគឺប្រាក់ដែលទទួលបានដោយសុច្ចរិត មិនមែនទទួលបានដោយទុច្ចរិតនោះទេ ។ តាមរយៈអង្គហេតុនេះ កូនក្តីខ្ញុំត្រូវបានចោទប្រកាន់ចំនួន ពីរបទល្មើស បទ រំលោភលើទំនុកចិត្ត និងបទ ស៊ីសំណូកនៃនិយោជិក ។ បើពិនិត្យទៅលើអង្គច្បាប់មាត្រា ២៧៨ នៃក្រមព្រហ្មទណ្ឌគឺជា អំពើដែលប្រព្រឹត្តដោយនិយោជិកដែលសុំ ឬយល់ព្រមទទួលអំណោយ, ជំនូន, ការសន្យា ឬអត្ថប្រយោជន៍ណាមួយដើម្បីបំពេញ ឬមិនបំពេញកិច្ចណាមួយនៃមុខងាររបស់ខ្លួនដោយនិយោជកមិនបានដឹងនឹងគ្មានការព្រមព្រៀងពីនិយោជកនោះទេ ត្រូវផ្តន្ទាទោស ០៦ ខែ ទៅ ០២ឆ្នាំ ។ បើប្រៀបធៀបអង្គហេតុមកអង្គច្បាប់គឺមិនស៊ីចង្វាក់គ្នាទេ អង្គហេតុក្នុងសវនាការបានបញ្ជាក់យ៉ាងច្បាស់ថា កូនក្តីខ្ញុំ និងជនជាប់ចោទឈ្មោះ ក បានឆ្លើយបញ្ជាក់ថា អតិថិជនមិនបានឲ្យប្រាក់គាត់ទាំងអស់នោះទេ ថ្នាក់ដឹកនាំក៏បានដឹង ហើយមិនមានការលាក់លៀមនោះទេ ដូច្នេះបើប្រៀបធៀបនឹងមាត្រានេះ ល្គឹកណានិយោជកហាម មិនបានដឹងសោះ ទើបត្រូវផ្តន្ទាទោសតាមមាត្រា ២៧៨ នៃក្រមព្រហ្មទណ្ឌ តាមការអះអាងក្នុងសវនាការឃើញថា កម្រៃជើងសារនេះតិចតួចដែលអតិថិជនឲ្យវាគឺជាទម្លាប់ទៅហើយក្នុងព្រះរាជាណាចក្រកម្ពុជា សូម្បីតែចតឡាន ឬហូបបាយ ក៏អតិថិជនផ្តល់លុយធីបដែរ ដូច្នេះតើអំពើនេះជាអំពើគួរផ្តន្ទាទោស ឬទេ ? ហើយការទិញរថយន្ត កូនក្តីខ្ញុំជួយមើលរថយន្ត ផ្តល់ព័ត៌មានត្រឹមត្រូវជូនអតិថិជន ហើយអតិថិជនផ្តល់ប្រាក់ចំនួន ១០០ ទៅ ១៥០ ដុល្លារ ចែកគ្នាបីនាក់ ហើយរយៈពេល ០២ ឆ្នាំកូនក្តីខ្ញុំទទួលបានប្រាក់ចំនួន ពីរម៉ឺនដុល្លារជាងគឺសមហេតុផលហើយ ប៉ុន្តែប្រាក់នេះ មិនមែនជាប្រាក់ដែលក្រុមហ៊ុនបាត់បង់នោះទេ ដូច្នេះ យោងតាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកាលណារកមិនឃើញកំហុសរបស់ជនជាប់ចោទត្រូវតែប្រកាស់ឲ្យរួចផុតពីបទចោទ ដូច្នេះបទល្មើស ស៊ីសំណូកនៃនិយោជិក ខ្ញុំសូមស្នើសុំលោកចៅក្រមសម្រេចលើកលែងចោទប្រកាន់មកលើកូនក្តីខ្ញុំ ។ បទល្មើស ទីពីរ ក្នុងអង្គហេតុដែលកូនក្តីខ្ញុំត្រូវបានចោទប្រកាន់ពីបទ រំលោភលើទំនុកចិត្ត យោងតាមមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តិថា អំពើរំលោភលើទំនុកចិត្តគឺជាអំពើកែបំបាត់ មូលនិធិ, តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ នាំឲ្យខូចប្រយោជន៍អ្នកដទៃប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឲ្យបុគ្គលនោះ ហើយបុគ្គលនោះ បានយល់ព្រមដោយមានការកិច្ចប្រគល់សងវិញ បង្ហាញ ឬ យកមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់ ។ ក្នុងអង្គហេតុនេះ កូនក្តីខ្ញុំបានទទួលប្រាក់ដោយផ្ទាល់ពីអតិថិជនដែលមកទិញរថយន្ត តើធ្វើឲ្យខូចផលប្រយោជន៍ក្រុមហ៊ុន ទេ ? តើគាត់មានកាតព្វកិច្ច យកប្រាក់ពីអតិថិជនឲ្យគាត់ទៅសងក្រុមហ៊ុនវិញទេ ? តើមានកាតព្វកិច្ចត្រូវសងថ្លៃអតិថិជន វិញទេ ? ជាការពិតគឺមិនមានទេ ដូច្នេះកូនក្តីខ្ញុំគ្មានកំហុសតាមការចោទប្រកាន់តាមមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌទេ ។ ជារួម ស្នើសុំលោកចៅក្រមជំនុំជម្រះសម្រេចឲ្យកូនក្តីខ្ញុំឈ្មោះ ក រួចផុតពីបទចោទប្រកាន់ពីបទស៊ីសំណូកនៃនិយោជិត និងបទ រំលោភលើទំនុកចិត្ត ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ ក បានសំណូមពរឲ្យតុលាការរកយុត្តិធម៌ឲ្យខ្លួនផង ។

ជនជាប់ចោទឈ្មោះ ខ បានសំណូមពរសុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង ។

ជនជាប់ចោទឈ្មោះ គ វានអវត្តមាននាពេលសវនាការ ។

ក្រោយពីសួរដេញដោលក្នុងអង្គសវនាការ

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាងនិងពិចារណាលើសំណុំរឿងត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

-តាមដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ [redacted] ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ ចៅក្រមស៊ើបសួរបានបញ្ជូនជនជាប់ចោទឈ្មោះ ក ឈ្មោះ ខ និងឈ្មោះ គ ទៅជំនុំជម្រះពីបទ **ស៊ីសំណូកនៃនិយោជិត និង រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧៨ មាត្រា ៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ ក បានទទួលស្គាល់ថា ជនជាប់ចោទពិតជាមានតួនាទីជាប្រធានផ្នែកលក់នៅក្នុងក្រុមហ៊ុន ហើយជនជាប់ចោទពិតជាបានទទួលប្រាក់ពីអតិថិជនដែលបានទិញឡានមួយទឹកពីក្រុមហ៊ុនមែន ប៉ុន្តែប្រាក់ទាំងនោះជាទឹកចិត្តដែលអតិថិជនប្រគល់ជូនប៉ុណ្ណោះ និងមិនមែនជាថ្នូរនឹងការលក់រថយន្តនោះទេ ព្រោះជនជាប់ចោទមិនមែនជាអ្នកសម្រេចលក់រថយន្តជូនអតិថិជននោះទេ ។

-ជនជាប់ចោទឈ្មោះ គ បានទទួលស្គាល់ថា ជនជាប់ចោទពិតជាមានតួនាទីជាអ្នកគ្រប់គ្រងផ្នែកលក់នៅក្រុមហ៊ុន មែន ហើយជនជាប់ចោទពិតជាបានទទួលប្រាក់ពីអតិថិជនដែលបានទិញឡានមួយទឹកពីក្រុមហ៊ុន ពិតមែន ប៉ុន្តែប្រាក់ទាំងនោះជាទឹកចិត្តដែលអតិថិជនប្រគល់ជូនប៉ុណ្ណោះ និងមិនមែនជាថ្នូរនឹងការលក់រថយន្តនោះទេ ព្រោះជនជាប់ចោទមិនមែនជាអ្នកសម្រេចលក់រថយន្តជូនអតិថិជននោះទេ ។

-តាមចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់សាក្សី ចម្លើយរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងដែលមានក្នុងសំណុំរឿងមានភាពស៊ីសង្វាក់ក្នុងការបញ្ជាក់ថា កាលពីអំឡុងឆ្នាំ២០១៨ រហូតដល់ឆ្នាំ ២០២០ នៅរាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ ក ជាប្រធានក្រុមការងារបណ្តាញលក់ ក្នុង ក្រុមហ៊ុន HDC ឈ្មោះ ខ ជាអ្នកគ្រប់គ្រងការលក់ នៅក្នុង ក្រុមហ៊ុន DAC និងជាប្រធានផ្នែកលក់ជាន់ខ្ពស់ក្នុង ក្រុមហ៊ុន HCD ព្រមទាំងឈ្មោះ គ ជាប្រធានផ្នែកលក់ជាន់ខ្ពស់ នៅក្នុង ក្រុមហ៊ុន DAC និង ក្រុមហ៊ុន DAC ដែលបានដឹងយ៉ាងច្បាស់អំពីគោលការណ៍ និងផែនការណ៍នានារបស់ក្រុមហ៊ុននៅក្នុងការលក់រថយន្ត ប៉ុន្តែជនជាប់ចោទបែរជាឃុបឃិតគ្នាទទួលប្រាក់ដោយខុសច្បាប់ពីអតិថិជន ដើម្បីបញ្ចុះបញ្ចូលក្រុមហ៊ុនឱ្យលក់រថយន្តទៅតែអតិថិជនណាដែលព្រមព្រៀងប្រគល់នូវប្រាក់ដោយខុសច្បាប់ឱ្យពួកគេ ក្នុងតម្លៃថោកជាងតម្លៃដែលក្រុមហ៊ុនកំណត់ ហើយបានបណ្តាលឱ្យក្រុមហ៊ុនខាតបង់នូវប្រាក់ជាច្រើនដោយសារសកម្មភាពល្មើសរបស់ពួកគេ ។

-បើទោះបីជាជនជាប់ចោទបានឆ្លើយបដិសេធថា ប្រាក់ដែលពួកគេទទួលពីអតិថិជនមិនមែនជាប្រាក់សំណូក តុលាការយល់ឃើញថា គ្រាន់តែជាការឆ្លើយដោះសារដើម្បីរួចផុតពីការទទួលខុសត្រូវប៉ុណ្ណោះ មិនអាចឱ្យតុលាការជឿជាក់បានឡើយ ។ យោងតាមឯកសារភស្តុតាងដែលជាសារឆ្លងឆ្លើយរវាងជនជាប់ចោទទាំងបីនាក់ក្នុងប្រព័ន្ធបណ្តាញសង្គមរបស់ពួកគេបានបង្ហាញយ៉ាងច្បាស់ថា ជនជាប់ចោទទាំងបីនាក់ពិតជាមានចេតនាទុច្ចរិតឃុបឃិតគ្នាដោយតម្រូវឱ្យអតិថិជនបង់នូវប្រាក់ជូនពួកគេដើម្បីអាចទទួលបាននូវការលក់ទិញក្រោមតម្លៃដែលក្រុមហ៊ុនបានកំណត់ ដោយមិនខ្វល់អំពីការខាតបង់របស់ក្រុមហ៊ុនឡើយ ។

-យោងតាមមាត្រា ២៧៨ នៃក្រមព្រហ្មទណ្ឌ អំពើប្រព្រឹត្តដោយនិយោជិតដែលសុំ ឬ យល់ព្រមទទួលអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍ណាមួយដើម្បីបំពេញ ឬ មិនបំពេញកិច្ចណាមួយនៃមុខងាររបស់ខ្លួនដោយនិយោជកមិនបានដឹង និងគ្មានការព្រមព្រៀងពីនិយោជកទេនោះ គឺជាបទល្មើស ស៊ីសំណូកនៃនិយោជិត ។

-អំពើរបស់ជនជាប់ចោទឈ្មោះ ក ឈ្មោះ ខ និងឈ្មោះ គ ដែលជានិយោជិតនៅក្នុង ក្រុមហ៊ុន DAC និង ក្រុមហ៊ុន HCD ដែលទាមទារ និងទទួលនូវអំណោយជាប្រាក់ពីអតិថិជនរបស់ក្រុមហ៊ុនដោយក្រុមហ៊ុនមិនបានដឹងទាល់តែសោះ ដើម្បីពួកគេប្រើប្រាស់នូវមុខងាររបស់ពួកគេដែលគ្រប់គ្រងការលក់ទាំងអស់ក្នុងក្រុមហ៊ុន បញ្ចុះបញ្ចូលក្រុមហ៊ុនដែលជានិយោជករបស់ពួកគេឱ្យលក់នូវរថយន្តក្រោមតម្លៃដែលក្រុមហ៊ុនបានកំណត់ ។ សកម្មភាពទាំងអស់នេះជាបទល្មើសស៊ីសំណូកនៃនិយោជិត បទល្មើសព្រហ្មទណ្ឌ មានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧៨ នៃក្រមព្រហ្មទណ្ឌ ។

-យោងតាមមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ អំពើកែបំបាត់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ នាំឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឱ្យបុគ្គលនោះហើយបុគ្គលនោះបានយល់ព្រមដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬ យកមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់ គឺជាបទល្មើស រំលោភលើទំនុកចិត្ត ។

-អំពើរបស់ជនជាប់ចោទឈ្មោះ ក ឈ្មោះ ខ និងឈ្មោះ គ ដែលទាមទារ និងទទួលនូវអំណោយជាប្រាក់ពីអតិថិជនរបស់ក្រុមហ៊ុន ដើម្បីពួកគេប្រើប្រាស់នូវមុខងាររបស់ពួកគេដែលគ្រប់គ្រងការលក់ទាំងអស់ក្នុងក្រុមហ៊ុន បញ្ចុះបញ្ចូលក្រុមហ៊ុនដែលជានិយោជករបស់ពួកគេឱ្យលក់នូវរថយន្តក្រោមតម្លៃដែលក្រុមហ៊ុនបានកំណត់ ដែលបានបណ្តាលឱ្យក្រុមហ៊ុនបានខាតបង់នូវប្រាក់ មិនមានធាតុផ្សំជាបទល្មើសរំលោភលើទំនុកចិត្តនោះទេ ។ អំពើរំលោភលើទំនុកចិត្ត តម្រូវឱ្យជនជាប់ចោទដែលបានទទួលនូវការប្រគល់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬយកមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះទៅធ្វើការប្រើប្រាស់ជាកំណត់ ធ្វើការកែបំបាត់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ។ នៅក្នុងអង្គហេតុជនជាប់ចោទទាំងបីនាក់មិនមានការកែបំបាត់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះទេ ។ ដូចនេះ មិនមានធាតុផ្សំជាបទល្មើសរំលោភលើទំនុកចិត្តនោះទេ ។

-ជនជាប់ចោទជានីតិជន នាពេលប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពដែលអាចយល់ដឹងអំពីលទ្ធផលតាមផ្លូវច្បាប់ចំពោះអំពើរបស់ខ្លួនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ និងមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីមានហេតុផលត្រឹមត្រូវតាមច្បាប់មួយចំនួន អាចឱ្យតុលាការពិចារណាបាន តែបដិសេធលើចំណុចមួយចំនួន ។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទមិនមានហេតុផលត្រឹមត្រូវតាមច្បាប់ មិនអាចឱ្យតុលាការពិចារណាបាន ។

-មានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ក ឈ្មោះ ខ និងឈ្មោះ គ ពីបទ **ស៊ីសំណូកនៃនិយោជិត** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧៨ នៃក្រមព្រហ្មទណ្ឌ ។

-មិនមានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ក ឈ្មោះ ខ និងឈ្មោះ គ ពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ៣៩១ និង មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងទាមទារឱ្យជនជាប់ចោទរួមគ្នាសងប្រាក់ ដែលខ្លួនបានបាត់បង់សរុបចំនួន ២៧០.០០០ (ពីររយចិតសិបពាន់) ដុល្លារអាមេរិក និងជម្ងឺចិត្តការខាតបង់ពេលវេលា និងសេវាកម្មច្បាប់ចំនួន

១០០.០០០ (មួយរយពាន់) ដុល្លារអាមេរិក ។ ជនជាប់ចោទឈ្មោះ ក និងជនជាប់ចោទឈ្មោះ ក បានបដិសេធចំពោះការទាមទារនេះ និងបានលើកឡើងថា ជនជាប់ចោទមិនបានទទួលនូវប្រាក់ពីអតិថិជនរហូតដល់ចំនួន ២៧០.០០០ (ពីររយចិតសិបពាន់) ដុល្លារអាមេរិក ដូចដើមបណ្ដឹងរដ្ឋប្បវេណីទាមទារនោះទេ ។ ប៉ុន្តែយោងតាមលិខិតសំទោស ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ ដែលមានស្នាមម្រាមដៃរបស់ឈ្មោះ ក បានបង្ហាញថា ជនជាប់ចោទពិតជាបានទទួលនូវប្រាក់ចំនួន ២៧០.០០០ (ពីររយចិតសិបពាន់) ដុល្លារអាមេរិក ពីអតិថិជន មែន ។ បន្ថែមពីលើនេះទៀត បើយោងតាមបញ្ជីគណនេយ្យសាច់ប្រាក់ដែលជនជាប់ចោទទទួលបានដោយខុសច្បាប់ពីអតិថិជនដែលជនជាប់ចោទឈ្មោះ ក ជាអ្នកធ្វើដោយខ្លួនឯង និងរក្សាទុកនៅក្នុងកំព្យូទ័រដែលជនជាប់ចោទប្រើប្រាស់នៅក្នុងក្រុមហ៊ុនក៏បានបង្ហាញផងដែរថា ជនជាប់ចោទបានទទួលប្រាក់ចំនួន ២១.៩០០ (ម្ភៃមួយពាន់ និងប្រាំបួនរយ) ដុល្លារអាមេរិក នៅឆ្នាំ ២០១៨ ចំនួន ២៣៦.៣០៧,៥០ (ពីររយសាមសិបប្រាំមួយពាន់ និងបីរយប្រាំពីរ ក្បៀសហាសិប) ដុល្លារអាមេរិក នៅឆ្នាំ ២០១៩ និងចំនួន ៣.៨០០ (បីពាន់ប្រាំបីរយ) ដុល្លារអាមេរិក នៅឆ្នាំ ២០២០ ពីអតិថិជន ។ ហេតុដូចនេះ ចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ គ និងឈ្មោះ ក មិនអាចឱ្យតុលាការជឿជាក់បានឡើយ ។ តាមលទ្ធផលនៃការពិភាក្សាដេញដោលឃើញថា កន្លងមក ភាគីដើមបណ្ដឹងរដ្ឋប្បវេណីធ្លាប់ទទួលបាននូវការសងនូវប្រាក់ចំនួន ១៥.០០០ (ដប់ប្រាំពាន់) ដុល្លារអាមេរិក ពីជនជាប់ចោទឈ្មោះ ក ។ ដូចនេះគប្បីតុលាការដកចេញនូវប្រាក់ចំនួន ១៥.០០០ (ដប់ប្រាំពាន់) ដុល្លារអាមេរិក ចេញពីទឹកប្រាក់ទាមទារចំនួន ២៧០.០០០ (ពីររយចិតសិបពាន់) ដុល្លារអាមេរិក ។ ក្រៅអំពីការខូចខាតជាក់ស្ដែង អំពើរបស់ជនជាប់ចោទដែលបានឃុបឃិតគ្នានេះបានបង្កការខាតបង់យ៉ាងធ្ងន់ធ្ងរដល់ដំណើរការក្រុមហ៊ុនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រមទាំងធ្វើឱ្យក្រុមហ៊ុនបាត់បង់នូវអតិថិជនជាបន្តបន្ទាប់ បន្ថែមពីលើនេះទៀត ក្រុមហ៊ុនក៏ត្រូវចំណាយពេលវេលា និងសោហ៊ុយលើសេវាកម្មច្បាប់ផងដែរ ។ ប៉ុន្តែដោយហេតុថា ភាគីដើមបណ្ដឹងរដ្ឋប្បវេណីក៏មិនមានភស្តុតាងច្បាស់លាស់ដើម្បីគាំទ្រនូវការទាមទារផងនោះ តុលាការនឹងពិចារណាសម្រេចអំពីចំនួននៃសំណងជំងឺចិត្ត ការខាតបង់ពេលវេលា ព្រមទាំងសេវាកម្មច្បាប់តាមជាក់ស្ដែង ។

## ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្ដី

១-ឱ្យឈ្មោះ ក ឈ្មោះ ខ និងឈ្មោះ គ ដែលមានអត្តសញ្ញាណខាងលើ រួចផុតបទចោទ ពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

២-ផ្ដន្ទាទោស ឈ្មោះ ក ឈ្មោះ ខ និងឈ្មោះ ក ដែលមានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ១៦ (ដប់ប្រាំមួយ) ខែ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល ០៨ (ប្រាំបី) ខែ ទោសនៅសល់ត្រូវព្យួរ តាមបញ្ញត្តិស្ដីពីការព្យួរទោសធម្មតា នៃក្រមព្រហ្មទណ្ឌ ពីបទ ស៊ីសំណូកនៃនិយោជិត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៧៨ នៃក្រមព្រហ្មទណ្ឌ ។

៣-បង្គាប់ឱ្យឈ្មោះ ក ឈ្មោះ ខ និងឈ្មោះ ក ដែលមានអត្តសញ្ញាណខាងលើ រួមគ្នាសងនូវប្រាក់ដែលបានបាត់បង់ចំនួន ២៥៥.០០០ (ពីររយហាសិបប្រាំពាន់) ដុល្លារអាមេរិក និងការខូចខាតផ្សេងទៀតចំនួន ៥០.០០០ (ហាសិបពាន់) ដុល្លារអាមេរិក ទៅដើមបណ្ដឹងរដ្ឋប្បវេណី

ក្រុមហ៊ុន DAC តំណាងដោយឈ្មោះ ឈ និង

ក្រុមហ៊ុន HDC តំណាងដោយឈ្មោះ

ការទាមទារលើសពីនេះច្រានចោល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ ក និងឈ្មោះ ក និងកំបាំងមុខជនជាប់ចោទឈ្មោះ ខ និងដើមបណ្ដឹងរដ្ឋប្បវេណី [illegible]

ក្រុមហ៊ុន DAC តំណាងដោយលោក សាយ
និង ក្រុមហ៊ុន HDC តំណាង
ដោយលោកស្រី ...ទំប្រកាសជាសាធារណៈ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ទុកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រាក្រឡាបញ្ជី [redacted] | ហត្ថលេខា និងត្រាចៅក្រម [redacted] |

| | |
|---|---|
| **បានឃើញ** | **បានចម្លងត្រឹមត្រូវតាមច្បាប់ដើម** |
| ថ្ងៃអង្គារ ១០កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥ | ថ្ងៃអង្គារ ១០កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥ |
| រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ | រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ |
| [redacted] | [redacted] |

**ឧបសម្ព័ន្ធទី ១០**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

សាលក្រមព្រហ្មទណ្ឌ

-លេខ [redacted]

ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១

-សំណុំរឿងព្រហ្មទណ្ឌលេខ [redacted]

ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០

-សំណុំរឿងស៊ើបសួរលេខ [redacted]

ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០

-សំណុំរឿងជំនុំជម្រះលេខ [redacted]

ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង០៨ព្រឹក នៅសាលសវនាការទី៤ ដោយមានសមាសភាពជំនុំជម្រះ ៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ ៖

-ឈ្មោះ [redacted] ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតសង្កាត់បឹងកេងកង៣ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះគ្មានលេខ ផ្លូវបេតុង ភូមិស្នាប់តាអោន ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] "ស្លាប់" ម្ដាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ជានីតិជន ។ ប្រវត្តិនៃការផ្ដន្ទាទោសពីមុន ធ្លាប់ជាប់ពន្ធនាគារខេត្តកណ្ដាលរយៈពេល១ឆ្នាំ ពីបទ៖ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ។ (ក្នុងឃុំ)

- ឃុំខ្លួននៅ(ម១) តាមដីកាលេខ [redacted] ចុះថ្ងៃទី១៣/១០/២០២០

ជាប់ចោទពីបទ៖ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខផ្ទះគ្មានលេខ ផ្លូវជាតិលេខ១ ភូមិជ្រោយអំពិល២ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

## <u>អង្គហេតុនៃរឿងមានដូចតទៅ</u>

កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង២៣និង០០នាទី កម្លាំងប៉ុស្ដិ៍នគរបាលរដ្ឋបាលក្បាលកោះនៃអធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅបានចុះល្បាតក្នុងមូលដ្ឋានលុះមកដល់ចំណុចមុខផ្ទះគ្មានលេខ ផ្លូវជាតិលេខ១ ភូមិជ្រោយអំពិល២ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ក៏ប្រទះឃើញជនត្រូវចោទឈ្មោះ [redacted] ដោយមានការសង្ស័យសមត្ថកិច្ចក៏ឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] និងត្រួតពិនិត្យរក

ឃើញក្រាមពណ៌សថ្លាចំនួន៣កញ្ចប់ដែលលាក់ទុកក្នុងហោប៉ៅខោមុខខាងស្តាំ បន្ទាប់មកសមត្ថកិច្ចក៏ឃាត់ខ្លួនជនត្រូវចោទ រួមទាំងវត្ថុតាងតែម្តង ។

-បានឃើញរបាយការណ៍សំយោគលេខ [redacted] ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ [redacted] ចុះថ្ងៃ១៤ ខែមករា ឆ្នាំ២០២១ ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ [redacted] ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ។

-បានឃើញកំណត់ហេតុទទួលវត្ថុចាប់យកលេខ [redacted] ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ។

## <u>នាពេលសវនាការ</u>

-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] នៅចៅក្រមស៊ើបសួរបានឆ្លើយថា៖ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង៩យប់ខ្ញុំបានទៅទិញថ្នាំញៀនពីមនុស្សស្រីមិនស្គាល់ឈ្មោះម្នាក់នៅម្តុំពេទ្យលោកសង្ឃចំនួន៣កញ្ចប់តូចក្នុងតម្លៃ៤៥,០០០រៀល ហើយពេលខ្ញុំមកដល់ចំណុចក្បាលកោះស្រាប់តែមាននគរបាលធ្វើការឆែកឆេរ និងត្រួតពិនិត្យគ្រឿងញៀន និងបានធ្វើការឆែកឆេររកឃើញថ្នាំញៀនចំនួន៣កញ្ចប់ ។ ខ្ញុំទិញគ្រឿងញៀនក្នុងគោលបំណងយកទៅប្រើប្រាស់ប៉ុណ្ណោះ ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានសុំរក្សាបទចោទប្រកាន់លើឈ្មោះ [redacted] ពីបទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារនានាក្នុងសំណុំរឿង

**ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

## <u>យល់ឃើញថា</u>

-កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង២៣និង០០នាទី ពិតជាមានករណី **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** មួយបានកើតឡើងនៅចំណុចមុខផ្ទះគ្មានលេខ ផ្លូវជាតិលេខ១ ភូមិជ្រោយអំពិល២ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៤ឆ្នាំ បានរក្សាទុកថ្នាំញៀននៅនឹងខ្លួនដើម្បីទុកប្រើប្រាស់ប្រាកដមែន ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថាខ្លួនពិតជាបានទិញថ្នាំញៀនចំនួន៣កញ្ចប់តម្លៃ៤៥,០០០រៀលដើម្បីយកមកទុកប្រើប្រាស់ប្រាកដមែន ។ ឃើញថាចម្លើយនេះមានភាពស៊ីសង្វាក់នឹងចម្លើយដែលបានឆ្លើយនាពេលកន្លងមក នោះអាចឱ្យតុលាការជឿជាក់បាន ។

-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ [redacted] ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ឃើញថាថ្នាំញៀនដែលបានដកហូតបានពីជនជាប់ចោទ ជាលទ្ធផលវិជ្ជមាន និងសន្និដ្ឋានថាសំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅថ្លាឈ្មោះ មេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធ ៧៨,៩១% នៃទម្ងន់សរុបស្ថិតក្នុងតារាងទី២មាត្រា៥ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។ ដូចនេះការ

គណនាភាពសុទ្ធគ្រឿងញៀនដែលដកហូតបានពីជនជាប់ចោទមានទម្ងន់សរុប ០,៣៧ (សូន្យក្បៀសសាមសិបប្រាំពីរ) ក្រាម វត្ថុមានសារធាតុញៀនឈ្មោះមេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់សរុបបង្ហាញឲ្យឃើញថា(០,៣៧ x៧៨,៩១)៖១០០=០,២៩១៩៦៧ នោះបរិមាណភាពសុទ្ធរបស់វាមានប្រហែល ០,២ (សូន្យក្បៀសពីរ)ក្រាម ហេតុនេះគប្បីតុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់ ។

-មានភាពស៊ីសង្វាក់គ្នារវាងចម្លើយសារភាពរបស់ជនជាប់ចោទ វត្ថុតាងដែលដកហូតបានពីជនជាប់ចោទ និងតាមការពិនិត្យឯកសារជាភស្តុតាងផ្សេងៗ ទៀតក្នុងសំណុំរឿងអាចឲ្យតុលាការកំណត់បាននៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៤ឆ្នាំ ពិតជាបានរក្សាទុកថ្នាំញៀននៅក្នុងខ្លួនដើម្បីទុកប្រើប្រាស់ប្រាកដមែន ។

-អំពើរបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់ដល់សុខភាព សណ្តាប់ធ្នាប់សង្គម និងរបៀបរៀបរយសាធារណៈដែលច្បាប់បានកំណត់ជាបទល្មើស **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ដោយមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-ជនជាប់ចោទឈ្មោះ [redacted] ជានីតិជនដែលមាននីតិសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណណាមួយដែលនាំឲ្យមានមន្ទិលសង្ស័យថាជននេះមានវិបល្លាសស្មារតីកើតចេញពីអំពើរបស់ខ្លួនដែលស្ថិតក្នុងលក្ខខណ្ឌនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ហេតុនេះត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន ។

-មានភស្តុតាង ពិរុទ្ធភាព និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតសង្កាត់បឹងកេងកង៣ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះគ្មានលេខ ផ្លូវបេតុង ភូមិស្នាប់តាអោន ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ជានីតិជន ។ ប្រវត្តិនៃការផ្តន្ទាទោសពីមុន ធ្លាប់ជាប់ពន្ធនាគារខេត្តកណ្តាលរយៈពេល១ឆ្នាំ ពីបទ៖ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ។ ពីបទ៖ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខផ្ទះគ្មានលេខ ផ្លូវជាតិលេខ១ ភូមិជ្រោយអំពិល២ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-វត្ថុតាងដែលចាប់យករួមមាន៖ គ្រឿងញៀនប្រភេទមេតំហ្វេតាមីនទម្ងន់ ០,៣៧ក្រាម និងថង់ប្លាស្ទិកចំនួន៣ ដែលដកហូតបានពីជនជាប់ចោទ គប្បីសម្រេចរឹបអូសដាច់ខាតតាមមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានគឺស្នើសុំឲ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ដូចនេះគប្បីតុលាការលើកយកមកពិចារណា និងសម្រេចតាមច្បាប់ ។

## <u>ហេតុដូច្នេះសម្រេច</u>

១.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន **០២(ពីរ)ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **៤,០០០,០០០(បួនលាន)រៀល** តែទោសនេះត្រូវអនុវត្តទោសដាក់ពន្ធនាគាររយៈពេល **៨ខែ១៥ថ្ងៃ(ប្រាំបីខែដប់ប្រាំថ្ងៃ)** ទោសសល់ពីនេះត្រូវព្យួរសាកល្បងរយៈពេល១ឆ្នាំ ពីបទ ៖ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខផ្ទះគ្មានលេខ ផ្លូវជាតិលេខ១ ភូមិជ្រោយអំពិល២ សង្កាត់ក្បាលកោះ ខណ្ឌច្បារ

អំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២.ចំពោះការអនុវត្តទោសសាកល្បងខាងលើមានអានុភាពដូចខាងក្រោម ៖

២.១-បង្គាប់ឲ្យដាក់ទណ្ឌិតខាងលើឲ្យស្ថិតក្រោមវិធានការត្រួតពិនិត្យមួយចំនួនដូចខាងក្រោម ៖

ក.ទណ្ឌិតត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញាឬរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ។

ខ.ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ។

គ.ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យនូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ជូនឲ្យទៅរស់នៅក្នុងសង្គមវិញ។

ឃ.ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន។

ង.ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន។

ច.ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញាមុនពេលធ្វើដំណើរទៅបរទេស។

២.២-បង្គាប់ឲ្យដាក់កាតព្វកិច្ចឃ្លាំមើលខ្សែកទៅលើទណ្ឌិតខាងលើមានដូចខាងក្រោម ៖

ក.ឲ្យទទួលការពិនិត្យ និងព្យាបាលគ្រឿងញៀននៅមជ្ឈមណ្ឌលបន្សាបថ្នាំញៀន ។

ខ.មិនត្រូវធ្វើសកម្មភាពទាំងឡាយណាដែលផ្ទុយនឹងច្បាប់ ។

គ.មិនត្រូវសេពគប់ជាមួយមិត្តភក្តិ ឬជនដែលប្រើប្រាស់ រក្សាទុក និងជួញដូរគ្រឿងញៀន ។

៣.វត្ថុតាងដែលចាប់យកមាន៖ គ្រឿងញៀនប្រភេទមេតំហ្វេតាមីនទម្ងន់ ០,៣៧ក្រាម និងថង់ប្លាស្ទិកចំនួន៣ សម្រេចរឹបអូសដាច់ខាត តាមមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទ ។ បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា៖ [redacted] | ហត្ថលេខា និងត្រា៖ [redacted] |

---

*"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"*

ថ្ងៃអង្គារ១៣រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

**ក្រឡាបញ្ជីសវនាការ**

**ឧបសម្ព័ន្ធទី ១១**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**តុលាការរដ្ឋប្បវេណី**

សំណុំរឿងលេខ [redacted]

ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១

សាលក្រមលេខ: [redacted]

ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២

**សាលក្រម**

**ក្នុងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២

**ចៅក្រមជំនុំជំរះ**

លោក [redacted] ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើមចោទ [redacted] មានអាសយដ្ឋាននៅផ្ទះលេខ៨៤ ផ្លូវលេខ៦០៦ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ តំណាងដោយលោក [redacted]។

មានលោកមេធាវី [redacted] អត្តលេខ [redacted] ជាមេធាវីនៃ ក្រុមមេធាវី នីតិ មានអាសយដ្ឋាននៅអគារ K Space ជាន់ទី៨ លេខ២០ ផ្លូវលេខ២៨៩ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាមេធាវីតំណាងដោយអាណត្តិ។

ចុងចម្លើយ សហជីពឯករាជ្យការពារកម្មករនៃ [redacted] ដែលមានតំណាងឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៦៧ អាយុ ៥៤ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ២T ផ្លូវលំ ភូមិជម្ពូវ័ន្ត សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

មានលោកមេធាវី [redacted] អត្តលេខ [redacted] និងលោកស្រីមេធាវី [redacted] អត្តលេខ [redacted] ជាមេធាវីនៃការិយាល័យមេធាវី អេស អ៊ិន អេ មានអាសយដ្ឋាននៅ J-Tower Condominium south BKK1 ជាន់ទី៤ ផ្ទះលេខ២៦៣ ផ្លូវលេខ៦៣ ភូមិ១៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីតំណាងដោយអាណត្តិ។

**អង្គហេតុ និងចំណុចវិវាទ**

**ក-ខ្លឹមសារនៃសាលក្រមដែលសហដើមចោទទាមទារឲ្យតុលាការចេញ**

១-រំលាយ [redacted] ស៊ីស្ទីម។

២-បង្គាប់ឲ្យចុងចម្លើយសងជម្ងឺចិត្តចំនួន ៥,០០០,០០០ (ប្រាំលាន) រៀល ទៅដើមចោទ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

## ខ-ដំណើររឿងក្តី និងចំណុចវិវាទ

### ខ.១-ការសង្ខេបអំពីរឿងក្តី

ឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted] ជាបុគ្គលិកក្រុមហ៊ុនផ្នែកសន្តិសុខរបស់ [redacted] នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១ ឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted] បានដាក់សេចក្តីថ្លែងការណ៍ស្តីពីគោលបំណងបង្កើតសហជីពប្រចាំ [redacted] ឈ្មោះសហជីពឯករាជ្យការពារកម្មករនៃ [redacted] ទៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីសុំចុះបញ្ជីការ ។ នៅក្នុងសេចក្តីថ្លែងការណ៍នោះឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted] បានផ្តល់ឈ្មោះនិយោជិត ចំនួន១០ នាក់ ក្នុងនោះរួមមានឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted],ឈ្មោះ [redacted], ឈ្មោះ [redacted] ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ថាជាអ្នកចូលរួមបង្កើតសហជីព ។ នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញវិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ [redacted] ទទួលស្គាល់សហជីពឯករាជ្យការពារកម្មករ នៃ [redacted] ។ ដោយសារឈ្មោះ [redacted] មិនបានចូលរួមក្នុងការស្នើសុំបង្កើតសងជីព នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ ឈ្មោះ [redacted] បានដាក់ពាក្យបណ្តឹងប្តឹងឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted] ពីបទ ក្លែងលិខិតកជនទៅស្នងការនគរបាលរាជធានីភ្នំពេញ និងបានដាក់ពាក្យបណ្តឹងទៅនាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រនៃអគ្គស្នងការនគរបាលជាតិ ដើម្បីសុំធ្វើកោសល្យវិច័យលើស្នាមមេដៃនិងហត្ថលេខារបស់ខ្លួន លើលិខិតស្នើសុំអន្តរាគមន៍ទៅនាយកដ្ឋានវិវាទការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេចក្តីថ្លែងការណ៍ ដែលឈ្មោះ [redacted] , ឈ្មោះ [redacted] និងឈ្មោះ [redacted] បានដាក់ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើតសហជីព ។ នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ នាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ នៃអគ្គស្នងការនគរបាលជាតិ បានចេញចម្លងរបាយការណ៍កោសលវិច័យដោយសន្និដ្ឋានថា ១.ស្នាមមេដៃលើលិខិតស្នើសុំអន្តរាគមន៍ទៅនាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនមែនជាស្នាមមេដៃ ឈ្មោះ [redacted] ឡើយ ២.ហត្ថលេខាលើសេចក្តីថ្លែងការណ៍ ដែលឈ្មោះ [redacted],ឈ្មោះ [redacted] និងឈ្មោះ [redacted] បានដាក់ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីសុំចុះបញ្ជីសហជីព ក៏មិនមែនជាហត្ថលេខារបស់ ឈ្មោះ [redacted] ដែរ ។ នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ [redacted] បានចេញលិខិតជូនដំណឹងទៅ ឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ ប៊ុន អេងស្រួ អំពីការព្យួរកិច្ចសន្យាការងារជាមួយក្រុមហ៊ុន គិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ និងបានដាក់បណ្តឹងមកតុលាការដើម្បីសុំរំលាយសហជីពឯករាជ្យការពារកម្មករនៃ [redacted]។

### ខ.២-អង្គហេតុដែលអះអាងដោយដើមចោទ

[redacted] តំណាងដោយឈ្មោះ [redacted] ដែលមាន[illegible] [redacted] ជាមេធាវីតំណាងដោយអាណត្តិ បានធ្វើការអះអាងថា: មូលហេតុដែលកូនក្តីខ្ញុំស្នើសុំរំលាយ

សហជីពឯករាជ្យការពារកម្មករ នៃ[redacted] ដោយមូលហេតុថា សហជីពនេះត្រូវបានបង្កើតឡើងពុំត្រឹមត្រូវតាមផ្លូវច្បាប់គឺថា អនុលោមតាមមាត្រា ១០ នៃច្បាប់ស្តីពីសហជីព បានចែងថា ការបង្កើតសហជីពមូលដ្ឋានមួយ ត្រូវបានបង្កើតឡើងដោយកម្មករនិយោជិតនៅក្នុងសហគ្រាស ឬគ្រឹះស្ថាននោះ យ៉ាងតិច ១០ នាក់ ។ ផ្អែកទៅលើសេចក្តីថ្លែងការណ៍ស្តីពីការស្នើសុំបង្កើតសហជីព ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១ គឺស្នើសុំដោយមានចំនួនកម្មករនិយោជិត ១០ នាក់ ក្នុងនោះមានលោក [redacted] ដោយមានហត្ថលេខារបស់ឈ្មោះ [redacted] នេះផងដែរ ។ ផ្អែកតាមសេចក្តីថ្លែងការណ៍របស់លោក [redacted] គាត់បានបដិសេធថា មិនបានចុះហត្ថលេខាស្នើសុំបង្កើតសហជីពនេះឡើយ ។ រហូតដល់លោក [redacted] ធ្វើការប្តឹងពួកគាត់មានឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលបានចូលរួមក្លែងបន្លំហត្ថលេខារបស់គាត់ក្នុងការស្នើសុំបង្កើតសហជីពនេះ។ ពួកគេត្រូវបានតុលាការចោទប្រកាន់ និងមានការឃុំខ្លួនពួកគេថែមទៀតផង។ ផ្អែកតាមមូលហេតុខាងលើ សហជីពនេះបង្កើតឡើងមិនគ្រប់ចំនួន១០នាក់ តាមច្បាប់កំណត់ ដែលជាការបង្កើតសហជីពដោយខុសច្បាប់ ។ អនុលោមតាមមាត្រា ១២៨ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហជីព នៅក្នុងចំណុចទី៣ បានចែងអំពីការរំលាយសហជីពត្រូវធ្វើឡើងដោយតុលាការ ។ នៅក្នុងមាត្រា ២៩ ថ្មី នៃច្បាប់ដដែលនេះ បានចែងអំពីមូលហេតុនៃការស្នើសុំរំលាយគឺ បានចែងថាភាគី ដែលពាក់ព័ន្ធមានសិទ្ធិប្តឹងទៅតុលាការ ដើម្បីរំលាយសហជីព។ សហជីពត្រូវបានរំលាយដោយតុលាការនៅក្នុងមូលហេតុណាមួយដូចខាងក្រោមការបង្កើត ឬសកម្មភាពនានារបស់សហជីពមានលក្ខណៈផ្ទុយច្បាប់ ។ ពាក់ព័ន្ធនឹងការលើកឡើងថា ដើមចោទមិនមានសិទ្ធិក្នុងការប្តឹងមកតុលាការដើម្បីសុំរំលាយសហជីព គឺជាការភាន់ច្រឡំ ដោយហេតុថា អនុលោមតាមមាត្រា២៩ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហជីពបានចែងថា ភាគីដែលពាក់ព័ន្ធមានសិទ្ធិប្តឹងមកតុលាការដើម្បីរំលាយសហជីព ។ ក្នុងរឿងនេះ ដើមចោទគឺជាភាគីដែលពាក់ព័ន្ធ ហេតុនេះដើមចោទមានសិទ្ធិក្នុងការប្តឹងដោយអនុលោមតាមមាត្រា ២៩ ខាងលើ។ ជាមួយគ្នានេះផងដែរ ការអះអាងរបស់ចុងចម្លើយថា ដើមចោទបានធ្វើការរំលាយសហជីពដោយខ្លួនឯងនោះ ជាការលើកឡើងពុំត្រឹមត្រូវឡើយ ព្រោះថាដើមចោទ មិនបានធ្វើការរំលាយសហជីពដោយខ្លួនឯងទេ ដើមចោទបានប្រើសិទ្ធិតឹងពាក់តុលាការ ដោយសមស្របទៅនឹងក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានចែងក្នុងមាត្រា ២ ។

### ខ.៣-អង្គហេតុដែលអះអាងដោយចុងចម្លើយ

ចុងចម្លើយ សហជីពឯករាជ្យការពារកម្មករ នៃ[redacted] ដែលតំណាងដោយឈ្មោះ [redacted] មានលោកមេធាវី [redacted] និងលោកស្រីមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិ បានធ្វើសេចក្តីថ្លែងការណ៍តបថា: ខ្លួនជាប្រធានសហជីពឯករាជ្យការពារកម្មករ នៃ[redacted] ដោយមានសមាជិក ចំនួន ១០នាក់ មានឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted] ឈ្មោះ [redacted] , ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted] ។ នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញវិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ លេខ [redacted] ទទួលស្គាល់សហជីពឯករាជ្យការពារកម្មករ នៃ[redacted] ដោយមានខ្លួនឈ្មោះ [redacted] ជាប្រធាន

[redacted] ជាអនុប្រធាន និងឈ្មោះ [redacted] ជាលេខាធិការ ។ ខ្លួនបង្កើតសហជីព ក្នុងគោលបំណងការពារផលប្រយោជន៍ និងសេរីភាពកម្មករ ។ ចំពោះការប្តឹងសុំរំលាយសហជីពឯករាជ្យការពារកម្មករ នៃ[redacted] ខ្លួនមិនទទួលយកបានទេ ។ មូលហេតុដោយសារនៅពេលខ្លួនស្នើសុំបង្កើតសហជីពឯករាជ្យការពារកម្មករនៃ[redacted] ខ្លួនបានជូនដំណឹងទៅក្រុមហ៊ុនហើយ ម្យ៉ាងទៀតឈ្មោះ [redacted] បានយល់ព្រមដែរ ហើយមុននឹងក្រសួងការងារចុះបញ្ជិការទទួលស្គាល់នេះ ក៏បានទុកពេលវេលាឱ្យភាគីពាក់ពន្ធប្តឹងជំទាស់ផងដែរ ប៉ុន្តែកម្រុហ៊ុនអត់បានប្តឹងជំទាស់ទេ ដោយសារនៅខាងក្រុមហ៊ុនដាក់សម្ពាធការងារ និងកាត់លុយកម្មករពេក នៅខែកុម្ភៈ ឆ្នាំ២០២១ ពួកខ្លួនបានធ្វើលិខិតអន្តរាគមន៍ទៅនាយកដ្ឋានវិវាទការងារ ដោយមានគ្នាច្រើន តែតំណាង ៤រូប គឺខ្លួន, ឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ដោយមានលក្ខខណ្ឌ ៩ ចំណុច ។ នៅពេលបង្កើតសហជីពឯករាជ្យការពារកម្មករនៃ[redacted] ឈ្មោះ [redacted] បានយល់ព្រម ប៉ុន្តែមិនបានជួបគ្នាដោយផ្ទាល់មុខចុះហត្ថលេខាលើលិខិតស្នើសុំបង្កើតសហជីពទេ ដោយសារសម័យនោះកូវីដកំពុងរីករាលដាលខ្លាំង តែបានយល់ព្រមតាមទូរស័ព្ទ និងផ្ញើឯកសារតាម TELEGRAM ឱ្យមេតំបន់ដើម្បីបំពេញបែបបទចុះបញ្ជីបន្ទាប់មកបានផ្ញើឯកសារដើម្បីចុះហត្ថលេខាតាមតំបន់រៀងៗខ្លួន ។ ចំពោះការប្តឹងទាមទារឱ្យខ្លួន, ឈ្មោះ [redacted] និងឈ្មោះ [redacted] រួមគ្នាសងសំណងជម្ងឺចិត្តចំនួន ៥,០០០,០០០ រៀល ទៅឱ្យក្រុមហ៊ុន ខ្លួនសុំច្រានចោលការទាមទារនេះ ពីព្រោះខ្លួនមិនបានធ្វើអីខុសទេ ។ សព្វថ្ងៃសហជីពរបស់ខ្លួនមិនបានដំណើរការទេ ដោយសារខាងក្រុមហ៊ុនបានព្យួរការងារខ្លួនមិនឱ្យចូលធ្វើការដោយចោទប្រកាន់ថា ខ្លួនក្លែងបន្លំស្នាមមេដៃ ។ ទាក់ទងនឹងការបង្កើតសហជីពនេះ ខ្លួនបានចុះបញ្ជីការត្រឹមត្រូវនៅក្រសួងការងារ និងមានគោលបំណងការពារផលប្រយោជន៍កម្មករ ចំពោះការដែលក្រុមហ៊ុនប្តឹងសុំរំលាយសហជីពដោយសំអាងថា ខ្លួនមិនបានជូនដំណឹង គឺជាការមិនត្រឹមត្រូវទេ ។ ដោយហេតុថា នៅមុនពេលបង្កើតសហជីព និងក្រោយពីទទួលបានការចុះបញ្ជីពីក្រសួងការងារ ខ្លួនសុទ្ធតែបានជូនដំណឹងក្រុមហ៊ុនទាំងពីរលើកហើយ ។ ដូច្នេះ ចំពោះក្រុមហ៊ុនសុំរំលាយសហជីពខ្លួនដោយផ្អែកថា ខ្លួនមិនបានជូនដំណឹង ខ្លួនសុំបដិសេធចោលទាំងស្រុង ។ ម្យ៉ាងវិញទៀត ក្រុមហ៊ុនមិនមានសិទ្ធិក្នុងការសុំរំលាយសហជីពបានទេ មានតែរដ្ឋមន្ត្រីក្រសួងការងារ និងសមាជិកនៃសហជីពចំនួន ៥០%+១ ប៉ុណ្ណោះ ដែលមានសិទ្ធិដាក់ពាក្យប្តឹងសុំរំលាយបាន ។ ខ្លួនសុំបញ្ជាក់ថា ប្រសិនបើក្រុមហ៊ុនមានសិទ្ធិក្នុងការរំលាយសហជីពដោយខ្លួនឯងនោះ វានឹងធ្វើឱ្យសហជីពទាំងអស់មិនអាចបង្កើតដើម្បីការពារផលប្រយោជន៍កម្មករបានឡើយ ។

**គ-អង្គហេតុដែលគ្មានវិវាទ:**

-គូភាគីទទួលស្គាល់ថា [redacted] មានសហជីពឯករាជ្យការពារកម្មករ នៃ[redacted] ដែលមានលោក ពេជ្រ បូរិន្ទ ជាប្រធានបានស្នើសុំចុះបញ្ជីការជាសហជីពក្នុងក្រុមហ៊ុន។

**ឃ-ចំណុចវិវាទ:**

១-ដើមចោទសុំរំលាយសហជីពការពារកម្មករនៃ [redacted] [illegible] បង្កើតសហជីពពុំត្រឹមត្រូវតាមច្បាប់ ដោយការសុំបង្កើតនេះពុំត្រឹមត្រូវតាមច្បាប់ ដោយកា[illegible]

សមាជិកដែលជាកម្មករនិយោជិតឲ្យបានចំនួន ១០នាក់នោះទេ។ ប៉ុន្តែចុងចម្លើយអះអាងថា ខ្លួនមានសមាជិក ១០នាក់ ហើយបានសុំច្បាប់ត្រឹមត្រូវ ដោយមានវិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ លេខ [redacted] ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

២-ដើមចោទអះអាងថា ឈ្មោះ [redacted] ពុំបានផ្តិតមេដៃចូលរួមក្នុងការបង្កើតសហជីព, ក្នុងការស្នើសុំចុះបញ្ជីការពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនោះទេ តែភាគីចុងចម្លើយអះអាងថា សមាជិកទាំង ១០ នាក់មាន ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted] ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted]។

## ការពិនិត្យភស្តុតាង

**១-ភស្តុតាងជាឯកសាររបស់ដើមចោទ**

១.១-ពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ ។

១.២-ចម្លងរបាយការណ៍កោសលវិច័យ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ ។

១.៣-កំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ របស់ឈ្មោះ [redacted]។

១.៤-កំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ របស់ឈ្មោះ [redacted]។

១.៥-កំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ របស់ឈ្មោះ [redacted]។

**២-ភស្តុតាងជាឯកសាររបស់ចុងចម្លើយ៖**

២.១-ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ [redacted] ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ។

២.២-វិញ្ញាបនប័ត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ លេខ [redacted] ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

២.៣-លិខិតលេខ [redacted] ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

២.៤-លិខិតលេខ [redacted] ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ របស់នាយកដ្ឋានវិវាទការងារ។

## សំអាងហេតុ

**ក.ការវិនិច្ឆ័យចំពោះអង្គហេតុ**

១-ការទទួលស្គាល់អង្គហេតុ គូភាគីទទួលស្គាល់ថា [redacted] មានសហជីពឯករាជ្យការពារកម្មករ នៃ [redacted] ដែលមានលោក [redacted] ជាប្រធានបានស្នើសុំចុះបញ្ជីការជាសហជីពក្នុងក្រុមហ៊ុន ។

២-ស្តីពីវិវាទចំណុចទី១៖ ដើមចោទអះអាងថា [redacted] ពុំបានផ្តិតមេដៃ និងចុះហត្ថលេខា ចូលរួមក្នុងការបង្កើតសហជីព ក្នុងការស្នើសុំបញ្ជីការពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនោះទេ តែភាគីចុងចម្លើយអះអាងថា មានស្នាមមេដៃ និងចុះហត្ថលេខាសមាជិក ទាំង១០ នាក់ រួមមាន ឈ្មោះ [redacted], ឈ្មោះ [redacted]

ឈ្មោះ [redacted] ,ឈ្មោះ [redacted] , ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted] ។

២-១-ដើមចោទអះអាងថា ការស្នើសុំរំលាយសហជីពឯករាជ្យការពារកម្មករនៃ [redacted] របស់ចុងចម្លើយពុំគ្រប់លក្ខខណ្ឌដែលច្បាប់បានកំណត់ ដោយសហជីពនេះ ជាសហជីពមូលដ្ឋាន ដូច្នេះ ការស្នើសុំបង្កើតសហជីពត្រូវមានបញ្ជីរាយនាមកម្មករនិយោជិតយ៉ាងតិច១០នាក់ ប៉ុន្តែការស្នើសុំបង្កើតសហជីព របស់ចុងចម្លើយមានកម្មករនិយោជិតតែ៩នាក់ ប៉ុណ្ណោះ ព្រោះថាឈ្មោះ [redacted] មិនបានចូលរួមក្នុងការស្នើសុំ បង្កើតសហជីពទេ តែចុងចម្លើយដាក់ឈ្មោះ [redacted] និងបានក្លែងបន្លំស្នាមមេដៃ និងហត្ថលេខា របស់ ឈ្មោះ [redacted] ដើម្បីស្នើសុំចុះបញ្ជីការជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ចំពោះស្នាម មេដៃ និងហត្ថលេខារបស់ឈ្មោះ [redacted] ត្រូវបាននាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រនៃអគ្គស្នងការ នគរបាលជាតិ ធ្វើកោសលវិច័យបញ្ជាក់ថា មិនមែនជាស្នាមមេដៃ និងហត្ថលេខារបស់ឈ្មោះ [redacted] ឡើយ ។

២-២-ចុងចម្លើយអះអាងថា ក្នុងការបង្កើតសហជីពឯករាជ្យការពារកម្មករ នៃ [redacted] គឺមានសមាជិកទាំង ១០ នាក់ រួមមាន ឈ្មោះ [redacted], ឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] , ឈ្មោះ [redacted], ឈ្មោះ [redacted] ,ឈ្មោះ [redacted] , ឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ។

២-៣-តាមការពិនិត្យភស្តុតាងជាឯកសារ កំណត់ហេតុសួរចម្លើយឈ្មោះ [redacted] ជាប្រធាន ឈ្មោះ [redacted] ជាអនុប្រធាន និងឈ្មោះ [redacted] ជាលេខាធិការ ក្នុងរឿងព្រហ្មទណ្ឌ ពួកគាត់បានឆ្លើយសារភាពថា ចំពោះលិខិតសុំអន្តរាគមន៍ ក្នុងខែកុម្ភៈ ឆ្នាំ២០២១ ដាក់ទៅក្រសួងការងារគឺ ឈ្មោះ [redacted] ជាអ្នកផ្តិតមេដៃជំនួស ឈ្មោះ [redacted] ពិតប្រាកដមែន ក្រោយពីផ្តិតមេដៃរួច ឈ្មោះ [redacted] បានយកឯកសារនោះទៅដាក់នៅក្រសួងការងារ។

២-៤.តាមការពិនិត្យភស្តុតាងជាឯកសារ របាយការណ៍កោសលវិច័យ លេខ [redacted] ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ របស់នាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលបាន ធ្វើកោសលវិច័យ លើស្នាមមេដៃរបស់ ឈ្មោះ [redacted] នៅលើលិខិតស្នើសុំជួយអន្តរាគមន៍ទៅនាយកដ្ឋាន វិវាទការងារ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ និងការធ្វើកោសលវិច័យលើស្នាមហត្ថលេខារបស់ឈ្មោះ [redacted] នៅលើលិខិតសេចក្តីថ្លែងការណ៍ស្តីពីគោលបំណងបង្កើតសហជីព ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១ ជាលទ្ធផលគឺ ស្នាមមេដៃ របស់ឈ្មោះ [redacted] នៅលើលិខិតស្នើសុំជួយអន្តរាគមន៍ទៅនាយកដ្ឋានវិវាទការងារ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ ជាមួយនិងគំរូស្នាមមេដៃរបស់ឈ្មោះ [redacted] មិនដូចគ្នាឡើយ និងស្នាមហត្ថលេខា របស់ ឈ្មោះ [redacted] នៅលើលិខិតសេចក្តីថ្លែងការណ៍ស្តីពីគោលបំណងបង្កើតសហជីព ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០២១ ជាមួយនិងគំរូស្នាមហត្ថលេខារបស់ឈ្មោះ [redacted] មិនដូចគ្នាឡើយ។

២-៥.យោងតាមសំអាងហេតុចំណុចទី ២-១, ២-៣, ២-៣ និង ចំណុច ២-៤ ខាងលើ ឃើញថា ក្នុង ការស្នើសុំបង្កើតសហជីពឯករាជការពារកម្មករនៃ [redacted]

[redacted]ជាប្រធាន និងជាអ្នករៀបចំឯកសារស្នើសុំចុះបញ្ជីជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានការរួមគ្នារវាង កម្មករនិយោជិតចំនួន ១០ នាក់ រួមមាន ឈ្មោះ [redacted] ឈ្មោះ [redacted], ឈ្មោះ [redacted] ឈ្មោះ [redacted] ,ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] គឺឈ្មោះ [redacted] ពុំបានចូលរួមចុះហត្ថលេខា និងផ្តិតមេដៃក្នុងការស្នើសុំបង្កើតសហជីពនេះទេ ពោលគឺមានការក្លែងស្នាមមេដៃ និងហត្ថលេខារបស់ឈ្មោះ [redacted] ។

៣-ស្តីអំពីចំណុចវិវាទី២: ដើមចោទសុំរំលាយសហជីពការពារកម្មករ នៃ[redacted] ដោយមូលហេតុការបង្កើតសហជីពពុំត្រឹមត្រូវតាមច្បាប់ ដោយការស្នើសុំបង្កើតនេះ ពុំមានការចូលរួម ពីកម្មករនិយោជិតឲ្យបានចំនួន ១០ នាក់ នោះទេ ប៉ុន្តែចុងចម្លើយអះអាងថាខ្លួនមានសមាជិក ១០ នាក់ ហើយបានសុំច្បាប់ត្រឹមត្រូវ ដោយមានវិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ លេខ [redacted] ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

៣-១.ដើមចោទអះអាងថា ការស្នើសុំបង្កើតសហជីពឯករាជការពារកម្មករនៃ[redacted] របស់ចុងចម្លើយពុំគ្រប់លក្ខខណ្ឌដែលច្បាប់បានកំណត់ ដោយសហជីពនេះ ជាសហជីពមូលដ្ឋាន ដូច្នេះការស្នើសុំបង្កើតសហជីព ត្រូវមានបញ្ជីរាយមានកម្មករនិយោជិតយ៉ាងតិច ១០នាក់ ប៉ុន្តែការស្នើសុំបង្កើតសហជីពរបស់ចុងចម្លើយ មានកម្មករនិយោជិតតែ ៩នាក់ ប៉ុណ្ណោះ ព្រោះថា ឈ្មោះ [redacted] មិនបានចូលរួមក្នុងការស្នើសុំបង្កើតសហជីពទេ តែចុងចម្លើយដាក់ ឈ្មោះ [redacted] និងបានក្លែងបន្លំស្នាមមេដៃ និងហត្ថលេខារបស់ ឈ្មោះ [redacted] ដើម្បីស្នើសុំការចុះបញ្ជីជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូច្នេះការបង្កើតសហជីពនេះ គឺខុសច្បាប់។ អនុលោមតាមមាត្រា២៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហជីពនៅក្នុងចំណុចទី៣ បានចែងអំពីការរំលាយសហជីពត្រូវតែធ្វើឡើងដោយតុលាការ រីឯមាត្រា ២៩ថ្មី ក៏បានចែងអំពីមូលហេតុនៃការស្នើសុំរំលាយ គឺបានចែងថា ភាគីដែលពាក់ព័ន្ធមានសិទ្ធិប្តឹងទៅតុលាការដើម្បីសុំរំលាយសហជីព។

៣-២.ចុងចម្លើយអះអាងថា ក្នុងការសុំបង្កើតសហជីពឯករាជការពារកម្មករ នៃ[redacted] ស៊ីស្ទឹម គឺមានសមាជិកទាំង១០កនាក់ រួមមាន ឈ្មោះ [redacted], ឈ្មោះ[redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] , ឈ្មោះ[redacted], ឈ្មោះ [redacted] ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted] ហើយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញវិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ លេខ[redacted] ទទួលស្គាល់សហជីពឯករាជការពារ កម្មករនៃ [redacted] ដោយមានរូបខ្លួន ឈ្មោះ [redacted] ជាប្រធាន ឈ្មោះ [redacted] ជាអនុប្រធាន និងឈ្មោះ [redacted] ជាលេខាធិការ ។ ក្រុមហ៊ុនមិនមានសិទ្ធិក្នុងការសុំរំលាយសហជីពបានទេ មានតែរដ្ឋមន្ត្រីក្រសួងការងារ និងសមាជិកសហជីពចំនួន ៥០% +១ ប៉ុណ្ណោះ ដែលមានសិទ្ធិដាក់ពាក្យសុំរំលាយបាន ។

៣-៣.ផ្អែកតាមសំអាងហេតុ ក្នុងចំណុចវិវាទី១ ខាងលើ តុលាការទទួលស្គាល់ថា ឈ្មោះ [redacted] ពុំបានចូលរួមចុះហត្ថលេខា និងផ្តិតមេដៃ ក្នុងការស្នើសុំបង្កើតសហជីពនេះទេ ពោលគឺមានការក្លែងស្នាមមេដៃ និងហត្ថលេខារបស់ឈ្មោះ[redacted]។

៣-៤.ផ្អែកតាមភស្តុតាងជាឯកសារ សេចក្តីថ្លែងការណ៍ ស្តីពីគោលបំណងបង្កើតសហជីពឯករាជ្យការពារកម្មករ នៃ[redacted] ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១ គឺមានការរួបរួមគ្នារវាងកម្មករនិយោជិត ស្ថាបនិកចំនួន ១០នាក់ ដែលមានឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted] ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted] ។ ប៉ុន្តែឈ្មោះ [redacted] ពុំបានចូលរួមចុះហត្ថលេខា និងផ្តិតមេដៃក្នុងការស្នើសុំបង្កើតសហជីពនេះទេ ពោលគឺមានការក្លែងស្នាមមេដៃ និងហត្ថលេខារបស់ ឈ្មោះ[redacted] ដូច្នេះ ការស្នើសុំបង្កើតសហជីពនេះ មានសមាជិកតែ០៩ រូប ប៉ុណ្ណោះ។

៣-៥.យោងតាមមាត្រា១២ នៃច្បាប់ស្តីពីសហជីព គឺបានកំណត់អំពីលក្ខខណ្ឌតម្រូវសម្រាប់ការស្នើសុំចុះបញ្ជីចំពោះសហជីពមូលដ្ឋាន ត្រូវមានបញ្ជីរាយនាមកម្មករនិយោជិតទាំងអស់ ដែលជាសមាជិកនៅក្នុងសហគ្រាស ឬគ្រឹះស្ថានមូលដ្ឋាននោះចំនួនយ៉ាងតិច ១០ នាក់ (មាត្រា១២ចំណុច ឆ) ។

៣-៦.យោងតាមសំអាងហេតុចំណុចទី ៣-១, ៣-២, ៣-៣, ៣-៤ និងចំណុច ៣-៥ ខាងលើ ឃើញថាការដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញវិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ លេខ [redacted] ទទួលស្គាល់សហជីពឯករាជការពារកម្មករនៃ [redacted] គឺដោយសារស្ថាបនិកសហជីព បានរៀបចំឯកសារ ភូតកុហកក្រសួង ដោយមានការក្លែងស្នាមមេដៃ និងហត្ថលេខារបស់ឈ្មោះ [redacted] ។ ប៉ុន្តែដើមចោទ [redacted] តំណាងដោយលោក [redacted] និងមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ដែលជាអ្នកមានផលប្រយោជន៍ បានដាក់ពាក្យបណ្តឹងរំលាយសហជីពឯករាជការពារកម្មករ នៃ [redacted] ស្របតាមបញ្ញតិ មាត្រា ២៨ ថ្មី និងមាត្រា ២៩ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហជីព។

***ខ-ការវិនិច្ឆ័យចំពោះការទាមទារ***

៤-ដើមចោទប្តឹងសុំ

៤-១.រំលាយសហជីពឯករាជ្យការពារកម្មករនៃ[redacted] មានមូលហេតុត្រឹមត្រូវ គប្បីតុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទ។

៤-២.បង្គាប់ឱ្យឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted] រួមគ្នាសងជម្ងឺចិត្ត ចំនួន ៥,០០០,០០០ (ប្រាំលាន)រៀល ទៅដើមចោទ គប្បីតុលាការពិចារណាតាមការជាក់ស្តែង។

**គ-ប្រាក់ប្រដាប់ក្តី**

៥-យោងតាមបញ្ញត្តិមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី ។

៦-នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ចុងចម្លើយឈ្មោះ[redacted] អវត្តមាន ក្រោយពីបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការក៏បានបញ្ជូនសេចក្តីថ្លែងការណ៍ ទាមទាររបស់ដើមចោទឱ្យទៅចុងចម្លើយ

រួចហើយ ដូច្នេះ តុលាការអាចចេញសាលក្រមកំបាំងមុខ ចុងចម្លើយបាន ដោយអនុលោមតាមបញ្ញត្តិមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**សេចក្ដីសម្រេចបញ្ចប់**

១-រំលាយ សហជីពឯករាជ្យការពារកម្មករនៃក្រុមហ៊ុន [redacted] ។

២-បង្គាប់ឱ្យចុងចម្លើយសងជម្ងឺចិត្ត ចំនួន ៣,០០០,០០០(បីលាន)រៀល ឱ្យទៅដើមចោទ ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះ ត្រូវបានប្រកាសនៅសវនាការជាសាធារណៈ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ។ ក្នុងករណីដែលប្ដឹងទាស់ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ២សប្ដាហ៍ និងប្ដឹងឧទ្ធរណ៍ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

"បានចំលងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ សុក្រ ៦រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២

**បានឃើញ**
**ចៅក្រម**

[redacted]

ក្រឡាបញ្ជី

[redacted]

**ឧបសម្ព័ន្ធទី ១២**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

[redacted]

**សាលាដំបូងរាជធានីភ្នំពេញ**

លេខៈ ........"ន"ដចន

## ដីកាបង្គាប់ឲ្យចាប់ និងឃុំខ្លួន

យើង [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញមាត្រា ៣៥៣ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៖ [redacted] ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ ៖ [redacted] ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ ។

-បានឃើញសំណុំរឿងជំនុំជម្រះលេខ ៖ [redacted] ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៖ [redacted] ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

### យល់ឃើញថា

ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ១៩៩៧ ជនជាតិខ្មែរ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ចំនួន០៤(**បួន)ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **៨,000,000៛(ប្រាំបីលានរៀល)** ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះគ្មានលេខ ផ្លូវលំ ភូមិតាង៉ូវកណ្តាល សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ និងបង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមលេខ [redacted] ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ ។

### ហេតុដូច្នេះសម្រេច

១/. បង្គាប់ឲ្យចាប់ និងឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ១៩៩៧ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះគ្មានលេខ ផ្លូវលំ ភូមិតាង៉ូវកណ្តាល សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" នៅលីវ ជានីតិជន ។ ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។

២/. បញ្ជាដល់កងកម្លាំងសាធារណៈ ឲ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនឈ្មោះខាងលើនេះ **ទៅមណ្ឌលអប់រំកែប្រែទី១ (ម១)**ដើម្បីឃុំខ្លួនតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

ថ្ងៃអង្គារ៧កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ , ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**